ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ជិះឡានមិនឃើញយករឿងអ្វីខ្លះ

◆ ហេតុអ្វីបានជាយើងចាំបាច់ធ្វើបដិវត្តន៍?

លេខ៣៨ ខែកុម្ភៈ ឆ្នាំ២០០៣

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៤ ខែកុម្ភៈ ឆ្នាំ២០០១


## មាតិកា


◆ សំបុត្រៈ ដំបៅមិនឈឺយកឈើឆ្កឹះ.................................. ១

**ផ្នែកឯកសារ**

◆ ញ៉ៀប សួង ហៅ ផាន់ អតីតអនុនេសាទរដ្ឋ.......................... ២

◆ ហេតុអ្វីបានជាយើងចាំបាច់ធ្វើបដិវត្តន៍? ............................ ៧

◆ ទីតាំងរណ្ដៅប្រល័យពូជសាសន៍ក្នុងស្រុកបាត់ដំបង.................. ៩

◆ សុន្ទរកថារបស់ឯកឧត្ដម សុខ អាន.................................១២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ករណីអ្នកទោស អ៊ីស្មាអែល អះម៉ាត់................................១៧

◆ សម្លេងពីមន្ទីរស-២១ ..................................................២២

◆ ជនដៃដល់ ឬ ជនរងគ្រោះ? ........................................ ២៧

◆ រន្ធាស់បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ........................ ៣១

**ផ្នែកច្បាប់**

◆ ការជម្លៀសប្រជាជន និង ការនិរទេសក្នុងប្រទេស.............. ៣៥

◆ គំរូមួយនៃភ័ស្ដុតាងឯកសារភ្ជាប់មេដឹកនាំជាន់ខ្ពស់................ ៣៩

**វេទិកាពិភាក្សាសាធារណៈ**

◆ បន្ទាប់ពីលើកលែងទោស................................................ ៤៣

◆ កំណត់ហេតុស្ដីពីអង្គប្រជុំរបស់សភាជាតិ.............................. ៤៨

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ សៀវភៅកំណត់ហេតុជីវិត..............................................៥៧

◆ ចង់ដឹងការពិត.............................................................. ៦០

**សិល្បៈខ្មែរក្រហមៈ**

**ចម្រៀងៈ** សូមកូនកុំភ្លេចឈាមស្រស់យុទ្ធមិត្តយើងឲ្យសោះ....... ក្របក្រោយ







រូបថតជនរងគ្រោះមន្ទីរស-២១


# រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**(រូបថតក្របមុខផ្ដល់ឲ្យដោយ ទស្សនាវដ្ដីភ្នំទេវី)**

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**វាគ្មិនលេខនេះៈ** អេលីហ្សាប៊ែត វ៉ាន់ស្កាក់, ទូច បូរ៉ា, ដេង ពង្សរាសុី, អៀ ម៉េងទ្រី, ទៀង សុភៈវិជ្ជា, ស៊ីវ ហេង៉រ, អ៊ីសា ឧស្មាន, វ៉ាន់ ថាន់ពោដារ៉ា **អ្នកនិពន្ធនិងស្រាវជ្រាវៈ** សាន់ កល្យាណ, លី សុជល, ជួង សុភារិទ្ធ **ជំនួយការនិពន្ធនាយកៈ** អែម សុខឃីម **និពន្ធនាយករងទី១ៈ** ផាត កុសល **និពន្ធនាយករងទី២ៈ** សឹម សុរិយ៉ា **អ្នកបកប្រែៈ** សួ ប៊ុនស៊ូ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** ទ្រី សុភក្ដិ

*សំបុត្រៈ*

# ដំបៅមិនឈឺយកឈើឆ្កឹះ

ខៀវ សំផន បានសម្តែងនូវការសុខចិត្តចូលខ្លួនមកបំភ្លឺចំពោះមុខតុលាការអំពីអ្វីដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ខៀវ សំផន ដែលមានចំណែកនៅក្នុងការធ្វើឲ្យប្រជាជនកម្ពុជារាប់លាននាក់ស្លាប់បាត់បង់ជីវិត បន្តការភ័ន្តច្រឡំរបស់ខ្លួនទៅលើផ្នត់គំនិតខ្មែរដោយបាននិយាយថា “ដំបៅដែលមិនឈឺ បើជ្រុលជាមានគេយកឈើឆ្កឹះទៅហើយ ខ្លួនសុខចិត្តស្រាយបំភ្លឺទៅចុះ” ។

“ដំបៅមិនឈឺយកឈើទៅឆ្កឹះ” គឺជាសុភាសិតខ្មែរដែលមានន័យសំដៅទៅការអុជអាលបំផ្លើសបុម្លួលបង្កាច់បំបែកបំបាក់ក្រុមគ្រួសារបុសង្គមមួយដែលមានសុភមង្គល ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) មានប្រជាជនកម្ពុជារាប់លាននាក់ដែលបានស្លាប់បាត់បង់ជីវិត ។ រឿងនេះគឺមិនមែនជាការបំផ្លើស ហើយក៏មិនមែនជារឿងដែលអាចកែប្រែក្រឡាស់បានដែរ ។ ការពិតគឺនៅតែជាការពិត ។ រីឯប្រវត្តិសាស្ត្រគឺនៅតែជាប្រវត្តិសាស្ត្រដដែល ។ ការពិតជាប្រវត្តិសាស្ត្រនោះគឺថារបបខ្មែរក្រហមដែលមានខៀវ សំផន ជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនិស្តកម្ពុជានិងគណៈកម្មាធិការអចិន្ត្រៃយ៍បានបង្កើតគោលនយោបាយសម្លាប់ប្រជាជនកម្ពុជា ។ គ្រួសារខ្មែរទូទាំងប្រទេសសុទ្ធតែមានសាច់សាលោហិតត្រូវបានស្លាប់ដោយសារខ្មែរក្រហម ។ការជំរុញឲ្យមានការបង្កើតនូវតុលាការមួយដើម្បីធ្វើការវិនិច្ឆ័យទៅលើករណីរបស់មេដឹកនាំខ្មែរក្រហមមិនមែនជាការយកឈើទៅឆ្កឹះដំបៅ ប៉ុន្តែគឺជាការព្យាបាលដំបៅ ។ មនុស្សដែលមានដំបៅត្រូវតែទទួលបាននូវការព្យាបាលដ៏សមរម្យមួយ ។ ការព្យាបាលនឹងត្រូវឆ្លងកាត់ការឈឺចាប់ ។ ប៉ុន្តែយើងមិនត្រូវរុញរាក្នុងដំណាក់កាលនៃការព្យាបាលឬទុកដំបៅឲ្យនៅជាប់នឹងខ្លួនបន្តភាពរ៉ាំរ៉ៃអស់រយៈពេលជាង២០ឆ្នាំកន្លងមកហើយបែបនេះទេ ។ មកទល់នឹងថ្ងៃនេះ ខៀវ សំផន នៅតែមិនអាចបង្ហាញបានថាខ្លួនជាកូនខ្មែរ អ្នកចេះដឹងមានសញ្ញាប័ត្រចាស់គម្រិលមួយមកពីស្រុកបារាំង ។ ផ្ទុយទៅវិញ ខៀវ សំផន បង្ហាញឲ្យឃើញកាន់តែច្បាស់ថែមទៀតនូវសារជាតិខ្មែរក្រហមដ៏ពិតៗរបស់ខ្លួនដែលតែងតែឆ្លៀតឱកាសដើម្បីបំបែកបំបាក់បងប្អូនខ្មែរនៅស្រុកស្រែចម្ការដែលខ្សត់ខ្សោយ ។ ខៀវ សំផន បានប្រើសុភាសិតខ្មែរនៅក្នុងការញុះញង់បំបែកបំបាក់ ដូចដែលខ្លួនបានធ្វើនៅក្នុងពេលកាន់កាប់អំណាចអស់រយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃដូច្នេះដែរ ។ ទោះបីជា ខៀវ សំផន បានលាបសក់ដែលមានពណ៌សឲ្យទៅជាខ្មៅដើម្បីឲ្យមានសភាពធម្មតាយ៉ាងណាក៏ដោយ ក៏ធាតុពិតរបស់ ខៀវ សំផន គឺមិនខុសពីមេដឹកនាំខ្មែរក្រហមដទៃទៀតឡើយ ដែលមានបំណងតែម្យ៉ាងគឺ “កសាងសង្គមបរិសុទ្ធ” មួយតាមរយៈការសម្លាប់និងបង្អត់អាហារប្រជាជនខ្លួនឯងហើយទម្លាក់កំហុសទៅលើអ្នកដទៃ ។





**ឆាំង យុ**

# ញៀប សួង ហៅ ផាន់ អនុនេសាទរដ្ឋ



អតីតអនុប្រធាននេសាទរដ្ឋ ញៀប សួង ហៅ ផាន់ បានក្លាយជាអ្នកទោសរបស់ខ្មែរក្រហម ហើយត្រូវបានបញ្ជូនមកឃុំឃាំងនៅមន្ទីរស-២១ ពីបទធ្វើសកម្មភាពក្បត់យកការណ៍ពីបក្សភូមិភាគមកផ្ដល់ឲ្យ តាចុង និងជាអ្នកបន្តខ្សែក្បត់។ ផាន់ ត្រូវបានសួរចម្លើយជាច្រើនលើក។ ប៉ុន្តែឯកសារចម្លើយសារភាពដែលសេសសល់មានចំនួនបួនដុំតែប៉ុណ្ណោះ (លើកទី៣ លើកទី៤ លើកទី១០និងលើកទី១៦) សរុបទាំងអស់មាន៨៦ទំព័រ។ ក្នុងចម្លើយនោះ ផាន់ បាននិយាយអំពីការទំនាក់ទំនងជាមួយសកម្មភាពរបស់គាត់ជាមួយ តាចុង និងកម្លាំងក្បត់ច្រើនទៀត។

## សកម្មភាពរបស់ ផាន់ ក្នុងពេលនៅជាមួយ តាចុង

ឆ្នាំ១៩៧២ ផាន់ រស់នៅជាមួយ តាចុង (តាចុងត្រូវជាប្អូនបង្កើតរបស់តាម៉ុក)។ តាចុង ដែលជាគណៈភាគនិរតីបានធ្វើសកម្មភាពក្បត់ដឹកនាំកម្លាំងទៅកោះកុងបើកការប្រជុំមួយនៅមន្ទីរដែលចូលរួមដោយ នួន ជាប្រធានអង្គប្រជុំមាន ខុដន យុទ្ធ ថៃ និង ម្នាក់ទៀតមិនស្គាល់ឈ្មោះ ដែលនៅក្នុងអង្គប្រជុំនោះ ផាន់ បានចូលរួមដើម្បីផ្លាស់ប្តូរយោបល់គ្នាដែរ។ ការប្រជុំត្រូវបានលើកឡើងនូវ៤ចំណុចៈ ទី១ ស្នើយោបល់មិត្តទាំងប្រាំសម្រេចចិត្តទៅនៅកោះកុងឬទេ? ទី២ ធ្វើសេចក្ដីស្នើសុំទៅគណៈភូមិភាគអំពីការសុំកម្មាភិបាលទាំងមហាជននៅសេនាធិការដែលមានស្រុកកំណើតនៅកោះកុងឲ្យត្រឡប់ទៅធ្វើការនៅកោះកុងវិញ ព្រមទាំងថៃ និងម្នាក់ទៀតមិនស្គាល់ឈ្មោះ ទី៣ ដោះស្រាយបញ្ហាស្មុគស្មាញនៅមន្ទីរសេនាធិការ ទី៤ បញ្ហាផ្សេងៗ។ បន្ទាប់ពីយល់ស្របតាមចំណុចទាំងបួនហើយ តាចុង បានសរសេរសំណើទៅកាន់តា១៥(តាម៉ុក)។ តួនាទីរបស់ ផាន់ នៅពេលនោះជាអ្នកចាំស្តាប់និងរាយការណ៍ទៅ តាចុង។ ក្រោយមក ផាន់ រាយការណ៍ប្រាប់ តាចុង បន្ថែមទៀតអំពីការរៀនសូត្រវគ្គមួយឲ្យពួកហាណូយដែលមិត្ត ស៊ី លើកឡើងថា "រឿងវៀតណាមមកស្រុកខ្មែរនេះ វាចង់លេបត្របាក់កម្ពុជា ចង់ក្តាប់កម្ពុជាតាំងពីលើដល់ក្រោម វាចង់ក្តាប់មជ្ឈិម ក្តាប់មជ្ឈិមមិនបានក្តាប់ភាគ ក្តាប់ភាគមិនបានក្តាប់តំបន់ បើក្តាប់តំបន់មិនបានក្តាប់ស្រុក ក្តាប់ស្រុកមិនបានក្តាប់ភូមិ ភូមិមិនបានក្តាប់ប្រជាជនទូទៅ ក្តាប់ប្រជាជនទូទៅមិនបានទៀត ក្តាប់ប្រជាជនម្នាក់ពីរនាក់ទៀត បើមិនបានទៀតទៅក្តាប់ដីមួយដុំមួយកន្លែង នេះធាតុពូជអាក្រក់របស់យួន"។ ក្រោយមក មានប្រជុំមួយទៀត។ តាចុង ក៏បានចូលរួមដែរ។ តាចុង បានប្រាប់ថា តា១៥ បានឯកភាពឲ្យពួក នួន ទៅ(១១តំបន់) ហើយដើម្បីមកប្រជុំ។

ខ្ទឹមសារនោះគឺប្រគល់ភារកិច្ចឲ្យ ថៃ ធ្វើជាសមាជិកស្រុក ចំពោះតែភារកិច្ចគឺនៅឃុំជីផាត ខេត្តកោះកុងតែប៉ុណ្ណោះ ។ យុទ្ធ បញ្ញានឲ្យទៅនៅខាងភ័ស្តុភារយោធាតំបន់ ឈ្លបចូលតាមឃុំ តាមមន្ទីរ តាមសាលា ទាំងសាលាយោធានិងនយោបាយ ខាងពាណិជ្ជកម្មប្រគល់មកឲ្យ ថៃ វិញ ។ សន (ចៅហ្វាយស្រុកត្រពាំងរូងពីមុន) ខាងបច្ចេកទេសជាអ្នកចាត់ចែងទិញសម្ភារ ដូចជាក្រណាត់ ក្រដាស ថ្នាំពេទ្យ ។ល។ ក្រោយរដ្ឋប្រហារ ឆ្នាំ១៩៧០ សន មកនៅ(ភូមិ)ភាគដំណាលនឹង តាចុងដែរ ។ មកដល់ភ្លាម សន ត្រូវបានចាត់តាំងឲ្យនៅមន្ទីរវប្បធម៌ជាមួយ គ្រិន ក្រោយមកផ្លាស់នៅជាមួយ នួន អនុលេខាទទួលខាង សេនាធិការតំបន់ ។ នៅពេលប្រជុំចប់ ចុង នួន ខដន នៅបន្ត ការពិភាក្សាគ្នាម្តងទៀតជាភាសាថៃផង ភាសាខ្មែរផង និង ភាសាវៀតណាមផង ។ ផាន់ និយាយថា «ខ្ញុំនៅក្បែរនេះគេប្រាប់ ថាចូលស្តាប់ក៏បានមិនចូលក៏បានស្តាប់បាន ដោយគេមិននិយាយ ខ្មែរឬយួនទេ ព្រោះខ្លាចពួកហាណូយនៅជិតៗ គេនិយាយភាសាថៃ» ។ ពេលពិភាក្សាចប់ ផាន់ ត្រូវបានចាត់តាំងឲ្យចេញសារាចរមួយ ជូនចំពោះ វ៉ន អំពីសមាសភាពថ្មី ។ សារាចរនោះ ផាន់ សរសេរថា «ជូនចំពោះ វ៉ន អំពីការចាត់តាំងសមាសភាពតំបន់ថ្មី ដែលមាន វ៉ន ជាលេខា នួន អនុនិងទទួលសេនាធិការ ខដន ជាសមាជិក ស្រុកត្រពាំងរូង (កោះកុង)ផង ទាំងបីនាក់អចិន្ត្រៃយ៍និង ម៉ែន សមាជិកទទួលស្រុកថ្មស(កោះកុង) ធីវ សមាជិកទទួលស្រុកថ្មបាំង» ។ សារាចរនេះមានចុះហត្ថលេខាដោយ តាចុង ហើយ តាចុង ក៏ បានសរសេរសំបុត្រយ៉ាងវែងជាភាសាថៃផ្ញើទៅជាមួយគ្នានោះ ទៀត ។ តាមការចាត់តាំងពេលនេះ ម៉ែន និង ធីវ បានទទួល ភារកិច្ចរៀងៗខ្លួន ដែលស្រុកទាំងពីរ ថ្មសនិងថ្មបាំង នៅជាប់ ព្រំដែនកំពង់សីលា ខេត្តកោះកុង ទីនោះភាគច្រើនមាន ប្រជាជនខ្មែររស់នៅ ។ ចំណែក ផាន់ មកនៅមន្ទីរភាគធ្វើជា ជំនួយការរបស់ តាចុង យកការណ៍ពីបក្សមកឲ្យ តាចុង ជាប្រចាំ ពីសភាពការណ៍មិនល្អដែលនៅជុំវិញខ្លួន ។ រហូតចុងដល់ឆ្នាំ ១៩៧២ មានសេចក្តីសម្រេចរបស់សន្និបាតចាត់តាំងឲ្យមាន គណៈកម្មាធិការបក្សនៃមន្ទីរនានានៅជុំវិញមន្ទីរភាគ ។ ផាន់ ជាលេខា គ្រិន ជាអនុលេខា យ៉េន ជាសមាជិក ដែលនៅប្រចាំ ការជាអចិន្ត្រៃយ៍ ក្រៅពីនោះមានសមាជិកពីររូបទៀតគឺ អ៊ីវែង និង លី ។ ដោយឈរលើជំហរបុណ្យសក្តិនិយមដាច់ខាត ផាន់ ចាប់ផ្តើមមានគោលជំហរយ្វេងយ្វាង ហើយរឹតតែក្បត់បក្ស កាន់តែខ្លាំង «នៅពេលនោះខ្ញុំមានគោលជំហរយ្វេងយ្វាងហើយ ព្រោះខ្ញុំពេញចិត្តនឹងភារកិច្ចដែលអង្គការចាត់តាំងក្នុងជំហរ បុណ្យសក្តិនិយម ។ ខ្ញុំពេញចិត្ត ខ្ញុំថាដាច់ខាតហើយ ។ តែខ្ញុំ រឹតតែក្បត់បក្សកាន់តែខ្លាំងថែមទៀត ។»

នៅខែ១ ឆ្នាំ១៩៧៣ ផាន់ និង តាយិន កសាងកម្លាំង បានពីរនាក់ឈ្មោះ ឈាង និងឈ្មោះ ស៊ាន អតីតជាអ្នកទិញដូរ សម្ភារនិងជាអ្នកកាន់បញ្ជីរបស់ពាណិជ្ជកម្មភូមិភាគនិរតី ក្រោយ មកអង្គការបានផ្លាស់ឲ្យទៅទទួលភារកិច្ចខាងពាណិជកម្មតំបន់ កំពង់សីលាមួយរយៈ ទើបឆ្លងទៅកោះកុងជួប តាចុង ហើយបាន ជួបបក្សពួកនៅទីនោះយ៉ាងច្រើន ពិសេស ប្រាឆា ជាអ្នកទទួល ភារកិច្ចគ្រប់គ្រងនៅតំបន់អណ្តូងទឹក (កោះកុង) ។ នៅកំពង់សីលា មានមនុស្សជាច្រើនតែងតែផ្សព្វផ្សាយថា «នៅកំពង់សីលានេះ មានការចាប់ចងកាប់សម្លាប់មនុស្សសម្បើមណាស់ ស៊ីទាំងថ្លើម ក្លែមស្រាទៀត» តែធាតុពិត ពេល ផាន់ ទៅដល់ នៅកំពង់សីលា នេះ«មានភាពស្រស់បំព្រង មនុស្សដើរហើរធ្វើការជាធម្មតា» ។ ផាន់ បានត្រឡប់មកសុំមនុស្សពីរនាក់ពីអង្គការឈ្មោះ ហន និង ស៊ាន ហើយចាប់ផ្តើមធ្វើសកម្មភាពទាក់ទងប្រជាជនយកឥវ៉ាន់ពី ភាគ រួមមានស្ករ អំបិល ទិញផលិតផលម្រេចពីប្រជាជន ។ ឆ្លៀតពេលនោះ ផាន់ ទៅក្តាប់និងពិនិត្យសភាពការណ៍តាំងពីប្រជាជន រហូតដល់ស្រទាប់លើ ដើម្បីក្តាប់ចំណុចខ្សោយធ្វើសកម្មភាព លួចលាក់ «ពួកខ្ញុំក្តាប់សភាពនេះបានទាំងអស់មានលាក់ទុកម្រេច ជាច្រើនសម្រាប់លួចរត់ចេញទៅកោះកុង ។ អ្នកធម្មតាៗគេ ស្មោះត្រង់នឹងបដិវត្តន៍ធម្មតា ។ ឯខ្ញុំ (ផាន់) ក៏ខំប្រឹងក្តាប់ពួក ស្រទាប់ឈ្មួញមួយចំនួនដែលយើងប្រើវាឲ្យទៅទិញឥវ៉ាន់នៅ ស្រុកយួន» ។ ឆ្លៀតពេលនោះដែរ ផាន់ បានឡើងទៅជួប តាចុង នៅកោះកុងរៀងរាល់ពីរខែម្តង ។ នួន បាននិយាយប្រាប់ ផាន់ ថា «គេថាខ្មែរយើងនៅកំពង់សីលាអត់មានទេ មានប៉ុន្មានគេ សម្លាប់អស់ទៅហើយ នៅសល់ខ្លះរត់មកនេះអស់ហើយ ។ ឥឡូវ នៅឯថ្មបាំងឯណោះសន្ទឹកសន្ទាប់ ។ ម្តងគេដាក់ផែនការឲ្យ

ប្រមូលពួកស្រទាប់លើដើម្បីឲ្យរត់មកខាងកោះកុង...ខ្ញុំ(ដាន់) ធ្វើតាមគេជាហូរហែ ។ ដាន់ ធ្វើជាបំភ័យសមាសភាពមួយចំនួនឲ្យរត់ទៅកោះកុង ដោយនិយាយថា "ចាប់គិញបាន វាយសួរចម្លើយឆ្លើយដាក់មួយចំនួនទៀត ពុំទាន់ចាប់ ពួកវាដាក់គិញពិតក៏រត់ទៅខ្ទាំងបាត់"។ ខែ៧ ដាន់ បានទៅកោះកុងរាយការណ៍ប្រាប់ពីសកម្មភាពឲ្យ តាចុង ។ តាចុង បានណែនាំថា "ខំប្រឹងធ្វើទៀតទៅប្រយ័ត្នគ្រោះថ្នាក់" រួចបានចាត់តាំង ដាន់ ទៅទាក់ទង ញ៉ឹក គណៈតំបន់៣៧ ។ ក្រោយមក ដាន់ បានមកធ្វើការជាមួយ អេង ប្រធានស្រុកស្រែអំបិល ។ អេង បានបញ្ជាក្រុម ដាន់ ឲ្យលាក់ក្រណាត់ទុកមិនចែកឲ្យប្រជាជន ដើម្បីឲ្យប្រជាជនវាយប្រហារអង្គការ ហើយឲ្យពួកអ្នកមានចេញចូលទៅស្រុកយួនទិញរបស់ល្អៗបញ្ឆិតចិត្តអ្នកក្រីក្រ ។ ដាន់ ក៏បានមកធ្វើការជាមួយមិត្ត នៅធ្វើសកម្មភាពកម្ទេចគិញជាបណ្តើរៗរហូតកាន់តែលេចធ្លោឡើង ។ ដាន់ និយាយថា "ពួកខ្ញុំមួយផ្នែកជួយក្នុងការកម្ទេចនេះដើម្បីលាក់មុខ...អប់រំផងកសាងផង រិះគន់ការផង បានបោសសម្អាតពួកនៅសល់យ៉ាងក្តៅគគុក"។ នៅចុងឆ្នាំ១៩៧៣ បក្សបានបោសសម្អាតខ្មាំងបង្កប់នៅតំបន់៣៧បានយ៉ាងរៀបរយ ។ ដាន់ ក៏បានចូលរួមកម្ទេចសមាសភាពមួយចំនួនដែរ ។ "ខ្ញុំ(ដាន់) ត្រូវរួមជាមួយបក្សកម្ទេចដើម្បីបិទបាំងមុខ" ។ ក្រោយមក ដាន់ ត្រូវទៅអប់រំរៀនសូត្រក្នុងសភាពការណ៍តំបន់៣៧ ដែលត្រូវប្រកាន់យកផ្លូវមួយច្បាស់លាស់ អង្គការជានឹងកម្ទេចដៃជើងណាដែលក្បត់ដូចពួកដៃជើងវាពីឆ្នាំ១៩៧៤ ។ ដាន់ និយាយថា "ចាប់តាំងពីពេលនោះមកខ្ញុំត្រូវខ្ជាចកម្លាំងចលនា ហើយសម្របខ្លួនដើរតាមមាគ៌ារបស់បក្សដោយដាច់ខាតវិញ គឺនៅខែ៨-៧៣ដែលចាប់ឈប់ធ្វើសកម្មភាពទាំងអស់គ្នា" ។

## ផែនការកុប្បកម្មនៅខែ៦ ឆ្នាំ១៩៧៦

តាមចម្លើយលើកទី៤បាននិយាយថា ដាន់ បានទៅទាក់ទងឈ្មោះ ញ៉ឹក នៅកំពង់សីលា ខេត្តកោះកុង ជាប់រហូត (តាចុង ខន្ទេសនាមពីខាងលើ) ។ រួចភ្ជាប់ខ្សែជាមួយឈ្មោះ ជា(ចំណាររបស់ឌុច ថា "**ជា នេះហៅ សា ជាប្អូនរបស់ ទីវ អុល ។ ជាមនុស្សស្មុគ ។ តាមឯកសារដែលភ្ជាប់បានពីមុនរហូតឥឡូវគ្មានបញ្ជាក់ថាជាខ្សែអាអេង ខរេយ្យ ទេ ។**") តាម អេង ចាត់តាំង ។ ចំណែកឈ្មោះ អេង ឌុច បានសរសេរថា "**អាអេង ហៅ ខរេយ្យ ភ្ជាប់បានតាមឯកសារពីមុនជាខ្សែអាគិម-សែត (សម័យន.ប) ទាក់ទង និង ឈុន-សុខដួន (សម័យកុប្បកម្ម) ទាក់ទងនិងធ្វើការងារក្រោមបញ្ជា ចុង ក្នុងខ្សែ ចុង (អតីតអនុលេខាធិការតំបន់ចាស់) សម័យសង្គ្រាម ។ មិនទាន់មានឯកសារនិយាយថានៅក្នុងខ្សែតាញ៉ឹកទេ ។**" មិត្តជា ត្រូវបាន ញ៉ឹក ប្រគល់ភារកិច្ចឲ្យទៅកាន់ការខាងនេសាទ និងធ្វើជានិរសានៅខាងតំបន់១១ផង ។ តាមរូបភាពខាងក្រៅ ញ៉ឹក ពេលនោះបានបំពេញភារកិច្ចវាយខ្មាំងកសាងតំបន់ កម្ចាត់សន្តិសម័ន្ធគិញយ៉ាងហ្មត់ចត់ តែរូបភាពខាងក្នុងវិញ ញ៉ឹក រក្សាសន្តិសម័ន្ធនិងកម្លាំងគិញដូចជាឈ្មោះ កុក សាយ ខៀន រហូតដល់ចុងឆ្នាំ១៩៧៤ ទើបអង្គការចាប់ ។ ដាន់ ឆាំ វុធ ជា ពេទ្យណា និងពេទ្យសុខ ប្រចាំការនៅក្រុងកំពង់សោម បានចូលរួមប្រជុំមួយដើម្បីដោះស្រាយផែនការត្រៀមវាយបក្សកុម្មុយនិស្តកម្ពុជា ខ្លឹមសារប្រជុំនោះនិយាយថា «ការរៀបចំឲ្យមានជាខ្សែសង្វាក់ទាក់ទងនៅកំពង់សោម ពិសេសនៅភូមិភាគបស្ចិម ដឹកស្បៀងបម្រុងទុកក្នុងការបំពេញភារកិច្ចដំណើរការបន្តទៅ» ។

## ទំនាក់ទំនង ឆាន និង ដាន់ ជាមួយវៀតណាម

នៅក្នុងចម្លើយសារភាពបានសរសេរថា ចុងឆ្នាំ១៩៧៥ កងការពារដែនសមុទ្ររបស់ ឆាន ដែលប្រចាំការនៅរាមបានប្រតិបត្តិការចាប់ទូកយួនពីរគ្រឿងមានគ្នា១៦នាក់ ក្នុងពេលដែលលួចចូលនេសាទក្នុងដែនសមុទ្រកម្ពុជា ភាគច្រើនជាសេ.អ៊ី.អាកាន់ផ្ទាកសញ្ញានាគខៀវ ។ ក្នុងនោះមានយួនម្នាក់ធ្លាប់ចូលមកឈ្លានពានកម្ពុជាម្តងកាលពីឆ្នាំ១៩៧០-១៩៧៣ (មិនស្គាល់ឈ្មោះ) ជាមេបញ្ជាការដែលធ្វើសកម្មភាពនៅតំបន់៣៧ ធ្លាប់ទាក់ទងជាមួយ ឆាន ដែរ កាលពីសម័យនោះ ។ យួន ម្នាក់នេះត្រូវបានយកទៅសួរចម្លើយដាក់ដោយឡែកពីគេតាមរបៀបអ្នកទោសនយោបាយ ខុសអំពីយួនទាំង១៥នាក់ដែលចាប់មកជាមួយ ។ យួនម្នាក់នេះវាបានរាយការណ៍ពីគោលបំណងរបស់ខ្លួនដែលចូលមកនេសាទក្នុងដែនកម្ពុជានេះពុំមែនមានន័យថា "នៅខាងស្រុកយួនខ្វះត្រីចាប់ទេ...ចង់ភ្ជាប់សភាពក្នុងដែនសមុទ្រកម្ពុជា ភ្ជាប់ក្រឹត្យក្រមនៃសកម្មភាពការពារសមុទ្រកម្ពុជាយ៉ាង

ណាខ្លះ បើដកប្រជាជនចេញពីក្រុងអស់ទៅហើយនោះ ?»

ដើមខែ២ ឆ្នាំ១៩៧៦ គណៈកម្មាធិការបក្សបានដឹកនាំផែនការដែលបក្សកុម្មុយនិស្តកម្ពុជាមានគម្រោងធ្វើកុប្បកម្មដណ្តើមរដ្ឋអំណាចពីបក្សនៅកំពង់សោម ។ ញ៉ែម បានឲ្យមិត្តឆាន ស្រាវជ្រាវកម្លាំងនៅតំបន់៣៧ ដែលធ្លាប់នៅធ្វើពាណិជ្ជកម្មមុនថ្ងៃ១៧ ខែមេសា ។ ឆាន រៀបរាប់ដំណើររឿងដែលបានចាប់យួនពីខាងលើប្រាប់សមូហភាព ទើបសម្រេចឲ្យយួនម្នាក់នោះទៅទាក់ទងតាម ឆាន ។ ញ៉ែម បានលើកឡើងនូវបញ្ហាមួយចំនួនពីការមិនទុកចិត្តខ្លាចយួនម្នាក់នេះថា «បញ្ហាប្រយ័ត្នយួននេះបានទៅដល់ប្រើល្បិចកលលេងយើងធ្លាក់ទឹកសមុទ្រក្នុងពេលទៅជួបវា បញ្ហាត្រូវដោះស្រាយពេលលែងយួននេះទៅវិញគឺចៀសមិនផុតពីការសង្ស័យរបស់យុទ្ធជនមហាជននិងបញ្ហាត្រូវរាយការណ៍ទៅអង្គការ បញ្ហាទៅទាក់ទងត្រូវចាត់តាំងយុទ្ធជនយ៉ាងម៉េចប្រើរូបភាពយ៉ាងម៉េចចៀសវាងបែកការណ៍» ។ ឆាន ក៏បានលើកយកវិធីដោះស្រាយបី ១) កំណត់ពេលវេលាជួបដោយរៀបចំទូកពីរគ្រឿងនិងកាណូត១គ្រឿងចេញទៅកន្លែងណាត់មុនពេលហៀបភ្លឺ ដើម្បីក្តាប់សភាពការណ៍បើកភ្លើងជាសញ្ញាត្រូវគ្នា ២) ទុកយួនម្នាក់នេះឲ្យនៅដោយឡែក ហើយយកមនុស្សរបស់ខ្លួនទៅសួរចម្លើយបន្ថែមដោយសម្ងាត់ រួចបញ្ចេញវានៅពេលយប់ឲ្យផុតពីដែនសមុទ្រ ចំណែកពួក១៥នាក់កម្ទេចចោលបន្តគ្នា ហើយរាយការណ៍ទៅអង្គការថា កម្ទេចចោលអស់ហើយ ។ ៣) ជ្រើសរើសយុទ្ធជនប្រចាំការកន្លែង ឆាន និង យ៉ាន មួយក្រុមតូចយករូបភាពខាងក្រៅធ្វើជាចេញទៅពិនិត្យសភាពការណ៍កុំឲ្យមហាជនដឹង ។ **ការជួបគ្នាលើកទី១ខែ២ ឆ្នាំ១៩៧៦ និងលើកទី២ថ្ងៃទី២៥ ខែ២ ឆ្នាំ១៩៧៦ ខាងខ្មែរមានគ្នាពីរនាក់ ផាន់ និង ឆាន់ ខាងវៀតណាមមាន ទឹកាម ទឹចារ និងឡេម៉ាយ** ។ ជំនួបគ្នាទាំងពីរលើកនេះ ខាងវៀតណាមបានបង្ហាញពីគោលបំណងថារដ្ឋាភិបាលខ្លួនមានបំណងចង់ទាក់ទងកម្ពុជាយូរមកហើយ តែខ្សែទាក់ទងរកចាប់ពុំបានសោះ ពេលនេះខាងវៀតណាមនឹងកសាងមិត្តឲ្យបានរឹងប៉ឹងសាជាថ្មីឡើងវិញ ហើយយល់ព្រមតាមកម្ពុជាគ្រប់ជំហាន "កម្ពុជាមានអ្វីខាងវៀតណាមត្រូវទទួលពិភាក្សានៅគ្រប់ជំហាន" ។ ខាងកម្ពុជាវិញ ឆាន បាននិយាយថា កម្ពុជាចង់សុំជំនួយពីវៀតណាមនូវគ្រឿងសព្វាវុធ ប្រេង និងស្បៀង ជាដើម ដើម្បីផ្លាស់ប្តូររបបដឹកនាំថ្មី (តាមគម្រោងរបស់ញ៉ែម) ។ ឆាន ក៏លើកយកបញ្ហាមកចរចាថា "កាលដែលមកទាក់ទងនេះ គឺដើម្បីកសាងមិត្តភាពរវាងប្រទេសទាំងពីរឲ្យបានជាប់កុំឲ្យពិភពលោកមើលងាយ" បើ "បក្សនៃរដ្ឋាភិបាលវៀតណាមត្រូវការអ្វីជាថ្នូរ យើងខ្ញុំអាចមានលទ្ធភាពរកជូនវិញបាន ពិសេសអនុផលផ្សេងៗ ដូចជាឈើនិងកៅស៊ូជាដើម" ។ ទឹកាម បានយល់ស្របតាមសំណើនេះ តែបញ្ហាធំៗមួយចំនួនមិនទាន់សម្រេច ។ ដូច្នេះការពិភាក្សាត្រូវលើកទៅជួបគ្នានៅថ្ងៃទី ១៥-៣-៧៦ម្តងទៀត ។ ខាងខ្មែរបន្ថែម យ៉ាន ម្នាក់ទៀត ។ ខាងវៀតណាមមានបន្ថែមខ្មែរយៀកមិញម្នាក់និងអ្នកតស៊ូ៣នាក់ អតីតនិរតីឈ្មោះ យុិន មេបញ្ជាការកងទ័ពល្បីនៅកំពង់សោម និងកោះកុងជំនាន់បារាំង សាន់ ក៏ជាមេបញ្ជាការជំនាន់បារាំងដែរ ឡាយ ជនជាតិកាត់យួននិងសៀមនៅកោះកុង(ធ្លាប់មានឈ្មោះក្នុងទ័ពយួននៅជំនាន់បារាំងឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៤) ជាកម្មាភិបាលបក្សរបស់ ចុង ទទួលកិច្ចការខាងអាណិកជនយួននិងកម្មាភិបាលនៅកោះកុងក្រោយមករត់ទៅស្រុកយួន ។ **ទឹកាម បាននាំពាក្យបក្សនិងរដ្ឋាភិបាលវៀតណាមយល់ព្រមតាមការស្នើរបស់កម្ពុជានូវជំនួយចំនួនពីរកប៉ាល់ដោយពុំមានទាមទារជាថ្នូរអ្វីឡើយ** ប៉ុន្តែសំណូមពរខាងរដ្ឋាភិបាលកម្ពុជាឲ្យ យុិន បានធ្វើការប្រាស្រ័យទាក់ទងជាមួយផង ព្រោះអ្នកទាំងបី (យុិន សាន់ និង ឡាយ) ចង់ដឹងពីសភាពការណ៍ថ្មីរបស់កម្ពុជា ។ យុិន ក៏និយាយបន្ថែមឡើងថា រយៈពេលដែលខ្លួននៅវៀតណាម ពួកខ្លួនទាំងបីនាក់បានរៀបកម្លាំងទ័ពក្តាប់បានម្នាក់មួយកងគោលបំណងថានឹងធ្វើសកម្មភាពនៅកម្ពុជាបង្កើតជាក្រុមចោរព្រៃចូលស្រុកខ្មែរ តាមច្រកខេត្តកំពង់ស្ពឺ តាកែវ កំពតខាងលិចកំពង់សីលា និងកោះកុង តែក្តាប់សភាពការណ៍មិនទាន់ច្បាស់ ។ ម្យ៉ាងទៀត នៅពេលមុនខ្លួនបានចាត់កម្លាំង៤នាក់ឲ្យចូលមកពិនិត្យសភាពការណ៍នៅតាមផ្លូវវាលរេញទៅកំពតនិងតាមសមុទ្រ រហូតដល់ពេលនេះក៏មិនទាន់ត្រឡប់មកវិញ ហេតុនេះពេលឮដំណឹងថាខាងកម្ពុជាមកទាក់ទងវៀតណាម ទើបពួកខ្លួនមានសង្ឃឹមថាអាចចូលមកកម្ពុជាវិញ ។ សំណូមពរនេះត្រូវបានពន្យារ

ពេលដំណាលគ្នានឹងថ្ងៃកុប្បកម្មផ្ទុះឡើង ។ ក្រោយមកវៀតណាមសុំជួបកម្ពុជានៅថ្ងៃ១៥-៤-៧៦ដើម្បីចរចាជាមួយកម្ពុជាឲ្យបានល្អិតល្អន់ ខាងក្រែងខាងកម្ពុជាមិនជឿចិត្តមិនហ៊ានស្នើ ឆាន និយាយថា **«ទឹកាម ពូកែនិយាយណាស់ ល្មមតែឯងចង់ចាប់ប្រករកដោះស្រាយមិនរួច»** ។ ម្យ៉ាងទៀតពួកខ្មែរយៀកមិញនេះសុំចូលមកកម្ពុជាឆាប់ៗ តាមរបៀបចំហក៏បាន របៀបលួចលាក់ក៏បាន ។

ផែនការធ្វើកុប្បកម្មខែ៦ ឆ្នាំ១៩៧៦ ត្រូវផ្អាកព្រោះសភាពការណ៍ទូទាំងប្រទេសមានការផ្លាស់ប្តូរ ។ យ៉ិន បានឆ្លើយតបមកខាង ឆាន វិញអំពីផែនការដែលខ្លួនកំពុងត្រៀមកម្លាំងមួយកងពលដែលដឹកនាំ សាន់ ទៅធ្វើសកម្មភាពនៅខាងត្បូងផ្លូវលេខ៤ (ជិតមូលដ្ឋានចាស់ភូមិភាគនិរតី) មួយកងពលទៀត ។ យ៉ិន និង ឡាយ ធ្វើសកម្មភាពនៅខាងត្បូងផ្លូវជាតិលេខ៤តំបន់កំពង់សីលានិងកោះកុង ចំណែកខាងវៀតណាមត្រៀមចាំជួយកងទ័ពជើងទឹក ក្នុងពេលមានកុប្បកម្មដណ្តើមរដ្ឋអំណាច ។ **ក្រោយពីនោះ ទឹកាម បានស្នើសុំជួបតំណាងកម្ពុជាម្តងទៀតដោយបញ្ជាក់ថា «រដ្ឋាភិបាលវៀតណាមចង់ជួយកម្ពុជាណាស់ចង់កសាងមិត្តភាពរវាងប្រទេសទាំងពីរបក្សទាំងពីរនិងប្រជាជនទាំងពីរមិនថាតែផ្នែកនិរតីទេ ឲ្យតែបក្សកម្ពុជាត្រូវការកម្លាំងព្រមជួយទាំងអស់»** ។ ឆាន បានឆ្លើយតបវិញថា«ការពឹងពាក់នេះថាមិនមែនខ្មែរមិនត្រូវការជំនួយនោះទេ នេះមកពីកម្ពុជាកំពុងតែរវល់ឆ្លៀតពេលមិនទាន់បាន ហើយក៏មិនចង្អៀតចង្អល់ចំពោះការចងមិត្តភាពជាមួយអន្តរជាតិនោះដែរ លើកលែងតែចក្រពត្តិអាមេរិក និងប្រទេសបរិវារមួយចំនួន ។ ដូច្នេះកុំថាឡើយត្រឹមការទាក់ទងជាមួយបក្សវៀតណាមឬប្រទេសអព្យាក្រឹត្យនិងសង្គមនិយមដទៃ ថ្ងៃក្រោយឲ្យតែកម្ពុជារៀបចំប្រទេសស្រួលបួលហើយ សូម្បីតែប្រទេសសូវៀតក៏កម្ពុជាចងមិត្តដែរ» ។ ចម្លើយលើកទី១៦ក៏បាននិយាយពីគោលបំណងរបស់វៀតណាមដែរថាៈ «វៀតណាមមានគោលបំណងទាក់ទងនឹងបក្សក្បត់នេះ ដើម្បីឆ្លងមកក្តាប់កម្ពុជា ព្រោះគេរង់ចាំឲ្យកម្ពុជាខ្សោយន្ទាលនឹងសង្កត់តាមរយៈត្រៀមបញ្ចូលពួកខ្មែរយៀកមិញមកកម្ពុជាគឺឈ្មោះ យ៉ិន នេះតែម្តង រួចត្រៀមកម្លាំងយោធាវៀតណាម ដើម្បីចូលក្តាប់ពេលកុប្បកម្ម ដោយមិនបាច់មានការអនុញ្ញាតត្រៀមកម្លាំងទាក់ទងជាមួយតំណាងបក្សក្បត់ឡើយ ក្តាប់សភាពការណ៍រួមឈានទៅរកផែនការក្តាប់ទូទាំងប្រទេស» ។

ឯកសារខាងលើសង្ខេបចេញពីចម្លើយសារភាពបួនដុំរបស់ ញ៉ែប សួង ។ នៅលើចម្លើយទី១៦ នេះមានចំណារមួយសរសេរថា **«សម្ងាត់បំផុត»** ខ្លឹមសារនៃចម្លើយនេះបាននិយាយដូចនឹងចម្លើយទី១០ដែរ ។ ញ៉ែប សួង ត្រូវបានឈ្មោះ ថា ពួកទី១ ជាអ្នកសួរនិងសរុបចម្លើយ ប៉ុន ជាអ្នកសង្កេត ។ គ្រប់សន្លឹកសុទ្ធតែមានឈ្មោះនិងហត្ថលេខា ដាន់ និងចំណារមួយព្រមទទួលស្គាល់ថា «បានអានម្តងទៀតឃើញត្រឹមត្រូវដូចអត្ថបទដែលខ្ញុំសរសេរហើយ» ។ នៅទំព័រមុខនៃចម្លើយលើកទីបីដាក់ថា **«អានហើយ ជូនអង្គការពីរច្បាប់១១-១១-៧៦»** ។ ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ចំណារលើកទី៤ សរសេរដោយ ឌុច «សង្កេតផែនការកុប្បកម្មដែលវារាយការណ៍គឺវារាយការណ៍ឃ្លោងជាមួយ ញ៉ែម គឺមានចំណុចឯកភាពនិងសេចក្តីរាយការណ៍របស់ ឆាន-មី-សោម-ធុង ។ ចំណែកមនុស្សដែលគ្មាននរណានិយាយថាក្បត់សោះ ហើយវានិយាយម្នាក់វាគឺបង ឆាំ(សភា) ខិម(ត៣២) តី(ត១១) និង ពេទ្យសុខ(១៦៤) ដោយគោរព ឌុច ថ្ងៃទី១១-១១-៧៦» ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ពេទ្យសុខនៅតំបន់៣៧កំពង់សោម ត្រូវបាន ឌុច គូសសម្គាល់បន្ថែមថា «កន្លងមកមិនមានឯកសារនិយាយពីពេទ្យសុខទេ ។ សូមរាយការណ៍ជូនតាមការក្តាប់បានផ្ទាល់ខ្លះ ។ ពេទ្យសុខ ឈ្មោះដើម នាមឈ្មោះបញ្ជីជាតិ សូ សំបន ។ ស្រុកកំណើត ឃុំសំព្រោចស្រុកស្ទោង ខេត្តកំពង់ធំ ។ ឪពុកមាឈ្មោះ ហ៊ឹម ធ្វើមេឃុំនៅឃុំពាមបាង ស្រុកស្ទោង ច្រើនជំនាន់ដែរ ។ ពេទ្យសុខ ជាសិស្សរួមថ្នាក់ឧត្តមដ្ឋានជាមួយខ្ញុំ ។ ចរិតឃ្លោងដែរពីក្មេង ។ ចេញធ្វើពេទ្យរៀបការជាមួយនឹងក្មួយបង កែ គិមហួត ។ ក្រោយមកធ្លាប់ឃើញគ្នាម្តងម្កាលនៅភ្នំពេញ (៦៦-៦៧) ក្នុងឋានៈជាមហាជនចំរើនរបស់បង គិមហួត ។ ឆាន ចាប់ហើយ ណា ស្លាប់» ។ ចំណារក្នុងចម្លើយទី១០ដាក់ថា **«អានហើយ ៧-១២-៧៦»** ។ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៧៦ និង ចំណារលើកទី១៦ ដាក់ថា **«សម្ងាត់បំផុត»** ថ្ងៃទី៤ ខែធ្នូ ឆ្នាំ ១៩៧៦ ។ **លី សុផល**

យើងលើកសំណួរនេះឡើងវិញដើម្បីបញ្ជាក់នូវទិសដៅសំណូមពរនិងឧត្តមគតិយើងជាជនបដិវត្តឲ្យច្បាស់ឡើងវិញ ។ កាលដើមឡើយ សង្គមជាតិយើងជាសង្គមអាណានិគមពាក់កណ្តាលសក្តិភូមិ ។ នេះបើគិតតែពីត្រឹមពេលដែលអាណានិគមបារាំងចូលរុករានឈ្លានពានទឹកដីកម្ពុជាយើង ។ ក្រោយឆ្នាំ៥៤ សង្គមកម្ពុជាយើង បានវិវត្តជាសង្គមពាក់កណ្តាលអាណានិគមពាក់កណ្តាលសក្តិភូមិ ។ លុះក្រោយរដ្ឋប្រហារថ្ងៃ១៨ ខែមីនា ឆ្នាំ១៩៧០ សង្គមកម្ពុជាយើងបានធ្លាក់ទៅជាសង្គមអាណានិគមពាក់កណ្តាលសក្តិភូមិជាថ្មីវិញម្តងទៀត ។ តែបើសរុបឲ្យខ្លីទៅក្នុងរយៈកាលទាំង៣នេះ ប្រទេសជាតិនិងប្រជាជនកម្ពុជាយើងត្រូវស្ថិតនៅក្រោមក្រញាំរបស់ចក្រពត្តិអាណានិគមនិយមចាស់ថ្មី និងស្ថិតនៅក្រោមរបបជិះជាន់ផ្តាច់ការហ្វាស៊ីសនៃពួកវណ្ណៈកាន់អំណាចជាសក្តិភូមិនិងនាយទុនជាប់ជាបន្តបន្ទាប់រៀងរហូតមក ។ ដូច្នេះ ប្រជាជនកម្ពុជា ហើយជាពិសេសជាងគេគឺប្រជាជន កម្មករកសិករក្រីក្រ ពលករដែលមានភាគច្រើនលើសលប់ក្នុងចំណោមប្រជាជនកម្ពុជាទាំងមូលត្រូវរស់នៅរងទុក្ខវេទនាឈឺចាប់ខ្លោចផ្សាអាប់ឱនកិត្តិយស ក្រោមការជិះជាន់សង្កត់សង្កិនមើលងាយ មើលថោករបស់ចក្រពត្តិអាណា-និគមនិយមចាស់ថ្មី និងពួកវណ្ណៈកាន់អំណាចក្បត់ជាតិយ៉ាងធ្ងន់ធ្ងរណាស់គ្មានពេលណាងើបមុខរួចនឹងគេឡើយ ។

ឯប្រទេសជាតិកម្ពុជាយើងក៏ត្រូវធ្លាក់ខ្លួនទៅជាប្រទេសខ្ញុំគេ អាប់ឱនកិត្តិយសបាត់ឈ្មោះបោះសំឡេងស្ទើរតែសូន្យឈឹងទៅហើយ ។ ដូច្នេះក្នុងរយៈកាលទាំង៣ខាងលើនេះ ទាំងប្រទេសជាតិ ទាំងប្រជាជនកម្ពុជា ត្រូវស្ថិតនៅក្នុងសភាពងងឹតសូន្យសុងគ្មានឃើញពន្លឺរស្មីនៃសេចក្តីរុងរឿងថ្លៃថ្នូរ ហើយក៏គ្មានឃើញពន្លឺអនាគតរបស់ខ្លួនបន្តិចសោះឡើយ ។ ទិសវិវត្តមានតែមួយគត់គឺឈានទៅវិនាសសាបសូន្យ បាត់បង់អស់ទាំងឈ្មោះ ទាំងសំឡេងបាត់បង់អស់ទាំងទឹកដី ។ និយាយឲ្យខ្លីទៅគឺឈានទៅស្លាប់តែម្តង ។

ស្ថិតនៅចំពោះមុខគ្រោះមហន្តរាយដ៏ធំធេងនិងទុក្ខសោកឈឺចាប់ខ្លោចផ្សាឥតត្រើយត្រាណរបស់ប្រទេសជាតិនិងប្រជាជនយើងយ៉ាងនេះ តើយើងទាំងអស់គ្នាដែលជាកុលបុត្រកុលធីតានៃមាតុភូមិកម្ពុជា សុខចិត្តអោបដៃនៅស្ងៀមរង់ចាំថ្ងៃស្លាប់ ឬក៏ក្រោកឡើងតស៊ូរើបម្រះឲ្យរួចចាកផុតពីច្រវ៉ាក់ខ្នោះឃ្នាងនិងនឹមដែកដ៏សែនធ្ងន់របស់ចក្រពត្តិអាណានិគមនិយមចាស់-ថ្មី ដើម្បីរំដោះប្រទេសជាតិរំដោះប្រជាជនរបស់ខ្លួន?

ចំពោះសំណួរនេះ មិត្តយុវជន-យុវនារីបដិវត្តយើងទាំងអស់គ្នាពិតជានឹងឆ្លើយជាឯកច្ឆ័ន្ទព្រមគ្នាឡើងថា "ដាច់ខាតតស៊ូដើម្បីរំដោះប្រជាជននិងរំដោះខ្លួនទោះបីជាត្រូវធ្វើពលិកម្មធំធេង



យ៉ាងណាក៏ដោយ រហូតដល់ត្រូវពលីអាយុជីវិតខ្លួនទៀតក៏ដោយ...» ។

នេះហើយជាមូលហេតុដែលនាំឲ្យបក្សកុម្មុយនិស្តកម្ពុជាកកើតឡើង ដើម្បីដឹកនាំប្រជាជនក្រីក្រ យើងងើបឡើងតស៊ូរើបម្រះខ្លួន ដណ្ដើមសិទ្ធិសេរីភាពនិងឋានៈខ្លួនជាម្ចាស់ប្រទេស ម្ចាស់ទឹក ម្ចាស់ដី ម្ចាស់ព្រៃព្រឹក្សា ម្ចាស់គិរីបព្វតា ម្ចាស់ស្រែចម្ការ និងម្ចាស់លើជោគវាសនាអនាគតរបស់ខ្លួនពេញទី ។ នេះហើយ ដែលជាហេតុផលនាំឲ្យយើងទាំងអស់គ្នាចាំបាច់ត្រូវតែធ្វើបដិវត្តន៍ វាយរំលំនឹមត្រួតត្រាជិះជាន់របស់ចក្រពត្តិ-អាណានិគមចាស់ថ្មី និងវាយបណ្ដេញពួកចក្រពត្តិបរទេសដែលរុករានទន្ទ្រានឈ្លានពានទឹកដីមាតុភូមិកម្ពុជាជាទីស្នេហានៃយើងឲ្យប្រាសចេញអស់រលីង ព្រមទាំងវាយរំលំនូវរបបជិះជាន់ផ្ដាច់ការហ្វាស៊ីសរបស់ពួកវណ្ណៈសក្តិភូមិនិងនាយទុនឲ្យរលំរលាយអស់ពីទឹកដីកម្ពុជាយើងផងដែរ ។ ដូច្នេះសរុបឲ្យខ្លីមកវិញ យើងធ្វើបដិវត្តន៍ដោយហ៊ានលះបង់អ្វីៗទាំងអស់ រហូតដល់អាយុជីវិតខ្លួនយើងទៀត គឺពុំមែនដើម្បីអ្វីក្រៅអំពីរំដោះប្រទេសជាតិ រំដោះប្រជាជននិងរំដោះវណ្ណៈក្រីក្រយើងឡើយ ។ យុវជនយុវនារីបដិវត្តយើងត្រូវក្ដាប់ទិសដៅនិងសំណូមពរនេះឲ្យច្បាស់លាស់និងឲ្យជាប់ជានិច្ច ។

តែមិត្តយើងខ្លះអាចសួរថា ចុះឥឡូវប្រទេសជាតិនិងប្រជាជនកម្ពុជាយើងត្រូវបានរំដោះទាំងស្រុង និងជាស្ថាពរយើងកាលពីថ្ងៃ១៧មេសា ១៩៧៥ តើយើងចាំបាច់ធ្វើបដិវត្តន៍សង្គមនិយមទៅទៀតធ្វើអ្វី?

សូមបញ្ជាក់ថា ចក្រពត្តិអាមេរិកព្រមទាំងមារសត្រូវគ្រប់ប្រភេទរបស់យើង ពិតមែនតែត្រូវបរាជ័យរត់ខ្ចាត់ខ្ចាយអស់ពីទឹកដីកម្ពុជាតាំងពីថ្ងៃ១៧ មេសា ១៩៧៥ ទៅមែន ហើយពួកវណ្ណៈសក្តិភូមិនាយទុន ព្រមទាំងវណ្ណៈជិះជាន់ផ្សេងៗទៀតដែលត្រូវរលំរលាយអស់ជាមូលដ្ឋានទាំងរបបនយោបាយ ទាំងមូលដ្ឋានសេដ្ឋកិច្ចក៏ពិតមែន តែពួកអស់នេះពុំទាន់រលាយសាបសូន្យអស់នៅឡើយទេ ។ ពួកនេះគឺទាំងចក្រពត្តិអាមេរិក ទាំងមារសត្រូវគ្រប់ទិសទីនៅក្រៅប្រទេស ទាំងពួកវណ្ណៈជិះជាន់គ្រប់ប្រភេទនៅក្នុងប្រទេស វាខឹងសម្បារ និងក្ដៅក្រហាយចំពោះមហាជ័យជំនះជាប្រវត្តិសាស្ត្ររបស់ប្រជាជាតិនិងប្រជាជនកម្ពុជាយើង ក្រោមការដឹកនាំនៃបក្សកុម្មុយនិស្តកម្ពុជាដ៏ត្រឹមត្រូវនិងភ្លឺស្វាងសម្បើមណាស់ ។ រីឯគោលបំណងនិងយុទ្ធសាស្ត្រលេបទឹកដីកម្ពុជា ឈ្លានពានឆក់ប្លន់កម្ពុជា និងជិះជាន់សង្កត់សង្កិនប្រជាជនកម្ពុជាយើងរបស់ពួកវានៅតែដដែល គ្មានពេលណាវាបំភ្លេចឬបញ្ឈប់នោះឡើយ ។ ឃើញយ៉ាងនេះ ទើបយុវជនយុវនារីបដិវត្តយើងយល់ច្បាស់ថា ក្រោយរំដោះប្រទេសជាតិហើយក៏ដោយ យើងចាំបាច់ត្រូវបន្តធ្វើបដិវត្តន៍សង្គមនិយមឲ្យខ្លាំងក្លាជ្រាលជ្រៅថែមទៀតតទៅទៀត ដើម្បីការពារប្រទេសជាតិយើង ការពារផលបដិវត្តដែលយើងដណ្ដើមបានមកហើយ និងការពារបក្សកុម្មុយនិស្តកម្ពុជាដ៏ត្រឹមត្រូវនៃយើងឲ្យបានជារៀងរហូត និងកាន់តែរឹងប៉ឹងខ្លាំងក្លាថែមទៀតទើបយើងរស់ ។ បើការពារមិនបានទេនោះ យើងប្រាកដជាស្លាប់ហើយ ។ ស្លាប់នេះមិនមែនស្លាប់ជាបុគ្គល១នាក់២នាក់ណាទេ មិនមែនស្លាប់ជាបក្សពួកឬជាក្រុមនយោបាយទេ ។ តែស្លាប់នេះគឺពិតជាស្លាប់ប្រទេសជាតិទាំងមូល ស្លាប់ប្រជាជនកម្ពុជាយើងទាំងមូល ។ ស្លាប់ជាខ្លឹមសារនយោបាយផង ស្លាប់ជាការបង្ហូរឈាមផង ។

ហេតុផលមួយទៀតដែលយើងចាំបាច់ត្រូវបន្តធ្វើបដិវត្តន៍សង្គមនិយមឲ្យកាន់តែខ្លាំងក្លាជ្រាលជ្រៅតទៅទៀត គឺដើម្បីកសាងប្រទេសយើងដែលជាប្រទេសក្រីក្រទន់ខ្សោយ ហើយទើបចេញផុតពីសង្គ្រាមវិនាសកម្មថែមទៀត ឲ្យទៅជាប្រទេសមួយរឹងប៉ឹងខ្លាំងក្លាមានសមត្ថភាពការពារខ្លួនបានដោយឯករាជ្យម្ចាស់ការផង និងរីកចំរើនលូតលាស់លើគ្រប់វិស័យយ៉ាងឆាប់រហ័សបំផុតដើម្បីឲ្យប្រជាជនយើងដែលធ្លាប់តែរស់នៅរងទុក្ខវេទនាឈឺចាប់ខ្លោចផ្សាអត់ឃ្លានជាង២០០០ឆ្នាំមកហើយ នោះមានជីវភាពសម្បូរសប្បាយ មានសុភមង្គលពិតប្រាកដ ។ បើរំដោះតែខាងនយោបាយហើយ ជីវភាពខាងសេដ្ឋកិច្ចនិងខាងស្មារតីនៅលំបាកតោកយ៉ាកដដែលក៏យើងមិនទាន់ហៅថារំដោះទាំងស្រុងបានដែរ ។

ហេតុផលទាំងអស់នេះហើយដែលយើងទាំងអស់គ្នាចាំបាច់បន្តធ្វើបដិវត្តន៍សង្គមនិយម រហូតឈានទៅធ្វើបដិវត្តន៍កុម្មុយនិស្តនិយមជាបន្តបន្ទាប់តទៅទៀតឲ្យខ្លាំងក្លានិងជ្រាលជ្រៅដាច់ខាត ដើម្បីការពារប្រទេសនិងកសាងកម្ពុជាប្រជាធិបតេយ្យយើងឲ្យរឹងប៉ឹងខ្លាំងក្លារីកចំរើនលូតលាស់សម្បូរសប្បាយនិងថ្កុំថ្កើងរុងរឿងទាំងនៅក្នុងប្រទេសទាំងនៅលើឆាកអន្តរជាតិ ។

# ទីតាំងរណ្តៅប្រល័យពូជសាសន៍ក្នុងស្រុកបាត់ដំបង

**(តពីលេខមុន)**

ស្រុកបាត់ដំបងមានចម្ងាយ២៧គីឡូម៉ែត្រពីសាលាខេត្តបាត់ដំបងតាមបណ្តោយផ្លូវជាតិលេខ៥ និងមានព្រំប្រទល់ខាងកើតជាប់នឹងបឹងទន្លេសាប(ភ្នំឯក) ខាងលិចជាប់នឹងស្រុកស្វាយប៉ោ ខាងជើងជាប់នឹងស្រុកមង្គលបូរី និងខាងត្បូងជាប់នឹងស្រុកបាណន់ ។ ផ្ទៃដីរួមនៃស្រុកមានចំនួន៦៨១០១ហិកតា និងមានឃុំចំនួន១០ភូមិចំនួន៧០ ប្រជាជនជាង៨៥ភាគរយជាកសិករ ។

ការអនុវត្តនូវនយោបាយសម្លាប់មនុស្សរបស់កម្ពុជាប្រជាធិបតេយ្យកាលពីជាង២២ឆ្នាំមុន នៅក្នុងស្រុកបាត់ដំបង មិនអាចលុបបាត់ពីផ្នត់គំនិតនៃប្រជាជនស្រុកបាត់ដំបងឡើយ ។ រហូតមកដល់បច្ចុប្បន្ននេះ ថ្វីដ្បិតមិនបានបន្សល់ទុកនូវស្លាកស្នាមប្រល័យពូជសាសន៍ទាំងស្រុងក៏ដោយ ប៉ុន្តែក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញច្បាស់នូវទីតាំងសម្លាប់មនុស្សធំៗចំនួនបីកន្លែងកាលពីចុងខែសីហា ឆ្នាំ១៩៩៨តាមរយៈការចង្អុលបង្ហាញរបស់អ្នកស្រុកដែលជាសាក្សីបានឃើញហេតុការណ៍សម្លាប់មនុស្សដោយផ្ទាល់ភ្នែកក្នុងជំនាន់ខ្មែរក្រហម ។

**១) ទួលបត់កង**

ទីតាំងសម្លាប់នៅទួលបត់កងស្ថិតនៅក្នុងភូមិតាសី ឃុំតាម៉ឺន ស្រុកបាត់ដំបង ខេត្តបាត់ដំបង ទីតាំងនេះមានចម្ងាយ៣គីឡូម៉ែត្រពីស្រុកបាត់ដំបង ប៉ែកខាងជើង ស្ថិតក្នុងរយៈបណ្តោយ១០៣°០៤'២៧:៥៤" និងខ្សែស្រប១៣°០៤' ១៣:៨៩" នៃការកំណត់ប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រពិភពលោកGPS ។

ការសម្លាប់មនុស្សនៅវាលបត់កងនេះបានប្រព្រឹត្តដោយមធ្យោបាយបាញ់រះទៅលើអ្នកទោសដែលជាប់ចំណងទាំងខ្សែៗដោយគ្មានត្រាប្រណី ។ ជនរងគ្រោះទាំងនោះភាគច្រើនបំផុតគឺជានាយទាហាននៃរបបសាធារណរដ្ឋខ្មែរដែលមានឋានន្តរសក្តិចាប់ពីសក្តិ២ឡើងទៅ ។ មធ្យោបាយយកនាយទាហានទាំងនោះទៅសម្លាប់ គឺពួកខ្មែរក្រហមបានបញ្ឆោតដោយប្រកាសថាមានការជ្រើសរើសពួកទាហានឲ្យទៅទទួលសម្តេចឪ ។ លុះជ្រើសអតីតទាហានបានមួយចំនួនហើយខ្មែរក្រហមបានដឹកទាហានទាំងនោះទាំងឡានៗយកទៅមែន ប៉ុន្តែមិនមែនយកទៅទទួលសម្តេចឪទេ គឺយកទៅសម្លាប់ចោលទាំងអស់នៅទួលបត់កង ។


លលាដ៍ក្បាលជនរងគ្រោះក្នុងរបបខ្មែរក្រហមដែលដឹកបាន

កង សេង

លោកពូ កង សេង អាយុ៥០ឆ្នាំ ជាប្រជាជនរស់នៅភូមិតាសី ឃុំតាម៉ឺន ស្រុកបាត់ដំបង បានរៀបរាប់ប្រាប់ក្រុមស្រាវជ្រាវយើងថា បណ្តានាយទាហានដែលជ្រើសរើសបាននោះគឺមានមួយចំនួនមិនមែនជាអតីតនាយទាហានអីទេ ប៉ុន្តែដោយចាញ់ពាក្យឃោសនារបស់ខ្មែរក្រហម ពួកគាត់ក៏បានស្ម័គ្រចិត្តទៅទទួលសម្តេចឪ ដោយកុហក

ថាខ្លួនធ្លាប់ពាក់សក្តិ២-៣-៤នឹងគេឯងដែរ ។ល។ លោកពូ កង សេង បានបន្តថា នៅពេលឡើងឡានទៅទទួលសម្តេចឪ ពួកខ្មែរក្រហមបានចាប់ផ្តើមចងស្លាបសេកជនស្ម័គ្រចិត្តទាំងនោះ ដោយយកលេសថា កុំឲ្យមានការលោតចុះពីលើឡាននៅពេលឃើញសម្តេចឪ ។ នេះគឺជាបោកប្រាសទាំងស្រុង ព្រោះប្រជាជនស្លូតត្រង់ទាំងនោះត្រូវបានបាញ់រះសម្លាប់ចោលទាំងអស់ភ្លាមៗ នៅទួលបត់កងក្រោមរូបភាពឈរបណ្តាក់ជាខ្សែៗ ដែលមានខ្សែនីឡុង(ខ្សែគោ)មួយខ្សែធ្វើជាត្រណោតដោតតាមប្រឡោះដៃ ដែលមានចងស្លាបសេកស្រាប់ នៅក្បែរទំនប់ភ្លឺស្រែខ្ទះនៅកណ្តាលវាលស្រែខ្ទះ ដែលមានទំហំបណ្តោយ១០០០ម៉ែត្រ ទទឹង ៣០០ម៉ែត្រ ។

ចំណែកលោក នៅ ពេញ រស់នៅភូមិតាសី ឃុំតាម៉ឺន ស្រុកបាត់ដំបងខេត្តបាត់ដំបងដែលបានឃើញសកម្មភាពនោះផ្ទាល់នឹងភ្នែក បាននិយាយប្រាប់ថា សាកសពដែលបានស្លាប់នៅទួលបត់កងទាំងអស់មិនត្រូវបានកប់ក្នុងរណ្តៅទេ គឺស្ថិតនៅរាយប៉ាយពេញវាលស្រែរណ្តូករណែលទាំងចំណង ។ លោក នៅ ពេញ បានបន្ថែមថា មូលហេតុដែលពួកខ្មែរក្រហមមិនបានកប់ ព្រោះពួកខ្មែរក្រហមប្រញាប់ទៅយកមនុស្សមកសម្លាប់ទៀត ។ តាមការប៉ាន់ស្មាន លោក នៅ ពេញ បានប្រាប់ថាចំនួនមនុស្សស្លាប់នៅវាលបត់កងនោះមានចំនួនចាប់ពី៣៥០ដល់៥០០នាក់ ។


នៅ ពេញ

## ២) ទួលសំរោង ឬ មេច្បារ

ទួលសំរោង ឬមេច្បារ (បច្ចុប្បន្នជាស្ថានីយពិសោធន៍ពូជស្រូវទួលសំរោង) គឺជាមន្ទីរឃុំឃាំងនិងសម្លាប់មនុស្សរបស់ខ្មែរក្រហម ។ ទីតាំងនេះមានចម្ងាយ៤១គីឡូម៉ែត្រពីសាលាខេត្តបាត់ដំបង និង១៦គីឡូម៉ែត្រពីសាលាស្រុកបាត់ដំបង ហើយត្រូវបានកំណត់ទុកតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រពិភពលោកនូវខ្សែស្រប១៣º២២'៤៧:៤៥" និងខ្សែបណ្តោយ១០៣º០១'៣១:០១" ដើម្បីដៅចំណុចនៅលើផែនទីរណ្តៅសាកសពដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបាននិងកំពុងបង្កើតឡើងតាមប្រព័ន្ធកុំព្យូទ័រក្នុងគោលបំណងថែរក្សាទុកនូវឯកសារប្រវត្តិសាស្ត្រ ។ ទីតាំងនេះមិនខុសគ្នានឹងទីតាំងសម្លាប់នៅទួលបត់កងទេ គឺជនរងគ្រោះភាគច្រើនជានាយទាហានដែលចាញ់បោកការឃោសនារបស់ខ្មែរក្រហមថាទៅទទួលសម្តេចឪ ។ អ្នកទោសដែលបានដឹកមកដល់វាលពិឃាតនេះមិនត្រូវបានសម្លាប់ភ្លាមៗទេ គឺឃុំទុកនៅផ្ទះថ្មបាក់បែកមួយល្វែងដែលត្រូវទុកចោលរហូតដល់បច្ចុប្បន្ន ស្ថិតក្នុងរបងជាមួយគ្នានៃស្ថានីយ៍ពិសោធន៍ពូជស្រូវសំរោង (ជាអតីតគុកបណ្តោះអាសន្នរបស់ខ្មែរក្រហម) ។ ក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានទៅដល់ព្រមទាំងបានថតយករូបបាក់បែក ស្នាមគ្រាប់សុះពេញជញ្ជាំងនិងស្នាមបាក់ក្រហែងក្រហូងនៅលើកម្រាលថ្មដែលទំនងខ្ទាំដោយសារការផ្ទុះគ្រាប់បែក ។

លោក រៀម ចិត្ត រស់នៅភូមិស្នួលកោង ឃុំបឹងព្រីង ស្រុកបាត់ដំបង បាននិយាយថា ផ្ទះមួយល្វែងនេះជាមន្ទីរឃុំឃាំងជិនាន់ប៉ុលពត ។ ជនរងគ្រោះភាគច្រើនជាទាហានដែលមានសក្តិធំៗ ហើយត្រូវបានដឹកយកមកតាមឡានធំៗជាច្រើនគ្រឿងមកដាក់នៅក្នុងមន្ទីរឃុំឃាំងនេះ ដោយម្នាក់ៗសុទ្ធតែជាប់ចំណងដៃជើង ។ រៀម ចិត្ត បន្តថា អ្នកទោសទាំងនោះមានជីវិតបានត្រឹមតែ៣-៤ថ្ងៃប៉ុណ្ណោះនៅក្នុងគុកនេះ បន្ទាប់មកត្រូវសម្លាប់ទាំងអស់ក្រោមការបាញ់នឹងកាំភ្លើងអាកានិងបោកគ្រាប់បែកពីពួកទាហានខ្មែរក្រហម ។ មុននឹងសម្លាប់ ខ្មែរក្រហមបានបញ្ជាឲ្យអ្នកទោសទាំងអស់តម្រៀបជួរទាំងចំណងនៅជាប់នឹងជញ្ជាំងនិងបង្កាន់ដៃគ្រប់ជ្រុងទាំង៤ រួចទើបបាញ់រះជាក្រោយ ។ ប្រសិនបើមានជនរងគ្រោះមិនទាន់ស្លាប់អស់ ខ្មែរក្រហមបានបោកគ្រាប់បែកចំកណ្តាលបន្ទប់ឃុំឃាំងមួយគ្រាប់ថែមទៀត ដើម្បីបញ្ចប់ជីវិតអ្នកដែលនៅសេសសល់ ។ សាកសពជនរងគ្រោះទាំងនោះ ត្រូវបានលើកដាក់ឡានរួចយកទៅចាក់ចោលនៅវាលស្រែខាងក្រោយការិយាល័យពិសោធន៍ពូជស្រូវទួលសំរោង ។ តាមការប៉ាន់ស្មានចំនួនសាកសព លោក រៀម ចិត្ត និងលោក ជូ ឈួន បានបញ្ជាក់ថាមានចំនួនប្រហែល៣០០នាក់ ។ សាកសពទាំងនេះគ្មានរណ្តៅកប់ទេគឺស្ថិតនៅពាសពេញវាលស្រែ ។

## ៣) ទួលជ្រៃ ឬ ទួលរូងជ្រៃ

ទួលជ្រៃ ឬទួលរូងជ្រៃ ជាទីតាំងសម្លាប់កាលពីជំនាន់ ប៉ុល ពត ស្ថិតនៅលើផ្ទៃវាលស្រែដ៏ល្វឹងល្វើយដាច់ឆ្ងាយពីផ្ទះប្រជាជន ។ ទីតាំងនេះស្ថិតនៅក្នុងភូមិកេនកេស ឃុំគោកឃ្មុំ ស្រុកបាត់ដំបង ហើយបច្ចុប្បន្នជាដីស្រែរបស់ប្រជាជន ។

នៅវេលាម៉ោង១០:១៥នាទី ក្រុមស្រាវជ្រាវបានធ្វើដំណើរទៅដល់ទីតាំងនិងបានជួបជាមួយអ្នកដឹងឮដែលបានឃើញហេតុការណ៍ផ្ទាល់ភ្នែកម្នាក់ឈ្មោះ វ៉ុធ ពន្ទក ជាប្រធាននគរបាលភូមិសំរោង ឃុំតាពូង ស្រុកបាត់ដំបង ។ លោក វ៉ុធ ពន្ទក បាននិយាយថា "ខ្ញុំបានឃើញហេតុការណ៍សម្លាប់មនុស្សនៅទួលរូងជ្រៃកាលពីជំនាន់ ប៉ុល ពត ដោយផ្ទាល់ភ្នែកពេលដែលខ្ញុំទៅឃ្វាលគោនៅក្បែរៗនោះ" ។ លោក វ៉ុធ ពន្ទក បន្តថា ប្រជាជនដែលខ្មែរក្រហមយកមកសម្លាប់នៅទួលរូងជ្រៃសុទ្ធតែត្រូវបានជ្រើសរើសកត់ឈ្មោះចូលក្នុងបញ្ជីក្រោយពីស៊ើបច្បាស់ថាជាអ្នកធ្លាប់ធ្វើទាហានកាលពីសង្គមមុន ។ វ៉ុធ ពន្ទក ប្រាប់ទៀតថា មានមនុស្សម្នាក់ឈ្មោះ ចៅ សំអឿន ពាក់សក្តិ៣អតីតស្នងការនគរបាលនៅស្រុកមោងខេត្តបាត់ដំបងក៏ត្រូវស្លាប់នៅទួលរូងជ្រៃនេះដែរ ។ សាកសពទាំងនោះមិនត្រូវបានកប់រហូតដល់ថ្ងៃ៧ មករា ឆ្នាំ១៩៧៩ ។ នៅវាលស្រែទួលរូងជ្រៃមានសុទ្ធតែឆ្អឹងដែលនៅជាប់ទាំងជាប់ចំណងរាយពាសពេញ ។ លោក ញ៉ុង សឿន បានប្រាប់ថា បើតាមការមើលឃើញគ្រោងឆ្អឹងនោះគឺប្រហែលជាមានមនុស្សស្លាប់រាប់ពាន់នាក់ ។ លោក ញ៉ុង សឿន បានអធិប្បាយថា អ្នកទោសណាក៏ដោយឲ្យតែបានមកដល់ទួលនេះ គឺគ្មាននរណាម្នាក់មានជីវិតរស់នៅឡើយ ទោះជាខំរត់គេចខ្លួនយ៉ាងណាក៏ដោយ ព្រោះការសម្លាប់របស់ខ្មែរ


អតីតគុកមេច្បារ ខេត្តបាត់ដំបង

ក្រហមនៅទីទួលនោះគឺសុទ្ធតែបាញ់រះដោយទាហានខ្មែរក្រហមជាច្រើននាក់ ។ ការសម្លាប់មនុស្សនេះមិនមែនសម្លាប់តែមួយលើកចប់នោះទេ ។ តាមការរៀបរាប់របស់លោក វ៉ុធ ពន្ទក ថាពួកខ្មែរក្រហមបានដឹកមនុស្សយកមកសម្លាប់ច្រើនលើកណាស់ ហើយវិធីសម្លាប់គឺប្រើវិធីបាញ់រះដូចមុនៗ ។ ទីតាំងនេះត្រូវបានកំណត់ទុកតាមរយៈម៉ាស៊ីនកត់ត្រាទីតាំងភូមិសាស្ត្រពិភពលោកនូវខ្សែស្រប១៣º១៤'១៤:៥១" និងខ្សែបណ្តោយ១០៣º០៥'៣៩:៦៥" ។ **ផេង ពង្សរ៉ាស៊ី**

**ពាក្យស្លោកខ្មែរក្រហម**

◆ **ឈរលើចលនាបដិវត្តរបស់មហាជនគ្រប់ផ្នែកនេះ យើងសិរិតសំរាំងជំរុះ បោសសំអាត ពង្រឹងនិងពង្រីកបក្សយើង កម្មាភិបាលបក្សជនយើង ដើម្បីដឹកនាំចលនាឱ្យបានតាមភារកិច្ចរបស់បក្ស។**

*(សៀវភៅទង់បដិវត្តលេខពិសេស ខែមេសា ១៩៧៧ ទំព័រ១២)*

# សម័យប្រជុំលើកទី៥ នីតិកាលទី២
# អំពីការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ
# ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០

*ថ្លែងដោយឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារសហប្រតិបត្តិការជាមួយអ្នកជំនាញច្បាប់បរទេស ដើម្បីរៀបចំនីតិវិធីសម្រាប់កាត់ទោសឧក្រិដ្ឋជនខ្មែរក្រហម*

**(តពីលេខមុន)** ប្រទេសនីមួយៗម្ចាស់ទៅលើការកាត់សេចក្តីលើប្រជាពលរដ្ឋរបស់គេ ឬអ្នកដែលបានប្រព្រឹត្តខុសពីច្បាប់រដ្ឋរបស់គេនោះ គឺជាការអនុវត្តច្បាប់ ហើយជាបន្តិចម្តងៗទើបកកើតឡើងនូវទ្រឹស្តីនៃនីតិរដ្ឋដែលសព្វថ្ងៃនេះ យើងកំពុងខិតខំជំរុញលើកកម្ពស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង ។

បើនិយាយពីខ្លឹមសារនេះ តាំងពីមុនការកកើតជារដ្ឋមក មុនសម័យកាលសង្គ្រាមលោកលើកទី២ គឺការគោរពអធិបតេយ្យភាពជាតិ គឺតុលាការជាតិកាត់ទោសប្រជាពលរដ្ឋនៅក្នុងប្រទេសរបស់ខ្លួន ។ មិនមានបញ្ហាដែលលើកឡើងពីចៅក្រមប្រទេសមួយទៅកាត់ក្តីប្រទេសមួយទៀតទេ ។ ប៉ុន្តែការវិវត្តនៅក្នុងប្រវត្តិសាស្ត្រដែលបានធ្វើឲ្យសញ្ញានេះទទួលនូវចំណុចដាក់ស្តែងថ្មីៗ ជាពិសេសគឺចាប់តាំងពីចន្លោះសង្គ្រាមលោកលើកទី១និងលើកទី២ ជាពិសេសនៅក្នុងសម័យកាលសង្គ្រាមលោកលើកទី២ មានការខិតខំបង្កើតឡើងនូវអ្វីដែលហៅថាតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC-International Criminal Court) ។ ប៉ុន្តែការខិតខំតាំងពីមុនសង្គ្រាមលោកលើកទី២ (១៩៣៧) រហូតមកដល់សព្វថ្ងៃនេះ ទើបតែចុះហត្ថលេខាបាននូវអ្វីដែលហៅថាអនុសញ្ញាដើម្បីប្រមូលផ្តុំប្រទេសដែលឯកភាពរៀបចំជាតុលាការឧក្រិដ្ឋកម្មអចិន្ត្រៃយ៍ ប៉ុន្តែពីឆ្នាំ១៩៣៧ មកដល់សព្វថ្ងៃនេះ មិនទាន់រៀបចំតុលាការឧក្រិដ្ឋកម្មអន្តរជាតិអចិន្ត្រៃយ៍ទេ ព្រោះនៅមានប្រទេសខ្លះមានការស្ទាក់ស្ទើរ ។




ក្រោយសង្គ្រាមលោកលើកទី២ នៅពេលដែលអាល្លឺម៉ង់និងជប៉ុនចាញ់សង្គ្រាម ពេលនោះមានការកកើតឡើងនូវតុលាការឧក្រិដ្ឋកម្ម ដើម្បីកាត់ទោសមេដឹកនាំអាល្លឺម៉ង់និងជប៉ុន ។ នៅប្រទេសអាល្លឺម៉ង់មានតុលាការមួយកើតឡើងហៅថា តុលាការយោធាអន្តរជាតិ (International Military Tribunal) នៅ Nuremberg ប្រទេសអាល្លឺម៉ង់ ហើយគឺតាំងពីសង្គ្រាមមិនទាន់ចប់ផង គេបានរៀបចំមានគំនិតបង្កើតតុលាការនេះឡើងតាមរយៈកិច្ចព្រមព្រៀងនៅទីក្រុងឡុងដ៍កាលពីថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៤៥ ។ ក្នុងអំឡុងឆ្នាំ១៩៤៥-៤៦ គេបានរៀបចំបង្កើតតុលាការនេះដែលដាក់ឈ្មោះហៅថាតុលាការយោធានៅ Nuremberg ។ តុលាការនេះបានរៀបចំដោយក្រុមប្រទេសឈ្នះសង្គ្រាម គឺមិនដូចជាតុលាការរបស់យើងសុទ្ធសាធទេ ។ ចំណុចនេះហើយដែលទូលបង្គំខ្ញុំបាទនឹងធ្វើការគូស

បញ្ចាក់ជាក្រោយ ។ ជាពិសេសប្រទេសសម្ព័ន្ធមិត្តមានសហរដ្ឋអាមេរិក បារាំង អង់គ្លេស និងអតីតសហភាពសូវៀត ។ គេរៀបចំជាតុលាការនេះឡើងដើម្បីកាត់ទោសមេដឹកនាំណាហ្ស៊ីអាល្លឺម៉ង់ ដែលជាអ្នកបានប្រព្រឹត្តខុក្រិដ្ឋកម្មសង្គ្រាមធំជាងគេ ។ ដូច្នេះតុលាការនៅ Nuremberg គឺបានកាត់ទោស២៤នាក់ ក្នុងនោះមានអ្នករួចខ្លួនខ្លះ មានអ្នកត្រូវប្រហារជីវិត មានអ្នកត្រូវជាប់គុកមួយជីវិត មានអ្នកជាប់គុកពី១០-២០ឆ្នាំ.... ។ ក្រោយនេះអ្វីដែលទូលបង្គំចង់បញ្ជាក់គឺការរៀបចំដោយក្រុមអ្នកច្បាប់នៃប្រទេសឈ្នះ ដើម្បីកាត់ទោសអ្នកចាញ់ ដូច្នេះអ្នកចាញ់គ្មានអ្នកការពារខ្លួនទេ គឺជាតុលាការដែលដាក់ចេញពីខាងក្រៅ ដើម្បីកាត់ទោសមេដឹកនាំខុក្រិដ្ឋកម្មរបស់អាល្លឺម៉ង់ ណាហ្ស៊ី ដែលបង្កសង្គ្រាមលោកលើកទី២ ។ ហើយតុលាការមួយទៀតនៅក្នុងអំឡុងឆ្នាំសង្គ្រាមលោកលើកទី២នេះពីឆ្នាំ១៩៤៦-១៩៤៩ ក្រោយ Nuremberg បន្តិចមកមានតុលាការមួយទៀតគេដាក់ឈ្មោះហៅថាតុលាការអន្តរជាតិសម្រាប់ចុងបូព៌ា តុលាការនេះរៀបចំនៅទីក្រុងតូក្យូ ដើម្បីកាត់ទោសមេដឹកនាំជប៉ុនក្នុងខុក្រិដ្ឋកម្មសង្គ្រាម ។ នៅក្នុងតុលាការ Nuremberg គេបានកំណត់នូវទោសខុក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាពខុក្រិដ្ឋកម្មប្រឆាំងនិងមនុស្សជាតិ ខុក្រិដ្ឋកម្មសង្គ្រាមគឺកកើតឡើងតាំងពីសម័យនោះមក ។ នៅជប៉ុនតុលាការយោធាអន្តរជាតិរៀបចំកាត់សេចក្តីបាន២៨នាក់ ហើយគេបានបង្កើតឡើងនូវសញ្ញាណខុក្រិដ្ឋកម្មនៃការទទួលខុសត្រូវជាបុគ្គល ខុក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងខុក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈតុលាការនៅជប៉ុន ។ ប៉ុន្តែតុលាការនេះក៏ដូច្នេះដែរគឺគេរៀបចំឡើងដោយប្រទេសឈ្នះសង្គ្រាម ។

មានតុលាការមួយទៀតក្រោយពីនេះយូរអង្វែងមក គឺមានតុលាការនៅយូហ្គោស្លាវី ដែលគេហៅថាតុលាការខុក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) និង រ៉ាន់ដា ។ តុលាការខុក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនេះបានកើតឡើងនៅឆ្នាំ១៩៩៣ ហើយតាំងនៅទីក្រុងឡាអេ ហើយក៏ជាការរៀបចំឡើងដោយអ្នកច្បាប់បរទេសដែរ ។ មកទល់ពេលនេះ (ICTY) បានកាត់សេចក្តីមនុស្សចំនួនប្រាំមួយនាក់ ហើយសែសិបមួយនាក់ឋិតនៅក្រោមការជំនុំជម្រះក្នុងចំណោមមនុស្សដែលត្រូវបានចោទប្រកាន់ជាសាធារណៈចំនួន៩៤នាក់ ។ តុលាការ (ICTY) ចំណាយទឹកប្រាក់អស់១០០លានដុល្លារក្នុងមួយឆ្នាំ ហើយប្រើប្រាស់បុគ្គលិកប្រមាណ១០០០នាក់ ។ តុលាការនៅរ៉ាន់ដា គឺមាន២ផ្នែក មានផ្នែកតុលាការអន្តរជាតិ ហើយមិនមែនតាំងនៅប្រទេសរ៉ាន់ដាទេ គឺតាំងទីនៅប្រទេសតង់ហ្សានី ដើម្បីកាត់ទោសមេដឹកនាំរ៉ាន់ដា ហើយនៅក្នុងការកាត់ទោសនេះគេអាចសន្និដ្ឋានថា គេបានរៀបចំការកាត់ទោសបាន៤៥ករណី ហើយជាមេដឹកនាំកម្រិតជាន់ខ្ពស់ ។ ទន្ទឹមនឹងនេះមានតុលាការមួយទៀតរៀបចំឡើងដោយខ្លួនឯង គេដាក់ថាតុលាការជាតិរ៉ាន់ដា គឺសម្រាប់កាត់ទោសអ្នកដែលបានប្រព្រឹត្តអំពើខុក្រិដ្ឋកម្មប្រល័យពូជសាសន៍នោះដែរ ប៉ុន្តែថ្នាក់ក្រោមដែលត្រូវចាប់ដាក់ឃុំឃាំងមានដល់ទៅ១២ម៉ឺននាក់ ដែលសព្វថ្ងៃនេះគឺថាការងារនេះគឺគេទទួលស្គាល់ថាលំបាកធ្ងើដែរ ដូច្នេះទើបមានការកែសម្រួលជាបន្តបន្ទាប់ ឧទាហរណ៍ កែសម្រួលទៅជារូបភាពកាត់ទោសតាមលក្ខណៈប្រជាប្រិយតាមភូមិ ឬការកាត់ទោសដោយប្រជាពលរដ្ឋជាដើម ។ ចំណុចមួយដែលដែលយើងទទួលស្គាល់ថាជាតុលាការកាត់ទោសខុក្រិដ្ឋកម្មដែរ គឺបានរៀបចំឡើងនៅកម្ពុជានៅឆ្នាំ១៩៧៩ ដើម្បីកាត់ទោសខុក្រិដ្ឋកម្មប្រល័យពូជសាសន៍របស់ខ្មែរក្រហមដែលនៅពេលនោះមេដឹកនាំខ្មែរក្រហម២នាក់បានត្រូវកាត់ទោសដោយតុលាការប្រជាជនបដិវត្តកម្ពុជា ដែលមានចៅក្រមខ្មែរនិងចៅក្រមបរទេសធ្វើការងារជាមួយគ្នា ។ តុលាការមួយទៀតមានឈ្មោះ ថាតុលាការខុក្រិដ្ឋកម្មអន្តរជាតិគេបានរៀបចំតាំងពីឆ្នាំ១៩៣៧ ហើយត្រូវបានកំណត់ជាចុងក្រោយដោយលក្ខន្តិកៈទីក្រុងរ៉ូមឆ្នាំ១៩៩៨ ដែលឥឡូវនេះគេទើបតែឈានមកដល់ការប្រមូលការឯកភាពបានពីប្រទេសចំនួនប្រមាណជា៦០ ហើយគឺទៅអនាគតគេនឹងខិតខំរៀបចំឲ្យទៅជាតុលាការអចិន្ត្រៃយ៍មិនបាច់មានតុលាការពិសេសដូចជា តុលាការ Nuremberg តុលាការនៅតូក្យូ តុលាការនៅរ៉ាន់ដា តុលាការអតីតយូហ្គោស្លាវីទៀតទេ បើសិនណាជាមានតុលាការខុក្រិដ្ឋកម្មអចិន្ត្រៃយ៍ ហើយគេសង្ឃឹមថាទៅអនាគតប្រហែលជាតាំងទីនៅទីក្រុងឡាអេ ។ ប្រទេសកម្ពុជាបានចុះហត្ថលេខាលើលក្ខន្តិកៈរួចហើយ ។

នេះជាករណីជាប្រវត្តិដែលទូលបង្គំខ្ញុំបាទសូមរៀបរាប់ជាសង្ខេបថា មានជាតុលាការសម្រាប់កាត់ទោសខុក្រិដ្ឋកម្មនៃខុក្រិដ្ឋកម្មនោះ ជាខុក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិប្រល័យពូជសាសន៍ជាបទខុក្រិដ្ឋកម្មប្រឆាំងសន្តិភាពជាដើម ដែលទស្សនទានទាំងនេះចេញអំពីការងាររបស់តុលាការពិសេសទាំងឡាយដែលទូលបង្គំបានលើកឡើង ។ ប៉ុន្តែតុលាការទាំងនេះ គឺបើយើងប្រៀបធៀបនឹងអ្វីដែលយើងកំពុងធ្វើ គឺមិនដូចគ្នាទេមួយផ្នែកដែលយើងរៀបរាប់គឺជាតុលាការដែលមានការរៀបចំពីខាងក្រៅ ដើម្បីកាត់ទោសអ្នកដែលជាប្រជាពលរដ្ឋ ឬក៏អ្នកដឹកនាំនៅក្នុងប្រទេសមួយហើយបើយើងប្រៀបធៀបអ្វីដែលយើងកំពុងធ្វើទៅនឹងតុលាការទាំងនេះ យើងឃើញថាមានលក្ខណៈថ្មី មានលក្ខណៈជាលើកដំបូងគេនៅលើសកលលោក នៅលើឆាកអន្តរជាតិ ព្រោះថាជាតុលាការដែលរៀបចំឡើងដោយមានការឯកភាពពីម្ចាស់ផ្ទះ ។ បើច្បាប់នេះរដ្ឋសភាមានការ

*អនុម័ត ហើយមានការឆ្លងតាមនីតិវិធី ហើយចូលជាធរមាននោះបានន័យថា ជាការព្រមព្រៀងរវាងម្ចាស់ផ្ទះនិងអ្នករៀបចំពីខាងក្រៅ ពោលគឺអង្គការសហប្រជាជាតិ ។ ដូច្នេះសេចក្តីព្រាងច្បាប់ដែលយើងធ្វើគឺអាចចាត់ទុកថាជាសេចក្តីព្រាងច្បាប់ដែលមានលក្ខណៈថ្មី ហើយគោលការណ៍ទាំងឡាយដែលយើងធ្វើជាគោលការណ៍ថ្មីដែលអ្នកច្បាប់នៅលើសកលលោកដែលអ្នកច្បាប់អន្តរជាតិ ឬអ្នកច្បាប់បរទេស ទោះជាអ្នកច្បាប់ធំឬតូចក៏ដោយ គឺអត់ដែលឃើញ អត់ដែលឮ អត់ដែលស្គាល់ទេ គឺជាករណីដែលចេញពីកម្ពុជាសព្វថ្ងៃនេះ ។ បើតាមពត៌មានជាក់ស្តែងគួរឲ្យជឿបានដែលយើងទទួលជាបន្តបន្ទាប់ គឺថានៅក្នុងក្រុមប្រឹក្សាសន្តិសុខគេចាប់ផ្តើមនិយាយអំពីគំរូតុលាការនៅកម្ពុជា ថ្វីដ្បិតតែច្បាប់យើងមិនទាន់ធ្វើចប់ មិនទាន់រៀបចំក្បាលម៉ាស៊ីនតុលាការចេញផង ប៉ុន្តែតាមការជជែកពិភាក្សាឯកភាពគ្នាលើគោលការណ៍ធំៗជាមូលដ្ឋានគេបានយល់ថា គោលការណ៍នេះប្រើប្រាស់បាន គេទទួលយកជាការបាន ហើយគេមាននិយាយបញ្ចេញមតិនៅក្នុងក្រុមប្រឹក្សាសន្តិសុខនិយាយអំពីគំរូនៅតុលាការនៅកម្ពុជា ។ នេះជាចំណុចទី១ ដែលទូលបង្គំខ្ញុំបាទលើកជាចំណុចជាក់ស្តែងនៅក្នុងបទអត្ថាធិប្បាយនេះ ។*

*ចំណុចទី២ៈ ទូលបង្គំខ្ញុំបាទសូមលើកឡើងអំពីទស្សនទាននិងគោលការណ៍សំខាន់ៗនៃសេចក្តីព្រាងច្បាប់នេះ ។ នៅក្នុងការរៀបរាប់ជាក់ស្តែងគឺអាចនិយាយថា យើងមានគោលការណ៍ធំចំនួន៣ដើម្បីរៀបចំជាយន្តការនេះ ។ គោលការណ៍ទី១ គឺគោលការណ៍គោរពយុត្តិធម៌ ការស្វែងរកយុត្តិធម៌ ។ ឯកឧត្តមទេសរដ្ឋមន្ត្រី គាត ឈន់ បានលើកឡើងនូវយោបល់មួយចំនួនដើម្បីវិនិច្ឆ័យអតីតកាល គឺការវិនិច្ឆ័យអតីតកាលពេលខ្លះក៏មានការខ្វែងយោបល់គ្នារវាងអ្នកស្រាវជ្រាវ អ្នកច្បាប់ និងអ្នកនយោបាយ ហើយពេលខ្លះមានការឯកភាពគ្នា ប៉ុន្តែអតីតកាលនេះដែលយើងកំពុងនិយាយគ្នានេះ ទូលបង្គំខ្ញុំបាទក៏យល់ឃើញដូចឯកឧត្តមទេសរដ្ឋមន្ត្រី គាត ឈន់ ដែរ គឺថាយើងនឹងងាយយល់គ្នាបាន ព្រោះជាអតីតកាលដ៏ខ្មៅចង្រៃទាំងអស់គ្នា ទាំងក្មេង ទាំងចាស់ ទាំងស្ត្រី ទាំងបុរស ទាំងអ្នកនយោបាយ ទាំងអ្នកច្បាប់ ទាំងអ្នកស្រាវជ្រាវ ទាំងអ្នកសិក្សា សុទ្ធតែថ្កោលទោសថាជាអំពើឧក្រិដ្ឋកម្ម ហើយដែលយើងដាក់ឈ្មោះថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។*

*ដូច្នេះចំណុចទី១នេះ គឺការដែលយើងខិតខំដើម្បីផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ផ្តល់យុត្តិធម៌ដល់ប្រជាពលរដ្ឋកម្ពុជា ផ្តល់យុត្តិធម៌ដល់ប្រជាជាតិកម្ពុជា ហើយលើសពីនេះទៅទៀតគឺជាការរួមចំណែកយ៉ាងសំខាន់ដល់មនុស្សជាតិដល់គោលកាណ៍មនុស្សធម៌នៅលើសកលលោកទាំងមូល ដែលគេត្រូវការថ្កោលទោសអំពើប្រល័យពូជសាសន៍ ថ្កោលទោសឧក្រិដ្ឋកម្ម ហើយទប់ស្កាត់អំពើប្រល័យពូជសាសន៍នេះកុំឲ្យមានកើតឡើង ។ ដូច្នេះការដែលយើងនៅចងចាំ ការដែលយើងរៀបចំការកាត់ទោសនេះក៏ជាជំហានមួយយ៉ាងជាក់ស្តែងដើម្បីផ្តល់យុត្តិធម៌ផង ដើម្បីបញ្ជាក់នូវការចងចាំផង ព្រោះថាការចងចាំនេះមានផលប្រយោជន៍ធំណាស់ គឺមានផលប្រយោជន៍គ្រង់រួមចំណែកទប់ស្កាត់មិនឲ្យឧក្រិដ្ឋកម្មកើតមានឡើងបានទៀតនៅកម្ពុជាជាពិសេស ហើយក៏អាចរួមចំណែកនូវការទប់ស្កាត់ឧក្រិដ្ឋកម្មអាក្រក់របៀបនេះមិនឲ្យកើតមានឡើងទៀតនៅលើប្រទេសផ្សេងៗឬក៏នៅលើពិភពលោកដែរ ។*

*យើងរួមចំណែកមិនអាចថាបាន១០០ភាគរយទេ ប៉ុន្តែជាការរួមចំណែកមួយយ៉ាងសំខាន់ដែលទូលបង្គំខ្ញុំបាទយល់ឃើញថា ច្បាប់ក្តី អ្នកនយោបាយក្តី អ្នកស្រាវជ្រាវក្តី នឹងស្វែងយល់ស្រាវជ្រាវនិងសិក្សារៀនសូត្រអំពីគំរូកម្ពុជានេះ អំពីអ្វីដែលយើងរៀបចំនេះជាចំណុចទី១ ដែលយើងលើកឡើងរកយុត្តិធម៌ដើម្បីបិទនូវទំព័រប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតដែលបានកើតមាននៅកម្ពុជា ។*

*គោលការណ៍ទី២ គឺគោលការណ៍រក្សាសន្តិភាព រក្សាស្ថិរភាពនយោបាយ រក្សាឯកភាពជាតិដែលកម្ពុជាទើបនឹងទទួលបាន ។ ទូលបង្គំយល់ថា គ្រប់មជ្ឈដ្ឋានទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងសុទ្ធតែអបអរសាទរនឹងសន្តិភាព ស្ថិរភាពនយោបាយ និងសន្តិសុខសណ្តាប់ធ្នាប់សង្គមដែលយើងខិតខំរកមកបាន បើយើងប្រៀបធៀបសភាពការណ៍សព្វថ្ងៃទៅនឹងសភាពការណ៍ក្នុងរយៈពេលមុននេះ ទោះបីយើងមិនទាន់បានសណ្តាប់ធ្នាប់សង្គម១០០ភាគរយ សន្តិសុខ១០០ភាគរយ ព្រោះថា១០០ភាគរយមិនងាយប្រទេសណាមានទេ ។ ប៉ុន្តែយើងក៏មានមោទនភាពដែលយើងបានឈានទៅមុខយ៉ាងជាក់ស្តែងនៅក្នុងដំណើរការនៃការពង្រឹងស្ថិរភាពនយោបាយ ពង្រឹងសន្តិភាព ពង្រឹងសន្តិសុខនៅកម្ពុជា ហើយនេះជាអ្វីដែលថ្លៃថ្លាបំផុតសម្រាប់មាតុភូមិកម្ពុជាជាទីស្នេហា ព្រោះថាបើចង់មើលចង់ដឹងរឿងនេះ វាមានការងាយយល់ណាស់ បើប្រៀបធៀបប្រទេសកម្ពុជាទៅនឹងប្រទេសជិតខាងកាលពីឆ្នាំមុន ឬក៏៤០ឆ្នាំមុន យើងឃើញថាព្រះរាជាណាចក្រកម្ពុជាគឺស្ថិតក្នុងកម្រិតអភិវឌ្ឍប្រហាក់ប្រហែលនឹងប្រទេសជិតខាងរបស់យើងដូចជា ថៃ សិង្ហបូរី ម៉ាឡេស៊ី ឥណ្ឌូណេស៊ី ឬតៃវ៉ាន់ កូរ៉េ ប៉ុន្តែឥឡូវនេះយើងមិនអាចប្រៀបជាមួយគេបានទេ យើងក្រីក្រជាងគេឆ្ងាយណាស់ យើងស្ថិតនៅក្នុងវង្វង់ប្រទេសដែលគេហៅថា LDC (least developed country) ប្រទេសដែលអភិវឌ្ឍតិចជាងគេ ហើយមានមូលហេតុច្រើន ប៉ុន្តែមូលហេតុដែលធំជាងគេគឺយើងសុទ្ធតែដឹងទាំងអស់គ្នា មកពីយើងមានសង្គ្រាម*

ស៊ីវិល មកពីយើងមានអស្ថិរភាពនយោបាយ មកពីយើងគ្មានសន្តិភាព ហើយយើងកាន់តែក្រទៅ គេកាន់តែមានឡើង ។ ដូច្នេះសព្វថ្ងៃមិនអាចប្រៀបធៀបយើងជាមួយគេទេ បើយើងគិតពីស្ថានភាពនៃការអភិវឌ្ឍនោះ ។ ដូច្នេះគឺទូលបង្គំបានយល់ឃើញថា ទាំងអស់គ្នាសុទ្ធតែវាយតម្លៃខ្ពស់ណាស់ចំពោះសន្តិភាព ស្ថិរភាព សន្តិសុខ ចំពោះសណ្តាប់ធ្នាប់សង្គមដែលយើងខិតខំទទួលបានមកនេះ ដូច្នេះការថែរក្សាសន្តិភាព ការថែរក្សាសន្តិសុខ វាជាភារកិច្ចដ៏ខ្ពង់ខ្ពស់របស់គ្រប់ស្ថាប័ននៅកម្ពុជា របស់ប្រជាពលរដ្ឋកម្ពុជាគ្រប់ៗរូប ដែលយើងវាយតម្លៃថាមានតម្លៃស្មើអាយុជីវិត ដូច្នេះធ្វើអ្វីក៏ដោយក៏យើងមិនត្រូវឲ្យប៉ះពាល់ទៅដល់សន្តិភាព ស្ថិរភាព ដែលយើងរកបានមកនេះទេ ។

ឯកឧត្តម ឈួរ លាងហួត បានលើកឡើងថា អ្នកខ្លះបានទិតៀនថាជាការអូសបន្លាយៗ ព្រោះជាការអូសរលំបាកដែលត្រូវស្វែងយល់គ្រប់ជ្រុងជ្រោយ រកឲ្យបាននូវឯកភាពគ្នាដែលហៅថា *Consensus* ត្រូវរ៉ូវគ្នាដោយឈរនៅលើការគោរពផលប្រយោជន៍ដ៏ខ្ពង់ខ្ពស់របស់ប្រទេសជាតិនេះ ជាការលំបាក មិនមែនជាការស្រួលទេប្រសិនបើយើងធ្វើដោយមិនគិតគូរ ។

ដូច្នេះចំណុចទី២នេះ ទូលបង្គំខ្ញុំបាទយល់ឃើញថាគឺជាចំណុចដែលនឹងមានការគាំទ្រច្បាស់លាស់ ហើយយ៉ាងសកម្មភាពពីសភាដ៏ខ្ពង់ខ្ពស់ពីប្រជាពលរដ្ឋគ្រប់ៗរូបដែលត្រូវការស្ថិរភាពនយោបាយ ត្រូវការនូវសន្តិភាព ។

គោលការណ៍ទី៣ គឺគោលការណ៍នៃការគោរពអធិបតេយ្យភាពជាតិ ។ ដូចដែលទូលបង្គំខ្ញុំបាទបានលើកឡើងរួចមកហើយ នៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិគោលការណ៍ធំជាងគេ ចម្បងជាងគេ គឺឯករាជ្យជាតិ អធិបតេយ្យភាព បូរណភាពទឹកដីនេះ ។ ដូច្នេះការដែលយើងលើកឡើងអំពីគោលការណ៍គោរពអធិបតេយ្យភាពជាតិ គឺជាការសមស្រប ហើយដែលយើងខិតខំតស៊ូនៅក្នុងន័យបែបនេះ ។ ដូច្នេះសួរថាការដែលយើងនិយាយអំពីការគោរពអធិបតេយ្យភាព ការដែលយើងធ្វើសេចក្តីព្រាងច្បាប់នេះ តើចំណុចណាខ្លះដែលបញ្ជាក់នូវការគោរពអធិបតេយ្យភាពជាតិ ។ ពីព្រោះថាការចរចាដូចដែលទូលបង្គំបានលើកឡើងរួចមកហើយ យើងត្រូវគោរពផលប្រយោជន៍គេមួយចំនួន គេត្រូវគោរពផលប្រយោជន៍យើងមួយចំនួន ។ ដូច្នេះមានចំណុចបីជាក់ស្តែងដែលទូលបង្គំខ្ញុំបាទសូមលើកឡើងគឺថា វាជាការដែលភាគីចរចាគោរពបាននូវគោលការណ៍អធិបតេយ្យភាពជាតិៈ ទី១ ការតែងតាំងចៅក្រម ។ យើងលើកឡើងថា អធិបតេយ្យភាពជាតិម្តេចក៏ឲ្យចៅក្រមបរទេសកាត់សេចក្តីនៅកម្ពុជា? ចំណុចនេះជាចំណុចរសើប ហើយដែលទូលបង្គំខ្ញុំបាទសូមធ្វើការអត្ថាធិប្បាយដូចតទៅនេះ គឺថាយើងទទួលយកចៅក្រមបរទេសមកកាត់សេចក្តីព្រោះយើងចង់បាននូវការគាំទ្ររបស់អន្តរជាតិ របស់អង្គការសហប្រជាជាតិ ។ ប៉ុន្តែអង្គការសហប្រជាជាតិលើកឡើងពីគោលការណ៍មួយអំពីអ្វីដែលហៅថា គោលការណ៍ដែលអាចជឿទុកចិត្តបាន (Credibility) គឺការជឿទុកចិត្ត ការទុកចិត្ត និងការជឿមកលើយើង ដើម្បីឲ្យគេជឿមកលើដំណើរការកាត់ទោស ។ ឲ្យគេទុកចិត្តមកលើដំណើរការកាត់ទោស គេក៏ត្រូវមានគំនិត មានគោលការណ៍មានទស្សនៈរបស់គេមួយចំនួនដែរ ដូច្នេះអំពីបញ្ហាការកាត់ទោស ទូលបង្គំខ្ញុំបាទក៏នឹងលើកឡើងអំពីបញ្ហាធំៗនៃការសម្រុះសម្រួលនោះ ។ គេចង់បានតុលាការអន្តរជាតិ យើងចង់បានតុលាការជាតិ ។ ការសម្រុះសម្រួលគឺតុលាការជាតុលាការជាតិ ប៉ុន្តែឲ្យមានចៅក្រមបរទេសចូលរួម ។ ចំណុចមួយសំខាន់គួរឲ្យកត់សម្គាល់គឺថា ចៅក្រមបរទេសទាំងនោះត្រូវទទួលការតែងតាំងពីស្ថាប័នជាន់ខ្ពស់របស់កម្ពុជាដែលមានសមត្ថកិច្ច ។ ក្នុងករណីនេះឧត្តមក្រុមប្រឹក្សាចៅក្រមលោកជាអ្នកតែងតាំង ។ នៅក្នុងសេចក្តីព្រាងច្បាប់គឺយើងចែងច្បាស់ថា អគ្គលេខាធិការអង្គការសហប្រជាជាតិជាអ្នកដែលជ្រើសរើស ប៉ុន្តែអ្នកតែងតាំងឲ្យមកកាត់សេចក្តីនៅប្រទេសកម្ពុជា គឺឧត្តមក្រុមប្រឹក្សាចៅក្រមកម្ពុជាដែលជាអ្នកតែងតាំង ចំណុចនេះទូលបង្គំខ្ញុំបាទជឿថា ជាការឆ្លុះបញ្ចាំងនូវការគោរពអធិបតេយ្យភាពជាតិកម្ពុជាមួយចំណុចដែរ ។ ទី២ ការរៀបចំសមាសភាពនៃអង្គជំនុំជម្រះ គឺយើងចង់បានភាគច្រើនជាចៅក្រមកម្ពុជា អង្គការសហប្រជាជាតិចង់បានភាគច្រើនជាចៅក្រមបរទេស ដូច្នេះតើត្រូវសម្រុះសម្រួលគ្នារបៀបដូចម្តេច យើងលើកឡើងថា ដើម្បីឆ្លុះបញ្ចាំងបានការគោរពអធិបតេយ្យជាតិកម្ពុជា គឺនៅក្នុងអង្គជំនុំជម្រះត្រូវតែចៅក្រមកម្ពុជាភាគច្រើន ។ បើក្នុងចំណោម៥នាក់គឺយើងត្រូវមាន៣នាក់ បើ៧នាក់យើងត្រូវមាន៤នាក់ បើ៩នាក់យើងត្រូវមាន៥នាក់ បានន័យថា ចៅក្រមភាគច្រើនគឺត្រូវនៅខាងកម្ពុជា ។ ខាងអង្គការសហប្រជាជាតិលោកលើកឡើងថាទេ ដើម្បីជឿទុកចិត្តបាននោះគេត្រូវការឲ្យចៅក្រមបរទេសមានភាគច្រើនវិញ ដូច្នេះការសម្រេចចិត្តនោះវាទ័លច្រក ដើម្បីជាការសម្របសម្រួលហើយនិងដើម្បីឆ្លុះបញ្ចាំងបានគោលការណ៍អធិបតេយ្យភាពជាតិ គឺទីបំផុតបានព្រមព្រៀងគ្នាថា ចៅក្រមកម្ពុជាភាគច្រើន ចៅក្រមបរទេសភាគតិច ប៉ុន្តែយកការសម្រេចមួយជារូបមន្តថ្មីដែលមិនដែលមាននៅលើសកលលោក គឺរូបមន្តដែលគេដាក់ឈ្មោះហៅថា *super majorité* ដែលមានន័យថា ភាគច្រើនលើសលប់បានន័យថា បើ៥នាក់ គេមាន២យើងមាន៣នាក់ ប៉ុន្តែការសម្រេចត្រូវសម្រេចដោយ៤នាក់ ដូច្នេះបើយើងគិតអំពីគោលការណ៍ច្បាប់បានន័យថា យើង

មានភាគច្រើនហើយ គេមានភាគតិច ដែលហៅថា *minorité bloquante* អាច *bloquer* បានជាភាគតិចតែមានលទ្ធភាពទប់ស្កាត់ មានលទ្ធភាពធ្វើឲ្យគាំងបានដែរ ដូច្នេះមានន័យថា ការចរចាត្រូវមានទៅមានមក តែមិនមែនជាការចម្លងតាមគេទេ វាគឺជាការសម្រុះសម្រួលគ្នា ដូច្នេះត្រូវគោរពគ្នាទៅវិញទៅមក នេះជាគោលការណ៍នៃការចរចា ហើយនេះជាចំណុចទី២ ដែលឆ្លុះបញ្ចាំងអំពីការគោរពអធិបតេយ្យភាពជាតិ ។ ចំណុចទី៣ ការផ្តួចផ្តើមគំនិតនៅក្នុងប្រទេសកម្ពុជា គឺដូចដែលទូលបង្គំបានលើកឡើងថា ប្រវត្តិតុលាការខុក្រិដ្ឋកម្មផ្សេងៗរៀបរាប់មកដែលបានកើតឡើងនៅលើសកលលោក ភាគច្រើនជាតុលាការដែលរៀបចំឡើងដោយចៅក្រមបរទេស ហើយផ្តើមគំនិតដោយបរទេសដាក់បន្ទុចូលទៅឲ្យធ្វើ ។ ចំណែកយន្តការរបស់យើងដែលយើងហៅថា អង្គជំនុំជម្រះវិសាមញ្ញនេះនៅក្នុងក្របខ័ណ្ឌនៃតុលាការកម្ពុជា ។ នេះជាការដែលមានការស្រុះស្រួលគ្នារវាងយើង ជាម្ចាស់ផ្ទះ ម្ចាស់រឿង ហើយនិងអង្គការសហប្រជាជាតិ ។ យើងចង់ឲ្យគេមកទទួលស្គាល់ ចង់ឲ្យគេមកដឹងពូរឿងរបស់យើង យើងចង់បានការទុកចិត្តរបស់គេ របស់សហគមន៍អន្តរជាតិ ដូច្នេះហើយបានជាមានការចូលគ្នា ព្រោះយើងក៏ត្រូវការគេ ហើយគេក៏ចង់បានការងារនេះពីយើង ។ ដូច្នេះចំណុចទាំង៣ ការតែងតាំងចៅក្រម សមាសភាពចៅក្រម និងការផ្តើមគំនិតរៀបចំជាយន្តការនេះឡើងឆ្លុះបញ្ចាំងនូវគោលគំនិតគោរពអធិបតេយ្យភាពដែលជាគោលការណ៍ធំចម្បងមួយ នៅក្នុងការរៀបចំយន្តការនេះ ។ ចំណុចនេះក៏ជាប់ពាក់ពន្ធ័នឹងចំណងជើងនៃអត្ថបទដែលមានអត្ថន័យថា «ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» ដូច្នេះទី១ ពាក្យអង្គជំនុំជម្រះវិសាមញ្ញនេះ ហើយនឹងតុលាការនេះ វាកើតចេញអំពីការសម្រុះសម្រួលរវាងថានៅក្នុងតុលាការកម្ពុជាដែលមានស្រាប់នោះ ប៉ុន្តែមានអង្គជំនុំជម្រះវិសាមញ្ញ ។ អំពីករណីមេដឹកនាំខ្មែរក្រហមនោះ មានពាក្យមួយទៀតដែលយើងប្រើថា ដើម្បីកាត់សេចក្តីខុក្រិដ្ឋកម្មដែលបានកើតឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ទូលបង្គំខ្ញុំបាទសូមធ្វើអត្ថាធិប្បាយនូវពាក្យនេះមុនឲ្យហើយគឺថាយើងប្រើពាក្យកម្ពុជាប្រជាធិបតេយ្យព្រោះយើងចង់ធ្វើការក្នុងចន្លោះពេលពីឆ្នាំ១៩៧៥មកឆ្នាំ១៩៧៩ ។ ប៉ុន្តែយើងប្រើពាក្យកម្ពុជាប្រជាធិបតេយ្យ ព្រោះថាខុក្រិដ្ឋកម្មនេះកើតឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែបើតាមការស្រាវជ្រាវជាក់ស្តែងកម្ពុជាប្រជាធិបតេយ្យ មិនមែនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ហើយមិនមែនចប់នៅថ្ងៃ៦ មករា ឆ្នាំ១៩៧៩ នោះទេ គឺបានកើតឡើងក្រោយថ្ងៃ១៧មេសា ព្រោះពេលនោះជារណសិរ្ស ដូច្នេះនៅពេលនោះគេដំណើរការបែបបទដែរដើម្បីបង្កើតកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៧៦ ហើយចប់នៅពេលដែលកើតត្រីភាគី គឺចប់នៅក្រោយឆ្នាំ១៩៧៩ ដូច្នេះការដាក់ចំណងជើងបែបនេះតើមានផលឥទ្ធិពលទៅដល់កាលបរិច្ឆេទនៃការកាត់ក្តីដែរឬទេ? ទូលបង្គំខ្ញុំបាទយល់ឃើញថា គឺនៅក្នុងសេចក្តីព្រាងច្បាប់អាចមានន័យគ្រប់គ្រាន់នៅក្នុងការកំណត់នៃរយៈកាលដែលយើងហៅថា compétence temporelle គឺយើងកំណត់នៅក្នុងមាត្រា១និងមាត្រា២ ច្បាស់ថាយើងយកតែរយៈពេលពី ១៧ មេសា ១៩៧៥ ទៅថ្ងៃ ៦ មករា ១៩៧៩ នៅក្នុងមាត្រា១ មានបញ្ជាក់ម្តងទៀតនៅក្នុងមាត្រា២និងមាត្រាផ្សេងៗទៀត ។ នៅពេលដែលយើងសរសេរចំណុចខ្លះដែលពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទ គឺយើងសុទ្ធតែបញ្ជាក់នូវកាលបរិច្ឆេទទាំងអស់ ។ ទូលបង្គំខ្ញុំបាទយល់ឃើញថា មាត្រាផ្សេងៗនេះដែលបានបញ្ជាក់កាលបរិច្ឆេទនេះគឺមិនធ្វើឲ្យមានការបកស្រាយច្រឡំទេ ព្រោះមួយជាចំណងជើងដែលឆ្លុះបញ្ចាំងនូវគំនិតរួម ហើយមួយទៀតជាវិសាលភាពពិតប្រាកដនៃការអនុវត្តឆ្លុះបញ្ចាំងនៅក្នុងមាត្រាផ្សេងៗនៃច្បាប់ ។ នេះជាចំណុចទី១និងទី២ ដែលទូលបង្គំខ្ញុំបាទសូមលើកឡើងថាមាន៥ចំណុចនេះ ។

◆ ឥឡូវនេះសុំឈានចូលចំណុចទី៣ៈ គឺការរៀបរាប់ទូលថ្វាយនិងជម្រាបជូនអំពីដំណើរការដែលឈានមកកកើតជាសេចក្តីព្រាងច្បាប់នេះ ។ តើឆ្នាំ១៩៩៧ យើងធ្វើអ្វី? ១៩៩៨ យើងធ្វើអ្វី? ហើយជាពិសេសឆ្នាំ១៩៩៩ និង ២០០០ នេះ ។ ដូច្នេះបើយើងគិតទៅវាជាង៣ឆ្នាំ ជិត៤ឆ្នាំហើយ នៅក្នុងការដែលរៀបចំដំណើរការនៃការវិនិច្ឆ័យទោសនេះ ។

◆ កាលពីខែមិថុនា ឆ្នាំ១៩៩៧ គឺមានសំណើរបស់យើងទៅអង្គការសហប្រជាជាតិដើម្បីឲ្យគេជួយផ្តល់ការឧបត្ថម្ភដំណើរការរៀបចំការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

◆ ខែវិច្ឆិកា ឆ្នាំ១៩៩៩ លោកអគ្គលេខាធិការ កូហ្វីអាណាន់ បានបញ្ជូនជំនាញការបីរូបមកកាន់កម្ពុជា ដើម្បីស្វែងយល់ដំណើរការនេះ បន្ទាប់មកគេបានធ្វើរបាយការណ៍ទៅឲ្យអគ្គលេខាអង្គការសហប្រជាជាតិវិញ ។

◆ ឆ្នាំ១៩៩៨ ដែលយើងបានកំណត់ដាក់ឈ្មោះថាជាឆ្នាំអន្តរកាល គឺមានព្រឹត្តិការណ៍នៃការបោះឆ្នោតដែលយើងបានទទួលការវាយតម្លៃថាជាអច្ឆរិយនៅតាមដងទន្លេមេគង្គនេះ ហើយចេញពីនេះគឺថាយើងបានរៀបចំរដ្ឋសភា ក្រោយមកមានការធ្វើសមាហរណកម្មនៃអតីតកងកម្លាំងរបស់ខ្មែរក្រហម ការស្លាប់របស់ ប៉ុល ពត ព្រមទាំងការចាប់ខ្លួនអ្នកទទួលខុសត្រូវមួយចំនួនរបស់កម្ពុជាប្រជាធិបតេយ្យ(តាម៉ុកនិងក្រោយមកឌុច) ។ **(តទៅទំព័រទី៤៦)**

# ករណីអ្នកទោស អ៊ីស្មាអែល អះម៉ាត់

នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៧៦ ក្នុងតំបន់៤២នៃភូមិភាគកណ្តាល ខេត្តកំពង់ចាម មានការប្រមូលផ្តុំនិស្សិតមកពីប៉េកាំងដែលត្រូវបានបញ្ជូនពីមូលដ្ឋានឲ្យត្រឡប់មកភ្នំពេញវិញ ដោយកំណត់ទីកន្លែងជួបជុំគ្នានៅភូមិអកមោក ឬហៅថាភូមិស្ពឺ ឃុំជយោ ស្រុកចម្ការលើ ខេត្តកំពង់ចាម ។ ក្រោយពីប្រមូលផ្តុំគ្នាអស់ហើយ ក៏បានចេញដំណើរមកដល់ភ្នំពេញនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៧៦ ឲ្យស្នាក់នៅ "សាលាបច្ចេកទេសខ្មែរ-សូវៀត" ។ នៅទីនោះមាននិស្សិតនិងអ្នកធ្លាប់ធ្វើការនៅប៉េកាំងទាំងអស់ចំនួន២៦នាក់ ដែលបានបញ្ជូនមកពីគ្រប់ទីកន្លែង ។ ក្រោយពីស្នាក់នៅ "សាលាបច្ចេកទេសខ្មែរ-សូវៀត" មួយរយៈត្រូវបានបំបែកគ្នា ។ មាននិស្សិតខ្លះត្រូវបានបញ្ជូនមកមន្ទីរស-២១ ឬទួលស្លែង ។ មាននិស្សិតម្នាក់ឈ្មោះ "អ៊ីស្មាអែល អះម៉ាត់" ជាជនជាតិចាមត្រូវបានចាប់ខ្លួននៅថ្ងៃទី២ ខែមករា ឆ្នាំ១៩៧៧ ។ អះម៉ាត់ ធ្លាប់បានសិក្សានៅប្រទេសអេហ្ស៊ីបរយៈពេល៦ឆ្នាំ និងនៅប្រទេសចិនរយៈពេលពីរឆ្នាំ ។ អះម៉ាត់ ដែលត្រូវបានអង្គការរណសិរ្សនៅប៉េកាំងរបស់ខ្មែរក្រហមបញ្ជូនមកជាមួយនិស្សិតដទៃទៀតចំនួន១០នាក់ត្រឡប់មកភ្នំពេញវិញនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៧៥ ។

តាមបញ្ជីអ្នកទោសផ្នែកនិស្សិតនិងអ្នករដ្ឋការពីបរទេសដែលរៀបចំដោយលោក អ៊ឹង ប៉ិច អតីតប្រធានសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងមាននិស្សិតនិងអ្នករដ្ឋការចំនួន១៨៤នាក់មកពីប្រទេសចំនួន២២ត្រូវបានពួកខ្មែរក្រហមយកមកឃុំឃាំងនៅគុកទួលស្លែង ។ ក្នុងចំណោមនោះមានឈ្មោះ អ៊ីស្មាអែល អះម៉ាត់ ស្ថិតនៅលេខរៀងទី៩២ ចុះកាលបរិច្ឆេទចូល"២-១-៧៧" រួចបញ្ជាក់ថា"និស្សិតមកពីប៉េកាំង" ។



អ៊ីស្មាអែល អះម៉ាត់

ក្នុងការចាប់ខ្លួន អះម៉ាត់ ក៏ដូចជានិស្សិតដទៃទៀត ពួកខ្មែរក្រហមបានអនុវត្តកលល្បិចបោកបញ្ឆោតថាយកទៅធ្វើការឲ្យអង្គការនៅភ្នំពេញវិញ ។ ប៉ុន្តែនេះជាមធ្យោបាយនៃការប្រមូលផ្តុំនិស្សិតឲ្យមកជួបជុំគ្នាវិញ ងាយស្រួលក្នុងការចាប់ខ្លួន ហើយជាមធ្យោបាយការពារមិនឲ្យបែកការណ៍ ឬលេចឮខ្ចរខ្ចាយដល់ប្រជាជន ។

គ្មានសាក្សីណាម្នាក់ដែលខ្ញុំបានជួបដឹងរឿងហេតុនិងគោលបំណងនៃការវិលត្រឡប់របស់ អះម៉ាត់ និងនិស្សិត៦ទៀតពីក្រុងប៉េកាំងមកប្រទេសកម្ពុជានោះឡើយ ។ បើតាមចម្លើយសារភាពរបស់ អះម៉ាត់ បានឲ្យដឹងថានិស្សិតជាច្រើននៅប៉េកាំង ដែលនៅក្រោមការគ្រប់គ្រងរបស់អង្គការរណសិរ្ស លួចឃុបឃិតគ្នាបង្កើតខ្សែរយៈក្បត់ ដោយមានឈ្មោះ "សិទ្ធិ" ជាអ្នកដឹកនាំក្រុមនិស្សិតផ្ទាល់ក្នុងរណសិរ្សនោះនិងឈ្មោះ ចែម ស្នួន ធ្វើការនៅទូតអាល់ហ្សេរី ក្នុងឆ្នាំ១៩៧៣ ជាមេដឹកនាំកម្លាំងក្បត់ ។ ក្នុងការបញ្ជូននិស្សិតមកស្រុកខ្មែរគឺដើម្បីមកជួប "ហ៊ូ យន់" ជាមេសេ.អ៊ី.អា នៅ

ស្រុកខ្មែរ ។ គ្មានប្រភពឯកសារច្បាស់លាស់បង្ហាញថា ហ៊ូ យន់ មិនមែនជាសេ.អ៊ី.អា ដូចតាមចម្លើយរបស់ អះម៉ាត់ នោះទេ ។ ហ៊ូ យន់ គឺជាតំណាងរាស្ត្រខេត្តកំពង់ចាមនៅឆ្នាំ១៩៥៨ ក្នុងសម័យសង្គមរាស្ត្រនិយម ហើយនៅឆ្នាំ១៩៧២ ហ៊ូ យន់ គឺជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ កែទម្រង់មូលដ្ឋាននិងសហករណ៍ នៅក្នុងរដ្ឋាភិបាលក្រៅប្រទេសរបស់សម្តេចសីហនុនិងជាសមាជិកការិយាល័យនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា ។ តាមរយៈការសម្ភាសរបស់ខ្ញុំជាមួយលោក ម៉ាត់លី ជាអតីតសមាជិកអចិន្ត្រៃយ៍សភានិងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ស្រុកត្បូងឃ្មុំរបស់ខ្មែរក្រហមបានឲ្យដឹងថាខ្មែរក្រហមសម្លាប់ ហ៊ូ យន់ ពីព្រោះ ហ៊ូ យន់ ប្រឆាំងជាមួយ ប៉ុល ពត ក្នុងការបង្កើតសហករណ៍និងជម្លៀសប្រជាជន ។

អះម៉ាត់ ក៏បានឲ្យដឹងអំពីដំណើររឿងដែលកើតឡើងចំពោះខ្លួននៅពេលមកដល់ស្រុកខ្មែរដំបូង តាមចម្លើយសារភាពសរសេរថា «ថ្ងៃទី២៧-១០-១៩៧៥ អង្គការរណសិរ្សក៏បានអនុញ្ញាតឲ្យចូលមកក្នុងប្រទេស ។ នៅថ្ងៃដដែលនេះ ពួកខ្ញុំទាំងអស់គ្នាក៏បានមកដល់ភ្នំពេញ ។ ក្រោយមកដល់ភ្នំពេញ អង្គការក្នុងប្រទេសបានឲ្យពួកខ្ញុំទៅនៅអគ្គសេនាធិការបានបីថ្ងៃ ក្រោយមកអង្គការយកទៅនៅជិតវិមានឯករាជ្យ ពួកខ្ញុំនៅភ្នំពេញបានកន្លះខែក៏អង្គការឲ្យចុះទៅជនបទ ។ ពួកខ្ញុំទាំងអស់ជាដំបូងចុះទៅតំបន់៤២ ហើយបែកគ្នាទៅតាមស្រុកទៀត» ។ ដូចគ្នានេះដែរ តាមរយៈនៃការសម្ភាសប្រជាជន៨នាក់ដែលធ្លាប់បានរស់នៅក្នុងឃុំព្រះអណ្តូង ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ក្នុងជំនាន់ប៉ុលពត គឺពិតជាបានឃើញនិស្សិតមកពីបរទេសពីរនាក់ត្រូវបានបញ្ជូនឲ្យទៅនៅក្នុងភូមិនោះ និងពីរនាក់ទៀតនៅភូមិជិតខាងគឺភូមិខ្ពបតាងួន និងទួលរការស្រុកស្ទឹងត្រង់ (ខេត្តកំពង់ចាម) ។ លោក ឈិន ដេន ធ្លាប់បានរស់នៅក្នុងផ្ទះតែមួយជាមួយនិស្សិតពីរនាក់នៅភូមិព្រះអណ្តូង ។ គាត់មានប្រសាសន៍ថា «ប្រហែលជាចុងឆ្នាំ១៩៧៥មាន(និស្សិត)បួននាក់ គឺឈ្មោះ សុក និង រុន និងពីរនាក់ទៀតគឺ ហាក់ នៅខាងខ្ពបតាងួន និងឈ្មោះ វុធ នៅទួលរការ ។ សុក និង រុន ពេលគាត់មកដំបូងគាត់មកនៅផ្ទះរបស់ខ្ញុំនៅភូមិព្រះអណ្តូង (ស្រុកស្ទឹងត្រង់)» ។

ក្នុងចម្លើយសារភាពរបស់ អះម៉ាត់ បានសរសេរថា «ខ្ញុំអង្គការឲ្យទៅនៅស្រុកស្ទឹងត្រង់ ឃុំព្រះអណ្តូង ភូមិព្រះអណ្តូង» ។ ចុះហេតុអ្វីបានជាប្រជាជនធ្លាប់រស់នៅភូមិអណ្តូងកាលជំនាន់ ប៉ុល ពត មិនបានស្គាល់ អះម៉ាត់ ហើយបានជួបត្រឹមតែ សុក និង រុន តែប៉ុណ្ណោះ ។ ដើម្បីបំភ្លឺរឿងនេះខ្ញុំបានទៅជួបជនជាតិចាមម្នាក់ឈ្មោះ អេល ឡី ដែលធ្លាប់ជម្លៀសមកនៅភូមិព្រះអណ្តូង ហើយ ធ្លាប់ស្គាល់ អះម៉ាត់


ប្អូនស្រីរបស់ អ៊ីស្មាអេល អះមាត់ ឈ្មោះ អ៊ីស្មាអេល ខតីបះ

តាំងពីកំណើតមកផងដែរ ។ អេលឡី ប្រាប់ខ្ញុំថា សុក នោះហើយគឺជា អះម៉ាត់ ។ អះម៉ាត់ ត្រូវបានពួកខ្មែរក្រហមប្តូរឈ្មោះរបស់គាត់ដែលមានលក្ខណៈជាចាមឲ្យទៅជាឈ្មោះថ្មីមានលំនាំដូចឈ្មោះខ្មែរគឺ«សុក» ។ នយោបាយនេះ ពួកខ្មែរក្រហមបានអនុវត្តទូទាំងប្រទេសមកលើជនជាតិចាម ។ ពេលខ្ញុំបានជួបបងប្អូនក្រុមគ្រួសាររបស់ អះមាត់ ដែលរស់នៅភូមិថ្មី ឃុំពពេល ស្រុកពញាក្រែក ខេត្តកំពង់ចាម ហើយសួរអំពី«សុក» តែពួកគាត់មិនបានស្គាល់ថា សុក នោះជាអ្នកណាឡើយ ។ ចំណែកក្នុងភូមិព្រះអណ្តូងនិងភូមិពាមប្រជាជនបានស្គាល់គាត់ថា «សុក» ។ ស្របគ្នានោះគាត់ក៏បានព្យាយាមលាក់សញ្ជាតិកំណើតនិងលាក់ប្រវត្តិរូបបន្ថែមទៀត ក្នុងបំណងកុំឲ្យមានការសង្ស័យពីអ្នកភូមិថា គាត់មានជាតិសាសន៍ផ្សេងពីខ្មែរ ។ ប៉ុន្តែទីបំផុតនៅពេលមកដល់ទួលស្លែង ហើយត្រូវបានសួរចម្លើយជាច្រើនដងទើប អះម៉ាត់ បានសារភាពការពិតនូវជីវប្រវត្តិរបស់គាត់ ។

អះម៉ាត់ បានរស់នៅភូមិព្រះអណ្តូងពីខែវិច្ឆិកា ឆ្នាំ១៩៧៥ ដល់ខែកក្កដា ឆ្នាំ១៩៧៦ ។ បន្ទាប់មកអង្គការតម្រូវឲ្យផ្លាស់ទីលំនៅទៅភូមិពាមក្នុងឃុំស្រុកជាមួយគ្នាដែរ ពីខែកក្កដា ឆ្នាំ១៩៧៦ ដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៦ ។ លោកយាយ ឆេង ទ្រឹម នៅភូមិព្រះអណ្តូងធ្លាប់រស់នៅស្និទ្ធស្នាលជាមួយ អះម៉ាត់ និយាយថា«គាត់(សុក)ចេញពីនេះទៅគាត់ទៅនៅពាម .....មុននឹងទៅគាត់និយាយថា គាត់មិនភ្លេចខ្ញុំទេ គាត់នឹងផ្ញើ

សំបុត្រមកលេងខ្ញុំ ។ លោកយាយបន្ថែមទៀតថា "តាំងពីទៅអត់ឃើញសោះ រហូតដល់សព្វថ្ងៃនេះ...គាត់មិនដែលមកទេ ។ គាត់ខ្លាចគេ(អ្នកភូមិព្រះអណ្តូង) គាត់ផ្តាំតាមអ្នកភូមិព្រះអណ្តូងថា គាត់មិនហ៊ានមកលេងទេ គាត់ខ្លាចអង្គការខ្មែរក្រហម គាត់មិនហ៊ានដើរ" ។

ស៊ិន កែវ ក្នុងជំនាន់ ប៉ុល ពត រស់នៅក្នុងភូមិព្រែកស្តី ឃុំព្រះអណ្តូង ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ក៏បានជួបនិងស្គាល់ អះម៉ាត់ ថា "សុក" ដែរ ។ ស៊ិន កែវ និយាយថា "ប្រហែលជាចុងឆ្នាំ១៩៧៦...គាត់...ដល់ពេលកំណត់អង្គការក៏ប្រមូលយកនិស្សិតទៅលើយកទៅធ្វើការងារឲ្យអង្គការនៅភ្នំពេញវិញ...គាត់(អះម៉ាត់) មកលាខ្ញុំហើយប្រាប់ខ្ញុំថាអង្គការយកគាត់ទៅភ្នំពេញវិញហើយ" ។ ចំពោះ អះម៉ាត់ ខ្លួនឯងក៏បានរៀបរាប់អំពីការចេញដំណើររបស់ខ្លួនជាមួយនិស្សិត ៦ ទៀតត្រឡប់មកភ្នំពេញវិញដោយហាក់ដូចជាមិនដឹងខ្លួនអ្វីសោះ ។ "នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ៧៦ បង ប៉ុត (ប្រធានសង្កាត់ព្រះអណ្តូង) បាននិយាយប្រាប់ខ្ញុំដែរថាអង្គការហៅឲ្យខ្ញុំត្រឡប់ទៅភ្នំពេញវិញ" អះម៉ាត់ សរសេរនៅក្នុងចម្លើយសារភាព ។ អះម៉ាត់ បានបន្តទៀតថា "នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ៧៦ ខ្ញុំចេញពីភូមិពាមសង្កាត់ព្រះអណ្តូង ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ឆ្ពោះទៅស្តី ឃុំជយោ ស្រុកចម្ការលើ(ខេត្តកំពង់ចាម) ខ្ញុំទៅដល់ស្តីក៏បានជួបនឹងនិស្សិតដែលមកពីប៉េកាំងជាមួយគ្នា និងអ្នកដែលធ្វើការក្នុងរណសិរ្សនៅប៉េកាំងជាបន្តបន្ទាប់ ។ នៅព្រឹកថ្ងៃទី ២២ ខែធ្នូ ឆ្នាំ៧៦ ទើបបានជួបជុំគ្នាទាំងអស់ពួកដែលមកពីគ្រប់មូលដ្ឋាន ។ រសៀលថ្ងៃទី២២ ខែធ្នូ ឆ្នាំ៧៦ ពួកខ្ញុំទាំងអស់គ្នាចេញពីស្តីមកកំពង់ចាម ។ ព្រឹកថ្ងៃទី២៣-១២-៧៦ ពួកខ្ញុំទាំងអស់គ្នាចេញពីកំពង់ចាមមកដល់ភ្នំពេញ ។ មកដល់ភ្នំពេញអង្គការឲ្យទៅនៅអគារគ្រូៗសូវៀតនៃសាលាបច្ចេកទេសមិត្តភាពខ្មែរ-សូវៀត" ។ ចុងក្រោយនៃចម្លើយសារភាព អះម៉ាត់ ក៏បានបញ្ជាក់ថា "ថ្ងៃទី២ ខែមករា ឆ្នាំ៧៧ អង្គការចាប់ខ្លួនខ្ញុំ" ។ ហេតុការណ៍ដែលគួរឲ្យចាប់អារម្មណ៍ក្នុងចម្លើយរបស់ អះម៉ាត់ ដំបូងថា "អង្គការហៅឲ្យខ្ញុំត្រឡប់មកភ្នំពេញវិញ" ហើយយកមកប្រៀបធៀបនឹងចម្លើយចុងក្រោយថា "អង្គការចាប់ខ្លួនខ្ញុំ" ។

តាមតារាង "កម្លាំងក្បត់និងខ្សែក្បត់" របស់ អះម៉ាត់ ក្នុងចម្លើយសារភាពបានសរសេរឈ្មោះមនុស្សចំនួន៥៦នាក់ ថាជាបក្ខពួកក្បត់ដែលធ្លាប់រួមគំនិតនិងធ្វើសកម្មភាពក្បត់ជាមួយគ្នា ។ ក្នុងចំណោមអ្នកទាំង៥៦នាក់នោះបានចែកចេញជាពីរប្រភេទគឺ២៤នាក់ជាខ្សែរយៈក្បត់ដែល អះម៉ាត់ បានកសាងបានកាលរស់នៅភូមិពាមនិងភូមិព្រះអណ្តូង និង៣២នាក់ផ្សេងទៀតជាខ្សែក្បត់ធ្លាប់បានរួមសកម្មភាពកាលនៅក្រុងប៉េកាំង ។ តាមតារាងនេះ ក៏បានបញ្ជាក់ ដែរថា និស្សិតនិងអ្នកធ្លាប់ធ្វើការរណសិរ្សនៅប៉េកាំងចំនួនទាំង៣២នាក់ មានចំនួន៧នាក់ដែល



ឡឹប ម៉ាត់

ត្រូវបានចាប់ខ្លួន ហើយ១៩នាក់កំពុងស្នាក់នៅ "សាលាបច្ចេកទេសខ្មែរ-សូវៀត" ហើយនិងមាន៦នាក់ផ្សេងទៀតមិនទាន់បានមកដល់ស្រុកខ្មែរគឺស្ថិតនៅក្រុងប៉េកាំងប្រទេសចិននៅឡើយ ។ ពុំមានប្រភពណាបញ្ជាក់ថាអ្នកទាំង៦នាក់នេះបានត្រឡប់មកស្រុកខ្មែរ ដែរឬអត់នោះទេ ។ យោងតាម "បញ្ជីអ្នកទោសផ្នែកនិស្សិតនិងអ្នករដ្ឋការដែលមកពីបរទេស" រៀបចំដោយលោក អ៊ឹង ប៉ិច ឃើញមានឈ្មោះនិស្សិតនិងអ្នករដ្ឋការមកពីប៉េកាំង

មានចំនួនត្រឹមតែ៦នាក់តែប៉ុណ្ណោះ ដែលបានចាប់ខ្លួនបញ្ជូនមកទួលស្លែងនិងកម្ទេចចោល ។ ក្នុងចំណោម៦នាក់នោះក៏មានឈ្មោះ អ៊ីស្មាអេល អះម៉ាត់ និង២នាក់ទៀតដែលឃើញក្នុងចម្លើយរបស់ អះម៉ាត់ ថា"ចាប់ហើយ" ។ ដូច្នេះបានសេចក្តីថាចម្លើយសារភាពរបស់អ្នកទោស៥នាក់ផ្សេងទៀតដែល អះម៉ាត់ ឆ្លើយថាបានចាប់ខ្លួនដែរនោះពុំមានឯកសារបញ្ជាក់ទេ ។ និស្សិត២រូបទៀតមានឈ្មោះក្នុង "បញ្ជីអ្នកទោសផ្នែកនិស្សិតនិងអ្នករដ្ឋការដែលមកបរទេស" ដែលថាបានចាប់ខ្លួននោះក៏ត្រូវបញ្ជូនមកទួលស្លែងនិងកម្ទេចចោល ប៉ុន្តែក្នុងចម្លើយសារភាពរបស់ អះម៉ាត់ ឆ្លើយថាពីរនាក់នោះ "នៅសាលាបច្ចេកទេសខ្មែរ-សូវៀតភ្នំពេញ" ។ ដូច្នេះអាចជួយបង្ហាញឲ្យឃើញថានិស្សិតស្នាក់នៅសាលាបច្ចេកទេសខ្មែរសូវៀតទាំង១៩នាក់នោះក៏ត្រូវបានចាប់ខ្លួនបញ្ជូនមកទួលស្លែងជាបន្តបន្ទាប់ដែរ ។ ឈ្មោះអ្នកទោសម្នាក់ចុងក្រោយក្នុងចំណោម៦នាក់ជានិស្សិតមកពីប៉េកាំងដែលមានក្នុងបញ្ជីអ្នកទោសទួលស្លែងរៀបចំដោយ អ៊ឹង ប៉ិច ដដែលនោះ ប៉ុន្តែបែរជាពុំមានក្នុងចម្លើយសារភាពរបស់ អះម៉ាត់ ទៅវិញ ។ យោងតាមបទសម្ភាសន៍ជាមួយលោក ឈិន ដេន មាននិស្សិតបីនាក់ផ្សេងទៀតក្រៅពី សុក (អះម៉ាត់) មានឈ្មោះ រុន នៅភូមិព្រះអណ្តូងដែរ ហាក់ នៅភូមិខ្ពបតាឆ្វន និង វុធ នៅភូមិខ្ពបរការក្នុងស្រុកស្ទឹងត្រង់ ។ ប៉ុន្តែឈ្មោះទាំងបីនេះក៏សុទ្ធតែមាននៅក្នុង "កម្លាំងនិងខ្មែរក្បត់" របស់ អះម៉ាត់ ហើយបានបញ្ជាក់ច្បាស់ថាហាក់បានចាប់ខ្លួន ។ រុន និង វុធ ស្នាក់នៅសាលាបច្ចេកទេសខ្មែរ-សូវៀត" ។ តាមការស្រាវជ្រាវរបស់ខ្ញុំខ្មែរក្បត់របស់ អះម៉ាត់ ធ្លាប់នៅបរទេសទាំងអស់ គឺទាំងអ្នកបានមកដល់ស្រុកខ្មែរនិងអ្នកដែលមិនទាន់បានដល់មកស្រុកខ្មែរដែលមានចំនួន៣២នាក់នោះមានតែពីរនាក់ប៉ុណ្ណោះដែលមានវាសនាឆ្លងផុតពីរបបនោះ គឺឈ្មោះ"ថែម ស្លូម" និង "កើ ស្រេង" ។

អំពីខ្មែររយៈក្បត់នៅក្នុងប្រទេសដែល អះម៉ាត់ កសាងបាននៅភូមិពាម ក្នុងឃុំព្រះអណ្តូង ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម មានចំនួន២៤នាក់ ។ តាមរយៈការសម្ភាសអ្នកភូមិនោះបានឲ្យដឹងថា មានខ្មែរក្បត់របស់ អះម៉ាត់ ចំនួន១៤នាក់ដែលនៅសេសសល់ពីការសម្លាប់របស់ពួកខ្មែរក្រហម ។ ក្នុងចំណោមនោះ ខ្ញុំបានសម្ភាសចំនួន៥នាក់ ហើយមានតែម្នាក់គត់ដែលបាននិយាយថាធ្លាប់ស្គាល់ អះម៉ាត់ ហៅថា "សុក" រីឯ៤នាក់ទៀតនិយាយថាមិនដែលស្គាល់មនុស្សឈ្មោះ "សុក" ទាល់តែសោះ ។ តាមចម្លើយសារភាពរបស់ អះម៉ាត់ ពួកគាត់ទាំង៥នាក់នេះពិតជាមានធ្វើសកម្មភាពក្បត់អង្គការ ។ ខ្ញុំសួរគាត់ថានៅក្នុងជំនាន់ប៉ុលពតធ្លាប់បានធ្វើសកម្មភាពអ្វីខ្លះក្បត់អង្គការនិងបានទទួលការបំផុសនិងចាត់តាំងពីអ្នកណា? ប៉ុន្តែគ្រប់ៗគ្នារកនឹកអ្វីបន្តិចមិនឃើញសោះថាខ្លួនបានធ្វើអ្វីខ្លះ ខុសឆ្គងនឹងអង្គការឬហៅថាក្បត់នោះ ។ "ខ្ញុំមិនដែលសោះ មិនដែលចង់រត់ទៅចូលបក្សណាទេ...ខ្ញុំមិនដែលស្គាល់ សុក ទេ បើខ្ញុំស្គាល់មែន ខ្ញុំប្រាប់ហើយ" នៅក្នុងចំណោមអ្នកទោសទាំង៥នាក់បាននិយាយថា ។ ចំណែក ឡាយ គុយ វិញ និយាយថា "ខ្ញុំមិនបានស្គាល់ឈ្មោះ សុក នោះទេ មិនស្គាល់ហើយរកនឹកមិនឃើញទៀតផង...ខ្ញុំមិនដែលសោះ មិនមានគម្រោងចង់រត់ទៅណាទេ ឬខ្មែររយៈអីទេ ...ខ្ញុំមិនដែលត្អូញត្អែរអំពីការងារមិនហ៊ានតវ៉ា" ។ ចំពោះ ឡាច និង យ៉ន ក៏បានបដិសេធដូចគ្នានេះដែរ ដោយសង្កត់ថា ឲ្យគាត់និយាយយ៉ាងម៉េច បើគាត់មិនដែលស្គាល់ សុក នោះជាអ្នកណាផង ។ មានតែ ស៊ឹន កែវ ម្នាក់គត់ដែលធ្លាប់បានស្គាល់ សុក ហើយប្រាប់ខ្ញុំថាគាត់ទាំងពីរធ្លាប់សម្តែងសុខទុក្ខជាមួយគ្នា ដូចជាការរអ៊ូរទាំអំពីការហេវហត់អស់កម្លាំងនិងការងារដែលអង្គការដាក់ឲ្យធ្ងន់ធ្ងរ ។ ប៉ុន្តែ ស៊ឹន កែវ នៅតែឆ្លើយដូចអ្នកឯទៀតដែរ "ខ្ញុំពុំមានធ្វើអ្វីក្បត់ឬខុសឆ្គងនោះទេ" ។

អះម៉ាត់ បានសរសេរនៅក្នុងចម្លើយសារភាពថា "ខ្ញុំបានស្គាល់និងដឹងចិត្តដឹងថ្លើមបងប្អូនមួយរយៈមក ខ្ញុំក៏បានដំណើរការទិសដៅដែល សេ.អ៊ី.អា ខាងក្រៅឲ្យមកអនុវត្តក្នុងប្រទេស ។ ខ្ញុំបានធ្វើសកម្មភាពបំផុសប្រជាជន" ។ តាមចម្លើយរបស់ អះម៉ាត់ និងចម្លើយសាក្សីចំនួន៤រូបមានភាពផ្ទុយស្រឡះពីគ្នានៅត្រង់"សកម្មភាពក្បត់" ។ ខ្ញុំបានសួរ ឆេង ទ្រឹម ជាមនុស្សដែល អះម៉ាត់ ធ្លាប់រាប់អានស្និទ្ធស្នាលជាងគេបំផុត ។ ឆេង ទ្រឹម និយាយថា "ពេលទៅធ្វើការ សុក ទៅតែជាមួយខ្ញុំទេ គេតែងតែហៅ សុក និងខ្ញុំនេះជាម៉ែនិងកូន ។ ខ្ញុំឃើញគាត់អត់ពិសាសាច់ជ្រូកគឺគាត់ជាចាម (សុកមិនបានប្រាប់ ឆេង ទ្រឹម ថាខ្លួន

ជាចាមទេ)»។ ឆេង ទ្រឹម បន្ត «មនុស្សដូចគាត់នោះដូចជាគ្មានធ្វើអ្វីខុសទេ គាត់ស្លូតណាស់ គាត់ជាអ្នករៀនចេះដឹងគាត់ល្អណាស់ ដឹងចាស់ដឹងទុំ...ខ្ញុំជឿថាគាត់អត់ហ៊ានសោះ (អត់ហ៊ានក្បត់)»។ នៅពេលបានស្តាប់ពាក្យសម្តីរបស់ ឆេង ទ្រឹម និងការអះអាង ពីមនុស្សដែល អះម៉ាត់ ឆ្លើយថា «ខ្សែរយៈក្បត់» ទាំងប៉ុន្មានមកនេះ ខ្ញុំពុំអាចរកឃើញថា អះម៉ាត់ មានសកម្មភាពក្បត់អង្គការត្រង់ចំណុចណាមួយឡើយ ហើយអាចឆ្លុះបញ្ចាំងឲ្យឃើញនូវចម្លើយសារភាពរបស់ អះម៉ាត់ ត្រង់ផ្នែក «សកម្មភាពនិងកម្លាំងក្បត់» ពុំមែនជារឿងរ៉ាវពិតដូចតាមសម្តីសារភាពនោះទេ។

ក្រោយពេលមកដល់ទួលស្លែងក្រោមការសួរចម្លើយរបស់ឈ្មោះ «សឿន» ជាអ្នកសួរប្រចាំមន្ទីរស-២១ បានចាប់ផ្តើមសួរ អះម៉ាត់ នៅថ្ងៃទី៣១ ខែមករា រួចបញ្ចប់ការសួរនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ក្នុងរយៈពេល១៧ថ្ងៃនៃការសួរចម្លើយនេះ អះម៉ាត់ បានឆ្លើយតាមកំណត់ត្រាជាលាយលក្ខណ៍អក្សរតាមឯកសារមួយកម្រាស់៨៩ទំព័រ។ ក្នុងនោះមាន៦៨ទំព័រ ចុះហត្ថលេខា កាលបរិច្ឆេទនិងឈ្មោះ «អ៊ីស្មាអែល អះម៉ាត់»។


នួន ជា

អះម៉ាត់ មានឪពុកឈ្មោះ លី អ៊ីស្មាអែល និងម្តាយឈ្មោះ សុះ សារីហ្វុះ មានស្រុកកំណើតនៅភូមិថ្មី ឃុំពពេល ស្រុកពញាក្រែក (អតីតស្រុកត្បូងឃ្មុំ) ខេត្តកំពង់ចាម។ សព្វថ្ងៃនេះ អះម៉ាត់ មានប្អូនស្រីបួននាក់ដែលរស់រានមានជីវិតពីរបបខ្មែរក្រហម ហើយរស់នៅក្នុងស្រុកកំណើត។ អះម៉ាត់ ចាប់ផ្តើមរៀនថ្នាក់ផ្នែកសាសនាពីឆ្នាំ១៩៥៣។ លុះដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៦៧ បានប្រឡងជាប់ទៅរៀននៅប្រទេសអេហ្ស៊ីបផ្នែកសាសនាឥស្លាម។ ឆ្នាំ១៩៧០ អះម៉ាត់ បានប្តូរមុខវិជ្ជារៀនសូត្រពីផ្នែកសាសនាមកខាងបច្ចេកទេសគ្រឿងយន្តវិញ។ ខែមេសា ឆ្នាំ១៩៧៣ អះម៉ាត់ មកក្រុងប៉េកាំង តាមចម្លើយសារភាពបញ្ជាក់ថាគាត់បានធ្វើអ្វី នៅប៉េកាំងនោះឡើយ។ ដល់ថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៧៥ ទើប អះម៉ាត់ បានត្រឡប់មកដល់ស្រុកខ្មែរវិញ។

**អ៊ីសា ឧស្មាន**

**សេចក្តីកែតម្រូវ**

នៅក្នុងទស្សនាវដ្តីលេខ១០ ទំព័រទី២៤ និងលេខ១២ ទំព័រទី១៤ អត្ថបទដែល មានចំណងជើងថាៈ លក្ខណៈសម្បត្តិ ១០«ខ»របស់បក្ស មានសរសេរថាៈ (ឯកសារទង់បដិវត្តលេខ៨ ខែកក្កដា ឆ្នាំ១៩៧៨) និង (ឯកសារទង់បដិវត្ត ខែកក្កដា ឆ្នាំ១៩៧៨) សូមកែតម្រូវមកជា (ឯកសារទង់បដិវត្តលេខ៨ ខែសីហា ឆ្នាំ១៩៧៨) វិញ។ សូមអរគុណ!។

**(តពីលេខមុន)** *ចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី២៣ ខែសីហា កម្មាភិបាលបក្សកុម្មុយនិស្តកម្ពុជាបានប្រមូលផ្តុំគ្នានៅភ្នំពេញមកទទួលការប្រជុំត្រួសៗស្តីអំពី«ផែនការ៤ឆ្នាំក្នុងការកសាងសង្គមនិយមលើគ្រប់វិស័យ» ដែលមានកម្រាស់១១០ទំព័រ ចងក្រងកាលពីដើមខែសីហា ។ ផែនការនោះបានស្នើឲ្យមានការសម្រុកបង្កបង្កើនផល ដើម្បីធ្វើការនាំចេញនូវកសិផលផ្សេងៗ ជាពិសេស ស្រូវ ដើម្បីទិញគ្រឿងម៉ាស៊ីនបម្រើផ្នែកកសិកម្ម និងបន្ទាប់មក ពេលដែលភោគផលកើនឡើងគឺសម្រាប់ឧបត្ថម្ភផ្នែកកសិកម្មទៀត ។ ដើម្បីជម្នះរាល់ឧបសគ្គទាំងឡាយ មជ្ឈិមបក្សបានពឹងផ្អែកទៅលើបដិវត្តន៍ដែលត្រូវរំពឹងថានឹងមានដំណើរការទូទាំងសង្គមកម្ពុជា ការធ្វើសមូហភាវូបនីយកម្មទៅលើមធ្យោបាយផលិតកម្ម និងការប្រើអំណាចដែលបានមកពីជ័យជម្នះខ្មែរក្រហមកាលពីខែមេសា ឆ្នាំ១៩៧៥ ។ គំនិតយល់ឃើញមិនទាន់ចេញជាសាច់ការឡើយ ។ ផែនការដែលមិនទាន់ទទួលបានលទ្ធផលនៅលើទីផ្សារពិភពលោកនៅឡើយនោះ មិនបានយកចិត្តទុកដាក់ចំពោះប្រភេទដីឬក៏ប្រភពទឹកនៅទូទាំងប្រទេសកម្ពុជាឡើយ ហើយមើលរំលងចំណុចខ្វះខាតរបស់ពលករ សម្ភារ និងបសុសត្វ ។ ជាពិសេសបំផុតនោះគឺផែនការ៤ឆ្នាំដែលបានលើកឡើងនោះ មិនបានទទួលស្គាល់ថាប្រជាជនភាគច្រើន អស់កម្លាំង នឿយណាយក្រោយពីសង្គ្រាមប្រាំឆ្នាំកន្លងមក ហើយមានប្រជាជនខ្លះពិបាកនឹងរកបាយហូបគ្រប់គ្រាន់ផង ។ តែផ្ទុយទៅវិញ មជ្ឈិមបក្សបានសន្និដ្ឋានថាប្រជាជនស្ទើរតែគ្រប់រូបបានរៀបចំខ្លួនរួចជាស្រេចមានសមត្ថភាព និងចង់ផលិតស្រូវឲ្យបានច្រើនជាអតិបរមា ។*

*ក្នុងន័យនយោបាយ ផែនការនេះបានផ្តល់ឲ្យ ប៉ុល ពត និងបក្ខពួកនូវឱកាសក្នុងការក្តាប់កង់ប្រវត្តិសាស្ត្រ និងបង្ហាញពីភាពបរិសុទ្ធព្រមទាំងកម្លាំងរបស់បដិវត្តន៍កម្ពុជាចំពោះសម្ព័ន្ធមិត្តនិងខ្មាំងខាងក្រៅរបស់ខ្លួន ។ សៀវភៅសរសេរដែលរៀបចំដោយកម្មាភិបាលមន្ទីរសន្តិសុខ ស-២១ និយាយថាមជ្ឈិមបក្សមានការជឿជាក់យ៉ាងខ្លាំងថា បដិវត្តន៍កម្ពុជាទទួលជោគជ័យខ្លាំងក្លាបំផុតនៅក្នុងប្រវត្តិសាស្ត្រពិភពលោក ។ ផែនការ៤ឆ្នាំគឺជាឯកសារគោលនយោបាយដ៏លម្អិតរបស់បក្សកុម្មុយនិស្តកម្ពុជា ។ មេដឹកនាំបក្សប្រហែលជាសង្ឃឹមថានឹងបានបង្ហាញគម្រោងផែនការនេះនៅក្នុងខួបកំណើតបក្សដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ៣០ ខែកញ្ញា គឺនៅពេលដែលមេដឹកនាំបក្សសង្ឃឹមថានឹងប្រកាសឲ្យដឹងនូវអត្ថិភាពរបស់បក្សកុម្មុយនិស្តកម្ពុជា ។*




**សម្លេងពីមន្ទីរ ស-២១**
**វគ្គទី៣: ការជ្រើសរើសសត្រូវ**
**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

*នៅក្នុងសម្តីសង្កត់ធ្ងន់ៗរបស់ ប៉ុល ពត ក្នុងអង្គប្រជុំនៅខែសីហា ទាក់ទងនឹងផែនការនេះ ភាសាពន្យល់នៅដើមដំបូងស្តាប់ទៅហាក់ដូចជាបញ្ឈរក់ពីស្ម័យភាពនៃផែនការរបស់ខ្លួន ។*

*សុខៗស្រាប់តែ ប៉ុល ពត បានលើកយកបញ្ហាសំខាន់មួយមកនិយាយថា «ពួកខ្មាំងនៅខាងកើតនិងនៅខាងលិច» (វៀតណាមនិងថៃ) ជាមូលហេតុនៃការប្រុងប្រយត្ន័ និងការគំរាមកំហែងរបស់យើង ។ ប៉ុល ពត មិនបាននិយាយអំពីរឿងខ្មាំងផ្ទៃក្នុងឡើយ ។*

*មរណភាពដែលហួសពីការស្មាន របស់ ម៉ៅ សេទុង នៅថ្ងៃទី៨ ខែកញ្ញា បានបង្កឲ្យមានភាព មិននឹងនរនៅក្នុងមជ្ឈិមបក្ស ។ អតីតកម្មាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យម្នាក់បានប្រាប់លោក ស៊ីវ ហេឌ័រ កាលពីឆ្នាំ ១៩៨០ថា «ក្រោយពី ម៉ៅ សេទុង ស្លាប់ទៅមានការព្រួយបារម្ភនៅក្នុងប្រទេសកម្ពុជា... ប្រជាជនមានការភ័យខ្លាចថា ភាពច្របូកច្របល់វឹកវរនៅក្នុងប្រទេសចិនអាចប៉ះពាល់ដល់សាមគ្គីភាពរវាងប្រទេសយើងនឹងប្រទេសចិន» ។ នៅថ្ងៃទី១៨ ខែកញ្ញា នៅពេលប្រារព្ធពិធីបុណ្យរំឭកដល់ ម៉ៅ សេទុង ដែលធ្វើឡើងនៅទីក្រុងភ្នំពេញ ប៉ុល ពត បានសារភាពជាលើកដំបូងជាសាធារណៈថា ប្រទេសកម្ពុជាកំពុង*

ត្រូវបានដឹកនាំដោយបក្សម៉ាក្ស-ឡេនីន ។ ប៉ុល ពត បានលើកសរសើរដល់សំណេររបស់ ម៉ៅ “ស្តីអំពីការដោះស្រាយត្រឹមត្រូវចំពោះបញ្ហាទំនាស់ក្នុងចំណោមប្រជាជន” ។ នៅក្នុងឱកាសនោះដែរ ឯកអគ្គរដ្ឋទូត ប្រទេសចិន ស៊ុន ហាវ បានកត់សម្គាល់ថា ម៉ៅ បានឈានដល់ “ការសន្និដ្ឋានជាលក្ខណៈវិទ្យាសាស្ត្រថាសូម្បីតែនៅក្នុងបក្សកុម្មុយនិស្តក៏នៅមានពួកគហិបតីដែរ” ។ នេះជាជំនឿបដិវត្តដ៏សំខាន់មួយរបស់ប្រទេសចិនដែលត្រូវបានប្រើប្រាស់សម្រាប់បន្តការធ្វើការបោសសម្អាតសមាសភាពមិនល្អតទៅទៀត ។

## ការលាលែងពីតំណែងរបស់ ប៉ុល ពត

នៅថ្ងៃទី២០ ខែកញ្ញា ប៉ុល ពត បាន“លាលែងពីតំណែង”ជានាយករដ្ឋមន្ត្រី ដោយសារបញ្ហាសុខភាព ។ ការលាលែងនេះត្រូវបានប្រកាសតាមវិទ្យុភ្នំពេញមួយសប្តាហ៍ក្រោយពីថ្ងៃលាលែងពិតប្រាកដ ។ សេចក្តីប្រកាសបានបន្តទៀតថា មុខតំណែងរបស់ ប៉ុល ពត ត្រូវបានជំនួសដោយ នួន ជា (បងទីពីរ) ដែលទទួលកាន់កាប់មុខតំណែងនេះតាំងពីឆ្នាំ១៩៦៣មកម្ល៉េះ និងត្រូវបន្តរហូតការផុតស្រមោលរបស់ ប៉ុល ពត កាលពីឆ្នាំ១៩៩៧ ។ ការលាលែងពីតំណែងរបស់ ប៉ុល ពត ប្រសិនជាកើតមានឡើងពិតមែនអាចមកពីបញ្ហាសុខភាព ព្រោះ ប៉ុល ពត លាប់ជំងឺគ្រុនចាញ់និងមានជំងឺអាសន្នរោគក្នុងពេលតែមួយ ឬក៏អាចថាពីព្រោះ ប៉ុល ពត មានការភ័យខ្លាចការធ្វើឃាតលើខ្លួន និងចង់លាក់ខ្លួនផង ។ ប៉ុន្តែមើលទៅហាក់ដូចជាថា ប៉ុល ពត មិនដែលលាឈប់ពីតំណែងឡើយ ហើយការប្រកាសជាសាធារណៈបែបនេះគឺប្រហែលមានបំណងចង់កម្ចាត់ខ្មាំងផ្ទៃក្នុងនិងវែកមុខជនផ្សេងៗទៀតប៉ុណ្ណោះ ។ ការទាញហេតុផលបែបនេះហាក់ដូចជាសមហេតុសមផលដោយសារថា ទាំង នួន ជា និង តាម៉ុក មិនបានចាំពីរឿងនេះឡើយនៅពេលធ្វើកិច្ចសម្ភាសន៍ជាមួយនឹង នេត ថេយ័រ នៅក្នុងឆ្នាំ១៩៩៧ ។

ណៃ សារ៉ន ត្រូវបានចាប់ខ្លួននៅថ្ងៃដែល ប៉ុល ពត លាលែងពីតំណែង ។ កែវ មាស ត្រូវបានចាប់ខ្លួនប្រាំថ្ងៃបន្ទាប់ពីពេលលាលែងនោះ ។ តាមរយៈវគ្គសិក្សាដែលធ្វើឡើង នៅពេលប្រហែលគ្នានេះ ដែលប្រហែលជាជាន់ពេលគ្នាជាមួយនឹងបុណ្យរំឭកខួបរបស់បក្ស មានលេចឡើងនូវឯកសារសង្ខេបដែលគួរឲ្យចង់ដឹងចង់ឃើញមួយមានចំណងជើងថា «សេចក្តីសង្ខេបលទ្ធផលនៃវគ្គសិក្សាឆ្នាំ១៩៧៦» ។ អត្ថបទនេះដែលរួមមានកំណត់ហេតុកត់អំពីសម្តីរបស់អ្នកនាំពាក្យរបស់បក្សដូចជាពិបាកយល់ជាងសម្តីរបស់ ប៉ុល ពត ដែលនិយាយអំពីផែនការ៤ឆ្នាំ ។ ឯកសារនេះមាននិយាយអំពីការសង្ស័យនិងព័ត៌មានទាក់ទងដល់ការចាប់ខ្លួនជនទាំងពីរនេះ ។

សម្តីរបស់ ប៉ុល ពត កាលពីខែសីហា បានលើកឡើងពីបញ្ហាខ្មាំងខាងក្រៅ រីឯ «សេចក្តីសង្ខេបកាលពីខែកញ្ញា» និយាយពីគ្រោះថ្នាក់របស់“អង្គការនិងភ្នាក់ងារ”របស់មហាអំណាចដែល“លួចជ្រៀតចូលលាក់ខ្លួននៅក្នុងជួរបដិវត្តន៍យើង” ។ សម្តីនេះបានឆ្លុះបញ្ចាំងពីការថ្លែងសុទ្ធរកថាកាលពីខែធ្នូ ដែលមានការសោកស្តាយចំពោះ“ជំងឺនៅក្នុងជួរបក្ស” ។ លើសពីនេះក៏មានប្រើឃ្លាថ្មីមួយទាក់ទងនឹងទំនាស់វណ្ណៈនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ ដែលអ្នកថ្លែងសុទ្ធរកថានោះនិយាយថាអាច“មានលក្ខណៈស្រួចស្រាល់...មិនអាចដោះស្រាយ ជូរចត់តឹងតែង និងស្លាប់រស់...នៅពេលអនាគត” ។

## ណៃ សារ៉ន “អាយ៉ា”

របបពោរពេញទៅដោយកំហឹងដែលចាប់ផ្តើមតាំងពីខែកញ្ញាទៅប្រហែលមានការពាក់ព័ន្ធទៅនឹងអ្វីដែលបណ្តាលឲ្យ កែវ មាស ណៃ សារ៉ន និងអ្នកទោសផ្សេងទៀតឆ្លើយសារភាពនៅមន្ទីរស-២១ ។ ជាការពិបាកណាស់ក្នុងការកំណត់ថាតើមានអ្នកទោសណាខ្លះបានចូលរួមនៅក្នុងផែនការក្បត់នោះ ទោះបីជាឯកសារនៅសេសសល់នៅឯមន្ទីរស-២១ដែលនិយាយអំពីអ្នកទាំងនេះមានលក្ខណៈគួរឲ្យសង្ស័យថាមានលក្ខណៈមិនគ្រប់គ្រាន់និងអាចត្រូវបានប្រមែប្រមូលចងក្រងក្រោយឆ្នាំ១៩៧៩ ដើម្បីលាក់បាំងភ័ស្តុតាងសមគំនិតជាមួយវៀតណាមយ៉ាងណាក៏ដោយ ។ ឯកសារទាំងនោះ អាចបកស្រាយបន្តិចបន្តួចតែប៉ុណ្ណោះចំពោះការសង្ស័យមិនទុកចិត្ត ដែលហាក់ដូចជាកើតមានទៅលើមេដឹកនាំនានាចាប់ពីពេលនោះមក ។

ចម្លើយសារភាពរបស់ ណៃ សារ៉ន មានតែ៣១សន្លឹកប៉ុណ្ណោះដែលបានមកពីការសួរចម្លើយចំនួន៧លើក ។ កំណត់សម្គាល់

ឬចំណារប្រើពាក្យធ្ងន់ៗរបស់ ប៉ុន ផ្ញើទៅ ឌុច និង ឌុច ផ្ញើទៅ ណៃ សារ៉ន ជាការបន្ថែមទៅលើឯកសារស្លួចស្លើងនេះ ។ ឧទាហរណ៍ នៅថ្ងៃទី២៣ ខែកញ្ញា ប៉ុន បានរាយការណ៍ទៅ ឌុច ថាខ្លួនបាន វាយ ណៃ សារ៉ន នឹងរំពាត់ផ្តៅនិងខ្សែភ្លើង ។ នៅក្នុងកំណត់សម្គាល់មួយមានបួនទំព័រសរសេរឲ្យអ្នកទោសមើលនៅថ្ងៃបន្ទាប់នោះ ឌុច បានបញ្ជាក់ប្រាប់ ណៃ សារ៉ន ថា "បងគិតមើល" បងជាមនុស្សដែលអង្គការមានជំនឿទុកចិត្តយ៉ាងខ្លាំង ពីព្រោះបងជាអ្នកនៅជិតនឹងអង្គការនិងចលនាបដិវត្តន៍កម្ពុជាយើង ប្រៀបទៅនឹងអ្នកដទៃទៀតដែលអង្គការបានចាប់ខ្លួនហើយ ។ អង្គការបានបញ្ជាក់ថាបងមិនអាចលាក់បាំងនូវអ្វីដែលកើតឡើងពីអតីតកាលទេ ។ អង្គការដឹងអស់ហើយអ្វីដែលអាក្រក់ ។ បងមិនអាចភូតភរឬទម្លាក់កំហុសទៅលើអ្នកដទៃឡើយ...អង្គការ... មានគំនិតច្បាស់លាស់អំពីមនុស្សដែលចចេសរឹងរូស ។

ពីរថ្ងៃបន្ទាប់មក ឌុច សរសេរទៅ ប៉ុន ថា"ប្រសិនបើ ណៃ (សារ៉ន) បន្តលាក់ខ្សែក្បត់វាទៀត...សម្លាប់វាចោលភ្លាម កុំទុកឲ្យនៅលេងល្បែងជាមួយនឹងបក្សទៀត" ។ ការធ្វើទារុណកម្មចេះតែបន្ត ហើយ ប៉ុន ក៏សរសេរទៅ ឌុច វិញថា "ពេលល្ងាច ខ្ញុំបានសុំបង ឌុច ធ្វើទាំងធម៌ក្តៅនិងធម៌ត្រជាក់ ។ ក្រោយពីបានទទួលការអនុញ្ញាតហើយល្ងាចបន្តិចខ្ញុំក៏ចូលទៅវាយវាដោយប្រាប់វាឲ្យរៀបចំខ្លួននៅម៉ោង៨ឬ៩ដើម្បីទទួលទារុណកម្មបន្ត ។ នៅប្រហែលម៉ោង១០យប់ខ្ញុំបានចូលទៅក្នុងរៀបចំធ្វើទារុណកម្មដោយដៃទទេ ។ ៩) ណៃ (សារ៉ន) ចាប់ផ្តើមឆ្លើយសារភាព ហើយឲ្យយើងចាំសង្ខេបអ្វីដែលគាត់រៀបនឹងរាយការណ៍ ។ យើងបានបញ្ជាក់ថា ចូរសរសេរជាខ្សែសន្ទាក់សកម្មភាពក្បត់ពីដើមដល់ចប់" ។

## *កែវ មាស*

ការប្រឈមមុខគ្នារវាង ប៉ុន និង ណៃ សារ៉ន ងាយស្រួលនឹងប្រមើលឃើញណាស់ ។ ប៉ុន្តែ"ដំណើររឿងជាប្រព័ន្ធ" នៃសកម្មភាពរបស់គាត់មិនមាននៅសល់ឡើយ ទោះគាត់បានសរសេរឬមិនបានសរសេរក៏ដោយ ។ ហើយចម្លើយសារភាពចំនួន៩៦សន្លឹកដែលសរសេរដោយដៃគាត់នៅក្នុងបណ្ណសារមន្ទីរ ស-២១មានសំបុត្រមួយចំនួនដែល កែវ មាស បានសរសេរទៅឲ្យ ប៉ុល ពត កាលពីមួយរយៈកន្លងទៅ ។ សំបុត្រជាច្រើនមានចំណាររបស់ ឌុច "កុំសង្ខេប" ។ នេះបង្ហាញថាសំបុត្រទាំងអស់មិនដែលត្រូវបានយកទៅណាចេញពីគុកទេ ។ ឯកសាររបស់ កែវ មាស ក៏មានសំណួររបស់ ប៉ុន ដែលចុះហត្ថលេខាថា "សន្តិបាល" ព្រមទាំងចំណារមានលក្ខណៈឃោរឃៅរបស់ ឌុច ទាមទារពត៌មានការពិនិត្យសាឡើងវិញ និងចាត់ការសាជាថ្មី ។ ទោះបីជាមានការគាបសង្កត់ធ្ងន់ធ្ងរយ៉ាងណាក៏ដោយក៏ កែវ មាស នៅតែបន្តជំទាស់ថាខ្លួនពិតជាគ្មានកំហុសទេ ។ កែវ មាស





មានបទពិសោធន៍ស្ទើរតែ៣០ឆ្នាំក្នុងការពិភាក្សាតឹងសរសៃកទៅលើលទ្ធិកុម្មុយនិស្ត ហើយនៅក្នុងសំបុត្ររបស់គាត់ផ្ញើទៅ ប៉ុល ពត កែវ មាស និយាយថាគាត់តស៊ូដើម្បីជីវិត ។ កែវ មាស បានសរសេរថា "ការចោទប្រកាន់នេះគួរឲ្យចង់សើច" ។ "គេមិនយល់អំពីខ្ញុំទេ ។ ខ្ញុំដឹងហើយគ្មានធ្វើអ្វីដូចដែលគេចោទប្រកាន់ខ្ញុំទេ" ។

ទាក់ទងនឹងបុណ្យខួបរបស់បក្ស កែវ មាស សរសេរនៅថ្ងៃទី២៩ ខែកញ្ញា ដែលជាថ្ងៃមុនពេលប្រារព្ធពិធីនេះថា"គំនិតគឺគាំទ្រ១៩៥១ ។ ហើយបើមានអ្នកណាចង់ដើរផ្លូវផ្សេងខ្ញុំមិនទៅទេ ។ ខ្ញុំនឹងជំទាស់ ហើយប្រកាន់ខាងក្រុមប្រជាជន ។ កាសែត

ប្រជាជនគឺជាអគ្គការច្បាប់របស់បក្សម៉ាក្ស-ឡេនីនដែលបង្កើតឡើងនៅក្នុងឆ្នាំ១៩៥១» ។

### តើកំណើតបក្សនៅថ្ងៃណា?

ជំហររបស់ កែវ មាស អំពីបញ្ហារំឭកខួបមានការប្រឆាំងគ្នាយ៉ាងធំមួយទៅនឹងគំនិតរបស់បក្សកុម្មុយនិស្តកម្ពុជា ដែលបានលាក់បាំងអស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ ដែលត្រូវដោះស្រាយឲ្យស្របតាមគំនិត ប៉ុល ពត ។ ទំនាស់នេះត្រូវបានសម្គាល់ដោយថែដន្យនៅក្នុងកិច្ចប្រជុំមជ្ឈិមបក្សធ្វើឡើងនៅថ្ងៃទី៣០ ខែមីនា ថា «ដាក់ថាកំណើតរបស់បក្សគឺឆ្នាំ១៩៦០ ។ កុំប្រើឆ្នាំ១៩៥១...សូមចែកឲ្យច្បាស់» ។

បញ្ហាដែលគ្រោះថ្នាក់នៅក្នុងការទាញហេតុផលតាមពាក្យមួយម៉ាត់ៗគឺបញ្ហាដឹកនាំរបស់បក្សនិងទំនាក់ទំនងកម្ពុជាជាមួយនឹងប្រទេសវៀតណាម ។ ចាប់ពីឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៧៥ ពិធីបុណ្យរំឭកខួបរបស់បក្សកុម្មុយនិស្តកម្ពុជាត្រូវបានប្រារព្ធធ្វើឡើងនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៥១ ពោលគឺជាថ្ងៃដែលមានឆ្នាំប្រឡំបល់មិនច្បាស់លាស់ ។ ឆ្នាំ១៩៦០ ជាឆ្នាំដែលមានកិច្ចប្រជុំនៅទីក្រុងភ្នំពេញដើម្បីបង្កើតបក្សពលករកម្ពុជា ចំណែកឯឆ្នាំ១៩៥១ជាឆ្នាំបង្កើតបក្សប្រជាជនបដិវត្តន៍ខ្មែរក្រោមការជំរុញរបស់ប្រទេសវៀតណាម ។

កម្មាភិបាលបក្សកុម្មុយនិស្តកម្ពុជាដែលរត់ពីភូមិភាគបូព៌ាទៅចុះចូលខាងវៀតណាមនៅឆ្នាំ១៩៧៨ បានរាយការណ៍ថាមានការរៀបចំប្រារព្ធខួបបក្សលើកទី២៥ តាំងពីពាក់កណ្តាលខែកញ្ញា ឆ្នាំ១៩៧៦ម្ល៉េះ ។ ប៉ុន្តែនៅពេលកំពុងរៀបចំ«យើងក៏ទទួលសារមួយពីរដ្ឋអំណាចថ្នាក់លើបញ្ជាឲ្យយើងផ្អាកការរៀបចំសិន ។ បន្ទាប់មកទៀតមានការណែនាំមកពីមន្ទីរមជ្ឈិមប្រាប់យើងថាបក្សត្រូវបានបង្កើតឡើងនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ ។ អ្នកណាដែលបានចូលបក្សមុនថ្ងៃនោះគួរតែគិតគូរខ្លួនឯងមិនមែនសមាជិកបក្សទេ ហើយប៉ុន្មានឆ្នាំដែលខ្លួនបានចូលរួមជាមួយបក្សមុនថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ គឺចាត់ទុកជាមោឃៈ ។ បើអ្នកណាយល់ព្រមគណៈមជ្ឈិមបក្សនឹងទទួលយក ។ បើមិនដូច្នេះទេជននោះនឹងត្រូវបានបញ្ជូនទៅកន្លែងអប់រំ ។

នៅក្នុងទស្សនាវដ្តីចេញផ្សាយសម្រាប់ខែកញ្ញារបស់បក្សកុម្មុយនិស្តកម្ពុជាមានឈ្មោះថា «យុវជនយុវនារីបដិវត្តន៍» មានអត្ថបទមួយនិយាយអំពីការអបអរសាទរចំពោះបុណ្យខួបលើកទី២៥របស់បក្ស ហើយអត្ថបទមួយនៅក្នុងទស្សនាវដ្តីទង់បដិវត្តន៍ច្បាប់ចេញផ្សាយសម្រាប់ខែកញ្ញា-ខែតុលា បានប្រកាសថា បក្សកុម្មុយនិស្តកម្ពុជាត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦០



ពីព្រោះ "យើងបានប្តូរលេខឆ្នាំថ្មី" ។ អ្នកនិពន្ធអត្ថបទនេះសរសេរថា មូលហេតុនៃការប្តូរនេះដោយសារ "អង្គការបដិវត្តន៍បានសម្រេចចិត្តថា ចាប់ពីពេលនេះតទៅយើងត្រូវតែរៀបចំប្រវត្តិ-សាស្ត្ររបស់បក្សឲ្យស្អាតនិងល្អឥតខ្ចោះស្របតាមនយោបាយឯករាជ្យម្ចាស់ការរបស់យើង" ។

សារនេះបានបង្ហាញឲ្យឃើញជំហានមួយទៀតនៃការប្រើអំណាចរបស់ ប៉ុល ពត និងបរិវារ ។ ដោយសារអត្ថបទទស្សនាវដ្តីទាំងពីរតែងតែត្រូវបានត្រួតពិនិត្យយ៉ាងហ្មត់ចត់ និងភាគច្រើនសរសេរដោយប៉ុល ពត និង នួន ជា ដូច្នេះលទ្ធភាពនៃការខ្វែងគំនិតគ្នារវាងទស្សនាវដ្តីទាំងពីរច្បាប់មើលទៅមិនអាចកើតឡើងទេ ។ ទស្សនាវដ្តីយុវជនយុវនារីបដិវត្តន៍ត្រូវបានចេញផ្សាយក្នុងគោលបំណងល្បួងក្រុមប្រឆាំងនឹងបក្ស "១៩៥១" ឲ្យចេញមកចំហមុខ ដើម្បីងាយស្រួលក្នុងការកម្ទេច ។ ចំណែកឯទស្សនាវដ្តីទង់បដិវត្តន៍គឺបង្ហាញអំពីការគិតពិចារណារបស់មជ្ឈិមបក្ស ។

នៅដើមខែវិច្ឆិកា នង សួន ដែលជាមិត្តរបស់ នួន ជា និង ប៉ុល ពត ត្រូវបានចាប់ខ្លួននៅពេលដែលគាត់ទើបចុះពីយន្តហោះមកពីបំពេញបេសកកម្មនៅប្រទេសចិន ។ នៅមន្ទីរ ស-២១ មុនដំបូង នង សួន បានឆ្លើយថាគាត់មិនបានធ្វើអ្វីខុសទេ តែក្រោយពីការសួរចម្លើយបីសប្តាហ៍មក នង សួន ក៏ព្រមឆ្លើយ ហើយសរសេរថា "ខ្ញុំគឺជាសត្វកណ្តៀរស៊ីរូងផ្ទៃក្នុង...និងបំផ្លាញបក្សតាមមធ្យោបាយដែលខ្ញុំអាចធ្វើទៅបាន ។ ទោះបីជាបក្សអប់រំនិងលត់ដំខ្ញុំយ៉ាងណាក៏ខ្ញុំមិនបោះបង់នូវបំណងខ្មៅងងឹតនិងកខ្វក់របស់ខ្ញុំដែរ...ខ្ញុំចង់បង្ហាញខ្លួនចំពោះមុខអង្គការបក្សដើម្បីទទួលទោសកំហុសដ៏ធ្ងន់ធ្ងរតាមកម្រិតទោសដែលខ្ញុំបានប្រព្រឹត្តក្នុងគោលបំណងក្បត់បក្ស ។ ធ្វើដូច្នេះទើបបក្សអាចពង្រឹងពង្រីកជួរបក្សនិងឈានទៅរកការកសាងសង្គមបែបកុម្មុយនិស្តបាន" ។

## ការបោសសម្អាតអ្នកការទូតនិងបញ្ញវន្ត

នៅខែធ្នូ ឆ្នាំ១៩៧៦ នៅពេលដែល ប៉ុល ពត ថ្លែងសុន្ទរកថាដែលមានចំណងជើងថា "ជំងឺនៅក្នុងបក្ស" មជ្ឈិមបក្សបានសម្រេចចិត្តថានឹងរក្សាការសម្ងាត់នៃអត្ថិភាពរបស់បក្សកុម្មុយនិស្តកម្ពុជាកុំឲ្យអ្នកក្រៅដឹងនិងរៀបចំផែនការបួនឆ្នាំ ។ មូលហេតុដែលនាំដល់ការសម្រេចចិត្តនៅក្នុងកិច្ចប្រជុំនេះគឺដោយសារមានឯកសារអនាមិកនិយាយថាខ្មាំងបានកំពុងព្យាយាមវាយយើងដោយប្រើប្រាស់គ្រប់វិធី" ។ នេះប្រហែលជាការនិយាយយោងទៅដល់ចម្លើយសារភាពដែលស្រង់មកពីមន្ទីរ ស-២១ ។ នៅក្នុងពេលដំណាលគ្នានេះដែរ ទោះបីជាឯកសារខ្លះមានការខុសចន្លោះនិងមានបញ្ជាក់មូលហេតុមិនច្បាស់លាស់ក៏ដោយ ប៉ុន្តែមជ្ឈិមបក្សប្រហែលជាសម្រេចចិត្តក្នុងការប្រកាសភាពប្រទូសរ៉ាយជាមួយនឹងវៀតណាម ។ នៅដើមឆ្នាំ១៩៧៧ កម្ពុជាប្រជាធិបតេយ្យបានធ្វើការវាយលុកចូលយ៉ាងសាហាវនៅតាមព្រំដែនកម្ពុជា-វៀតណាមនៅភូមិភាគបូព៌ានិងភូមិភាគនិរតី ។ នៅក្នុងការវាយប្រហារនេះ ជនស៊ីវិលរាប់រយនាក់ត្រូវបានសម្លាប់រង្គាល ប៉ុន្តែប្រទេសទាំងពីរមិនបានផ្សព្វផ្សាយជាសាធារណៈឡើយ ។

នៅពេលដែលប្រទេសទាំងពីររៀបចំខ្លួនធ្វើសង្គ្រាម បក្សកុម្មុយនិស្តកម្ពុជាក៏បានបោសសម្អាតបុគ្គលិកការទូតនិងបុគ្គលិកធ្វើការនៅក្រសួងការបរទេសដែលត្រូវបានសង្ស័យថាជា "អ្នកគាំទ្រសូវៀត" ឬ "អ្នកគាំទ្រវៀតណាម" ។ ជនរងគ្រោះសំខាន់ៗមានដូចជាឯកអគ្គរដ្ឋទូតរបស់កម្ពុជាប្រជាធិបតេយ្យប្រចាំនៅប្រទេសវៀតណាមឈ្មោះ សៀន អាន និង ហាក់សៀងឡាយនី មន្ត្រីក្រសួងការបរទេសដែលត្រូវបានចោទប្រកាន់ថាបានបង្កើតបក្សកុម្មុយនិស្តមួយទៀតនៅក្នុងទសវត្សរ៍ឆ្នាំ៦០ដោយមានការជួយជំរុញពីប្រទេសសូវៀត ។ នៅមានអ្នកការទូតជាច្រើនរូបទៀតត្រូវបានប្រមូលផ្តុំ ។ ចំណាត់វិធានការដាក់ទណ្ឌកម្មទាំងអស់នេះក៏បង្ហាញអំពីការមិនទុកចិត្តរបស់បក្សចំពោះអ្នកដែលមានការហ្វឹកហាត់ជំនាញច្បាស់លាស់និងមានលំនៅដ្ឋានស្កឹមស្កៃនៅបរទេស ឬអ្នកដែលមានការទាក់ទងជាមួយនឹងបុគ្គលដែលមិនមែនជាខ្មែរ ។ **(នៅមានត)**

**ពាក្យស្លោកខ្មែរក្រហម**

◆ **ខ្នះខ្នែងកម្ទេចកម្លាំងខ្មាំង ថែរក្សានិងបំប៉នកម្លាំងយើង កាន់តែវាយកាន់តែខ្លាំង កាន់តែវាយកាន់តែឈ្នះ។**

*(សៀវភៅកំណត់ហេតុលេខ ១៩៨)*

◆ **កងទ័ពស្រួចប្រមូលផ្តុំវាយកម្ទេចខ្មាំង កម្ទេចកម្លាំងធំរបស់ ទើបយើងឆាប់រហ័សបានទទួលជ័យជម្នះ និងអាចការពារពង្រីកកម្លាំងយើងបាន។** *(សៀវភៅកំណត់ហេតុលេខ២០០)*

# ជនដៃដល់ ឬ ជនរងគ្រោះ?

## កសិណារបស់យុទ្ធជនវ័យក្មេងនៃមន្ទីរស-២១



ដោយៈ អៀ ម៉េងទ្រី

**(តពីលេខមុន)** យុទ្ធជនទាំងអស់ត្រូវពន្លកស្មារតីដោយការបំពាក់បំប៉នមនោគមវិជ្ជាបដិវត្តន៍ខ្មែរក្រហមឲ្យមើលឃើញតែអំពើល្អរបស់បក្ស ឲ្យគោរពស្រឡាញ់តែអង្គការ ហើយមិនត្រូវមានមនោសញ្ចេតនា នឹកនាគិតបារម្ភដល់ឪពុកម្តាយបុបងប្អូនរបស់ខ្លួនជាដាច់ខាត ។ ចំពោះភារកិច្ចយុទ្ធជនបដិវត្តន៍ត្រូវតែមានចិត្តគំនិតស្រឡាញ់ការងារបដិវត្តន៍និងអង្គការបដិវត្តន៍ឲ្យអស់ពីចិត្តពីថ្លើម ជាពិសេសនៅក្នុងដំណាក់កាលក្លាយខ្លួនទៅជាអ្នកបម្រើបដិវត្តន៍ ក្នុងនាមជាយុទ្ធជនកងការពារ យុទ្ធជនសួរចម្លើយ ក៏ដូចជាយុទ្ធជនកងដទៃទៀតនៃមន្ទីរស-២១ ។ ពេលដែលយុទ្ធជនទាំងអស់ចាប់ផ្តើមចូលបម្រើការងារនៅក្នុងមន្ទីរស-២១ដែលជាទីតាំងសម្ងាត់និងមានសារៈសំខាន់របស់ខ្មែរក្រហម ពេលនោះហើយដែលយុទ្ធជនវ័យក្មេងទាំងនោះត្រូវរស់នៅនិងធ្វើការក្រោមការគំរាមកំហែងនិងវិន័យកាន់តែតឹងរ៉ឹងកាន់តែខ្លាំង ហើយជីវិតកាន់តែកម្សត់និងឯកោ ។ យុទ្ធជនវ័យក្មេងទាំងអស់ត្រូវគណៈមន្ទីរសន្តិសុខស-២១ ចាត់តាំងបង្ខំឲ្យធ្វើទារុណកម្មនិងសម្លាប់អ្នកទោស ។ យុទ្ធជនវ័យក្មេងមន្ទីរស-២១ ត្រូវបង្ខំចិត្តធ្វើតាមបញ្ជារបស់ថ្នាក់លើទោះជាខ្លួនចង់ឬមិនចង់ក៏ដោយ ជាពិសេសការសម្លាប់និងធ្វើទារុណកម្មលើអ្នកទោស ដើម្បីឲ្យខ្លួនបានរស់ ។ អ្វីដែលធ្វើឲ្យយុទ្ធជនវ័យក្មេងមន្ទីរស២១ភ័យបារម្ភនិងតក់ស្លុតកាន់តែខ្លាំងថែមទៀតនោះគឺក្នុងចំណោមអ្នកទោសទាំងអស់នោះរួមមានទាំងក្មើនិងយុទ្ធមិត្តរួមការងាររបស់ខ្លួនដែរ ។ ជីវិតរបស់យុទ្ធជនវ័យក្មេងមន្ទីរស-២១រស់នៅដោយគ្មានសិទ្ធិសេរីភាពស្ថិតក្រោមការគាបសង្កត់បង្ខិតបង្ខំគ្រប់បែបយ៉ាងពីសំណាក់ប្រធានក្រុមក៏ដូចជាគណៈមន្ទីរស-២១ ។

យុទ្ធជនវ័យក្មេងទាំងអស់នៅមន្ទីរស-២១ធ្វើការដោយគ្មានពេលសម្រាកនិងគ្មានសិទ្ធិគ្រប់គ្រាន់ សូម្បីតែការនឹកនាមកផ្ទះឬជជែកលេងជាមួយយុទ្ធមិត្តរួមការងារកុំថាឡើយសិទ្ធិវិលត្រឡប់មកលេងឪពុកម្តាយបងប្អូននៅឯផ្ទះ ។ យុទ្ធជនទាំងអស់ត្រូវរស់នៅដោយក្តីភ័យខ្លាចនិងអស់សង្ឃឹមព្រោះការប្រព្រឹត្តខុសដោយអចេតនាលើវិន័យណាមួយសូម្បីតែបន្តិច

បន្តួចក៏ត្រូវប្រឈមមុខនឹងទារុណកម្មនិងការបាត់បង់ជីវិត ។

ដោយសង្កេតឃើញនូវទារុណកម្មការកាប់សម្លាប់នៅក្នុងមន្ទីរ ស-២១ យុទ្ធជនវ័យក្មេងទាំងអស់ត្រូវខំតាំងចិត្តតស៊ូទ្រាំប្រឈមមុខនឹងការលំបាកគ្រប់បែបយ៉ាង ធ្វើតាមបញ្ជាដើម្បីគេចចេញពីគោលនយោបាយកាប់សម្លាប់ជនមិនស្អាតស្អំឬជនមិនបដិវត្តរបស់ខ្មែរក្រហម ។ ក៏ប៉ុន្តែ ទោះបីយុទ្ធជនទាំងអស់ខំអនុវត្តតាមបញ្ជាដោយបានដឹងពីការសម្លាប់គ្មានញញើតដៃមកលើយុទ្ធជនដែលបានប្រព្រឹត្តកំហុសសូម្បីតែតិចតួចក៏យុទ្ធជនវ័យក្មេងជាច្រើននៅតែគ្មានវាសនាគេចផុតឡើយ ជាពិសេស គេចពីទាសភាពនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

## ការពិនិត្យឡើងវិញ

មានអ្នកស្រាវជ្រាវវិទ្យាសាស្ត្រច្រើនដែលបានធ្វើការសិក្សាចិត្តសាស្ត្ររបស់ជនរងគ្រោះរាប់ទាំងការសិក្សាលើប្រជាជនកម្ពុជាដែលរងគ្រោះក្រោមរបបប្រល័យពូជសាសន៍នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ផ្ទុយទៅវិញ ការសិក្សាចិត្តសាស្ត្រនៃរបបកម្ពុជាប្រល័យពូជសាសន៍ គឺមានចំនួនតិចតួចបំផុត ។ ដូចលោកបណ្ឌិត យូឌីត ហឺរមែន អ្នកឯកទេសខាងវិភាគលើបច្ច័យនៃការប៉ះពាល់ បានកត់សម្គាល់ថា "ការសិក្សាស្វែងយល់អំពីអារម្មណ៍របស់ឃាតករគឺជាការលំបាកបំផុត" ។

តាមការសិក្សារបស់វេជ្ជវិទ្យាវិកលចរិតលើប្រជាជនរងគ្រោះនៃរបបប្រល័យពូជសាសន៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យបង្ហាញថា ទោះបីជាការប៉ះទង្គិចឬសោកនាដ្យកម្មនោះបានបញ្ចប់អស់រយៈពេលយូរមកហើយក៏ដោយ ក៏ប្រជាជនកម្ពុជានៅតែទទួលរងនូវរោគសញ្ញាធ្ងន់ធ្ងរជាច្រើន មានដូចជាការរអ៊ូរទាំច្រើនយល់សប្តិអាក្រក់ ដេកមិនបានលក់ស្កប់ស្កល់ ជាពិសេសបង្កឲ្យមានជំងឺធុញថប់អារម្មណ៍ជាដើម ។ លទ្ធផលនៃការសិក្សាថ្មីៗនេះបង្ហាញថា ប្រជាជនកម្ពុជាភាគច្រើនក៏នៅតែរងគ្រោះដោយសារបញ្ហាទាំងអស់ខាងលើ ។ តាមរោគវិនិច្ឆ័យនោះហៅថាជំងឺដែលទទួលរងក្រោយសោកនាដកម្ម ឬក្រោយមានការប៉ះទង្គិច (PTSD) ។ អ្នកឯកទេសបានបញ្ជាក់ថា ឥទ្ធិពលអាក្រក់នៃការប៉ះពាល់នេះអាចអូសបន្លាយពេលយូរ ឬអាចអស់មួយជីវិតក៏មានជាពិសេសចំពោះជនដែលជាប់ឃុំឃាំងនិងទទួលរងការធ្វើបាបនៅក្នុងគុករយៈពេលវែង ។

យូឌីត ហឺរមែន សរសេរថា "អត្តសញ្ញាណរបស់អ្នកទោសអាចផ្លាស់ប្តូរដោយសារតែការជាប់ឃុំឃាំងរយៈពេលវែង ។ អត្តចរិត រូបរាង រួមនឹងលក្ខណៈផ្សេងទៀតមានទាំងគំនិតគុណសម្បត្តិក៏ត្រូវផ្លាស់ប្តូរដែរ ។ ទោះជាក្រោយមកបានរួចខ្លួនពីការឃុំឃាំងក៏ដោយ ក៏អ្នកទោសនេះមិនអាចរក្សាបាននូវអត្តសញ្ញាណចាស់របស់ខ្លួនឡើយ ។ អត្តសញ្ញាណថ្មីនៅក្រោយពេលមានសេរីភាពមិនអាចកាត់ផ្តាច់ពីពិរុទ្ធភាពដែលខ្លួនឆ្លងកាត់ឡើយ ។ អត្តសញ្ញាណរូបរាងរស់នៅក្នុងសង្គមក្រោយមានការប៉ះទង្គិចគឺស្ថិតក្រោមការត្រួតត្រានិងការរំលោភបំពាន ចំណែកអត្តសញ្ញាណសតិអារម្មណ៍គឺតែងតែមានការចុះចាញ់និងបរាជ័យចំពោះអ្នកដទៃ ។ ម្យ៉ាងទៀត លក្ខណៈសម្បត្តិសីលធម៌នឹងនៅលាយឡំជាមួយគ្នាលទ្ធភាព សភាព ឬអំពើអាក្រក់ទាំងចំពោះខ្លួនឯងនិងចំពោះអ្នកដទៃ" ។

ទោះបីមានការសិក្សាតិចតួចលើឥទ្ធិពលដែលប៉ះពាល់ចំពោះជនដៃដល់ក៏លទ្ធផលបង្ហាញជាវិជ្ជមានចំពោះការប៉ះពាល់លើជនរងគ្រោះអាចកើតឡើងចំពោះជនដៃដល់ដែរ ។ ពិសេសយុទ្ធជនកងការពារនៅមន្ទីរឃុំឃាំងនិងមន្ទីរដែលបម្រើការងារផ្នែកសន្តិសុខដទៃផ្សេងទៀត ។ លទ្ធផលនៃការសិក្សាលើ អ្នកធ្វើទារុណកម្មនៅក្នុងរបបយោធានៃប្រទេសក្រិចបង្ហាញថាអ្នកធ្វើទារុណកម្មទាំងនោះក៏ត្រូវរងគ្រោះនូវផលប៉ះពាល់ខាងចិត្តសាស្ត្រដូចអ្នកទោសដែរ ។

"យុទ្ធជនធ្វើទារុណកម្មត្រូវតែធ្វើទារុណកម្មអ្នកទោសតាមភារកិច្ចនិងបញ្ជា ប៉ុន្តែយុទ្ធជនទាំងនោះក៏មានអារម្មណ៍ភ័យខ្លាចនិងលំបាកដែរ នៅពេលខ្លួនធ្វើទារុណកម្មលើអ្នកទោសម្តងៗ ។ ការសិក្សាស្រាវជ្រាវមួយក្នុងចំណោមការសិក្សាស្រាវជ្រាវជាច្រើនបង្ហាញថា បន្ទាប់ពីរបបគ្រប់គ្រងដោយយោធាក្នុងប្រទេសក្រិចបានរលំរលាយទៅ មានអតីតយុទ្ធជនធ្វើទារុណកម្មអ្នកទោសជាច្រើននាក់បានសម្តែងចេញនូវក្តីឈឺចាប់សោកស្តាយ និងការសោកសង្រេងរបស់ខ្លួនដែរ ។ វិបត្តិទាំងនោះរួមមានដូចជាសុបិនអាក្រក់ ការកើតទុក្ខ ពិបាកចិត្ត វិប្បដិសារី និងអារម្មណ៍ឆាប់ឆេវឆាវជាដើម ។ វិបត្តិទាំងនេះឃើញមានក្នុងក្រុមមនុស្សដទៃ

ទៀតដែរ ។»

មកដល់សព្វថ្ងៃនេះពុំទាន់មានការសិក្សាណាមួយអំពីវិបត្តិចិត្តសាស្ត្រដែលកើតឡើងចំពោះយុទ្ធជនមន្ទីរស-២១ដែលចូលរួមក្នុងការធ្វើទារុណកម្មអ្នកទោសក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅឡើយ ។ ដូច្នេះអត្ថបទស្រាវជ្រាវដែលពាក់ព័ន្ធដល់យុទ្ធជនខ្មែរក្រហមទីមួយនេះត្រូវយកលទ្ធផលអំពីការសិក្សាវិបត្តិចិត្តសាស្ត្រដែលបានធ្វើឡើងចំពោះយុទ្ធជននៅជុំវិញពិភពលោក



ក្រុមកងការពារមន្ទីរ ស-២១ ហាត់ក្បាច់គុន

ធ្វើជាមូលដ្ឋាន ព្រោះលទ្ធផលនេះអាចជាកញ្ចក់ឆ្លុះបញ្ចាំងនូវស្ថានភាពពិតរបស់យុទ្ធជនវ័យក្មេងមន្ទីរស-២១ក្នុងរបបកម្ពុជាប្រជាធិបតេយ្យបាន ។

របាយការណ៍របស់អង្គការសហប្រជាជាតិស្តីអំពីយុទ្ធជនវ័យក្មេងដែលបានចូលរួមបម្រើជាកងទ័ពបានឲ្យដឹងថា «មេបញ្ជាការយោធាខ្លះមានបំណងចង់បានប្រើប្រាស់កងទ័ពដែលជាយុទ្ធជនវ័យក្មេង ព្រោះយុទ្ធជនទាំងនោះចេះគោរពវិន័យនិងបញ្ជាបានល្អ ។ យុទ្ធជនវ័យក្មេងទាំងនោះមិនដែលជជីករកឫសគល់ ឬមូលហេតុមុននឹងចាប់ផ្តើមបំពេញភារកិច្ចឡើយ ។ ម្យ៉ាងទៀត វ័យនេះមានភាពងាយស្រួលក្នុងការអូសទាញនិងបំពាក់បំប៉នមនោគមវិជ្ជាឲ្យធ្វើអ្វីមួយ ប្រសើរជាងកងទ័ពដែលមានវ័យចំណាស់» ។ របាយការណ៍សង្កត់បន្ថែមថា «ជាទូទៅ មនោគមវិជ្ជាមានឥទ្ធិពលខ្លាំងលើយុទ្ធជនវ័យក្មេង ព្រោះក្នុងវ័យនេះកំពុងតែមានការលូតលាស់ខាងគំនិតស្មារតីនិងជាវ័យដែលស្រាក់ស្រាំប្រឡូកក្នុងសង្គមរស់នៅ» ។ អ្នកនិពន្ធ ដេវីត ឆេនដល័រ ដកស្រង់សម្តីរបស់លោក រឹឆាត ម៉ូលីកា អ្នកឯកទេសខាងចិត្តវិទ្យាដែលបានពិភាក្សាករណីនៅប្រទេសរ៉ាន់ដាថា «ការបំពាក់បំប៉នមនោគមវិជ្ជាលើយុវវ័យមានឥទ្ធិពលយ៉ាងខ្លាំង» ។ លោក រឹឆាត ម៉ូលីកា ឲ្យហេតុផលថា «មនុស្សវ័យក្មេងមានលក្ខណៈប្រាកដនិយមនិងត្រេកត្រអាលអំណាច» ។

ចំពោះ លោក ជេម ក្រាន វិញធ្វើការបកស្រាយថា៖ កុមារដែលមានអាយុប្រាំពីរឆ្នាំឬប្រាំបីឆ្នាំតែងតែត្រូវបានប្រើឲ្យធ្វើជាកងទ័ពហើយបំពាក់ឲ្យនូវអាវុធស្វ័យប្រវត្តិសម្រាប់វាយប្រហារ ។ កុមារទាំងនេះពេលខ្លះត្រូវបានជ្រើសរើសដោយការបង្ខិតបង្ខំ ប៉ុន្តែភាគច្រើនបានចូលរួមធ្វើសង្គ្រាមដើម្បីតែរស់ ។ កុមារភាគច្រើនបានឃើញពួកទាហានយកឪពុកម្តាយរបស់ខ្លួនទៅសម្លាប់ចោលយ៉ាងឃោរឃៅ អំពើដ៏រន្ធត់នេះត្រូវបានធ្វើឡើងចំពោះកុមារ ហើយកុមារខ្លួនឯងបានធ្វើអំពើដ៏រន្ធត់នេះវិញ

ដោយបានចូលក្នុងសង្គ្រាមសម្ងាប់ផ្កាល ។ ការដាក់បញ្ចូលនូវកុមារទាំងនេះទៅក្នុងសហគមន៍ឡើងវិញគឺជាបញ្ហាដ៏លំបាក ។

លោកស្រី ចនណា បាបារា បានសិក្សាលើយុទ្ធជនក្មេងៗ ដែលត្រូវបានជ្រើសរើសចូលក្នុងជួរកងទ័ព ។ សម្រាប់កុមារដែលទទួលរងនូវការឈឺចាប់នឹងដោតវាសនានេះ បែកពីឪពុកម្តាយគឺជាបទរំលោភយ៉ាងហួសនិស្ស័យ ។ ចំពោះបញ្ហា "កុមារកម្ពុជា" វិញ អ្នកស្រីគត់បានសម្គាល់ថា "យុវជនវ័យក្មេងៗដែលឆ្លងកាត់របប ប៉ុល ពត ចាប់ពីអាយុ៦ដល់អាយុ១២ឆ្នាំបានជួបប្រទះនូវព្រឹត្តិការណ៍ដ៏គួររន្ធត់ប្រកបដោយគ្រោះថ្នាក់ ។ សេចក្តីទុក្ខព្រួយការបាក់ទឹកចិត្តបានថមថយបណ្តើរៗទៅតាមពេលវេលា ប៉ុន្តែឥទ្ធិពលអាក្រក់នៃភាពច្របូកច្របល់កាលពីអតីតកាលនៅតែមានអត្រាខ្ពស់នៅឡើយ ។ លោកស្រី បានលើកឧទាហរណ៍ពីឥទ្ធិពលអាក្រក់ដែលបន្សល់ទុកពីអតីតកាលមកបង្ហាញថាការវិវត្តផ្នែកសីលធម៌របស់យុវជនវ័យក្មេងទាំងនោះត្រូវទទួលរងនូវការប៉ះពាល់ធ្ងន់ធ្ងរបំផុត ជាពិសេសយុវជនដែលត្រូវបង្រៀនឲ្យសម្លាប់មនុស្ស ។ ពេលសង្គ្រាមបានផុតរលត់ ហើយកុមារត្រូវតែវិលត្រឡប់មកសង្គមវិញ វាជាការលំបាកណាស់ក្នុងការដាក់កុមារឲ្យចូលតាមសាលារៀនឬនៅក្នុងសហគមន៍គ្រួសារ ។

បូមីស្មើ បានលើកមកពិភាក្សានូវបញ្ហាមួយចំនួននៃសកម្មភាពឃោរឃៅដែលជនដៃដល់បានជួបប្រទះ ។

ជនដៃដល់ភាគច្រើនចាត់ទុកខ្លួនថាជាជនរងគ្រោះនៅពេលនឹកដល់រឿងដែលបានកន្លងទៅ ហើយភាគច្រើនក៏បានចាត់ទុកខ្លួនថា ជាមនុស្សដែលទទួលរងភាពអយុត្តិធម៌ ហេតុដូច្នេះខ្លួនសមនឹងទទួលបានការអាណិតអាសូរ ការគាំទ្រ និងទទួលបានការលើកលែងទោស ជាពិសេសសម្រាប់កំហុសណាមួយដែលខ្លួនបានប្រព្រឹត្ត ។

លោក បូមីស្មើ ទាញហេតុផលថា ជនដៃដល់តែងតែជួបប្រទះនូវអារម្មណ៍ថាខ្លួនមានកំហុសចំពោះអ្វីដែលខ្លួនធ្វើកន្លងមកដោយសារខ្លួនផ្តោតតែលើកបញ្ហាមិនសូវបានការឬមិនសំខាន់ ។ លោកបានលើកយកសកម្មភាពមួយចំនួនដែលធ្វើឡើងដោយអ្នកធ្វើទារុណកម្មនៅគុកទួលស្លែងមកធ្វើជាឧទាហរណ៍បញ្ជាក់ៈ

ការងាររកំប៉ិកកំប៉ុកមានច្រើននៅក្នុងកំណត់ហេតុប្រជុំជីវភាពប្រចាំសប្តាហ៍ទិតៀន និងស្វ័យទិតៀនរបស់យុទ្ធជនសួរចម្លើយនៅមន្ទីរស-២១ ។ មិនខុសពីជនកម្មុយនិស្តនៅគ្រប់ទីកន្លែងទេ យុទ្ធជនសួរចម្លើយចាំបាច់ត្រូវតែចូលរួមប្រជុំជីវភាពទិតៀន និងស្វ័យទិតៀន ។ តើយុទ្ធជនសួរចម្លើយធ្វើនេះដើម្បីអ្វី? កំណត់ហេតុក្នុងការប្រជុំជីវភាពនោះមានចំណុចពិភាក្សាអំពីការងារកំប៉ិកកំប៉ុក ដូចជាការដេកសួរចម្លើយអ្នកទោស ការភ្លេចសម្រួចខ្មៅដៃ និងធ្វើឲ្យមានស្នាមប្រឡាក់លើក្រដាសជាដើម ។ ទាំងនេះសុទ្ធតែជារឿងសាមញ្ញនិងមិនសមហេតុផល ឬមិនមានប្រយោជន៍ទាល់តែសោះ ។ អ្វីដែលយុទ្ធជនសួរចម្លើយនៅមន្ទីរស-២១គឺសុទ្ធតែគ្មានប្រយោជន៍ ដូចជាការភ្លេចសម្រួចខ្មៅដៃជាដើម ។

ផលវិបាកខាងសតិអារម្មណ៍ស្មារតីដែលទទួលរងទារុណកម្ម និងការគំរាមកំហែងដល់អាយុជីវិតជាប្រចាំជាបញ្ហាដ៏ធំបំផុតមួយទាំងចំពោះជនរងគ្រោះដ៏ដូចជាជនដៃដល់ ។ អ្នកឯកទេសបានសិក្សាឃើញថា ជំងឺផ្នែកចិត្តសាស្ត្រដែលកើតឡើងពីការប៉ះពាល់ពីអតីតកាលនេះមានការលំបាកព្យាបាលយ៉ាងខ្លាំង ។ ជាពិសេសចំពោះប្រជាជនកម្ពុជា ។

លោក គីនហ្សី ដែលបានសិក្សាវិភាគលើជំងឺខាងលើបានឲ្យដឹងថាការព្យាបាលជំងឺផ្លូវចិត្តតាមវិធីរំសាយបញ្ហាក្នុងចិត្តដែលធ្លាប់ប្រើប្រកបដោយប្រសិទ្ធភាពពីមុនមកនោះ ដូចជាគ្មានប្រសិទ្ធភាពសោះចំពោះអ្នកជំងឺកម្ពុជា ព្រោះ"អ្នកជំងឺតែងតែមិនចង់និយាយពីទុក្ខរបស់ខ្លួនប្រាប់អ្នកដទៃ ហើយអ្នកជំងឺអាចនិយាយអំពីទុក្ខសោករបស់ខ្លួនប្រាប់ដល់អ្នកដទៃបានគឺនៅពេលដែលមានវត្តមានគ្រូពេទ្យ ឬការជួយជ្រោមជ្រែងជំរុញពីអ្នកដទៃប៉ុណ្ណោះ ។ ដូច្នេះហើយបានជាលទ្ធផលនៃការខិតខំប្រឹងប្រែង ដើម្បីជួយលុបបំបាត់បញ្ហាក្នុងចិត្តតាមវិធីខាងលើនេះពុំទទួលបានលទ្ធផលល្អ" ឡើយ ។ "ក្រុមមនុស្សនៅភូមិភាគអាស៊ី ហាក់ដូចជាមិនចង់និយាយអំពីរឿងរ៉ាវផ្ទាល់ខ្លួន និងស្ថានភាពដែលខ្លួនបានឆ្លងកាត់ក្នុងជីវិតរបស់ខ្លួនប្រាប់អ្នកដទៃទេ ។ កត្តានេះហើយដែលធ្វើឲ្យវិធីព្យាបាលតាមការរំសាយបញ្ហាក្នុងចិត្តគ្មានប្រសិទ្ធភាព" ។ លោក គីនហ្សី មានជំនឿថាលទ្ធផលមិនល្អនេះបណ្តាលមកពីកត្តាវប្បធម៌ ។

**(នៅមានត)**

# រង្វាស់បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងប្រទេសកម្ពុជា

**(តពីលេខមុន) អ្នករស់រានមានជីវិត**

ទាក់ទងនឹងទំហំនៃការសម្លាប់របស់មន្ទីរសន្តិសុខខ្មែរក្រហមនៅទូទាំងប្រទេសកម្ពុជា អាចនាំដល់ការគិតថា ការចាប់ខ្លួនដោយក្រុមខ្មែរក្រហមគឺមានន័យស្មើគ្នានឹងការប្រហារជីវិតយ៉ាងដូច្នេះ ។ មានប្រជាជនជាច្រើនប្រាកដជាយល់របៀបនេះចំពោះរបបដែលខ្មែរក្រហមកាន់កាប់ ហើយសូម្បីតែមកដល់សព្វថ្ងៃនេះ ក៏នៅមានអារម្មណ៍ដូចគ្នាដែរ ។ ប៉ុន្តែវាមិនមែនជាការពិតទាំងអស់នោះទេ ។ របាយការណ៍បានមកពីការចុះធ្វើផែនទីនាឆ្នាំ ១៩៩៩ និងបានមកពីអ្នកដែលបានធ្វើផែនទីរណ្តៅសាកសពកាលពីបួនឆ្នាំមុនបញ្ជាក់ថា មានប្រជាជនខ្លះបានរស់ម្តងទៀតពីក្រញាំនៃប្រព័ន្ធគុករបស់ខ្មែរក្រហម ។ ដូច្នេះយើងនៅសល់សាក្សីនៅរស់ជាច្រើនដែលមានវាសនារួចផុតពីប្រព័ន្ធគុកពោរពេញទៅដោយអំពើឃោរឃៅ ។ ក្នុងឆ្នាំ១៩៩៩ ក្រុមការងារធ្វើផែនទីបានជួបសម្ភាសជាមួយនឹងសាក្សីរបៀបនេះចំនួន១៨នាក់ ។

ការសិក្សាស្រាវជ្រាវផ្នែកចិត្តសាស្ត្ររយៈពេលវែងទៅលើអ្នកនៅរស់រានមានជីវិតពីរបបប្រល័យពូជសាសន៍នៅប្រទេសកម្ពុជាបានបង្ហាញថា រោគសញ្ញាច្បាស់ក្រឡែតនៃបញ្ហាចិត្តសាស្ត្រដ៏ធ្ងន់ធ្ងរ ដូចជាការកើតឡើងនូវសុបិនអាក្រក់ ការបណ្តាលឲ្យមានបញ្ហាការដេកមិនបានលក់ស្រួល និងការធ្លាក់ចុះដុនដាបនៃជំងឺអាចកើតឡើងជាច្រើនឆ្នាំទៀតក្រោយពីខ្លួនបានជួបប្រទះនូវរឿងរ៉ាវដ៏គួរឲ្យរន្ធត់ ។ ការសិក្សាថ្មីៗនេះបានបញ្ជាក់ថា មានប្រជាជនកម្ពុជាចំនួនច្រើននៅតែទទួលរងនូវបញ្ហាទាំងអស់នេះ ដែលជារឿយៗត្រូវបានចាត់ទុកថាជា "ភាពគានតឹងផ្នែកអារម្មណ៍មិនប្រក្រតីក្រោយពីដំណើរប៉ះទង្គិចយ៉ាងខ្លាំងផ្នែកចិត្តសាស្ត្រ" ។ ជាការពិត អ្នកជំនាញផ្នែកជំងឺដំណើរប៉ះផ្នែកទង្គិចចិត្តសាស្ត្រជឿជាក់ថាឥទ្ធិពលរបស់ជំងឺប្រភេទនេះមានពេញមួយជីវិត ។ "ការឃុំឃាំងដែលមានរយៈពេលវែង គំរាមបំផ្លាញដល់វិញ្ញាណនៃការផ្តើមគំនិតដែលមានការអត់ឱនចំពោះការសាកល្បងនិងកំហុស ។ ចំពោះមនុស្សដែលបានទទួលប៉ះទង្គិចផ្នែកចិត្តសាស្ត្រអំពើណាក៏ដោយ ក៏នៅតែបង្កឲ្យមានផលវិបាកធ្ងន់ធ្ងរខ្លះដែរ ។ មិនអាចមានការប្រព្រឹត្តកំហុសឆ្គងឡើយ ។ ការឃុំឃាំងដែលមានរយៈពេលយូរក៏បណ្តាលឲ្យមានការផ្លាស់ប្តូរអត្តសញ្ញាណរបស់ជនរងគ្រោះដែរ ។ គ្រប់រចនាសម្ព័ន្ធផ្នែកចិត្តសាស្ត្ររបស់អត្តដែលមានដូចជា រូបភាពខ្លួនប្រាណ រូបភាពរបស់អ្នកដទៃ ដែលថតទុកនៅក្នុងថតខួរក្បាល តម្លៃនិងគំនិតគំរូ ដែលធ្វើមនុស្សម្នាក់មានវិញ្ញាណនៃភាពទាក់ទងគ្នាជាហូរហែ និងគោលបំណងត្រូវបានឃាយីនឹងបំផ្លាញខ្ទេចខ្ទី ។ សូម្បីតែក្រោយពីការដោះលែងពីការឃុំឃាំង ក៏ជនរងគ្រោះមិនអាចទទួលយកនូវអត្តសញ្ញាណដើមរបស់ខ្លួនដែរ ។ ទោះបីជនរងគ្រោះអភិវឌ្ឍអត្តសញ្ញាណរបស់ខ្លួនដោយសេរីយ៉ាងណាក៏ដោយ ក៏នៅតែជិតជាប់អនុស្សាវរីយ៍នៃគំនិតដែលចងចាំនូវអំពើទាសភាពដែរ ។ រូបភាពផ្ទាល់របស់ជនរងគ្រោះដែលមានទំនាក់ទំនងជាមួយរូបភាពផ្សេងៗទៀតច្បាស់ជាមានរូបខ្លួនឯងដែលអាចត្រូវបានគ្រប់គ្រងនិងរំលោភបំពាន ។ ហើយផ្នត់គំនិតផ្នែកសីលធម៌មានអត្ថិភាពជាមួយនឹងការដឹងឮអំពីលទ្ធភាពនៃអំពើអាក្រក់ទាំងនៅក្នុងខ្លួនអ្នកផ្សេងនិងខ្លួនឯងផ្ទាល់ ។"

អ្នករស់រានមានជីវិតពីគុករបស់ខ្មែរក្រហមមួយចំនួនបានទទួលរងនូវការឃុំឃាំងយ៉ាងធ្ងន់ធ្ងរអស់រយៈពេលយ៉ាងយូរ ហើយឥទ្ធិពលនៃដំណើរប៉ះទង្គិចចំពោះបុគ្គលទាំងនេះហាក់ដូចជាមានលក្ខណៈធ្ងន់ធ្ងរជាងឥទ្ធិពលដែលប្រជាជនកម្ពុជាទូទៅទទួលរងនៅក្នុងរបបពោរពេញទៅដោយការភ័យខ្លាច ។ នៅខេត្តរតនគិរី លោក ប៊ុន វ៉ាន់ថា ត្រូវបានឃុំឃាំងយ៉ាងគួរឲ្យភ្ញាក់ផ្អើលអស់រយៈពេល១៣ឆ្នាំ ចាប់ពីឆ្នាំ១៩៦៦ ដល់ឆ្នាំ១៩៧៩ នៅគុកបឹងកន្សែង ។ លោក វ៉ាន់ថា ជឿជាក់ថារូបគាត់ត្រូវបានចាប់ខ្លួនដោយសារតែគាត់សរសេរសំបុត្របណ្តឹងមួយច្បាប់ទៅឲ្យ នួន ជា នៅឆ្នាំ១៩៦៣ ប្តឹងអំពីភាពច្របូកច្របល់និងអសន្តិសុខនៅក្នុងតំបន់"រំដោះ"ដឹកនាំដោយ

ខ្មែរក្រហមចាប់តាំងពីដំបូងមក ។ វ៉ាន់ថា មិនបាននិយាយអំពីមូលហេតុដែលគាត់ត្រូវខ្មែរក្រហមទុកជីវិតឲ្យ ហើយក៏មិននិយាយលម្អិតអំពីការដោះលែងរូបគាត់ដែរ ។

នៅខេត្តមណ្ឌលគិរី លោក ចាន់ តូច ត្រូវបានចាប់ខ្លួននៅក្នុងខែធ្នូ ឆ្នាំ១៩៧៧ ហើយឃុំឃាំងនៅគុកភ្នំក្រោល ។ តូច និយាយថាគាត់ត្រូវបានចាប់ខ្លួនដោយមានការសង្ស័យថាមានការពាក់ព័ន្ធជាមួយកម្មាភិបាលតំបន់ជាន់ខ្ពស់មួយក្រុមដែលត្រូវបានបោសសម្អាត ។ នៅចុងបញ្ចប់ តូច និយាយថាគាត់បានរួចចាកផុតពីសេចក្ដីស្លាប់ហើយត្រូវបានដោះលែង ពីព្រោះក្រោយមកអ្នកដែលចាប់ចងគាត់ជឿថាតូចគឺជាមនុស្សសាមញ្ញប៉ុណ្ណោះ ហើយគ្មានជាប់ទាក់ទងជាមួយនឹងកម្មាភិបាលដែលត្រូវបានបោសសម្អាតឡើយ ។

ក្នុងករណីប្រហាក់ប្រហែលគ្នានេះដែរ លោក មែន សាវើត ត្រូវបានឃុំខ្លួនចាប់ពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៩ នៅក្នុងគុកភ្នំក្រោល ប៉ុន្តែគាត់មិនបានប្រាប់ពីមូលហេតុពីការចាប់ខ្លួននិងការដោះលែងឡើយ ។ ដូចគ្នានេះដែរ នៅខេត្តមណ្ឌលគិរី លោក ប៉ុន ឡឹងជ័យ ត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧៧ ហើយឃុំឃាំងនៅមន្ទីរសន្តិសុខកោះញែក ។ ជ័យ និយាយថា គាត់ត្រូវបានចោទប្រកាន់ថាមានការពាក់ព័ន្ធជាមួយក្រុមក្បត់ ប៉ុន្តែគាត់មិនបានប្រាប់ពីមូលហេតុអ្វីដែលគាត់បានរួចរស់រានមានជីវិតឡើយ ។ លោក សាល់ វ៉ា ត្រូវបានចាប់ខ្លួននៅក្នុងខែធ្នូ ឆ្នាំ១៩៧៨ ហើយយកទៅដាក់នៅមន្ទីរ ក១១ ។ គាត់និយាយថា មូលហេតុដែលខ្មែរក្រហមចាប់គាត់គឺដោយសារតែមានការចោទប្រកាន់ថាបងប្រុសរបស់គាត់បានរត់ទៅប្រទេសវៀតណាម ។ ប៉ុន្តែ វ៉ា មិនបានរៀបរាប់អំពីមូលហេតុនិងពេលវេលាដែលគាត់ត្រូវបានដោះលែងឡើយ ។




នៅឯទីក្រុងភ្នំពេញវិញ និស្សិត អ្នកការទូត និងជនជាតិខ្មែរដទៃទៀតដែលវិលត្រឡប់មកពីបរទេសក្រោយពីខ្មែរក្រហមបានកាន់កាប់ប្រទេស បន្ទាប់ពីមកដល់ព្រលានយន្តហោះពោចិនតុងភ្លាម ត្រូវបាននាំយកទៅកន្លែងមួយដែលហៅថា“មន្ទីរអប់រំកសាងខ្លួន” ដែលស្ថិតនៅក្នុងទីក្រុងភ្នំពេញ ។ បុគ្គលទាំងអស់

នេះត្រូវបានឃុំខ្លួនទុកក្រោមការសង្កេត ។ អ្នកដែលមើលទៅហាក់ដូចជាមិនមាន“ការភ្ញាក់រឭក” គ្រប់គ្រាន់ ត្រូវបានបញ្ជូនទៅកាន់គុកទួលស្លែងដើម្បីធ្វើទារុណកម្មនិងសម្លាប់ចោល ។ អ្នកដែលមិនធ្វើឲ្យរដ្ឋអំណាចខ្មែរក្រហមពេញចិត្តត្រូវបានដាក់ទោសឲ្យធ្វើការងារជាទម្ងន់ ។ អ្នកស្រី ហែម វណ្ណា ពេលវិលត្រឡប់មកពីសិក្សានៅប្រទេសបារាំងភ្លាមត្រូវបានបញ្ជូនទៅកាន់មន្ទីរអប់រំខ្លួននៅបឹងត្របែក ។ លោកស្រីនិយាយថានៅទីនោះគាត់ធ្វើការជាទម្ងន់ ហើយមិនហ៊ាននិយាយស្ដីអ្វីសូម្បីតែមួយម៉ាត់ក៏មិនហ៊ានផង ។ លោកស្រីពោលថា “មូលហេតុនេះហើយបានជាយើងនៅរស់” ។ អ្នកទោសម្នាក់ទៀតនៅឯមន្ទីរអប់រំខ្លួនគឺលោក ទេព វុត្ថា ត្រូវបានឃុំខ្លួននៅបឹងត្របែកអស់រយៈពេលបីឆ្នាំ ពោលគឺរហូតដល់ឆ្នាំ១៩៧៩ ។ គាត់និយាយថា គាត់បានត្រឡប់មកពីសិក្សានៅប្រទេសបារាំងនិងប្រទេសរូម៉ានីដើម្បីជួយកសាងប្រទេស ប៉ុន្តែដឹងខ្លួនថាតួនាទីរបស់គាត់ក្នុងការកសាងប្រទេសគឺបានតែត្រឹមតែជាកម្មករសិប្បកម្មតែប៉ុណ្ណោះ ។ វុត្ថា និយាយថា រូបគាត់និងអ្នកទោសដែលជាប់ឃុំជាមួយគ្នា



ប៉ុល ពត

ហាត់រៀនសម្របខ្លួនដើម្បីរស់នៅដោយគ្មានធ្វើអ្វីក្រៅពីប្រឹងប្រែងធ្វើការធ្ងន់ៗ និងមិននិយាយអ្វីទាំងអស់ ។

នៅខេត្តក្រចេះ លោក យឿន ឈឿន ត្រូវឃុំខ្លួនអស់រយៈពេលប្រាំមួយខែដប់ថ្ងៃនៅឯមន្ទីរសន្តិសុខឃុំកញ្ជោរដោយការចោទប្រកាន់ថាគាត់មានទំនាក់ទំនងជាមួយនឹងវៀតណាម ។ ឈឿន និយាយថា ពេលដែលឆ្មាំគុកផ្តល់ទឹកមិនគ្រប់គ្រាន់គាត់បានដឹកទឹកនោមខ្លួនឯងដើម្បីកុំឲ្យស្រេកទឹកស្លាប់ ។ គាត់និយាយថាការដែលគាត់បានរួចខ្លួនពីសេចក្តីស្លាប់គឺដោយសារតែគាត់កុហកកម្មាភិបាលខ្មែរក្រហមដែលទទួលខុសត្រូវក្នុងគុកអំពីឈ្មោះពិតរបស់គាត់ ហើយដូរឈ្មោះថ្មីដើម្បីកុំឲ្យកម្មាភិបាលគុកដឹងថាគាត់ជានរណា ។ លោក ឈឿន និយាយថា នៅក្នុងចំណោមអ្នកទោសប្រាំបីរយនាក់ដែលត្រូវឃុំខ្លួននៅមន្ទីរសន្តិសុខមានតែបីនាក់ប៉ុណ្ណោះដែលមានវាសនារស់រានមានជីវិត ។

ដូចគ្នានេះដែរនៅក្នុងខេត្តក្រចេះ អ្នកស្រី ប៉ាល់ វ៉ន ត្រូវ បានឃុំខ្លួនអស់រយៈពេលជាងបីឆ្នាំនៅឯវត្តខ្នុរការជាទូទៅប្រជាជនហៅវត្តនោះថា កោះបារ៉ុង ។ វ៉ន និយាយថា ក្រោយពីខ្មែរក្រហមយកប្តីគាត់ទៅសម្លាប់ រូបគាត់ត្រូវបានចោទប្រកាន់ថាបានដាក់ផែនការបោលគ្រាប់បែកទៅលើកម្មាភិបាលខ្មែរក្រហម ។ ប៉ុន្តែ វ៉ន មិនប្រាប់អ្នកធ្វើបទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាអំពីមូលហេតុច្បាស់លាស់និងការរួចពីសេចក្តីស្លាប់ដោយរបៀបណាឡើយ ។

នៅខេត្តកំពង់ឆ្នាំង លោក គីម ពន ត្រូវបានចាប់ខ្លួនក្នុងខែមេសា ឆ្នាំ១៩៧៧ ហើយយកទៅឃុំខ្លួនរហូតដល់ខែតុលា ឆ្នាំ១៩៧៨ នៅមន្ទីរសន្តិសុខហៅថាគុកព្រៃដីស្រុត ។ ទោសកំហុសរបស់គាត់គឺថា គីម ពន បានឲ្យកូនចៅដាំបាយឲ្យ"ប្រជាជន ១៧មេសា"ហូប ដែលតាមលោកទស្សនៈរបស់ខ្មែរក្រហមគឺជាអំពើមួយត្រូវបានចាត់ទុកជាអំពើឧក្រិដ្ឋ ។ ពន មិនបានប្រាប់អំពីមូលហេតុដែលគាត់ត្រូវបានដោះលែងឲ្យរួចខ្លួនទេ ប៉ុន្តែនិយាយថាគាត់ជា"អ្នកទោសកម្រិតស្រាល"តែប៉ុណ្ណោះ ។

នៅឆ្នាំ១៩៩៩ អ្នកសិក្សាស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជាបានតាមរកសម្ភាសអ្នកទោសខ្មែរក្រហមដែលចាកផុតពីសេចក្តីស្លាប់បួននាក់រស់នៅខេត្តកំពង់ធំ ។ លោក ម៉ែន ឡេ ត្រូវបានចោទប្រកាន់ថាមាន"ជាប់ពាក់ព័ន្ធ"ជាមួយនឹងរបបសីហនុ និងរបប លន់ ណុល ។ លោក ឱ យឿង បាននិយាយពីមូលហេតុនៃការចាប់ខ្លួនគាត់ថា គាត់ត្រូវបានចោទប្រកាន់ថាមានការពាក់ព័ន្ធផ្នែកនយោបាយ ពោលគឺជាមេខ្យល់ក្នុងចលនាព្រះពុទ្ធសាសនា ។ ចាប់ ប៊ុន ត្រូវបានចោទប្រកាន់ថាជាចៅហ្វាយស្រុកបារាយណ៍ ។ លោក ហេ ហៃ មិនបានចង្អុលបង្ហាញពីមូលហេតុនៃការចាប់ខ្លួនរបស់គាត់ឡើយ ។ អ្នកទោសទាំងអស់លើកលែងតែលោក ចាប់ ប៊ុន មុនដំបូងត្រូវបានឃុំឃាំងនៅគុកត្រដែត ហើយបន្ទាប់មកបញ្ជូនទៅវត្តបារាយណ៍ជាន់ដែក ដោយឃុំខ្លួនចាប់ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៩ ។ លោក ប៊ុន និយាយថា គាត់ជឿថារូបគាត់បានរួចពីសេចក្តីស្លាប់នេះគឺដោយសារតែគាត់ជាអ្នកធ្វើការសកម្មដោយបានធ្វើរទេះគោជាច្រើនគ្រឿងឲ្យខ្មែរក្រហម ។ ប៉ុន្តែគ្មានការបញ្ជាក់ច្បាស់អំពីមូលហេតុនិងការរស់រានរបស់ខ្លួនតាមរបៀបណាទេ ។

គួរឲ្យកត់សម្គាល់ដែរថា ភាគច្រើននៃអតីតអ្នកទោសខ្មែរក្រហមមិនស្មោះស្ម័គ្រផ្តល់ពត៌មានមកអ្នកសិក្សាស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាស្តីអំពីមូលហេតុដែលអ្នកទោសទាំងនោះគិតថាខ្លួនបានគេចផុតពីសេចក្តីស្លាប់ពីមន្ទីរសន្តិសុខខ្មែរក្រហមរបស់របបកម្ពុជាប្រជាធិបតេយ្យឡើយ ។ នេះជាសំណួរមួយសំខាន់គួរឲ្យចាប់អារម្មណ៍នៅក្នុងករណីផ្សេងៗដែលអ្នកផ្តល់ពត៌មានអះអាងថាខ្លួនគឺជាមនុស្សមានសំណាងមួយក្តាប់តូចក្នុងចំណោមអ្នកទោសរាប់រយឬរាប់ពាន់នាក់ដែលបានរស់រានមានជីវិតសាជាថ្មីពីប្រព័ន្ធគុក ដូចជា លោក យឿន ឈឿន ដែលរស់នៅខេត្តក្រចេះជាដើម ។ វាអាចជាការពិតដែលថាអ្នកទោសត្រូវតែធ្វើអ្វីៗដើម្បីឲ្យខ្លួនរួចពីសេចក្តីស្លាប់ ហើយដែលមកដល់សព្វថ្ងៃនេះខ្លួនមិនអាចលើកមកនិយាយបានជាពិសេសចំពោះអ្នកសម្ភាសយកពត៌មានដែលមានកាន់កូនម៉ាញ៉េនិងមានបេសកកម្មវែកមុខឧក្រិដ្ឋជន"កាលពីរបប ប៉ុល ពត" ។

**(នៅមានត)** **របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា**

◆ **សម្រួបនិងឱនលំទោនរៀនសូត្រពីមហាជន ផ្សារភ្ជាប់នឹងជំហរមហាជន ជិតសិទ្ធមហាជន។** (សៀវភៅទិសស្លោក អ៊ីវ)

# ការជម្លៀសប្រជាជន និង ការនិរទេសក្នុងប្រទេស

ច្បាប់ព្រហ្មទណ្ឌអន្តរជាតិបានប្រឆាំងនឹងការជម្លៀសប្រជាជនទាំងហ្វូងៗ ប៉ុន្តែពុំបានថ្កោលទោសឲ្យច្បាស់នូវការជម្លៀសដោយគ្មានការស្ម័គ្រចិត្តទាំងអស់នោះទេ ។ ការជម្លៀសចេញខ្លះអាចត្រូវបានចាត់ទុកថាជាលក្ខណៈគួរឲ្យទទួលយកបាន ប្រសិនបើផលប្រយោជន៍សហគមន៍វាលើសលប់ទៅលើការខាតបង់របស់បុគ្គល ហើយមនុស្សតិចណាស់ដែលផ្តល់ទស្សនីករណ៍ថា តាមនិយមន័យរាល់ការជម្លៀសដោយបង្ខំទាំងអស់គឺសុទ្ធតែខុសច្បាប់ ។ ទោះបីជាយ៉ាងណាក៏ដោយ ការជម្លៀសមហាជន




ជាច្រើនបានរំលោភទៅលើបទដ្ឋានសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ ហេតុដូច្នេះហើយចលនាទាំងនោះគឺជាការរំលោភលើច្បាប់អន្តរជាតិដែលត្រូវបានទទួលយក ។ ដូចការពន្យល់ខាងក្រោមនេះ ច្បាប់ជាវិជ្ជមានដែលមានស្រាប់ស្តីអំពីការជម្លៀសគឺសំដៅដោះស្រាយ ដោយផ្ទាល់បានតែនៅក្នុងស្ថានការណ៍មួយចំនួនតូចប៉ុណ្ណោះ ។

ច្បាប់និយាយពីប្រធានបទនេះ បានកើតចេញពីការជំនុំជម្រះក្តីនៅ នូរិមប៊ឺក ដែលជាលើកដំបូងដាក់ឲ្យការជម្លៀសប្រជាជន ឬដែនសមត្ថកិច្ចរបស់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ ការបណ្តេញឬបង្ខំឲ្យជម្លៀសចេញទាំងហ្វូងឆ្លងកាត់ព្រំដែនអន្តរជាតិ ស្រដៀងគ្នាទៅនឹងសកម្មភាពទាំងឡាយដែល ហ៊ីត្លែរបានអនុវត្តក្នុងអំឡុងសង្គ្រាមលោកលើកទី២ ។ ហេតុដូចនេះការជម្លៀសចេញត្រូវបានចាត់ទុកថាជាការរំលោភបំពានយ៉ាងច្បាស់មកលើច្បាប់មនុស្សធម៌អន្តរជាតិ ។ ការជម្លៀសចេញទាំងនេះដែលសំដៅទៅលើក្រុមជនជាតិភាគតិច និងការនិរទេសជនស៊ីវិលទាំងហ្វូងៗចេញពីដែនដីក្រោមការកាន់កាប់របស់ខ្លួន គឺជាការរំលោភបំពានដែលត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ ។ ទោះបីជាយ៉ាងណាក៏ដោយ ការផ្លាស់ប្តូររវាងរដ្ឋនិងរដ្ឋអាចត្រូវបានអនុញ្ញាតក្រោមលក្ខន្តិកៈមួយចំនួនឲ្យតែរដ្ឋដែលមានបំណងចង់ផ្លាស់ប្តូរគ្នាទាំងនោះ គឺជាប្រទេសដែលបានចុះហត្ថលេខាលើអនុសញ្ញាក្រុងហ្សឺណែវទី៤ ។ ទោះជាយ៉ាងណាក៏ដោយ កត្តាជាច្រើនអាចជះឥទ្ធិពលលើស្ថានភាពផ្លូវច្បាប់នៃការផ្លាស់ប្តូរឬជម្លៀសដទៃទៀត ។ កត្តាទាំងនេះរួមមានដូចខាងក្រោម ហើយអាចមានលើសពីនេះទៀត អំពើនោះគឺ÷

- ក្នុងប្រទេសឬឆ្លងកាត់ព្រំដែនអន្តរជាតិ ។
- កើតឡើងពេលមានជម្លោះប្រដាប់អាវុធឬក្នុងពេលមានសន្តិភាព ។
- ទាក់ទងដល់ការជម្លៀសនូវបុគ្គលឬមនុស្សទាំងហ្វូងៗ ។

◆ សំដៅលើក្រុមជនជាតិភាគតិចច្បាស់លាស់ណាមួយ ។

លើសពីនេះទៅទៀត ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរទាំងឡាយដែលបង្កដោយជំរុញឲ្យតាំងទីលំនៅដ្ឋាននានាក្នុងតំបន់ច្បាស់លាស់ណាមួយ ឬក្នុងទឹកដីក្រោមការកាន់កាប់ណាមួយ កំពុងត្រូវបានយកចិត្តទុកដាក់កាន់តែខ្លាំងឡើងៗ ។ ទោះបីជាយ៉ាងណាក៏ដោយ ការរំលោភបំពានទាំងនេះ ជារឿយៗត្រូវបានដោះស្រាយដោយឡែកពីការជម្លៀសទាំងឡាយដែលបានពិភាក្សាខាងលើ ។ សកម្មភាពដទៃទៀតដូចជាការផ្លាស់ទីលំនៅរបស់ជនភៀសខ្លួន ឬការផ្លាស់ទីលំនៅដើម្បីប្តូរបរិយាកាសសេដ្ឋកិច្ចគឺពុំត្រូវបានចាត់ទុកថាស្ថិតក្នុងអង្គច្បាប់នេះឡើយ ។

### ក) ប្រភពនៃច្បាប់

១) គោលការណ៍ច្បាប់

ភាពគួរឲ្យរន្ធត់នៃការជម្លៀសមនុស្សទាំងហ្វូងៗគឺត្រូវបានទទួលស្គាល់ជាផ្លូវការជាលើកដំបូងនៅក្នុងការជំនុំជម្រះទាំងឡាយនៅ នូរិមប៊ឹក ដែលចាត់ចំណាត់ថ្នាក់ការជម្លៀសមនុស្សរបស់ពួកណាហ្ស៊ីជាច្រើនថាជា "ឧក្រិដ្ឋកម្មសង្គ្រាម" និងជា "ឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ"មាត្រាទី៦(គ) នៃរដ្ឋធម្មនុញ្ញតុលាការយោធាអន្តរជាតិកំណត់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថាជា"អំពើមនុស្សឃាត ការសម្លាប់រង្គាល ការបង្ខំធ្វើទាសករ ការនិរទេស និងសកម្មភាពអមនុស្សធម៌មួយចំនួនដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនស៊ីវិលមុនឬនៅពេលសង្គ្រាម" ។ ការនិរទេសប្រជាជនដើមកំណើតនិងការប៉ុនប៉ង "ធ្វើណាហ្ស៊ីភាវូបនីយកម្ម" លើដែនដីដែលនៅក្រោមការកាន់កាប់ទាំងឡាយ គឺត្រូវបានថ្កោលទោសម្តងហើយម្តងទៀតក្នុងពេលជំនុំជម្រះក្តីទាំងនេះ ។

២) អនុសញ្ញាក្រុងហ្សឺណែវ

មាត្រា៤៩ នៃអនុសញ្ញាក្រុងហ្សឺណែវទាក់ទងទៅនឹងការការពារជនស៊ីវិលក្នុងពេលសង្គ្រាម ហាមឃាត់ការជម្លៀសបុគ្គលនិងមនុស្សទាំងហ្វូងៗ ហើយនិងការនិរទេសមនុស្សដែលទទួលបានការការពារពីរដ្ឋដែលនៅក្រោមការកាន់កាប់ ទៅរដ្ឋរបស់អ្នកដទៃកាន់កាប់ឬទៅកាន់ទឹកដីនៃប្រទេសអំណាចណាមួយផ្សេងទៀតដែលនៅក្រោមការគ្រប់គ្រងឬអត់ ដោយមិនគិតពីទស្សនៈយល់ឃើញរបស់ខ្លួន ។ អនុសញ្ញាទីក្រុងហ្សឺណែវ ជាទូទៅត្រូវបានចាត់ទុកថាជាផ្នែកមួយនៃច្បាប់អន្តរជាតិ ។ ទោះបីជាយ៉ាងណាក៏ដោយ "ខ" ទាំងឡាយនេះនិយាយជាចម្បងតែពីជម្លោះប្រដាប់អាវុធអន្តរជាតិប៉ុណ្ណោះ ។ មាត្រារួមពនិយាយពីជម្លោះទាំងឡាយដែលមិនមែនជាលក្ខណៈអន្តរជាតិ ។ មាត្រានេះចែងថា បុគ្គលទាំងឡាយណាដែលមិនបានចូលប្រឡូកយ៉ាងសកម្មក្នុងជម្លោះប្រទូសរ៉ាយទាំងនោះ «ទោះក្នុងកាលៈទេសៈណាក៏ដោយ ត្រូវទទួលនូវការប្រព្រឹត្តមកលើខ្លួនក្នុងភាពថ្លៃថ្នូរជាមនុស្ស ហើយពុំមានការបែងចែកឲ្យប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ជំនឿសាសនា ឬភេទ ការចាប់កំណើត ឬទ្រព្យសម្បត្តិ ឬដោយផ្អែក



លើលក្ខណៈវិនិច្ឆ័យដទៃផ្សេងទៀតឡើយ" ។ ទោះបីជាយ៉ាងណាក៏ដោយ មាត្រានេះពុំបាននិយាយឲ្យច្បាស់ពីការជម្លៀសប្រជាជនឡើយ ។ ជាងនេះទៅទៀត ភាពដែលអាចអនុវត្តទៅបាននៃការហាមឃាត់ទៅលើការជម្លៀសទាំងហ្វូងៗក្នុងមាត្រា៤៩គឺមានកម្រិតចំពោះជនស៊ីវិលទាំងឡាយក្នុងដែនដីក្រោមការកាន់កាប់ដែលមានការលើកលែងដូចតទៅនេះ÷

◆ ភាគីរដ្ឋដែលពុំចង់ដោយអនុសញ្ញានេះ ។ ◆ ប្រជាជាតិនៃរដ្ឋដែលមានតំណាងការទូតនៅក្នុងរដ្ឋមួយទៀតដែលប្រជាជនរបស់ពួកខ្លួននៅក្រោមការកាន់កាប់ ។ ◆ បុគ្គលទាំងឡាយនៅក្រោមអនុសញ្ញាក្រុងហ្សឺណែវ រួមមានទាហានដែលរបួសក្នុងទីលានប្រយុទ្ធឬនៅក្នុងសង្គ្រាមឈូងសមុទ្រឬអ្នកទោសសង្គ្រាម ។

៣) អនុសញ្ញាសហព័ន្ធអឺរ៉ុប

មាត្រា២និងមាត្រា៣នៃពិធីសារទី៤នៃអនុសញ្ញាសហព័ន្ធអឺរ៉ុបចំពោះការការពារសិទ្ធិមនុស្ស ក៏បាននិយាយពីស្ថានការណ៍ច្បាប់ស្តីពីការជម្លៀសប្រជាជន ។ មាត្រា២ធានានូវសិទ្ធិសេរីភាពក្នុងការដើរហើរ និងសិទ្ធិសេរីភាពក្នុងការជ្រើសរើសលំនៅដ្ឋានរបស់ខ្លួនដែលនៅក្រោមការរឹតត្បិតមួយចំនួនដូចជា "ត្រូវធ្វើយ៉ាងណាឲ្យស្របទៅតាមច្បាប់ និងចាំបាច់ត្រូវអនុលោមទៅតាមតម្រូវការក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីបម្រើផលប្រយោជន៍សន្តិសុខជាតិឬសុវត្ថិភាពសាធារណៈ ដើម្បីថែរក្សាសណ្តាប់ធ្នាប់សាធារណៈ ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មការពារសុខភាពនិងសីលធម៌សង្គ្រាម ឬដើម្បីការពារសិទ្ធិនិងសេរីភាពរបស់អ្នកដទៃ ។

មាត្រា៣ះ បានចែងថា÷ ◆ គ្មាននរណាម្នាក់ត្រូវបង្ខំឲ្យជម្លៀសដោយប្រើប្រាស់វិធានការជម្លៀសជាបុគ្គលឬទាំងហ្វូងៗពីទឹកដីរបស់ខ្លួនឡើយ ។ ◆ គ្មាននរណាម្នាក់ត្រូវបានដកហូតយកសិទ្ធិចេញចូលទឹកដីរបស់ខ្លួនឡើយ ។

ក្នុងរឿងក្តីរវាង ស៊ីព្រូស ទល់នឹង ទួរគី គណៈកម្មការសហព័ន្ធអឺរ៉ុបស្តីអំពីសិទ្ធិមនុស្សក៏បានផ្សារភ្ជាប់ការជម្លៀសប្រជាជនទៅនឹងសិទ្ធិរស់នៅដោយពុំមានការជ្រៀតជ្រែក ។ គណៈកម្មការនេះថ្កោលទោសទាំងចំពោះការជម្លៀសក្នុងប្រទេសនិងការជម្លៀសឆ្លងកាត់ព្រំដែនអន្តរជាតិ ។ ជាការពិតណាស់ "ខ" ទាំងនេះ គឺអាចយកទៅអនុវត្តបានតែចំពោះប្រទេសជាហត្ថលេខីនៃអនុសញ្ញាសហព័ន្ធអឺរ៉ុបស្តីអំពីសិទ្ធិមនុស្សប៉ុណ្ណោះ ក៏ប៉ុន្តែក៏អាចចង្អុលបង្ហាញដល់ការហាមឃាត់មួយដែលទើបនឹងចាប់បដិសន្ធិឡើងប្រឆាំងនឹងការជម្លៀសទាំងហ្វូងដែរ ។

ការជម្លៀសជាច្រើនដែលពុំត្រូវវែតខ្វះទៅនឹងចំណាត់ប្រភេទខាងលើ អាចត្រូវបានយកមកនិយាយដោយអនុសញ្ញាស្តីអំពីសិទ្ធិមនុស្សនៅត្រង់មាត្រា៣ បានទទួលស្គាល់នូវសិទ្ធិទទួលសុវត្ថិភាពផ្ទាល់ខ្លួន និងត្រង់មាត្រាទី២៥ សិទ្ធិទទួលកម្រិតជីវភាពរស់នៅគ្រប់គ្រាន់ ។

៤) ការជម្លៀសគឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

ការជម្លៀសដោយបង្ខំមួយចំនួនត្រូវបានចាត់ទុកថា



ដំណើរជម្លៀសប្រជាជនកម្ពុជាទៅកាន់ទីជនបទ

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬជាការរំលោភលើច្បាប់មនុស្សធម៌ ។ ការជម្លៀស ការផ្លាស់ប្តូរឲ្យទៅនៅទីកន្លែងផ្សេងៗ ភាពសាហាវយោរយៅ ឬលក្ខណៈរើសអើងដែលរំលោភទៅលើមនសិការរបស់មនុស្ស និងបទដ្ឋានមនុស្សធម៌ជាមូលដ្ឋានទាំងឡាយពុំចាំបាច់ត្រូវបញ្ចូលក្នុងប្រភេទណាមួយក្នុងចំណោមបទល្មើសខាងលើ អាចចាត់ទុកជាប្រការរំលោភលើច្បាប់អន្តរជាតិនោះឡើយ ។ ការជម្លៀសដែលអាចចាត់ទុកជាបទល្មើសណាមួយដូចបានរៀបរាប់ខាងលើ លុះត្រាតែការជម្លៀសនោះ ត្រូវបានធ្វើឡើងដោយពុំមានការស្ម័គ្រចិត្ត ហើយមានការចុះស្នាមនិងដឹងឮដោយរដ្ឋ ។ ប្រសិនបើការជម្លៀសនេះសំដៅបំផ្លាញទាំងស្រុងឬដោយផ្អែកលើក្រុមជនជាតិភាគតិចមួយ ការជម្លៀសនេះក៏អាចត្រូវបានចាត់ទុកឧក្រិដ្ឋកម្មប្រល័យពូជសាសន៍បានដែរ ។

៥) ការដាក់កម្រិតនានាដោយឈរលើអធិបតេយ្យភាព

មាត្រា២ («៧») នៃធម្មនុញ្ញអង្គការសហប្រជាជាតិដល់កម្រិតធ្ងន់ធ្ងរបំផុតលើច្បាប់ជាវិជ្ជមានស្តីអំពីការជម្លៀសប្រជាជន ។ មាត្រានេះនិយាយថា«គ្មានអ្វីដែលមានចែងក្នុងធម្មនុញ្ញនាពេលបច្ចុប្បន្នផ្តល់សិទ្ធិអំណាចសមត្ថកិច្ចឲ្យដល់អង្គការសហប្រជាជាតិ ដើម្បីជ្រៀតជ្រែកក្នុងបញ្ហានានា ដែលមានសារៈសំខាន់ក្នុងដែនសមត្ថកិច្ចក្នុងស្រុករបស់រដ្ឋទាំងឡាយនោះឡើយ» ។

ហេតុដូច្នេះហើយការជម្លៀសទាំងឡាយដែលបានកើតឡើងក្នុងសង្គ្រាមស៊ីវិល ហើយមិនសំដៅបំផ្លិចបំផ្លាញដល់ក្រុមជនជាតិភាគតិចណាមួយនោះ អាចត្រូវបានចាត់ទុកថាស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់អង្គការសហប្រជាជាតិ លុះត្រាតែការជម្លៀសទាំងនោះមានលក្ខណៈធ្ងន់ធ្ងរល្មមដល់ក្លាយទៅជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ល្មមរហូតដល់ក្លាយទៅជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ ឬការរំលោភបំពានលើបទដ្ឋានច្បាប់អន្តរជាតិជាមូលដ្ឋានដទៃទៀត ។

**៦) ការអនុវត្តចំពោះប្រទេសកម្ពុជា**

ភាពសាហាវយោរយៅនិងទំហំនៃការជម្លៀសទាំងហ្វូងក្នុងប្រទេសកម្ពុជារវាងពីឆ្នាំ១៩៧៥ដល់១៩៧៨ បង្ហាញពីស្ថានការណ៍តែមួយគត់នៅក្នុងច្បាប់អន្តរជាតិ ។ ទីក្រុងនិងទីប្រជុំជនទាំងមូលត្រូវស្ងាត់ឈឹងដោយប្រជាជនទីក្រុងទាំងអស់ត្រូវបានជម្លៀសទៅតំបន់ជនបទ ។ ជាបន្តបន្ទាប់ អ្នកទាំងនោះត្រូវបង្ខំឲ្យធ្វើការជាទម្ងន់ដើម្បីប្រែក្លាយតំបន់ថ្មីៗទាំងឡាយឲ្យទៅជាតំបន់កសិកម្ម ។ ទំហំនៃការបាត់បង់ជីវិតមនុស្សដ៏ធំមហិមាដោយសារការជម្លៀស គ្រោះទុរ្ភិក្ស និងការលំបាកដ៏ធ្ងន់ធ្ងរ ជាផលវិបាកដែលរបបនេះបានបន្សល់ទុក បង្ហាញភ័ស្តុតាងថាការជម្លៀសទាំងនេះគឺជាឧក្រិដ្ឋកម្មសង្គ្រាម ។ ការជម្លៀសទាំងនេះពុំមានការយល់ព្រមឡើយគឺធ្វើឡើងដោយបង្ខំ ហើយពុំត្រូវបានអនុវត្តក្នុងលក្ខណៈជាមនុស្សជាតិមានវប្បធម៌ជឿនលឿន និងបណ្តាលឲ្យមនុស្សស្លាប់ច្រើនរាប់មិនអស់ ។ ទោះបីជាយ៉ាងណាក៏ដោយ ការជម្លៀសដោយអមនុស្សធម៌ទាំងនេះ ពុំមានចែងច្បាស់នៅក្នុងការហាមឃាត់ដែលបានកំណត់យ៉ាងតឹងរ៉ឹងស្តីអំពីការជម្លៀសប្រជាជនឡើយ ។ ការជម្លៀសទាំងនេះគឺងាយនឹងចាត់ចំណាត់ថ្នាក់ចូលក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាង ។

ដោយសារការជម្លៀសទាំងនេះស្ថិតនៅក្នុងប្រទេស ដែលលំបាកកំណត់ថាជា«ការនិរទេស» ដែលនឹងមានលក្ខណៈចាំបាច់សម្រាប់ដាក់អំពើជម្លៀសទាំងនេះក្រោមការហាមឃាត់នៅក្នុងមាត្រា៦នៃរដ្ឋធម្មនុញ្ញ IMT ។ ជាងនេះទៅទៀតដោយហេតុថា អ្នកដែលត្រូវជម្លៀសទាំងនោះគឺជាប្រជាពលរដ្ឋនៃរដ្ឋដែលទទួលខុសត្រូវលើការជម្លៀសទាំងនោះ ស្រដៀងគ្នានេះដែរ ការជម្លៀសទាំងនេះពុំបាននិយាយដល់មាត្រា៤៩នៃអនុញ្ញាក្រុងហ្សឺណែវលើកទី៤ ។ ទោះជាយ៉ាងណាក៏ដោយ ភាពអមនុស្សធម៌នៃការជម្លៀសទាំងនោះគឺប្រឆាំងយ៉ាងច្បាស់ក្រឡែតចំពោះមាត្រា៣រួមនៃអនុសញ្ញាក្រុងហ្សឺណែវ ដែលអំពាវនាវឲ្យប្រព្រឹត្តក្នុងភាពថ្លៃថ្នូរជាមនុស្សមកលើជនស៊ីវិលដែលពុំបានចូលប្រឡូកសកម្មភាពប្រទូសរ៉ាយនោះ ។


ម្ចាស់គំនូរខាងលើ អាយុ១៨ឆ្នាំ

**អេលីហ្សាប៊ែត វ៉ាន់ស្កាក់**

# គំរូមួយនៃភ័ស្តុតាងឯកសារភ្ជាប់មេដឹកនាំថ្នាក់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជាដែលនៅរស់ នៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

**(តពីលេខមុន)** អត្ថបទស្រាវជ្រាវខ្លីមួយនេះមានការបំពេញបន្ថែមនិងផ្លាស់ប្តូរមួយចំនួនទៅលើសេចក្តីសន្និដ្ឋាននៅក្នុងឯកសារគំរូភ័ស្តុតាងចុះខែឧសភាឆ្នាំ១៩៩៩ ដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ អត្ថបទនេះអាចអានផ្គួបជាមួយនឹងឯកសារមុនដែលជាការផ្តល់នូវសារធាតុនៃបញ្ហា និងលទ្ធភាពក្នុងការភ្ជាប់បុគ្គលជាមេដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជាទៅនឹងអំពើណាមួយជាក់លាក់ដែលអាចក្លាយជាបទដ្ឋានមួយនៃអំពើឃាតកម្ម និងអំពើដទៃផ្សេងទៀតដែលអាចផ្តុំបានជាបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលត្រូវបានប្រព្រឹត្តមកលើជនរងគ្រោះដោយហេតុផលនយោបាយ ។

អត្ថបទនេះបង្ហាញពីលទ្ធផលនៃដំណើរទស្សនកិច្ចបន្ថែមមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាចាប់ពីចុងខែកក្កដាដល់ដើមខែសីហា ឆ្នាំ១៩៩៩ ដែលនៅក្នុងអំឡុងពេលនោះខ្ញុំបានពិនិត្យមើលជាទូទៅព្រមទាំងចម្លងឯកសារទើបប្រមូលបានថ្មីស្តីអំពីបក្សកុម្មុយនិស្តកម្ពុជា ។ ឯកសារទាំងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាដាក់ឈ្មោះថា «ការទាក់ទងគ្នារបស់ខ្មែរក្រហម» មានទូរលេខមួយចំនួននិងសារដទៃទៀតផ្ញើមកពីភូមិភាគផ្សេងៗនៃបក្សកុម្មុយនិស្តកម្ពុជាអង្គភាពយោធាដែលស្ថិតនៅក្រោមគណៈមជ្ឈិមបក្សនៃបក្សកុម្មុយនិស្តកម្ពុជា និងមកពីឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យ ។ ឯកសារទាំងនេះទាក់ទងរវាងពាក់កណ្តាលឆ្នាំ១៩៧៧និងពាក់កណ្តាលឆ្នាំ១៩៧៨ ។ លើសពីនេះទៀត ឯកសារថ្មីនេះពង្រីកយ៉ាងច្រើនដល់បរិមាណនិងបង្កើនភ័ស្តុតាងយ៉ាងហោចណាស់អំពី«ទោសកំហុសនៃការដឹងឮ(ហើយមិនព្រមចាត់វិធានការ)»របស់សមាជិកដែលនៅរស់នៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជាចំពោះករណីមនុស្សឃាត ដោយហេតុផលនយោបាយនៅភូមិភាគក្រោមការកាន់កាប់របស់បក្សកុម្មុយនិស្តកម្ពុជា និងការសម្លាប់ជនជាតិវៀតណាម ព្រមទាំងបទឧក្រិដ្ឋកម្មផ្សេងៗទៀតពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យនិងសាធារណរដ្ឋសង្គមនិយមវៀតណាម ។ សមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ដែលនៅរស់នៅឡើយគឺ នួន ជា (ដែលជាអនុលេខាទីមួយនៃគណៈកម្មាធិការមជ្ឈិមបក្សនៃបក្សកុម្មុយនិស្តកម្ពុជា) និង អៀង សារី (ហៅវ៉ាន់) ដែលជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស ។

ឯកសារទាំងនេះមានប្រើពាក្យដែលប្រើសម្រាប់សម្រាលឬបិទបាំងន័យពិតដើម្បីជំនួសពាក្យមួយចំនួនដូចជា សម្លាប់ជំនួសដោយ «កម្ទេច» ឬ«បោសសម្អាត» និង«ផ្តន្ទាទោសកម្រិតខ្ពស់បំផុត» ដែលមានប្រើក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ។ ឯកសារដែលរៀបរាប់ពីខាងលើនេះត្រូវបានសរសេរថា «គោរពជូនបង (ប៉ុល ពត)ជាទីស្នេហានិងរលឹក» «ជូនបងជាទីគោរព» «ជូនបងជាទីគោរពស្នេហា»«ចំពោះបងជាទីស្នេហានិងរលឹក» «គោរពជូន ពូជាទីគោរពស្នេហានិងនឹករលឹក» «ជូនបង ០០៩ ជាទីស្នេហានឹករលឹក»«ជម្រាបអង្គការជាទីគោរពស្នេហា» «គោរពជូនគណៈ៨៧០(លេខកូដតំណាងឲ្យគណៈមជ្ឈិម)» «គោរពជូនអង្គការម.៨៧០(ម.តំណាងឲ្យមន្ទីរ)»«ជូនចំពោះគណៈ៨៧០ ជាទីគោរពនិងនឹករលឹក» «ជូនចំពោះម.៨៧០ជាទីស្នេហា» «ជូនចំពោះគណៈ៨៧០ ជាទីស្នេហា» និង «ជូនចំពោះគណៈ៨៧០ ជាទីនឹករលឹក» ។ វៀរលែងតែឈ្មោះ ប៉ុល ពត ត្រូវបានបញ្ជាក់ច្បាស់តាមរយៈអក្សរកាត់ ក្រៅពីនេះមិនដឹងថាតើឯកសារទាំងនេះត្រូវបានបញ្ជូនទៅអ្នកណាខ្លះឡើយ ។ ក៏ប៉ុន្តែឯកសារទាំងនេះមានចំណារថា ចម្លងជូនចំពោះសមាជិកប្រាំនាក់នៃគណៈកម្មាធិការអចិន្ត្រៃដែលមានទីលំនៅនៅក្នុងរដ្ឋធានីភ្នំពេញ ។ ប៉ុល ពត ត្រូវបានហៅថា «ពូ» នួន ជាត្រូវបានហៅថា «ពូនួន» អៀង សារី ត្រូវបានហៅថា «បងវ៉ាន់» វន វេត ត្រូវបានហៅថា «បងវន» ហើយ សុន សេន ត្រូវបានហៅថា «បងខៀវ» ។ ឯកសារទាំងនេះមិនបញ្ជាក់ឲ្យបាន

ច្បាស់ថាអ្នកណាម្នាក់ក្នុងចំណោមអ្នកទាំងប្រាំមានអំណាចធ្វើការសម្រេចចិត្តទៅលើបញ្ហាផ្សេងៗ ឬក៏សម្រេចចិត្តនៅក្នុងវេទិកាណាមួយឡើយ ប៉ុន្តែហាក់ដូចជាបញ្ជាក់ច្បាស់ថាទាំង នួន ជា និង អៀង សារី គឺជាផ្នែកមួយនៃក្រុមទទួលពត៌មាន ដែលក្នុងនោះរួមមាន ប៉ុល ពត វន វេត និង សុន សេន។ នៅក្នុងករណីខ្លះ ឯកសារមានសុំការអនុញ្ញាតពីអ្នកដែលបានទទួលសំបុត្រក្នុងការសម្លាប់មនុស្សទៀតផង។

ឧទាហរណ៍ នួន ជា និង វ៉ាន់ គឺជាមនុស្សក្នុងចំណោមអ្នកដែលត្រូវបានបញ្ជូនជូននូវទូរលេខមួយចុះនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៧ ដោយ អ៊ុំ នាង ហៅ វី លេខាភូមិភាគឦសាន(ក្រោយមកត្រូវបានបោសសម្អាតនិងធ្វើអត្តឃាត)។ ទូរលេខនេះរាយការណ៍អំពីការចាប់បានយួនចំនួន២០៩នាក់ ក្នុងនោះមានស្ត្រី៩នាក់។ វី ពន្យល់ថាអ្នកទោស «សឹងទាំងអស់ជាជនជាតិចារ៉ាយ។ ពេលជួបវា វាឆ្លើយថាវាជាប្រជាជនមកសុំចុះចូលនៅក្នុងទឹកដីកម្ពុជានិយាយថាចង់ចុះចូលជាមួយកម្ពុជាប្រជាធិបតេយ្យ ហើយជាទាហានពីរទៅដប់ឆ្នាំ»។ ប៉ុន្តែក្រោយពីការសួរចម្លើយរួចហើយ វី បានវាយតម្លៃថា «តាមពិនិត្យពួកអានេះជាខ្មាំងខាងក្រៅមកបង្កប់នៅក្នុងដីយើង»។ វី បានស្នើ«សុំមិត្តអង្គការថែម» ដើម្បីចាត់វិធានការជាមួយអ្នកទោសទាំងនេះ។ ដោយប្រើឃ្លានៅក្នុងរដ្ឋធម្មនុញ្ញ វី បានបញ្ជាក់ថាកងផលិតរបស់ភូមិភាគដែលជាអ្នកចាប់វាបាន «សុំស្នើសម្រេចកម្រិតខ្ពស់តែម្តង» ហើយថា «ខ្ញុំរង់ចាំចម្លើយព្រមសម្រេចរបៀបនេះ»។ របាយការណ៍របស់ វី ក៏មានប្រើភាសារដ្ឋធម្មនុញ្ញដែរ ទាក់ទងនឹង«ពួកអាបង្កប់នៅចំការកៅស៊ូកប្បាសនិងអង្គភាពកងចល័តដែលដកពីយោធាឆ្នាំ១៩៧៤»។ វី បានបញ្ជាក់ថាមានការសម្រេចឲ្យរកវិធីស្ងាត់ៗ ហើយបន្ថែមថា «ទាំងអស់ក្រោយបានចម្លើយក៏ផុតសំឡេងច្បាស់ និងសុំសម្រេចកម្រិតខ្ពស់ទាំងអស់»។



គ្រែដេករបស់អ្នកទោសនៅទួលស្លែង

នួន និង វ៉ាន់ ត្រូវបានបញ្ជូនជូននូវទូរលេខចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៧៧ មកពីភូមិភាគបស្ចិម «ជម្រាបអង្គការជាទីគោរពស្នេហា»។ ទូរលេខនេះនិយាយអំពីការឃាត់ខ្លួនមនុស្ស២៤នាក់ដោយ «កងការពារ» ប្រចាំការនៅតំបន់ កំពង់ឆ្នាំង ក្នុងនោះមានស្ត្រីម្នាក់ផង។ តាមចម្លើយថា «រយៈពេលរត់ចំនួន១២០ថ្ងៃ ហើយមកពីស្រុកព្រៃឈរ ខេត្តកំពង់ចាម គោលបំណងវារត់ទៅភ្នំគូលែនទៅរកអាច័ន្ទរង្សី»។ ទូរលេខនេះបានស្នើមតិពីអង្គការ «អង្គការមានវិធានការយ៉ាងណាដែរ»។ ទូរលេខមួយទៀតចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៧៧ ផ្ញើមកពីលេខាភូមិភាគឧត្តរ(ថ្មី) ឈ្មោះ ចាន់ សម ហៅ កង ចាប ហៅ សែ (ដែលក្រោយមកត្រូវបានបោសសម្អាត និងសម្លាប់ចោល)«គោរពជូនគណៈ៨៧០»បានរាយការណ៍ថាសភាពការណ៍ខ្មាំងខាងក្នុងនៅប៉ែកឧត្តរថា÷ «នៅតាមមូលដ្ឋាននៅតាមមន្ទីរក្រសួងនិងយោធាយើងបានរកឃើញខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងជាបន្តបន្ទាប់ ទាំងការតាមដានសកម្មភាពក្បត់ប្រឆាំងបដិវត្តន៍ទាំងតាមចម្លើយ។ ឯពួកខ្មាំងជារដ្ឋការនឹងប៉ូលិសទាហានចាស់យើងរកឃើញជាបន្តបន្ទាប់។ ចំពោះខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងបើប្រៀបធៀបពីមុនឥឡូវនេះ យើងកាន់តែថមថយចុះ

បណ្តើរៗ ហើយមាននៅសល់ដៃជើងវាបន្តិចបន្តួច" ។

សែ បានធានាថា តទៅទៀតជាវិធានការយើងបន្តការបោសសម្អាតខ្មាំងទាំងនោះជាបន្តបន្ទាប់ ។ ដំណើរការក្នុងចលនាប្រយុទ្ធគ្រប់ផ្នែកពិសេសយកចលនាបង្កបង្កើនផលជាគន្លឹះដើម្បីរកខ្មាំង គឺរកសមរភូមិប្រយុទ្ធ សម្រិតសម្រាំង និងបោសសម្អាត ។ សែ បញ្ជាក់ថា "តែក៏នៅមានមួយចំនួនតិចតួចនៅបំផ្លើសមាគ៌ាបង្កបង្កើនផល នៅមានប្រឆាំងបដិវត្តន៍តាមវិធីស្របច្បាប់ តាមទម្លាប់ចាស់ និងតាមរបៀបរបបចាស់តាំងពីភ្ជួរ-រាស់ ដក-ស្ទូង-សាប-ព្រោះ នៅរឹងរូសចចេសមិនព្រមតាមមាគ៌ាបង្កបង្កើនផល" ។

ការប្រឆាំងនៅតែកើតមានឡើងទោះបីជាភូមិភាគអប់រំបំពាក់បំប៉នមាគ៌ាបង្កបង្កើនផលច្រើនលើកច្រើនដងហើយក៏ដោយ ។ ភូមិភាគកំពុងតែបែងចែកអ្នកមិនទាន់យល់និងអ្នកប្រឆាំងហើយនឹងមានវិធានការទៅតាមការជាក់ស្តែង ។

ចំពោះវិស័យយោធាវិញក៏មានសកម្មភាពប្រហាក់ប្រហែលគ្នានេះដែរ ។ ទោះបីជាមានការសម្រិតសម្រាំង និងអប់រំបំពាក់នយោបាយសតិអារម្មណ៍ចាត់តាំងជាបន្តបន្ទាប់ក៏ដោយ ក៏យុទ្ធជនយើងដែលមានការប្រយុទ្ធទាំងនយោបាយសតិអារម្មណ៍ និងចាត់តាំងនៅមានភាគតិចតួចដែលជាដៃជើងខ្មាំងបង្កប់ពីមុននៅមានសល់ខ្លះៗ ។ មានម្នាក់បានរត់ទៅថៃ ហើយក្រោយមកភូមិភាគបានដកសមាសភាពអាក្រក់និងសេរីមួយចំនួនចេញពីកងទ័ពឲ្យមកបង្កបង្កើនផលនៅក្រោយ ។ ហើយទន្ទឹមនឹងនេះភូមិភាគចាត់វិធានការអប់រំសម្រិតសម្រាំងជាបន្តបន្ទាប់ ។

នួន និង វ៉ាន់ សុទ្ធតែត្រូវបានចម្លងជូននូវរបាយការណ៍ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ស្តីអំពីសភាពការណ៍នៅភូមិភាគឧត្តរពោលគឺសកម្មភាពខ្មាំងដែលប្រហែលជាបណ្តាលឲ្យប្រជាជនលួចរត់ជាបន្តបន្ទាប់ទៅប្រទេសថៃ ។ ទាក់ទងនឹងការចាប់ខ្លួននិងការបាត់ខ្លួនប្រជាជនទាំងនេះ របាយការណ៍បានសរសេរថា ខ្មាំងឃោសនាថា "បើមានគេយកទៀតគឺទៅទៀត" ។ ទូរលេខនេះបានលើកឡើងពីការចាប់ខ្លួន"ឈ្មោះអាឈឿន អានេះវាទៅបំផុសប្រជាជនឲ្យរត់" ។ ទូរលេខបានធានាថា ក្រៅពី"ការចេញទៅអប់រំប្រជាជនឲ្យយល់ពីបដិវត្តន៍សង្គមនិយមឲ្យច្បាស់ថែមទៀត តំបន់ផ្សេងៗនៅក្នុងភូមិភាគពាយ័ព្យទាំងមូលដ្ឋាននិងយោធា ត្រូវសហការគ្នាឲ្យជិតស្និទ្ធដើម្បីកម្ទេចខ្មាំងគ្រប់បែបយ៉ាង" ។ សារមួយទៀតមកពីភូមិភាគពាយ័ព្យចុះថ្ងៃទី២១ ខែធ្នូ របស់លេខាតំបន់ឈ្មោះ មូល សម្បត្តិ ហៅ រស់ ញឹម (ក្រោយមកត្រូវបានបោសសម្អាតនិងសម្លាប់ចោល) គោរពជូនអង្គការ៨៧០ ដោយស្នើថា "ខាងសន្តិសុខប្រាកដជាមន្ទីរមជ្ឈិមស-២១នៅ(ទីក្រុងភ្នំពេញ) សួរឈ្មោះ ហំ ដែលទទួលខុសត្រូវភ័ស្តុភារយោធាភូមិភាគចង់បានខ្សែបានឆាប់ដើម្បីរកខ្សែឲ្យអស់" ។

ដប់ថ្ងៃក្រោយមក នួន និង វ៉ាន់ ត្រូវបានចម្លងជូននូវសារមួយច្បាប់មកពីលេខាគណៈកងពលទាហានជើងទឹកមជ្ឈិមលេខ១៦៤ ឈ្មោះ មុត ។ នៅក្នុងសារនោះ មុត ប្តេជ្ញាចិត្តថានឹង"បោសសម្អាតគ្មានស្នាក់ស្នើរសមាសបង្កប់របស់ខ្មាំងជាយួននិងខ្មាំងដទៃទៀត" ។

នៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៨ លេខាភូមិភាគឧត្តរ (ថ្មី) ឈ្មោះ សែ បានផ្ញើទូរលេខនិយាយពីសភាពការណ៍មួយទៅ"គណៈ៨៧០" ហើយ នួន និង វ៉ាន់ ក៏បានទទួលដែរ ។ ទូរលេខនេះបានលើកឡើងពីវិធានការទប់ទល់ជាមួយនឹងសមាសភាពប្រឆាំងប្រដាប់អាវុធដែលលួចចូលមកពីប្រទេសថៃតាមព្រំដែននៅខាងខេត្តព្រះវិហារ ក៏ដូចជានៅឧត្តរមានជ័យ និងក៏ដូចជា "អាខ្មាំងដែលរត់ចេញពីកងទ័ពយើងនិងមូលដ្ឋានយើង" ។ ចំណែកឯវិធានការក្នុងការចាត់ការបញ្ហានេះរួមមានការ"ពង្រឹងសហករណ៍ពិសេសផ្អែកលើវណ្ណៈមូលដ្ឋាន ដើម្បីបោសសម្អាតខ្មាំងបង្កប់ក៏ដូចជាខ្មាំងចោរព្រៃ" ។ សារមួយទៀតបញ្ជូនមកថ្ងៃបន្ទាប់គឺមកពីលេខាភូមិភាគឦសានឈ្មោះ វី ។ របាយការណ៍នេះបានលើកឡើងអំពីការរកឃើញ"ខ្មាំងបង្កប់" ដែលបាន"ចិញ្ចឹមពួកក្បត់ដោយលាក់ស្រូវ" និង "បំផុសបំផុលឲ្យអ្នកដទៃទៀតរត់"រួមទាំង"មេក្បត់ខ្មាំងបង្កប់ឈ្មោះ នូ ដែលធ្វើសកម្មភាពជាយូរមកហើយ" ។ សារមួយទៀតរបស់ វី ចុះថ្ងៃទី១៣ ខែមករា បានរាយការណ៍ថា ខ្លួនបាន"ណែនាំឲ្យស្អាតផ្ទៃក្នុង" ក្រោយពីមានមនុស្សបួននាក់ចូលមកមន្ទីរយោធាភូមិភាគ ។ បីខែក្រោយមក សែ បានរាយការណ៍ថែមទៀតទៅលើបញ្ហា

ផ្សេងៗ និងការបោសសម្អាតនៅក្នុងភូមិភាគឧត្តរតាមរយៈសារមួយផ្ញើជូន "គណៈ៨៧០" និងចម្លងជូន នួន ជា និង វ៉ាន់ ។ ទាក់ទងនឹង"សភាពការណ៍ខ្មាំងនៅតាមបណ្តោយព្រំដែនថៃ" សែ និយាយថា "ពួកអាក្បត់វាលួចលួចវាយឈ្លបយើងនៅព្រំដែនព្រះវិហារក្នុងពេលដែលទ័ពយើងដើរក្នុងព្រៃ ម្យ៉ាងមកពីមូលហេតុផ្ទៃក្នុងកងទ័ពយើងមិនទាន់ល្អបណ្តាលឲ្យបែកការណ៍ខ្មាំងវាដឹងមុន" ។ តែទោះជាយ៉ាងនេះក្តីក៏ សែ អះអាងថា "បញ្ហានេះបានមានវិធានការហើយ" ។ ចូលទៅជ្រៅភូមិភាគឧត្តរមាន"ក្រុមចោរព្រៃមួយក្រុមប្រហែល៣០ ឬ៤០នាក់" ប៉ុន្តែកងទ័ពស្រុកនិងតំបន់កំពុងតែរុករកកម្ទេចចោរព្រៃទាំងនេះ កន្លងមកយើងកម្ទេចនិងចាប់បានអាចោរព្រៃទាំងនេះជាបន្តបន្ទាប់" ។ លើសពីនេះ "ដៃជើងវាដែលលួចផ្តល់ស្បៀងឲ្យវាត្រូវយើងចាប់អស់ទៀត" ។ចុងបញ្ចប់ សែ បានលើកឡើងអំពី "សភាពការណ៍ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង" ។ "ពួកខ្មាំងដែលនៅសល់វាងើបក្បាលឡើងវិញធ្វើសកម្មភាពប្រឆាំងនឹងយើង" ។ "វាទាក់ទងជាមួយប៉ូលិស ទាហាន និងពួករដ្ឋការ ពួកនេះវាបន្លំខ្លួនធ្វើជាប្រជាជនថ្មី" ។ ប៉ុន្តែ "ក្រោយពីវាធ្វើសកម្មភាពប្រឆាំងនឹងយើងទើបយើងស្គាល់មុខវាច្បាស់ ទន្ទឹមនឹងនេះយើងក៏បានបោសសម្អាតវាជាខ្សែសង្វាក់" ។ ទោះបីជា"ពួកទាហាន ប៉ូលិស និងរដ្ឋការ មួយចំនួនត្រូវរត់បាត់ក្រោយពីយើងបោសសម្អាតចំនួនប្រមាណជាង២០ក្បាល យើងក៏មានវិធានការបន្តរកចាប់ពួកនេះតទៅទៀត" ។ ទាក់ទងរឿង"ខ្មាំងបង្កប់នៅតំបន់ព្រះវិហារក្រោយពីយើងបានបោសសម្អាតនិងកំពុងបោសសម្អាតតទៅទៀតនោះក៏គ្មានបណ្តាលឲ្យមានបាតុភាពអ្វីទេ" ។

នៅថ្ងៃទី១០ ខែមេសា សែ ដដែលបានរាយការណ៍ថាក្រុមប្រឆាំងប្រដាប់អាវុធ"ធ្វើសកម្មភាពអុកឡុកយើងនៅតាមព្រំដែន" ហើយបានសន្យាថានឹង "កម្ទេចវា" ។ សែ អះអាងថាក្រោយពីយើង "ចាប់អាហាន់ (ហៅ ប៊ូ ដាត) ជាលេខាតំបន់១០៣ (ព្រះវិហារ) និងដៃជើងរបស់វាពួកវាត្រូវអស់បង្អែក ។ ចំពោះខ្មាំងជាចោរព្រៃដែលពីមុន អាហាន់ វាចាត់តាំងឲ្យមកនៅព្រៃយើងបានចាប់ហើយ កម្ទេចវាជាបន្តបន្ទាប់ហើយយើងកំពុងដំណើរការរុករកវាតទៅទៀត ។ យើងកំពុងបន្តបោសសម្អាតពួកអានៅសេសសល់ជាបន្តបន្ទាប់ទោះជាវាប្រឆាំងបដិវត្តន៍យើងទាំងចំហរក្តីទាំងសម្ងាត់ក្តី" សែ ពន្យល់ថា "ដោយយើងកាន់តែមានបង្អែករឹងមាំលើប្រជាជន ពិសេសប្រជាជនវណ្ណៈមូលដ្ឋាន គេកាន់តែឃើញមិត្តនិងសត្រូវច្បាស់លាស់ ។ បញ្ជាក់ឲ្យឃើញថាកម្លាំងភ្ញាក់រលឹករបស់ប្រជាជនទ្រឡើងជាលំដាប់ គេកាន់តែជឿលើសមូហភាព ជឿបក្សដឹកនាំ ។ ដោយម្យ៉ាងពួកប្រឆាំងក៏ត្រូវយើងសម្រិតសម្រាំងអស់ជាបន្តបន្ទាប់ ។ នៅឯតំបន់១០៣យើងបានដំណើរការបោសសម្អាតខ្មាំងបង្កប់ស៊ីរូង យើងក៏បានផ្អែកលើប្រជាជនយើងដំណើរការបានល្អ ខ្មាំងវាងើបក្បាលឡើងវិញមិនរួចក៏មកពីកម្លាំងប្រជាជនខ្លាំង ហើយកម្លាំងនេះ សង្កត់វាជាប់ និងបោសសម្អាតសម្រិតសម្រាំងវាជាប់ ។ យើងបានជ័យជម្នះលើខ្មាំងទាំងនោះតាំងពីដើមទីរហូតដល់ឥឡូវនេះ ។ ការបោសសម្អាតខ្មាំងនៅតំបន់១០៣នេះប្រជាជនមានការរីករាយជាអតិបរមា ។ **(នៅមានត)**

**ស៊ីវ ហេង៉រ**

## ពាក្យស្លោកខ្មែរក្រហម

- **សូមកុំបោះបង់ចោលហិឡ្យាបដិវត្តរបស់បក្សឱ្យសោះ!**
- **សូមយុទ្ធមិត្តបន្តការប្រយុទ្ធទៅទៀត ប្រយុទ្ធរហូតដល់ទីអវសាន កុំខ្លាចលះបង់ឡើយ!**

(យុវជននិងយុវនារីបដិវត្តលេខពិសេសខែកញ្ញា១៩៧៥ ទំព័រ៥៤-៥៥)

- **ធាលតែបក្សល្អ កម្មាភិបាលល្អ បក្ខជនល្អ ទើបសេដ្ឋកិច្ច យោធា សង្គមកិច្ច វប្បធម៌ បច្ចេកទេសផ្សេងៗល្អនឹងខ្លាំង។**

(សៀវភៅទង់បដិវត្តលេខពិសេស ខែមេសា ១៩៧៧ ទំព័រ១២) ។

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហមផ្ញើមក
**ទស្សនាវដ្តី"ស្វែងរកការពិត"**
ប្រអប់សំបុត្រលេខ ១១១០ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ឬតាមទូរសារលេខៈ (៨៥៥)(២៣)២១០៣៥៨
ឬ Email: dccam@bigpond.com.kh

# បន្ទាប់ពីលើកលែងទោស តើយុត្តិធម៌នៅអាចលង អៀង សារី បានទេ?



ដោយឡែកពីកផ្ទះនីតិវិធីយុត្តិធម៌ “សវនាការ” ប៉ុល ពត អៀង សារី ឆ្នាំ១៩៧៩ គ្មានសុពលភាពដោយហេតុថា រដ្ឋាភិបាលកម្ពុជានៅពេលនោះមិនទទួលស្គាល់ដោយច្បាប់អន្តរជាតិនិងសហប្រជាជាតិ ទោះបីការមិនទទួលស្គាល់របស់សហប្រជាជាតិមិនចាំបាច់ក្នុងការឲ្យអត្ថិភាពនៃរដ្ឋាភិបាល ឬរដ្ឋមួយមានធម្មានុរូបភាពក៏ដោយ តែគេអាចយកការមិនទទួលនេះទៅគាំទ្រនូវទឡ្ហីករណ៍មួយដែលថាសវនាការ ឆ្នាំ១៩៧៩ គ្មាននីត្យានុកូលភាព ឬ (គ្មានធម្មានុរូបភាព) ។ រដ្ឋាភិបាលស្របច្បាប់អន្តរជាតិពេលនោះគឺរដ្ឋាភិបាលខ្មែរក្រហមដែលក្រោយមកហៅថារដ្ឋាភិបាលចម្រុះត្រីភាគីកម្ពុជាប្រជាធិបតេយ្យដែលក្នុងរដ្ឋាភិបាលនេះ អៀង សារី គឺជាចៅហ្វាយធំម្នាក់ដែរ ។ ក្រោមច្បាប់អន្តរជាតិ អ្នកដែលត្រូវធ្វើជាព្រះរាជអាជ្ញាចោទប្រកាន់លើ អៀង សារី គឺរដ្ឋាភិបាលចម្រុះនេះតែម្តង គឺមិនមែនក្រុមប្រឹក្សាបដិវត្តន៍ដែលក្រោយមកហៅថាសាធារណៈរដ្ឋប្រជាមានិតកម្ពុជានោះទេ ។

ក្នុងក្រសែភ្នែកច្បាប់អន្តរជាតិ“សវនាការ”ឆ្នាំ១៩៧៩ គឺមិនខុសគ្នាពី “សវនាការ” អន្លង់វែង ឆ្នាំ១៩៩៧ នោះទេ ។ ក្នុងសវនាការក្រោយនេះ ប៉ុល ពត និងបនបរិវាររបស់ខ្លួនត្រូវ “តុលាការ” ប្រជាជនកាត់ទោសពីបទឃាតកម្មលើអតីតរដ្ឋមន្ត្រីការពារជាតិ សុន សេន (អ្វីដែលគួរកត់ចំណាំគឺថ្វីលី ទណ្ឌកម្មនេះពុំទាក់ទងនឹងបទល្មើសប្រល័យពូជសាសន៍ក៏ដោយ ក៏តុលាការនេះពុំបានសម្រេចមិនបញ្ជូន ប៉ុល ពត ឲ្យទៅប្រឈមមុខនឹងតុលាការអន្តរជាតិណាមួយឡើយ) ។ ដូច្នេះបើគេទទួលយកលទ្ធផលសវនាការឆ្នាំ១៩៧៩ គឺមិនខុសពីការទទួលយកសវនាការ ឆ្នាំ១៩៩៧ទេ ។ ត្រឡប់មកវិញបើគេមិនទទួលយកសវនាការឆ្នាំ១៩៩៧ទេ គេក៏មិនត្រូវទទួលយកសវនាការឆ្នាំ១៩៧៩ដែរ ព្រោះ“សវនាការ” ទាំងពីរមានរូបភាពនិងស្ថានភាពដូចគ្នា ។ រដ្ឋាភិបាលខុសច្បាប់ទាំងអស់គ្មានធម្មានុរូបភាព សវនាការនីត្យានុកូលភាព អៀង សារី រួចខ្លួន ។

ម្យ៉ាងទៀត តាមអំណានរបស់ខ្ញុំក្រឹត្យច្បាប់លេខ០១ (ច្បាប់កាត់ក្តី អៀង សារី ឆ្នាំ១៩៧៩) និងទណ្ឌកម្មឆ្នាំ១៩៧៩ ត្រូវទទួលនិរាករណ៍បន្ទាប់ពីកិច្ចព្រមព្រៀងប៉ារីសឆ្នាំ១៩៩១ ទទួលសច្ចាប័ន ពោលគឺបន្ទាប់ពីសន្និសញ្ញាចូលធរមានអ្វីៗនៅកម្ពុជាត្រូវចាប់ផ្តើមថ្មី អៀង សារី គ្មានទណ្ឌកម្មឆ្នាំ១៩៧៩ ដូច្នេះគ្មានរាជក្រឹត្យលើកលែងទោសឆ្នាំ១៩៩៦ ។ (ចំណាំៈ លើកលែងទោសគេផ្តល់ឲ្យទណ្ឌិត ឯនិទ្ទោសកម្មគេផ្តល់ឲ្យជនពុំទាន់មានទោស) ការលើកលែងទោសឲ្យ អៀង សារី តាមរយៈរាជក្រឹត្យឆ្នាំ១៩៩៦ អាចមានធម្មានុរូបភាពបាន បើការលើកលែងនេះបានធ្វើឡើងក្នុងរូបភាពផ្តល់និទ្ទោសកម្ម(គឺមុនតុលាការសម្រេច) នេះបើព្រះមហាក្សត្រទ្រង់មានអំណាចធម្មនុញ្ញក្នុងការវេទាននិទ្ទោសកម្ម ។ ទាក់ទងនឹងអំណាចនេះ បើតាមប្រពៃណីនិងការអនុវត្តជាក់ស្តែងនៃរដ្ឋធម្មនុញ្ញនៅអង់គ្លេស សហរដ្ឋអាមេរិក និងបារាំងប្រធានាធិបតីប្រមុខរដ្ឋ ឬគណៈរដ្ឋមន្ត្រីក្នុង(ករណីនៅអង់គ្លេសគឺគណៈរដ្ឋមន្ត្រីលើកលែងទោសបានក្នុងព្រះរម្យនាមមហាក្សត្រិយានី) មានអំណាចលើកលែងទោសនិងធ្វើនិទ្ទោសកម្មបាន ។ ខ្ញុំអាចនិយាយបានទាំងនេះគឺជាប្រពៃណីអង់គ្លេស បារាំង អាមេរិក តែប៉ុណ្ណោះ នៅក្នុងព្រះរាជាណាចក្រកម្ពុជាព្រះមហាក្សត្រទ្រង់ពុំមានរាជអំណាចដូចប្រទេសខាងលើបាន ។

ពាក្យដែលប្រើក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ទាក់ទងនៅនឹងអំណាចលើកលែងទោសរបស់ព្រះមហាក្សត្រពុំមានភាពប្រាកដច្បាស់លាស់ ។ ពាក្យប្រើក្នុងមាត្រា២៧គ “ស្តេចមានព្រះរាជសិទ្ធិបន្ធូបន្ថយទោសនិងលើកលែងទោស” ។ តាមន័យត្រង់នៃឃ្លានេះអាចនិយាយថា ស្តេចមានសិទ្ធិតែលើកលែងទោសដល់ជនណាដែលតុលាការបានសម្រេចឲ្យមានទោសរួចហើយគឺទណ្ឌិត ព្រោះថាជនដែលតុលាការមិនទាន់សម្រេចកាត់ទោសគឺពុំមានឲ្យស្តេចលើកលែងទេ ។ ក្នុងករណីនេះមានប្រទេសមួយចំនួនដែលស្តេចឬប្រមុខរដ្ឋមានត្រឹមតែសិទ្ធិលើកលែងទោសឲ្យទណ្ឌិត នេះមិនអាចមានន័យថាកម្ពុជាមិនអាចបង្កើតច្បាប់ស្តីពីនិទ្ទោសកម្មនេះទេ ។ ចំពោះក្រឹត្យលេខ២៨ក្រ ស្តីពីការលើក

លែងទោស ឬបន្ថយទោសឲ្យទណ្ឌិត(២០-០៦-៨៨) គឺអនុវត្តបានតែទៅលើទណ្ឌិតតែប៉ុណ្ណោះ ។ ម្យ៉ាងទៀត ក្រឹត្យលេខ២៨ក្រ នេះមិនអាចយកមកអនុវត្តក្រោយរដ្ឋធម្មនុញ្ញបានទេ ដោយក្រឹត្យនេះចេញដោយក្រុមប្រឹក្សារដ្ឋដែលជាផ្នែកមួយនៃអង្គនីតិប្រតិបត្តិនៃទោស ក្រោមរដ្ឋធម្មនុញ្ញថ្មីនេះគ្មានអំណាចចេញក្រឹត្យដែលមានអំណាចប្ញន័យជាច្បាប់បែបនេះឡើយ ។ លើចំណុចនេះរដ្ឋធម្មនុញ្ញខ្មែរគឺចុងពីរដ្ឋធម្មនុញ្ញបារាំង ។


អៀង សារី

ទោះបីជាការលើកលែងទោសឲ្យ អៀង សារី ពីទណ្ឌកម្មឆ្នាំ១៩៧៩សមតាមធម្មានុរូបភាពក៏ដោយ ក៏ អៀង សារី មិនអាចគេចរួចពីការចោទប្រកាន់បានទេ ព្រោះដូចសាស្ត្រាចារ្យ ស៊ីវ ម៉ាក្ស បានចង្អុលបង្ហាញបទប្រល័យពូជសាសន៍ដែលមកយកទៅដាក់ទោស អៀង សារី គឺមាននិយមន័យខុសពីនិយមន័យបទប្រល័យពូជសាសន៍ដែលបានចែងក្នុងអនុសញ្ញាស្តីពីការពារនិងប្រឆាំងអំពើប្រល័យពូជសាសន៍ ។

ដូច្នេះតាមច្បាប់គ្មានឧបសគ្គក្នុងការចោទប្រកាន់ អៀង សារី ពីបទប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋសង្គ្រាមឡើយ ។ ហើយក៏គ្មានអ្វីឃាត់ឃាំងការចោទប្រកាន់ អៀង សារី ពីបទល្មើសព្រហ្មទណ្ឌជាតិ (ឃាតកម្ម) ក្រោមច្បាប់ព្រហ្មទណ្ឌមុនឆ្នាំ១៩៧៥ (តែដើម្បីធ្វើដូច្នេះបានសភាជាតិត្រូវផ្តល់សច្ចាប័នជាថ្មីដល់ច្បាប់ព្រហ្មទណ្ឌនេះប្រយោជន៍ឲ្យច្បាប់នេះមានសុពលភាពជាថ្មី) ។

ដោយមិននិយាយពីធម្មានុរូបភាពនៃរាជក្រឹត្យលើកលែងទោស អៀង សារី ឆ្នាំ១៩៩៦ និងធម្មនុញ្ញនៃច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់(១៩៩៤)ច្បាប់ឆ្នាំ១៩៩៤ នេះហាមមិនឲ្យព្រះមហាក្សត្រមិនឲ្យរាជទានការលើកលែងទោសដល់មេដឹកនាំខ្មែរក្រហម ។ ដូច្នេះការលើកលែងទោសនេះគ្មាននីត្យានុកូលភាពទេ ហើយការលើកទោសគឺអាចជាការរំលោភច្បាប់ទាំងស្រុង ។ ទាក់ទងនឹងច្បាប់ឆ្នាំ១៩៩៤ នេះមានអ្នកឯកទេសកិច្ចការខ្មែរមួយចំនួនដូចជាបណ្ឌិត ស៊ីវ ហេឌ័រ បានធ្វើទន្សីករណ៍ថា អៀង សារី បានឃ្លាតចេញពីថ្នាក់ដឹកនាំ

ខ្មែរក្រហមតាំងពីឆ្នាំ១៩៩៣មកម្ល៉េះ គឺមួយឆ្នាំបន្ទាប់ពីច្បាប់ឆ្នាំ១៩៩៤នេះចូលជាធរមាន ។ ដូច្នេះមាត្រាស្តីពីការមិនឲ្យលើកលែងទោសនេះមិនគ្រប់ដណ្តប់លើ អៀង សារី ទេ ។ តែតាមទស្សនៈ អៀង សារី បាននៅតែជាមេដឹកនាំខ្មែរក្រហមឬយ៉ាងហោចណាស់ក៏ត្រូវបានសន្មតថាជាមេដឹកនាំម្នាក់ ។ ថ្វីបើច្បាប់ឆ្នាំ១៩៩៤ ពុំបានផ្តល់និយមន័យថាតើ «មេដឹកនាំ» ខ្មែរក្រហមជាអ្វីឬជានរណាក៏ដោយក៏មនុស្សភាគច្រើនឯកភាពថាទោះជា អៀង សារី បានចេញពីថ្នាក់ដឹកនាំពីឆ្នាំ១៩៩៣ ក៏ អៀង សារី ត្រូវបានសន្មតថា អៀង សារី នៅតែជាអ្នកដឹកនាំខ្មែរក្រហមម្នាក់ដែរ ។

ជាការពិតណាស់ថា ពេលដែល អៀង សារី បំបែកខ្លួន អៀង សារី ពុំបានចូលមកខាងរដ្ឋាភិបាលពេលនោះទេ ហើយពីឆ្នាំ១៩៩៣-១៩៩៦ អៀង សារី មិនមែនជាពលទោសាមញ្ញម្នាក់នោះឡើយ ។ អាចនិយាយបានទៀតថារាជការបំណែកថ្នាក់ដឹកនាំមិនមែនជាការចាត់ចេញពីថ្នាក់ដឹកនាំទេ ក្នុងក្រសែភ្នែកច្បាប់និងការណ៍ ។ ម្យ៉ាងទៀត សកម្មភាពរបស់ អៀង សារី ពីឆ្នាំ១៩៩៣-១៩៩៤ អាចផ្តល់នូវសេចក្តីសន្និដ្ឋានមួយបានថា អៀង សារី បានប្រព្រឹត្តបទល្មើសដែលបានចែងក្នុងច្បាប់ឆ្នាំ១៩៩៤ ។ បើពិនិត្យមើលនិយមន័យមាត្រា៤នៃច្បាប់ឆ្នាំ១៩៩៤ វិសាលភាពរបស់វាមានភាពទូលាយណាស់ នេះបើសិនជា «សវនាការ» និងទណ្ឌកម្មធ្វើឡើងក្រោយរដ្ឋប្រហារឆ្នាំ១៩៩៧ លើទ្រង់ រណឫទ្ធិ និងឧត្តមសេនីយ៍របស់ទ្រង់មានតម្លៃខ្លះក្នុងបរិបទនេះ ព្រោះកត្តានេះអាចជួយគាំទ្រទ្រឹស្តីដែលថា អៀង សារី ពុំអាចគេចពីទំនួលខុសត្រូវក្រោមច្បាប់ឆ្នាំ១៩៩៤បាន ។

សរុបមករាជក្រឹត្យឆ្នាំ១៩៩៦ ពុំមានជាសន្និកមូលប្បទានប័ត្រចំហរដូចមនុស្សមួយចំនួនយល់នោះទេ ។ អ្វីដែលត្រូវធ្វើដើម្បីទាញ អៀង សារី មកឲ្យទទួលខុសត្រូវគឺឆន្ទៈនយោបាយពីខាងរដ្ឋាភិបាលកម្ពុជាដើម្បីបើកឲ្យយុត្តិធម៌ធ្វើការលើ អៀង សារី ។

កត្តាមួយទៀត ចំពោះការលើកលែងទោស អៀង សារី គឺរាជក្រឹត្យឆ្នាំ១៩៩៦នេះ ត្រូវបានចុះហត្ថលេខា មុនទទួលការអនុម័តពីសភាជាតិ ។ តាមប្រវត្តិវិទូរបស់ព្រះករុណា គឺលោក ហ្វូលីយូ ហៀលជ្រេស ក្រោយពីបានចុះព្រះហត្ថលេខាហើយ ព្រះករុណាទ្រង់បានទទូចឲ្យសម្តេចក្រុមព្រះ និងលោក ហ៊ុនសែន ទទួលការអនុម័តពីភាគបីមកពីរដ្ឋសភាសិន ទើបនាំឲ្យរាជក្រឹត្យចូលធរមានបញ្ញត្តិ ឬប្រកាសជាសាធារណៈ ។

ការយក អៀង សារី មកកាត់ក្តីពេលនេះ នឹងមិនរំលោភវិធានកាត់ក្តីទ្វេ ដែលបានចែងក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិលនិងនយោបាយដោយហេតុថា÷

ក) បទឧក្រិដ្ឋដែល អៀង សារី ត្រូវចោទប្រកាន់ថាបានប្រព្រឹត្តនិង "សវនាការ" ឆ្នាំ១៩៧៩ កើតឡើងមុនកម្ពុជាផ្តល់សច្ចាប័នលើអនុសញ្ញាខាងលើ ។ អនុសញ្ញានេះពុំមានអនុភាពប្រតិសកម្មទេ ។

ខ) គ្មានសិទ្ធិណាមួយត្រូវបានរំលោភដោយកាត់ក្តី អៀង សារី ម្តងទៀតទេ ព្រោះលទ្ធផលសវនាការឆ្នាំ១៩៧៩ អៀង សារី ពុំបានរួចខ្លួនទេ តែត្រូវ **ផ្តន្ទាទោសប្រហារជីវិត** ។

ជាទ្រឹស្តី ការកាត់ក្តីថ្មី ចំណេញ អៀង សារី វិញទេ ព្រោះលទ្ធផលសវនាការថ្មីមិនអាចលើកពីលទ្ធផលឆ្នាំ១៩៧៩ កើតឡើយ ។ ម្យ៉ាងទៀតការបង្គាប់ឲ្យកាត់ក្តីថ្មីតែងតែត្រូវបានឡើងជាញឹកញយក្នុងប្រទេសប្រជាធិបតេយ្យ បើសិនជាការសន្ទនាដំបូងពុំយុត្តិធម៌ ឬមានបាតុភាពអសកម្ម ។ លើនេះទៅទៀតការចោទប្រកាន់ថ្មីលើ អៀង សារី ចំពោះបទល្មើសក្រោមអនុសញ្ញាព្រហ្មទណ្ឌនានា (ដូចបានពោលខាងលើ) ពុំមានជាការកាត់ក្តីទ្វេទេ ។

ធាតុសំខាន់មួយនៃការផ្សះផ្សាជាតិគឺការហ៊ានទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត ។ ប្រសិនបើ អៀង សារី ពុំបានប្រព្រឹត្តខុស ឬសម្លាប់មនុស្ស ចុះហេតុអ្វីបានជា អៀង សារី មិនឲ្យតុលាការឯករាជ្យមួយស្តាប់រឿងរបស់ខ្លួន?

ប្រសិនបើ អៀង សារី ចង់ឲ្យខ្មែរអភិវឌ្ឍដូចដែលខ្លួនបានអះអាង ចុះហេតុអ្វីបានជា អៀង សារី មិនឲ្យខ្មែរអភិឌ្ឍលើមាគ៌ាធម្មាធិបតេយ្យ ជាជាងមាគ៌ានិទ្ទណ្ឌធិបតេយ្យ?

ប្រសិនបើ អៀង សារី អះអាងថាខ្លួនជាអ្នកផ្សះផ្សាជាតិ និងស្រឡាញ់សន្តិភាព ចុះហេតុអ្វីបានជា អៀង សារី គំរាមជ្រមុជក្បាលខ្មែរចូលទៅក្នុងសង្គ្រាមស៊ីវិលវិញ រាល់ពេលមានការអំពាវនាវឲ្យខ្លួនទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនក្នុងអតីតកាល?

**ធូច ប៉ូរ៉ា**

**(តមកពីទំព័រទី១៦)** យើងយល់ថា ដើម្បីបិទនូវទំព័រខ្មៅងងឹតនេះឲ្យចប់នៅឆ្នាំ១៩៩៩ គឺមានព្រឹត្តិការណ៍ការងារច្រើននៅក្នុងដំណើរការរៀបចំយន្តការនេះ ជាពិសេសគឺថាការដែលប្តូរទស្សនទានពីតុលាការអន្តរជាតិ ឬពីតុលាការជាតិសុទ្ធសាធមកកាន់គោលការណ៍មួយដែលយើងបានមកដល់ការឈានរកគ្នានូវជំហរពីរដែលខុសគ្នា គោលការណ៍នោះពីមុនគឺម្ខាងនិយាយពីតុលាការអន្តរជាតិ ម្ខាងទៀតនិយាយពីតុលាការជាតិ ដូច្នេះគោលការណ៍ថ្មីមួយដែលធ្វើឲ្យមានការសម្រុះសម្រួលគ្នាបាននោះ គឺគោលការណ៍ដែលយើងដាក់ឈ្មោះថាគោលការណ៍ស្តីអំពីការកាត់សេចក្តីដែលមានចរិតលក្ខណៈអន្តរជាតិ ។ ដូច្នេះគេក៏ឈប់ទាមទារ គេក៏បានឈានថយក្រោយមួយជំហានដែរ ហើយគេឈប់ទាមទារតុលាការអន្តរជាតិ គេនិយាយអំពីការកាត់សេចក្តីដែលមានចរិតលក្ខណៈអន្តរជាតិ ។

◆ នៅក្នុងខែមេសា ឆ្នាំ១៩៩៩នេះ គឺមានជំនួបរវាងព្រឹទ្ធសភា ចន ឃែរី និងសម្តេចនាយកមន្ត្រី ហ៊ុន សែន ហើយបានលើកជាគោលការណ៍តុលាការជាតិដោយមានការចូលរួមពីចៅក្រមបរទេស ។

◆ ខែឧសភា យើងបានអញ្ជើញក្រុមអ្នកច្បាប់ពីប្រទេសបារាំង ដើម្បីជួយពិចារណា ជួយគិតពីបញ្ហានេះ ហើយប្រទេសបារាំងក៏បានបញ្ជូនក្រុមអ្នកច្បាប់មួយក្រុមដែលជាអ្នកច្បាប់កម្រិតខ្ពស់របស់គេដែលធ្វើការនៅតុលាការកំពូល មានមេធាវីចាស់ទុំដែលធ្វើការនៅតុលាការផ្សេងៗមកកម្ពុជាផងដែរ ។ ◆ ខែឧសភា ឆ្នាំ១៩៩៩ យើងបានពិគ្រោះពិភាក្សាជាមួយនឹងក្រុមអ្នកច្បាប់បារាំង ។ ◆ ខែសីហា ឆ្នាំ១៩៩៩ គឺរាជរដ្ឋាភិបាលបានបង្កើតជាក្រុមការងាររបស់រាជរដ្ឋាភិបាល គឺការងារនេះដែលមានខ្លួនទូលបង្គំខ្ញុំបាទជាប្រធាន ។ ◆ នៅខែសីហា ឆ្នាំ១៩៩៩ ក្រុមការងារចាប់ផ្តើមធ្វើការងារនេះដោយរៀបចំសេចក្តីព្រាងច្បាប់ជាពង្រាង ដែលពង្រាងនេះធ្វើជាច្រើនលើក ហើយពង្រាងលើកទី១ត្រូវបានរៀបចំហើយនៅខែសីហា ឆ្នាំ១៩៩៩ ហើយដាក់ជូនទៅឲ្យគណៈប្រតិភូរបស់អង្គការសហប្រជាជាតិដែលដឹកនាំដោយឯកឧត្តម រ៉ាក់ ហ្សាក់គ្លីន ដែលលោកជាអនុប្រធានរបស់ឯកឧត្តម ហែន កូរែល ដែលជាអ្នកទទួលបន្ទុកខ្ពស់បំផុតខាងច្បាប់របស់អង្គការសហប្រជាជាតិដែលមានឋានៈជាអគ្គលេខាធិការរងនោះ ហើយលោក ហ្សាក់គ្លីន គឺគាត់ជាអ្នកនៅបន្ទាប់ពីលោក ហែន កូរែល នោះ ។ ◆ ខែសីហា ឆ្នាំ១៩៩៩ លោក ហ្សាក់គ្លីន បានដឹកនាំគណៈប្រតិភូមកពីលេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិមក ។ យើងបានដាក់ពង្រាងរបស់យើងជូនលោក បានន័យថាពង្រាងនេះបានធ្វើហើយតាំងពីឆ្នាំ១៩៩៩ ហើយពង្រាងទីមួយនេះមិនមែនជារបស់គេទេវាជារបស់យើង ជារបស់អ្នកច្បាប់កម្ពុជាដែលធ្វើដោយមានការពិភាក្សាជាមួយនឹងអ្នកជំនាញការផ្សេងៗដែរ ។

សូមទូលថ្វាយនិងជម្រាបជូនអង្គសភាដែរ គឺថាយើងមានការចូលរួមពីអ្នកជំនាញការបច្ចេកទេសច្បាប់មកពីប្រទេសបារាំងផង ឥណ្ឌាផង ពីរុស្ស៊ីផង ហើយពីសហរដ្ឋអាមេរិកដែរ ហើយសហរដ្ឋអាមេរិកបានដើរតួនាទីច្រើនដែរក្នុងការសម្របសម្រួល ជាពិសេសសម្របសម្រួលរវាងយើងជាមួយនឹងអង្គការសហប្រជាជាតិ ។ ដូច្នេះហើយគឺមានការជជែកគ្នា ការចរចាច្រើន ហើយក៏សូមបញ្ជាក់នូវចំណុចនេះដែរគឺថាពង្រាងទី១ត្រូវបានយើងជាអ្នករៀបចំ ហើយដាក់ជូនឲ្យគណៈប្រតិភូលោក ហ្សាក់គ្លីន ពិនិត្យ ។ ព្រោះថាអង្គការសហប្រជាជាតិបានបញ្ជូនគណៈប្រតិភូមកបីដង ដឹកនាំដោយអ្នកច្បាប់ខ្ពស់បំផុតរបស់អង្គការសហប្រជាជាតិ ហើយម្តងប្រហែលមួយសប្តាហ៍ ក្នុងមួយក្រុមមានគ្នាប្រហែល៧ទៅ៨នាក់ ដែលជាអ្នកច្បាប់ចំណានៗរបស់គេ ហើយគឺលើកទី១ គឺនៅខែសីហា ឆ្នាំ១៩៩៩ នេះគឺគេបានទទួលពិនិត្យគម្រោងរបស់យើង នៅពេលនោះគឺថាមិនទាន់ត្រូវគ្នាទេ នៅចំណុចដែលខ្វែងគ្នាធំគឺថាលោក ហ្សាក់គ្លីន គាត់ទាមទាររកចៅក្រមបរទេសភាគច្រើន ហើយយើង យើងទាមទារថាចៅក្រមកម្ពុជាត្រូវតែភាគច្រើន ដូច្នេះបានជជែកគ្នាត្រូវគ្នាលើចំណុចមួយចំនួន ចំណុចមូលដ្ឋានដែលនៅតាំងគឺចំនួននៃចៅក្រមនេះ ។ ◆ នៅខែកញ្ញា ១៩៩៩ នេះជាធម្មតានៅខែកញ្ញា គឺមានសម័យប្រជុំមហាសន្និបាតអង្គការសហប្រជាជាតិ ដែលសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន តែងតែដឹកនាំគណៈប្រតិភូទៅចូលរួមប្រជុំ ដូច្នេះនៅពេលនោះយើងក៏បានជួបប្រាស្រ័យជាមួយឯកឧត្តមអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ នៅពេលនោះសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រគល់ជូននូវអនុស្សារណៈមួយ ដែលមានសំណើ៣ចំណុចដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងឱសានុវាទដែរ ។ ◆ ចំណុចទី១ គឺយើងលើកឡើងថា អង្គការសហប្រជាជាតិអាចជួយរួមចំណែកក្នុងការជួយផ្តល់ចៅក្រមផងនិងផ្តល់អ្នកជំនាញ ដើម្បីជួយកែសម្រួលសេចក្តីព្រាងច្បាប់យើងឲ្យទៅជាអ្វីដែលគេលើកឡើងថា ឲ្យជឿទុកចិត្ត ឲ្យសមស្របទៅនឹងនីតិវិធីដែលសមស្របនូវការទុកចិត្តរបស់សហគមន៍អន្តរជាតិ ហើយនឹងផ្តល់ចៅក្រមឲ្យជួយចូលរួមកាត់សេចក្តីជាមួយចៅក្រមកម្ពុជាផង ។ ◆ លទ្ធភាពទី២ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិជួយត្រឹមតែផ្តល់អ្នកជំនាញការមកជួយធ្វើច្បាប់បានហើយ ទុកឲ្យចៅក្រមកម្ពុជាកាត់ក្តីដោយខ្លួនឯង ។ ◆ លទ្ធភាពទី៣ គឺអង្គការសហប្រជាជាតិនៅស្ងៀម ទុកឲ្យកម្ពុជាធ្វើខ្លួនឯង ទាំងច្បាប់ ទាំងចៅក្រមទាំងអស់ ។

នៅពេលនោះឯកឧត្តមអគ្គលេខាធិការអង្គការសហប្រជាជាតិគឺមិនបានឆ្លើយតបទេ គឺស្នើឲ្យមានចាត់តាំងជាក្រុមការងារបន្តការងារនេះ ពេលនោះគឺខ្លួនខ្ញុំត្រូវបានចាត់តាំងជាតំណាងរាជរដ្ឋាភិបាល ហើយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិគឺចាត់តាំងលោក ហែន កូរែល ដែលជាអគ្គលេខាធិការរងនិងជាអ្នកប្រធានខាងច្បាប់ ។ នៅពេលនោះឯកឧត្តម ហែន កូរែល បានបញ្ជាក់ប្រាប់យើងថា មិនទាន់ឆ្លើយបានទេ នូវសំណួរទាំងបីចំណុចនេះ គឺត្រូវការស្វែងយល់ពីគ្នាសិនមុននឹងឯកឧត្តមជូនយោបល់ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ដូច្នេះគេបានសួរខ្ញុំវិញថា ចុះបើទៅកម្ពុជាវិញ តើឯកឧត្តមធ្វើអ្វីក្នុងការងារនេះ? ខ្ញុំបានជម្រាបជូនឯកឧត្តម ហែន កូរែល ថា ខ្ញុំទៅកម្ពុជាវិញ ទី១ខ្ញុំបន្តធ្វើច្បាប់ហើយខ្ញុំនឹងដាក់ជូនរាជរដ្ឋាភិបាល រដ្ឋាភិបាលសម្រេចហើយនឹងបញ្ជូនទៅរដ្ឋសភា រដ្ឋសភាសម្រេចហើយគឺតាមនីតិវិធីទៅព្រឹទ្ធសភា ហើយបន្ទាប់មកដោយសារនេះជាច្បាប់ក្របខ័ណ្ឌច្បាប់ Organic គឺត្រូវបញ្ជូនជូនទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្រោយមកបានព្រះរាជក្រមចូលជាធរមាន យើងខ្ញុំអនុវត្តអ្វីដែលខ្ញុំជម្រាបជូនឯកឧត្តមអគ្គលេខាធិការរង គឺជម្រាបដូចខាងលើ គឺយើងធ្វើដូចខាងលើ ប្រសិនណាបើអង្គការសហប្រជាជាតិមិនចូលរួមគឺយើងនឹងធ្វើ ។ ដូច្នេះនៅពេលនោះឯកឧត្តមអគ្គលេខាធិការរងលោកបានស្នើមកទូលបង្គំវិញថា ឯកឧត្តមធ្វើដូច្នេះក៏ធ្វើចុះ តែមុននឹងជូនសេចក្តីព្រាងច្បាប់ដែលក្រុមការងាររបស់ឯកឧត្តមធ្វើនេះទៅជូនរដ្ឋាភិបាល សូមមេត្តាឲ្យយើងខ្ញុំដឹងផង ហើយយើងខ្ញុំកំពុងតែគិតថាតើត្រូវធ្វើដូចម្តេច? ។

◆ សុំទាក់ទាញការចាប់អារម្មណ៍ដែរថា ការងារច្បាប់នេះមិនមែនជាការងាយស្រួលចេះតែថាទេ សូម្បីតែកម្រិតអ្នកច្បាប់ខ្ពស់បំផុតរបស់អង្គការសហប្រជាជាតិហើយក្តី រៀបនឹងឆ្លើយសំណួរម្តងៗគឺគេសុំផ្អាកពិគ្រោះគ្នាជាមួយអ្នកច្បាប់សិន គឺពិគ្រោះគ្នាហ្មត់ចត់ណាស់មុននឹងឆ្លើយមួយៗ មិនមែនចេះតែធ្វើទេ គឺផ្អែកលើគោលការណ៍ច្បាប់ ។ យើងសួររឿងអ្វីមួយគេសុំឈប់ផ្អាកពិគ្រោះគ្នាសិន ហើយយើងក៏ដូច្នោះដែរ ចំណុចខ្លះគឺត្រូវពិគ្រោះគ្នាឲ្យបានហ្មត់ចត់បានឆ្លើយជាមួយគេ គឺធ្វើទៅសុទ្ធតែគោរពគោលការណ៍ គោរពផលប្រយោជន៍អង្គការសហប្រជាជាតិ គោរពអគ្គលេខាធិការ ហើយចំពោះយើងគឺគោរពផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះការចរចានេះមិនមែនជាការឆាប់ទេ គឺយូរណាស់ ។ ដូច្នេះនៅខែកញ្ញា ឆ្នាំ១៩៩៩ គឺយើងក៏បានទទួលសំណើថា សុំឲ្យមានការបន្តការងាររវាងក្រុមការងារជាមួយនឹងសហគមន៍អន្តរជាតិ ។ សូមឲ្យបើកចំហការចរចា ពីព្រោះថា នៅពេលដែលយើងលើកចំណុច៣នេះគឺថាការងារដូចជាយឺតបន្តិចហើយ មិនទាន់មានចំណុចណាដែលត្រូវដោះស្រាយយ៉ាងណា ។ ដូច្នេះបានជានៅខែកញ្ញានេះយើងបានទទួលសំណូមពរថាឲ្យបើកការចរចាឲ្យទូលាយដើម្បីបន្តការចរចានេះតទៅទៀត ។

◆ នៅខែតុលា ឆ្នាំ១៩៩៩នេះ យើងបានចាប់ផ្តើមបន្តការងារវិញជាមួយមន្ត្រីជាន់ខ្ពស់បំផុតរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិកដែលលោកខំធ្វើជាអាជ្ញាកណ្តាល ដែលលោកបានជួយសម្របសម្រួលអង្គការសហប្រជាជាតិ ។ ហើយនៅខែធ្នូ ឆ្នាំ១៩៩៩នេះ យើងបានទទួលក្រុមជំនាញអ្នកច្បាប់ជាន់ខ្ពស់ពីឥណ្ឌា រុស្ស៊ី និងពីបារាំង មិនមែនទទួលថ្ងៃជាមួយគ្នាទេ គឺទទួលថ្ងៃផ្សេងៗគ្នា ដើម្បីពិគ្រោះយោបល់ឲ្យគេផ្តល់យោបល់ថាតើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីកុំឲ្យខុសគោលការណ៍ច្បាប់ដែលគេយល់ឃើញ ។ ដូច្នេះអ្នកជំនាញការរុស្ស៊ីលោកជូនយោបល់តាមការយល់ឃើញរបស់គេ ។ ឥណ្ឌាលោកជូនយោបល់តាមការគិតគូររបស់លោក បារាំងក៏ជូនយោបល់តាមការគិតគូររបស់គេដែរ គេយកចិត្តទុកដាក់បញ្ហានេះ គឺគេរៀបចំជាក្រុមអ្នកច្បាប់មួយ ។ ◆ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៩ នេះគឺក្រុមការងារបានបញ្ចប់សេចក្តីព្រាងច្បាប់ជាលើកទី២ ពង្រាងទី២ ដែលពង្រាងនេះមានន័យច្រើនណាស់គឺចប់នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៩ នឹងដាក់មកគណៈរដ្ឋមន្ត្រី នៅថ្ងៃទី២៤ ធ្នូ ឆ្នាំ១៩៩៩ នេះជាការងារដែលបានវិវត្តនៅក្នុងឆ្នាំ១៩៩៩ គឺថាឆ្នាំ២០០០ នៅថ្ងៃ៦ មករា ឆ្នាំ២០០០នេះ គឺគណៈរដ្ឋមន្ត្រីឆ្លងជាលើកទី២ ប្រជុំជាលើកទីពីរដោយមានវិសោធនកម្មខ្លះ ។ ◆ នៅថ្ងៃ១០ មករា មានទស្សនកិច្ចរបស់ឯកឧត្តមនាយករដ្ឋមន្ត្រីជប៉ុន អូប៊ូជី អតីតនាយករដ្ឋមន្ត្រីជប៉ុន ក្នុងនោះក៏មានពិភាក្សាពីបញ្ហានេះដែរ ។ ◆ ថ្ងៃ១៤ មករា ឆ្នាំ២០០០ រាជរដ្ឋាភិបាលបានធ្វើការកែសម្រួលម្តងទៀតដោយអនុញ្ញាតឲ្យមានសហចៅក្រមស៊ើបអង្កេត ។ ពង្រាងលើកទី២ដែលយើងដាក់ឆ្លងគណៈរដ្ឋមន្ត្រីមានចៅក្រមស៊ើបអង្កេតតែមួយទេ ព្រោះយើងលើកឡើងថាវចនាសម្ព័ន្ធរបស់គេនៅខាងក្រៅ គេអត់មានចៅក្រមស៊ើបអង្កេត ដូច្នេះកម្ពុជានៅអនុវត្តតាមប្រព័ន្ធ romano-germanique ។ យើងមានចៅក្រមស៊ើបអង្កេត ដូច្នេះអ្នកខាងក្រៅមិនបាច់ធ្វើទេ ព្រោះថាអស់លោកមិនធ្លាប់ធ្វើទុកឲ្យកម្ពុជាធ្វើដោយខ្លួនឯង ។ ប៉ុន្តែនៅថ្ងៃ១៤ មករានេះ យើងបានកែសម្រួលបញ្ហានេះ ហើយនៅថ្ងៃទី១៨ មករា ទូលបង្គំខ្ញុំបាទបានថ្វាយពង្រាងនេះ ទៅសម្តេចព្រះប្រធានរដ្ឋសភា ។ **(នៅមានត)**

# កំណត់ហេតុស្តីអំពីអង្គប្រជុំរបស់សភាជាតិនៃព្រះរាជាណាចក្រកម្ពុជា
# លើសេចក្តីព្រាងច្បាប់ស្តីពី
## ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
## ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

**(តពីលេខមុន)** ហើយចូលជាធរមាននោះបានន័យថាជាការព្រមព្រៀងរវាងយើងជាម្ចាស់ផ្ទះ ហើយនិងអ្នកដែលគេជួយរៀបចំពីខាងក្រៅពោលគឺអង្គការសហប្រជាជាតិ ។ ដូច្នេះសេចក្តីព្រាងច្បាប់ដែលយើងធ្វើគឺអាចចាត់ទុកថាជាសេចក្តីព្រាងច្បាប់ដែលមានលក្ខណៈថ្មីហើយ គោលការណ៍ទាំងឡាយដែលយើងធ្វើដែលទូលបង្គំខ្ញុំបាទនឹងទូលថ្វាយនិងជម្រាបជូននៅពេលខាងក្រោយទៀត និងជាបន្តបន្ទាប់នេះគឺជាគោលការណ៍ថ្មីដែលច្បាប់នៅលើសកលលោក ដែលជាច្បាប់អន្តរជាតិ ច្បាប់បរទេស ទោះជាអ្នកច្បាប់ធំឬច្បាប់តូចក៏ដោយ គឺអត់ដែលឃើញអត់ដែលឮ អត់ដែលស្គាល់ទេ ។ គឺជាករណីដែលចេញពីកម្ពុជា ហើយសព្វថ្ងៃនេះបើតាមពត៌មានជាក់ស្តែងគួរឲ្យជឿបានដែលយើងទទួលជាបន្តបន្ទាប់គឺថា ក្នុងក្រុមប្រឹក្សាសន្តិសុខគេចាប់ផ្តើមនិយាយអំពីគំរូតុលាការនៅកម្ពុជា ។ ថ្វីដ្បិតតែច្បាប់យើងមិនទាន់ធ្វើចប់ផង យើងមិនទាន់រៀបចំក្បាលម៉ាស៊ីនតុលាការចេញផង ប៉ុន្តែតាមការជជែកគ្នាពិភាក្សាឯកភាពគ្នាលើគោលការណ៍ធំៗជាមូលដ្ឋាន គេបានយល់ថាគោលការណ៍នេះប្រើប្រាស់បានគេទទួលយកជាការបានហើយគេមាននិយាយមានបញ្ចេញមតិនៅក្នុងក្រុមប្រឹក្សាសន្តិសុខនិងនិយាយអំពីគំរូតុលាការនៅកម្ពុជា ។ នេះជាចំណុចទី១ ដែលទូលបង្គំខ្ញុំបាទបានស្នើសុំនិងលើកជាចំណុចជាក់ស្តែងនៅក្នុងបទអត្ថាធិប្បាយនេះ ។

ចំណុចទី២ ទូលបង្គំខ្ញុំបាទសូមលើកឡើងអំពីទស្សនទាន និងគោលការណ៍សំខាន់ៗនៃសេចក្តីព្រាងច្បាប់នេះនៅក្នុងការរៀបរាប់ ជាក់ស្តែងគឺអាចនិយាយបានថាយើងមានគោលការណ៍ធំចំនួន៣ដើម្បីរៀបចំជាតុលាការដែលលើកឡើងថាជាយន្តការនេះ ។ គោលការណ៍ទី១ គឺគោលការណ៍គោរពយុត្តិធម៌ ការស្វែងរកយុត្តិធម៌ ឯកឧត្តមទេសរដ្ឋមន្ត្រី គាត ឈន់ ក៏បានលើកឡើងនូវយោបល់មួយចំនួនឃើញថាដើម្បីវិនិច្ឆ័យអតីតកាលគឺការវិនិច្ឆ័យអតីតកាលពេលខ្លះក៏មានការខ្វែងយោបល់គ្នារវាងអ្នកស្រាវជ្រាវរវាងអ្នកច្បាប់រវាងអ្នកនយោបាយ ហើយពេលខ្លះក៏មានការឯកភាពគ្នា ប៉ុន្តែអតីតកាលនេះដែលយើងកំពុងនិយាយគ្នានេះ ទូលបង្គំខ្ញុំបាទក៏យល់ឃើញដូចឯកឧត្តមទេសរដ្ឋមន្ត្រី គាត ឈន់ ដែរ គឺថាយើងងាយយល់គ្នាបាន ទោះជាអតីតកាល ដ៏ខ្មៅងងឹតដែលទាំងអស់គ្នា ទាំងក្មេង ទាំងចាស់ ទាំងស្ត្រី ទាំងបុរស ទាំងអ្នកនយោបាយ ទាំងអ្នកច្បាប់ ទាំងអ្នកស្រាវជ្រាវ ទាំងអ្នកសិក្សា សុទ្ធតែថ្កោលទោសថាជាអំពើឧក្រិដ្ឋកម្ម ហើយដែលយើងដាក់ឈ្មោះថាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ដូច្នេះចំណុចទី១ ជាគោលការណ៍ធំទី១នេះ គឺការដែលយើងខិតខំដើម្បីផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ផ្តល់យុត្តិធម៌ដល់ប្រជាពលរដ្ឋកម្ពុជាផ្តល់យុត្តិធម៌ដល់ប្រជាជាតិកម្ពុជា ហើយលើសពីនេះទៅទៀតគឺជាការរួមចំណែកយ៉ាងសំខាន់ដល់មនុស្សជាតិដល់គោលការណ៍មនុស្សធម៌នៅលើសកលលោកទាំងមូលដែលគេត្រូវការថ្កោលទោសអំពើប្រល័យពូជសាសន៍ ថ្កោលទោសឧក្រិដ្ឋកម្ម ហើយទប់ស្កាត់អំពើប្រល័យពូជសាសន៍នេះកុំឲ្យកើតមានបានទៀត ។ ដូច្នេះការដែលយើងនូវចងចាំការដែលយើងធ្វើរៀបចំជាការកាត់ទោសនេះក៏ជាជំហានមួយយ៉ាងជាក់ស្តែង ដើម្បីផ្តល់យុត្តិធម៌ផងដើម្បីបញ្ជាក់នូវការចងចាំរបស់យើងផង ព្រោះថាការចងចាំនេះមានផលប្រយោជន៍ធំណាស់ មានផលប្រយោជន៍ត្រង់ណាគឺមានផលប្រយោជន៍ត្រង់រួមចំណែកទប់ស្កាត់មិនឲ្យឧក្រិដ្ឋកម្មរបៀបនេះកើតមានឡើងបានទៀតនៅកម្ពុជាជាពិសេស ហើយក៏អាចទប់ស្កាត់រួមចំណែកដល់ការទប់ស្កាត់ឧក្រិដ្ឋកម្មរបៀបនេះ បាតុភាពអាក្រក់របៀបនេះមិនឲ្យកើតមានឡើងនៅប្រទេសផ្សេងៗឬក៏នៅពិភពលោកដែរ ។ បើយើងរួមចំណែកយើងមិនអាចទប់ស្កាត់បានមួយរយភាគរយទេ ប៉ុន្តែជាការរួមចំណែកមួយយ៉ាងសំខាន់ដែលទូលបង្គំខ្ញុំបាទយល់ឃើញថា អ្នកច្បាប់ក្តី អ្នកនយោបាយក្តីអ្នកសិក្សាស្រាវជ្រាវក្តី នឹងស្វែងយល់ នឹងស្រាវជ្រាវ នឹងសិក្សា នឹងរៀនសូត្រអំពីគំរូកម្ពុជានេះ អំពីអ្វីដែលយើងរៀបចំធ្វើនេះ ។នេះជាចំណុចទី១ ជាគោលការណ៍ទី១ដែលយើងលើកឡើង គឺថាគោលការណ៍រកយុត្តិធម៌ដើម្បីបិទនូវទំព័រប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតដែលបានកើតមាននៅកម្ពុជា ។ គោលការណ៍ទី២ គឺគោលការណ៍រក្សាសន្តិភាព រក្សាស្ថិរភាពនយោបាយ រក្សាឯកភាពជាតិដែលកម្ពុជាទើបនឹងទទួលបាន ។ ទូលបង្គំយល់ថាគ្រប់មជ្ឈដ្ឋានទាំងអស់នៅកម្ពុជា នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងក៏សុទ្ធតែអបអរសាទរនូវសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់សង្គមដែលយើងខិតខំរកមកបាន បើយើងប្រៀបធៀបសភាពការណ៍សព្វថ្ងៃទៅនឹងសភាពការណ៍ក្នុងរយៈពេលមុននេះ ។ ទោះបីយើងមិនទាន់បានសណ្តាប់ធ្នាប់សង្គមមួយរយភាគរយ សន្តិសុខ មួយរយភាគរយ សន្តិភាព មួយរយភាគរយ គឺគ្មានប្រទេសណារកបានទេ ប៉ុន្តែយើងក៏មាន

មោទនភាពដែលយើងបានឈានមកមុខយ៉ាងជាក់ស្តែងនៅក្នុងដំណើរការនៃការពង្រឹងស្ថិរភាពនយោបាយ ពង្រឹងសន្តិភាព ពង្រឹងសន្តិសុខនៅកម្ពុជា ។ ហើយនេះជាអ្វីដ៏ថ្លៃថ្លាបំផុតសម្រាប់មាតុភូមិកម្ពុជាជាទីស្នេហា ព្រោះបើយើងចង់មើលឃើញរឿងហ្នឹង យើងចង់គិតរឿងហ្នឹងគឺងាយយល់ណាស់ បើយើងប្រៀបធៀបកម្ពុជាទៅនឹងប្រទេសជិតខាងកាលពី៣០ឆ្នាំមុនឬ៤០ឆ្នាំមុន យើងនឹងឃើញថារាជាណាចក្រ កម្ពុជាគឺស្ថិតក្នុងកម្រិតអភិវឌ្ឍប្រហាក់ប្រហែលទៅនឹងប្រទេសជិតខាងរបស់យើង ថៃ សាំងហ្គាពួរ ម៉ាឡេស៊ី ឥណ្ឌូណេស៊ី ប្រ៊ុយ តៃវ៉ាន់ កូរ៉េ ប៉ុន្តែឥឡូវនេះយើងមិនអាចប្រៀបធៀបទៅគេបានទេ យើងក្រីក្រជាងគេឆ្ងាយណាស់ យើងស្ថិតនៅក្នុងវង្វង់ប្រទេសដែលគេហៅថា LDC (Least Developed Country) ប្រទេសដែលអភិវឌ្ឍតិចជាងគេ ហើយមានមូលហេតុច្រើន ប៉ុន្តែមូលហេតុធំជាងគេគឺសុទ្ធតែដឹងទាំងអស់គ្នា មកពីយើងមានសង្គ្រាមស៊ីវិល មកពីយើងមានអស្ថិរភាពនយោបាយ មកពីយើងគ្មានសន្តិភាព ដូច្នេះហើយយើងកាន់តែក្រទៅគេកាន់តែមានឡើង ដូច្នេះសព្វថ្ងៃមិនអាចប្រៀបធៀបយើងជាមួយគេទេ បើយើងគិតពីគេហៅថាស្ថានភាពនៃការអភិវឌ្ឍនោះ ។ ដូច្នេះទូលបង្គំខ្ញុំបាទយល់ឃើញថាទាំងអស់គ្នាសុទ្ធតែវាយតម្លៃខ្ពស់ណាស់ចំពោះសន្តិភាព ស្ថិរភាព ចំពោះសន្តិសុខ ចំពោះសណ្តាប់ធ្នាប់សង្គមដែលយើងខិតខំបានមកនេះហើយទទួលបានមកនេះ ដូច្នេះការថែរក្សាសន្តិភាព ការថែរក្សាសន្តិសុខជាភារកិច្ចដ៏ខ្ពង់ខ្ពស់របស់គ្រប់ស្ថាប័ននៅកម្ពុជារបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់ៗរូបដែលយើងវាយតម្លៃថា មានតម្លៃស្មើនឹងអាយុជីវិត ដូច្នេះយើងធ្វើអ្វីក៏ដោយគឺយើងមិនត្រូវឲ្យប៉ះពាល់ទៅដល់ សន្តិភាព ស្ថិរភាពដែលយើងរកបានមកនេះគឺមុននឹងយើងធ្វើការងារធំនេះយើងបានគិតគូរ យើងបានរៀបចំជាគោលការណ៍ច្បាស់លាស់របស់យើង ហើយឯកឧត្តម ឈួរ លាងហួត ដែលបានលើកឡើងគឺអ្នកខ្លះគេជឿថាយូរ យូរក៏ជាការងារលំបាក ជាការងារដែលត្រូវស្វែងយល់គ្រប់ជ្រុងជ្រោយ ជាការងារដែលត្រូវរកឲ្យបាននូវការឯកភាពគ្នារកឲ្យបាននូវការដែលថាកុងសង់ស៊ីស (Concensus) ត្រូវរ៉ូវគ្នាដោយឈរលើដោយគោរពផលប្រយោជន៍ខ្ពង់ខ្ពស់របស់ប្រទេសជាតិ ។ នេះជាការលំបាកមិនមែនជាការស្រួលទេ បើយើងធ្វើដោយពុំគិតគូរការណ៍អ្វីទាំងអស់លឿនណាស់ ប៉ុន្តែបើយើងធ្វើដោយថ្លឹងថ្លែងឲ្យគ្រប់ជ្រុងជ្រោយនោះជាការដែលមិនអាចធ្វើបានតាមចិត្តយើងចង់ទេ ប៉ុន្តែយើងដើរមកមុខយើងឈានមកមុខ ដូច្នេះចំណុចទីពីរនេះទូលបង្គំខ្ញុំបាទយល់ឃើញថាគឺជាចំណុចដែលនឹងមានការគាំទ្រយ៉ាងច្បាស់លាស់ ហើយយ៉ាងសកម្មអំពីសភាដ៏ខ្ពង់ខ្ពស់អំពីប្រជាពលរដ្ឋគ្រប់ៗរូបសុទ្ធតែត្រូវការនូវស្ថិរភាពនយោបាយ ត្រូវការនូវសន្តិភាព ត្រូវការនូវសន្តិសុខ ។ គោលការណ៍ទី៣គឺគោលការណ៍នៃការគោរពអធិបតេយ្យភាពជាតិ ។ ដូចដែលទូលបង្គំខ្ញុំបាទបានលើកឡើងអំពីចឹងគឺថានៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ គោលការណ៍ធំជាងគេ ចម្បងជាងគេគឺការគោរពឯករាជ្យអធិបតេយ្យភាពបូរណភាពទឹកដីនេះ ។ ដូច្នេះការដែលយើងលើកឡើងអំពីគោលការណ៍គោរពអធិបតេយ្យភាពជាតិជាការសមស្របជាការត្រឹមត្រូវ ហើយដែលយើងត្រូវតែខិតខំតស៊ូនៅក្នុងន័យនេះ ។ អ៊ីចឹងសួរថាយើងនិយាយពីការគោរពអធិបតេយ្យភាពជាតិ អ៊ីចឹងនៅក្នុងការដែលយើងធ្វើសេចក្តីព្រាងច្បាប់នេះតើចំណុចណាខ្លះដែលបញ្ជាក់នូវការគោរពអធិបតេយ្យភាពជាតិ ព្រោះថាការចរចាដូចដែលទូលបង្គំខ្ញុំបាទបានលើកឡើងអ៊ីចឹង យើងត្រូវគោរពផលប្រយោជន៍គេមួយចំនួន គេត្រូវគោរពផលប្រយោជន៍យើងមួយចំនួន ។ ដូច្នេះមានចំណុច៣ជាក់ស្តែងដែលទូលបង្គំខ្ញុំបាទសូមលើកឡើងថាវាជាការដែលភាគីចរចាគោរពបាននូវគោលការណ៍អធិបតេយ្យភាពជាតិកម្ពុជា ។ ចំណុចទី១គឺការ...បញ្ហាចៅក្រមអ៊ីចឹង យើងលើកឡើងថាអធិបតេយ្យភាពជាតិយើងម៉េចឲ្យចៅក្រមបរទេសមកកាត់សេចក្តីនៅកម្ពុជា ចំណុចនេះជាចំណុចរសើប ហើយដែលទូលបង្គំខ្ញុំបាទសូមធ្វើការអត្ថាធិប្បាយដូចតទៅនេះ គឺថាយើងទទួលយកចៅក្រមបរទេសមកកាត់សេចក្តី បើប្រទេសយើងចង់បាននូវការគាំទ្ររបស់សហគមន៍អន្តរជាតិ ជាពិសេសរបស់អង្គការសហប្រជាជាតិ ដែលលោកលើកឡើងពីគោលការណ៍មួយដែលគេហៅថា គ្រេឌិប៊ីលីធី (Credibility) គឺការជឿទុកចិត្ត ការទុកចិត្តនិងការជឿ ការជឿមកលើយើង អ៊ីចឹងគឺថាដើម្បីឲ្យគេជឿមកលើដំណើរការកាត់ទោស ឲ្យគេទុកចិត្តមកលើដំណើរការកាត់ទោស គេក៏ត្រូវមានគំនិតមានគោលការណ៍ទស្សនៈរបស់គេមួយចំនួនដែរ អ៊ីចឹងអំពីបញ្ហាកាត់ទោសគឺទូលបង្គំខ្ញុំបាទនឹងលើកឡើងអំពីជំហានធំៗនៃការកុំប្រូមី (Compromise) នៃការសម្រុះសម្រួលហ្នឹង ក៏ប៉ុន្តែគេចង់បានតុលាការអន្តរជាតិ យើងថាចង់បានតុលាការជាតិ អ៊ីចឹងការសម្រុះសម្រួលគឺតុលាការជាតិ ប៉ុន្តែឲ្យមានចៅក្រមបរទេសចូលរួម ។ ចំណុចមួយសំខាន់គួរឲ្យកត់សម្គាល់គឺថាចៅក្រមបរទេសទាំងនោះត្រូវទទួលការតែងតាំងពីស្ថាប័នជាន់ខ្ពស់របស់កម្ពុជាដែលមានសមត្ថកិច្ច ហើយក្នុងករណីនេះគឺឧត្តមក្រុមប្រឹក្សាចៅក្រម លោកជាអ្នកតែងតាំង អ៊ីចឹងនៅក្នុងសេចក្តីព្រាងច្បាប់ គឺយើងចែងច្បាស់ថាអគ្គលេខាអង្គការសហប្រជាជាតិជាអ្នកដែលជ្រើសរើស ប៉ុន្តែអ្នកដែលតែងតាំងឲ្យមកកាត់សេចក្តីនៅកម្ពុជាគឺឧត្តមក្រុមប្រឹក្សាចៅក្រមកម្ពុជាដែលជាអ្នកតែងតាំង ចំណុចនេះទូលបង្គំខ្ញុំបាទជឿថាជាការឆ្លុះបញ្ចាំងនូវការគោរពអធិបតេយ្យភាពជាតិកម្ពុជាមួយចំណែកដែរ ។ ចំណុចមួយទៀតនៅក្នុងការរៀបចំសមាសភាពនៃអង្គជំនុំជម្រះវិសាមញ្ញនេះ គឺយើងចង់បានភាគច្រើនជាចៅក្រមកម្ពុជា ។ អង្គការ

សហប្រជាជាតិចង់បានភាគច្រើនជាចៅក្រមបរទេស ។ អ៊ីចឹងតើសម្រុះសម្រួលគ្នារបៀបម៉េច...យើងលើកឡើងថាដើម្បីឆ្លុះបញ្ចាំងបាននូវការគោរពអធិបតេយ្យភាពជាតិកម្ពុជា គឺនៅក្នុងអង្គជំនុំជម្រះត្រូវតែចៅក្រមកម្ពុជាមានភាគច្រើន បើ៥នាក់យើងត្រូវមាន៣នាក់ បើ៧នាក់យើងត្រូវមាន៤នាក់ បើ៩នាក់យើងត្រូវមាន៥នាក់ បានន័យថា (Majority) ភាគច្រើនគឺត្រូវនៅខាងកម្ពុជា ខាងអង្គការសហប្រជាជាតិលោកលើកឡើងថាទេគឺថាដើម្បី (Credibility) ដើម្បីការជឿទុកចិត្តបាននោះគឺគេត្រូវការឲ្យចៅក្រមបរទេសមានភាគច្រើនវិញ អ៊ីចឹងត្រង់ចំណុចហ្នឹងវាទាល់ច្រកហើយ ដូច្នេះដើម្បីជាការសម្របសម្រួលគឺថា ហើយដើម្បីឆ្លុះបញ្ចាំងបាននូវគោលការណ៍អធិបតេយ្យភាពជាតិគឺទីបំផុតបានព្រមព្រៀងគ្នាថាចៅក្រមកម្ពុជាមានភាគច្រើន ចៅក្រមបរទេសភាគតិច ប៉ុន្តែយកការសម្រេចមួយគឺរូបមន្តថ្មីដែលមិនដែលមាននៅលើសកលលោក គឺរូបមន្តដែលមានឈ្មោះហៅថា (super majority) (majorité qualifieé) ខ្មែរយើងបកថាភាគច្រើនលើសលប់ បានន័យថាបើ៥នាក់គឺគេមាន២យើងមាន៣ ប៉ុន្តែការសម្រេចត្រូវសម្រេចដោយ៤នាក់ បានន័យថាកម្ពុជា៣នាក់ក៏មិនទាន់សម្រេចបានទេ ទាល់តែមានគេម្នាក់ដែរបានសម្រេចបាន អ៊ីចឹងបើយើងគិតជាគោលការណ៍ច្បាប់បានន័យថាយើងមាន (Majorité) យើងមានភាគច្រើនហើយ ប៉ុន្តែគេមានភាគតិចដែលគេហៅថា (Minorité)ប៉ុន្តែ (minorité bloquant) អាចប្លុកគេបានតែមិនអាចទប់មិនឲ្យយើងទៅមុខបានដែរ ជាភាគតិចតែមានលទ្ធភាពទប់ស្កាត់មានលទ្ធភាពធ្វើឲ្យគាំងបានដែរ អ៊ីចឹងបានន័យថាការចរចាវាត្រូវមានទៅមានមក អ៊ីចឹងមិនមែនជាការចម្លងតាមគេទេ នេះជាការដែលសម្រុះសម្រួលជាមួយគ្នា គេត្រូវគោរពយើង យើងត្រូវគោរពគេ នេះជាគោលការណ៍នៃការចរចា ហើយនេះជាចំណុចដែលទូលបង្គំខ្ញុំបាទលើកឡើងថាជាចំណុចទី២ ដែលឆ្លុះបញ្ចាំងអំពីការគោរពអធិបតេយ្យភាពជាតិ ។ ចំណុចមួយទៀតជាចំណុចទី៣ គឺដូចដែលទូលបង្គំបានលើកឡើងថាប្រវត្តិតុលាការឧក្រិដ្ឋកម្មផ្សេងៗដែលបានរៀបរាប់មកដែលបានកើតឡើងនៅលើសកលលោក គឺភាគច្រើនជាតុលាការដែលរៀបចំដោយចៅក្រមបរទេស ហើយផ្តើមគំនិតដោយបរទេសដាក់បង្ខំចូលទៅឲ្យធ្វើ ។ ចំណែកការរៀបចំរបស់យើងយន្តការរបស់យើងដែលយើងហៅថាអង្គជំនុំជម្រះវិសាមញ្ញនេះ នៅក្នុងក្របខ័ណ្ឌនៃតុលាការកម្ពុជានេះគឺជាការស្រុះស្រួលគ្នារវាងយើងជាម្ចាស់ផ្ទះ ម្ចាស់រឿង ហើយនិងអង្គការសហប្រជាជាតិដែលជាអ្នកយើងចង់ឲ្យគេមកទទួលស្គាល់យើង ចង់ឲ្យគេមកដឹងឮរឿងហ្នឹង យើងចង់បានការជឿទុកចិត្តរបស់គេ របស់សហគមន៍អន្តរជាតិ ។ ដូច្នេះហើយបានវាមាន វាត្រូវការចូលគ្នាអ៊ីចឹង យើងក៏ត្រូវការគេ គេក៏ចង់បានការងារនេះពីយើង ដូច្នេះចំណុចទាំង៣ ការតែងតាំងចៅក្រមសមាសភាពចៅក្រមការផ្តើមគំនិតរៀបចំជាយន្តការនេះឡើងឆ្លុះបញ្ចាំងនូវគោលគំនិតនៃការគោរពអធិបតេយ្យភាពជាតិដែលជាគោលការណ៍ធំចម្បងមួយនៅក្នុងការរៀបចំយន្តការនេះ ។ នេះជាចំណុច...ចំណុចនេះក៏ជាប់ពាក់ព័ន្ធនឹងចំណងជើងនៃអត្ថបទទូលបង្គំខ្ញុំបាទសូមធ្វើអត្ថាធិប្បាយនៃចំណងជើងនេះបន្តិចហើយ គឺថាយើងដាក់ចំណងជើងថាការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដូច្នេះទី១ពាក្យថាអង្គជំនុំជម្រះវិសាមញ្ញនេះ ហើយនិងតុលាការនេះ វាកើតចេញអំពីការសម្រុះសម្រួលរវាងថាជាតុលាការកម្ពុជា ប៉ុន្តែមានអង្គជំនុំជម្រះវិសាមញ្ញដែលអង់គ្លេសហៅថា (extra ordinary chamber) ហើយដែលយើងប្រែជាបារាំងថា (information extra ordinaire) បានន័យថានៅក្នុងតុលាការកម្ពុជាដែលមានស្រាប់ហ្នឹង ប៉ុន្តែមាន (Chamber) ណឹង ប៉ុន្តែមានអង្គជំនុំជម្រះវិសាមញ្ញហ្នឹងសម្រាប់ធ្វើការអំពីករណីមេដឹកនាំខ្មែរក្រហមនេះ ហើយមានពាក្យមួយទៀតដែលយើងប្រែថា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ទូលបង្គំខ្ញុំបាទសូមធ្វើអត្ថាធិប្បាយនៅពាក្យនេះមុនឲ្យហើយ គឺថាហេតុដូចម្តេចបានជាយើងប្រើពាក្យកម្ពុជាប្រជាធិបតេយ្យព្រោះយើងចង់កាត់ទោសយើងចង់ធ្វើការក្នុងចន្លោះពេលពីឆ្នាំ១៩៧៥មកឆ្នាំ១៩៧៩ ប៉ុន្តែយើងប្រើពាក្យកម្ពុជាប្រជាធិបតេយ្យ ព្រោះថាឧក្រិដ្ឋកម្មនេះកើតឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែបើតាមការស្រាវជ្រាវជាក់ស្តែងកម្ពុជាប្រជាធិបតេយ្យ មិនមែនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ហើយមិនមែនចប់នៅថ្ងៃ៦ មករា ឆ្នាំ១៩៧៩នោះទេ គឺបានកើតឡើងក្រោយថ្ងៃ១៧ មេសា ព្រោះពេលនោះជារណសិរ្ស អ៊ីចឹងគឺត្រូវមាន...នៅពេលនោះជាដំណើរការបែបបទដែរ ដើម្បីបង្កើតកម្ពុជាប្រជាធិបតេយ្យហ្នឹងអ៊ីចឹងគឺនៅឆ្នាំ១៩៧៦ ហើយចប់ទៅគឺ នៅពេលដែលកើតត្រីភាគីវិញអ៊ីចឹងគឺចប់ក្រោយ១៩៧៩ អ៊ីចឹងសួរថា គឺយើងដាក់ចំណងជើងអ៊ីចឹងតើវាមានឥទ្ធិពលទៅដល់កាលបរិច្ឆេទនៃការកាត់សេចក្តីទេ ទូលបង្គំខ្ញុំបានយល់ឃើញថាគឺនៅក្នុងសេចក្តីព្រាងច្បាប់ គឺអាចមានន័យគ្រប់គ្រាន់ក្នុងការកំណត់រយៈកាលដែលយើងហៅថា (compétence temporelle) យើងមានកំណត់នៅក្នុងមាត្រា១ និង២ច្បាស់ថាយើងយកតែរយៈពេលពី១៧ មេសា ១៩៧៥ ទៅរយៈពេលពីថ្ងៃ៦ មករា ឆ្នាំ១៩៧៩ ហើយមាននៅក្នុងមាត្រា១មានបញ្ជាក់ម្តងទៀត នៅក្នុងមាត្រា២ ហើយក៏មាននៅក្នុងមាត្រាផ្សេងៗទៀត ហើយនៅពេលដែលយើងសរសេរចំណុចខ្លះដែលពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទគឺយើងសុទ្ធតែបញ្ជាក់កាលបរិច្ឆេទនេះទាំងអស់ ដូច្នេះទូលបង្គំខ្ញុំបាទយល់ឃើញថាដែលមាត្រានេះមិនធ្វើឲ្យមាន

ការបកស្រាយប្រឡំទេ ព្រោះថាមួយជាចំណាងជើងដែលឆ្លុះបញ្ចាំងនូវគំនិតរួមជាទូទៅ ហើយមួយទៀតគឺជាវិសាលភាពពិតប្រាកដនៃការអនុវត្ត ដែលឆ្លុះបញ្ចាំងនៅក្នុងមាត្រាផ្សេងៗនៃច្បាប់ ។ នេះជាចំណុចទី១និងទី២ ដែលទូលបង្គំខ្ញុំបាទសូមលើកឡើងអម្បាញ់មិញ គឺបញ្ជាក់ថាមាន៥ចំណុចនោះឥឡូវឈានចូលចំណុចទី៣ ។ ចំណុចទី៣គឺការរៀបរាប់ទូលថ្វាយនិងជម្រាបជូនអំពីដំណើរការដែលឈានមកកកើតជាសេចក្តីព្រាងច្បាប់នេះ ។ តើឆ្នាំ១៩៩៧ យើងធ្វើអី៩៨ យើងធ្វើអី ហើយជាពិសេសឆ្នាំ៩៩ និងឆ្នាំ២០០០នេះ បើអីចឹងយើងគិតទៅជាង៣ឆ្នាំ ជិត៤ឆ្នាំហើយក្នុងការដែលរៀបចំដំណើរការវិនិច្ឆ័យនេះ វិនិច្ឆ័យទោសនេះ? កាលពីខែមិថុនា ឆ្នាំ១៩៩៧ គឺមានសំណើរបស់យើងទៅអង្គការសហប្រជាជាតិដើម្បីឲ្យគេជួយផ្តល់ការជួយឧបត្ថម្ភក្នុងដំណើរការការរៀបចំកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ខែវិច្ឆិកា លោកអគ្គលេខាធិការ កូហ្វីអាណាន់ បានបញ្ជូនជំនាញការ៣រូបមក ដើម្បីស្វែងយល់អំពីដំណើរការនេះ ហើយឆ្នាំ៩៧ គឺថាមានតែប៉ុណ្ណឹងទេ គឺថាគេបានបញ្ជូនអ្នកជំនាញការជាន់ខ្ពស់របស់គេដែលជាអតីតចៅក្រមជាន់ខ្ពស់នោះដែលយកមកពីប្រទេសខុសគ្នាផ្សេងៗមកនោះ អីចឹងគេមកសិក្សា គេធ្វើរបាយការណ៍ទៅអគ្គលេខាអង្គការសហប្រជាជាតិវិញ ។ ឆ្នាំ៩៨ ដែលយើងកំណត់ថាជាឆ្នាំអន្តរកាលគឺមានព្រឹត្តិការណ៍នៃការបោះឆ្នោត ដែលយើងបានទទួលការវាយតម្លៃថាជាអច្ឆរិយៈនៅតាមទន្លេមេគង្គនោះ ហើយចេញពីនេះគឺថាយើងបានរៀបចំរដ្ឋសភារាជរដ្ឋាភិបាលយើង យើងយល់ថាត្រូវរៀបចំដើម្បីបិទទំព័រប្រវត្តិសាស្ត្រខ្មៅងងឹតនេះឲ្យចប់ ។ ចំពោះដែលខុសគ្នាហើយឈានមករកគ្នាបន្តិចម្តងនោះនៅឆ្នាំ៩៩ គឺមានព្រឹត្តិការណ៍មានការងារច្រើនដែលនៅក្នុងដំណើរការនៃការរៀបចំយន្តការនេះ ជាពិសេសគឺថាការដែលប្តូរទស្សនទានពីតុលាការអន្តរជាតិឬពីតុលាការជាតិសុទ្ធសាធមកកាន់គោលការណ៍មួយដែលយើងបានដូចថាយើងប្រើពាក្យថា *Comversente* វាឈានមករកគ្នា ។ ចំណុចពីរដែលខុសគ្នាហើយឈានមករកគ្នាបន្តិចម្តងនោះគឺនៅខែមេសាឆ្នាំ... គោលការណ៍នោះគឺពីមុនគឺម្ខាងនិយាយពីតុលាការអន្តរជាតិ ម្ខាងនិយាយពីតុលាការជាតិ ដូច្នេះគោលការណ៍ថ្មីមួយដែលធ្វើឲ្យមានការសម្រុះសម្រួលគ្នាបានលើចំណុចនេះគឺគោលការណ៍ដែលយើងដាក់ឈ្មោះថា គោលការណ៍ស្តីអំពីការកាត់សេចក្តីដែលមានចរិតលក្ខណៈអន្តរជាតិ អីចឹងគេឈប់ទាមទារ គេក៏បានឈានថយក្រោយមួយជំហានដែរ គេឈប់ទាមទារតុលាការអន្តរជាតិ គេនិយាយពីការកាត់សេចក្តីដែលមានចរិតលក្ខណៈអន្តរជាតិ ហើយនៅក្នុងខែមេសា ឆ្នាំ៩៩ នៅក្នុងអំឡុងឆ្នាំ៩៩នេះ នៅខែមេសា គឺមានជំនួបរវាងលោកព្រឹទ្ធសភា ចន ឃែរី ជាមួយនឹងសម្តេច នាយករដ្ឋមន្ត្រី ហ៊ុន សែន ហើយបានលើកជាគោលការណ៍ជាតុលាការជាតិដែលមានការចូលរួមពីចៅក្រមបរទេស ខែឧសភា យើងបានអញ្ជើញអ្នកច្បាប់ ក្រុមអ្នកច្បាប់ពីប្រទេសបារាំងដើម្បីជួយពិចារណា ជួយគិតគូរពីបញ្ហានេះ ប្រទេសបារាំងក៏បានបញ្ជូនក្រុមអ្នកច្បាប់មួយក្រុមដែលអាចនិយាយបានថាជាអ្នកច្បាប់កម្រិតខ្ពស់របស់គេដែរ មានអ្នកធ្វើការនៅតុលាការកំពូលរបស់គេ មានអ្នកធ្វើការជាមេធាវីចាស់ទុំរបស់គេ មានអ្នកធ្វើការនៅតុលាការផ្សេងៗ អីចឹងខែឧសភា ឆ្នាំ៩៩ គឺយើងបានពិគ្រោះពិភាក្សាជាមួយក្រុមអ្នកច្បាប់បារាំង ខែសីហា ឆ្នាំ៩៩នេះគឺរាជរដ្ឋាភិបាលបានបង្កើតជាក្រុមការងារ *task force* របស់រាជរដ្ឋាភិបាលដើម្បីគិតគូរការងារនេះ គឺដែលមានខ្លួនទូលបង្គំខ្ញុំបាទជាប្រធានក្រុមការងារនេះ នៅខែសីហា ឆ្នាំ១៩៩៩ ក្រុមការងារបានចាប់ផ្តើមធ្វើការងារនេះដោយរៀបចំជាសេចក្តីព្រាងច្បាប់ជាពង្រាង ព្រោះពង្រាងនេះលើកទីច្រើនណាស់គឺមិនមែនលើកទី លើកទី១ លើកទី២ លើកទី៣ លើកទី៤ លើកទី៥ ហើយអីចឹងពង្រាងលើកទី១ដែលបានរៀបចំហើយនៅខែសីហា ឆ្នាំ៩៩ ហើយដាក់ជូនទៅឲ្យគណៈប្រតិភូរបស់អង្គការសហប្រជាជាតិដែលដឹកនាំដោយឯកឧត្តម រ៉ាក់ ហ្សាក់គ្លីន ដែលលោកជាអនុប្រធានរបស់ឯកឧត្តម ហែន កូរែល ដែលជាអ្នកទទួលបន្ទុកខ្ពស់បំផុតខាងច្បាប់របស់អង្គការសហប្រជាជាតិ ដែលមានឋានៈជាអគ្គលេខាធិការរងនោះ ហើយលោក ហ្សាក់គ្លីន នេះ គាត់ជាអនុរបស់អ្នកនៅផ្ទាល់ជាមួយលោកឯកឧត្តម ហែន កូរែល អីចឹងខែសីហា ឆ្នាំ៩៩ លោក ហ្សាក់គ្លីនបានដឹកនាំគណៈប្រតិភូមកចេញពីអគ្គលេខាធិការដ្ឋានរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិមក អីចឹងយើងបានដាក់ពង្រាងរបស់យើងជូនគាត់ អីចឹងវាបានន័យថាពង្រាងនេះបានធ្វើហើយតាំងពីឆ្នាំ១៩៩៩ ហើយពង្រាងទីមួយមិនមែនរបស់គេទេ គឺទី១គឺរបស់យើងរបស់ដែលច្បាប់កម្ពុជាដែលធ្វើដោយមានការពិភាក្សាជាមួយនឹងអ្នកជំនាញការផ្សេងៗដែរ ក៏សូមទូលថ្វាយនឹងជម្រាបជូនអង្គសភាដែរគឺថាយើងមានអ្នកបច្ចេកទេសច្បាប់នឹងពីបារាំងផង ពីឥណ្ឌាផង ពីស្វីរៀតផង ហើយពីសហរដ្ឋអាមេរិកដែរ សហរដ្ឋអាមេរិកក៏បានដើរតួនាទីច្រើនដែរក្នុងការសម្របសម្រួលជាពិសេសសម្របសម្រួលរវាងរឿងយើង និងអង្គការសហប្រជាជាតិ អីចឹងហើយមានការជជែកគ្នាការចរចាច្រើនណាស់ ហើយក៏សូមបញ្ជាក់នៅចំណុចនេះដែរគឺថាពង្រាងទីមួយត្រូវបានយើងជាអ្នករៀបចំហើយដាក់ជូនឲ្យគណៈប្រតិភូលោក ហ្សាក់គ្លីនពិនិត្យសួរថាអង្គការច្បាប់គណៈប្រតិភូអញ្ជើញមកពាជង ដែលដឹកនាំដោយអ្នកច្បាប់ជាន់ខ្ពស់បំផុតរបស់អង្គការសហប្រជាជាតិ ហើយម្តងប្រហែលមួយអាទិត្យគេមកម្តង ប្រហែលមួយអាទិត្យ មួយក្រុមប្រហែលជា៦-៧នាក់ ឬ៨-៩នាក់ ហើយជាអ្នកច្បាប់ចំណានៗរបស់គេ ហើយគឺលើកទីមួយនៅខែសីហា ៩៩នេះ

គឺគេបានទទួលពិនិត្យគម្រោងរបស់យើង ។ នៅពេលនោះគឺថាមិនទាន់ត្រូវគ្នាទេដោយ នៅចំណុចដែលខ្វែងគ្នា ធំគឺថាលោក ហ្សាក់គ្លីនគាត់ទាមទារភាគច្រើនដែលចៅក្រមបរទេសត្រូវតែភាគច្រើន ហើយយើងនៅទាមទារថាចៅក្រមកម្ពុជាត្រូវតែភាគច្រើន ដល់អីចឹងទៅគឺបានជជែកគ្នាត្រូវគ្នាលើចំណុចមួយចំនួន ប៉ុន្តែចំណុចជាមូលដ្ឋានដែលនៅគាំងគឺចំណុចចំនួនចៅក្រមនេះ ។ នៅខែកញ្ញា ឆ្នាំ១៩៩៩នេះ គឺធម្មតានៅខែកញ្ញា គឺមានសម័យប្រជុំមហាសន្និបាតអង្គការសហប្រជាជាតិដែលសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន តែងតែដឹកនាំគណៈប្រតិភូទៅចូលរួមប្រជុំ អីចឹងនៅពេលនោះយើងក៏បានជួបប្រាស្រ័យជាមួយនឹងឯកឧត្តមអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ហើយនៅពេលនោះសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រគល់ជូននូវអនុស្សារណៈមួយដែលមានសំណើ៣ចំណុច សំណើ៣ចំណុចនោះគឺថាចំណុចទី១ សំណើ៣ចំណុចដែលមានលក្ខណៈដូចជាប្រហាក់ប្រហែលគ្នានិងអង្គសន្និបាតដែរ ចំណុចទី១ យើងលើកឡើងថា អង្គការសហប្រជាជាតិអាចជួយ បានន័យថាលោកអគ្គលេខាធិការអង្គការសហប្រជាជាតិអាចជួយរួមចំណែកក្នុងបញ្ហានេះដោយជួយផ្តល់ចៅក្រមជួយផ្តល់ចៅក្រមផង និងជួយអ្នកជំនាញដើម្បីជួយកែសម្រួលសេចក្តីព្រាងច្បាប់របស់យើងឲ្យទៅជាអ្វីដែលគេលើកឡើងថា Credibility ឲ្យទៅជាជឿទុកចិត្តឲ្យសមស្របទៅនឹងនីតិវិធីសព្វបែបយ៉ាងដើម្បីពង្រឹងនូវការទុកចិត្តរបស់សហគមន៍អន្តរជាតិហ្នឹង ហើយនិងផ្តល់ចៅក្រមឲ្យចូលរួមកាត់សេចក្តីជាមួយនឹងចៅក្រមកម្ពុជាផងលទ្ធភាពទី២គឺថា លោកអគ្គលេខាធិការអង្គការសហប្រជាជាតិជួយត្រឹមតែផ្តល់នូវជំនាញការមកជួយធ្វើច្បាប់បានហើយ ទុកឲ្យចៅក្រមកម្ពុជាកាត់ខ្លួនឯង ធ្វើខ្លួនឯង លទ្ធភាពទី៣គឺអង្គការសហប្រជាជាតិនៅស្ងៀម ទុកឲ្យកម្ពុជាធ្វើខ្លួនឯងទាំងច្បាប់ ទាំងចៅក្រមទាំងអស់ អីចឹងនៅពេលនោះគឺថាឯកឧត្តមអគ្គលេខាធិការអង្គការសហប្រជាជាតិគឺមិនបានឆ្លើយតបទេ គឺថាចាត់តាំងជាក្រុមការងារបន្តការងារនេះ អីចឹងនៅពេលនោះគឺខ្លួនខ្ញុំត្រូវបានចាត់តាំងជាតំណាងរាជរដ្ឋាភិបាលហើយលោកអគ្គលេខាធិការសហប្រជាជាតិគេចាត់តាំងលោក ហែន កូរែល ដែលជាអគ្គលេខាធិការរងហើយជាអ្នកវិភាគច្បាប់ អីចឹងហើយនៅពេលនោះគឺគេបានបញ្ជាក់ប្រាប់យើងថាឯកឧត្តម ហែន កូរែល បានបញ្ជាក់ប្រាប់យើងថា មិនទាន់ឆ្លើយបានទេនូវសំណួរទាំង៣ចំណុចនេះមិនទាន់ឆ្លើយទេ គេត្រូវការស្វែងយល់ពីគ្នាសិនមុននឹងឯកឧត្តមជូនយោបល់ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិថានឹងត្រូវឆ្លើយយ៉ាងម៉េច អីចឹងគេបានសួរខ្ញុំវិញថាចុះបើទៅកម្ពុជាវិញតើឯកឧត្តមធ្វើអីក្នុងការងារនឹងនៅបន្តការងារនឹងធ្វើអីទៀតធ្វើអីតទៅទៀត ខ្ញុំបានជម្រាបជូនទៅឯកឧត្តម ហែន កូរែល ថាខ្ញុំត្រឡប់ទៅកម្ពុជាវិញ ទី១ខ្ញុំបន្តធ្វើច្បាប់ហ្នឹង បន្តធ្វើច្បាប់ហ្នឹងហើយគឺខ្ញុំនិងដាក់ជូនរដ្ឋាភិបាលសម្រេច រដ្ឋាភិបាលសម្រេចហើយនឹងជូនរដ្ឋសភា រដ្ឋសភា សម្រេចហើយគឺតាមនីតិវិធីត្រូវព្រឹទ្ធសភា ហើយបន្ទាប់មកដោយសារនេះជាច្បាប់ក្របខ័ណ្ឌច្បាប់អរខានិច ច្បាប់គឺត្រូវបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្រោយមកបានព្រះរាជក្រមចូលជាធរមាន យើងខ្ញុំអនុវត្តដូចអ្វីដែលយើងខ្ញុំជម្រាបជូនឯកឧត្តមអគ្គលេខាធិការរងគឺជម្រាបអីចឹង គឺថាដំណើរការហ្នឹងគឺថាយើងខ្ញុំធ្វើអីចឹង ដល់បានន័យថាបើអង្គការសហប្រជាជាតិមិនចូលរួមគឺយើងធ្វើហើយ គឺយើងនឹងធ្វើអីចឹងនៅពេលនោះគឺឯកឧត្តមអគ្គលេខាធិការរងបានស្នើមកខ្ញុំវិញ មកទូលបង្គំខ្ញុំថា សូមឯកឧត្តមធ្វើអីចឹង គឺធ្វើចុះ ប៉ុន្តែមុននឹងជូនសេចក្តីព្រាងច្បាប់ដែលរាល់ការគ្រោងរបស់ឯកឧត្តមធ្វើនេះទៅជូនរដ្ឋាភិបាល សូមមេត្តាឲ្យខ្ញុំដឹងផង ហើយយើងខ្ញុំកំពុងគិតថាត្រូវឆ្លើយយ៉ាងម៉េច សូមទាក់ទាញការចាប់អារម្មណ៍ដែរ គឺថាការងារច្បាប់នេះមិនមែនជាការងារដែលស្រួលចេះតែថាទេ សូម្បីតែកម្រិតអ្នកច្បាប់ខ្ពស់បំផុតរបស់អង្គការសហប្រជាជាតិហើយក្តី គឺនៅពេលប្រជុំរៀបនឹងឆ្លើយសំណួរម្តងៗគឺគេត្រូវការសុំផ្អាកពិគ្រោះជាមួយគ្នាអ្នកច្បាប់សិន ពិគ្រោះជាមួយគ្នាហ្មត់ចត់ណាស់បានគេស្រាយរឿងមួយៗ មិនមែនព្រួសទៅមាំុងទៅមាំុងមក មិនមែនចេះតែព្រួសប្រាសៗទេ គឺថាផ្អែកលើគោលការណ៍ច្បាប់យើងធ្វើរឿងអ្វីមួយគេសុំឈប់ផ្អាក អង់ម័របន្តិចសិន ពិគ្រោះគ្នាសិនបានគេឆ្លើយជាមួយយើងហើយយើងក៏អីចឹងដែរយើងម៉េចខ្លះ យើងត្រូវពិគ្រោះគ្នាហ្មត់ចត់ បានឆ្លើយជាមួយគេ មិនមែននិយាយមាំុងទៅមាំុងមកតាមការនឹកឃើញរៀងខ្លួនទេ គឺថាសុទ្ធតែគោរពគោលការណ៍ ប៉ុន្តែគោរពផលប្រយោជន៍ គេគោរពផលប្រយោជន៍របស់អង្គការសហប្រជាជាតិរបស់អគ្គលេខាធិការ បើយើងគោរពផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា អីចឹងហើយការចរចានេះគេថាមិនមែនជាការដែលឆាប់ទេយូរណាស់ ។ អញ្ចឹងនៅខែកញ្ញា ឆ្នាំ១៩៩៩ គឺយើងក៏បានទទួលសំណើរថាសុំឲ្យមានការបន្តជជែករវាងក្រុមការងារដែលយើងថា Task Force នេះបាទជាមួយនិងសហគមអន្តរជាតិបាទសូមឲ្យបើកចំហរការចរចា ព្រោះថានៅពេលនោះដែល នៅពេលដែលយើងលើកនៅចំណុច៣នេះ ការងារដូចជាយឺតទៅបន្តិចហើយ វាដូចថាមិនទាន់មានចំណុចត្រូវដោះស្រាយយ៉ាងណា អញ្ចឹងវាត្រូវយឺតទៅបន្តិចដែរ អញ្ចឹងហើយបានជានៅខែកញ្ញា នៅខែកញ្ញានេះ យើងបានពិគ្រោះសំណូមពរថាសូមឲ្យបើកការចរចាឲ្យទូលាយ បាទដើម្បីបន្តដំណើរការនេះទៀត ។ នៅខែតុលា ឆ្នាំ១៩៩៩នេះ គឺយើងបានចាប់ផ្តើមបន្តការងារវិញជាមួយនឹងអ្នកមន្ត្រីជាន់ខ្ពស់បំផុតរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិកដើម្បីលោកខំធ្វើអាជ្ញាកណ្តាលលោកជួយសម្របសម្រួលរវាងយើងនិងអង្គការសហ

ប្រជាជាតិ ។ ហើយនៅខែធ្នូ ឆ្នាំ១៩៩៩នេះ យើងបានទទួលក្រុមជំនាញ អ្នកច្បាប់ជាន់ខ្ពស់ពីឥណ្ឌា ពីរុស្ស៊ី និងពីបារាំងមិនបានទទួលថ្ងៃជាមួយគ្នា ទទួលថ្ងៃផ្សេងៗគ្នា ដើម្បីពិគ្រោះយោបល់ ហើយគេផ្តល់យោបល់ថា ត្រូវធ្វើម៉េចថាដើម្បីកុំឲ្យខុសគោលការណ៍ច្បាប់ដែលគេយល់ឃើញ ។ អ៊ីចឹង អ្នកជំនាញការរុស្ស៊ី គាត់ជូនយោបល់តាមទស្សនៈការគិតគូររបស់គាត់អ្នកច្បាប់ឥណ្ឌាគាត់ជូនយោបល់តាមការគិតគូររបស់គាត់ ហើយអ្នកច្បាប់បារាំងក៏ជូនយោបល់តាមការគិតគូររបស់គេដែរនេះគេបានយកចិត្តទុកដាក់ពីបញ្ហានេះគេរៀបចំក្រុមអ្នកច្បាប់មួយនៅប៉ារីស បើយើងមានការគោលការណ៍ការងាររសួរគេ គេថា គេប្រជុំ អ្នកច្បាប់នោះភ្លាម ប្រជុំហើយគេឆ្លើយមកយើងវិញថា គេយកធ្វើអ៊ីចេះគេយកធ្វើអ៊ីចុះនៅអំពីសំណួរអំពីអ៊ីដែលយើងចង់ឲ្យគេអត្ថាធិប្បាយ ។ នៅខែធ្នូ ដដែលនេះ នៅថ្ងៃ១៧ ខែធ្នូ ឆ្នាំ១៩៩៩ នេះគឺក្រុមការងារ Task Force បានបញ្ចប់សេចក្តីព្រាងច្បាប់ជាលើកទី២ ពង្រាងទី២ ពង្រាងនោះមានលេខច្រើនណាស់ អាពង្រាងលើកទី២វាចប់នៅ១៧ ធ្នូ ឆ្នាំ១៩៩៩ហ្នឹង ហើយបានដាក់ឆ្លងគណៈរដ្ឋមន្ត្រីនៅថ្ងៃ២៤ ធ្នូ ឆ្នាំ១៩៩៩ ។ បាទ! នេះជាការងារដែលមានការវិវត្តន៍នៅឆ្នាំ១៩៩៩ គឺថាឆ្នាំ២០០០ នៅថ្ងៃទី៦ មករា ឆ្នាំ២០០០ នេះគឺគណៈរដ្ឋមន្ត្រីឆ្លងជាលើកទី២ បាទ! ប្រជុំជាលើកទី២ដោយមានការវិសោធនកម្មខ្លះ ។ ហើយនៅថ្ងៃ១០ មករា គឺមានទស្សនកិច្ចរបស់ឯកឧត្តមនាយករដ្ឋមន្ត្រីជប៉ុន អ៊ូប៊ូជី អតីតនាយករដ្ឋមន្ត្រីជប៉ុន អ៊ូប៊ូជី ដែលក្នុងនោះក៏មានពិភាក្សាបញ្ហានេះដែរ ។ ថ្ងៃ១៤ មករា រាជរដ្ឋាភិបាលបានធ្វើការកែទម្រង់ម្តងទៀតដោយអនុញ្ញាតឲ្យមានសហចៅក្រមស៊ើបអង្កេត ។ បាទ!ពង្រាងលើកទី២ដែលយើងធ្វើដាក់ឆ្លងគណៈរដ្ឋមន្ត្រីលើកទី២ យើងស្នើឲ្យមានចៅក្រមស៊ើបអង្កេតតែមួយទេ ពីព្រោះយើងលើកឡើងថារចនាសម្ព័ន្ធរបស់គេនៅខាងក្រៅគេអត់មានចៅក្រមស៊ើបអង្កេត ។ អ៊ីចឹងកម្ពុជានៅអនុវត្តតាមប្រព័ន្ធ Romano-Germanique យើងមានចៅក្រមស៊ើបអង្កេត អ៊ីចឹងគឺអស់លោកមិនបាច់ធ្វើទេ ពីព្រោះថាអស់លោកមិនធ្លាប់ធ្វើអាណឹងផង អ៊ីចឹងទុកឲ្យកម្ពុជាធ្វើតែឯង ប៉ុន្តែនៅថ្ងៃ១៤ មករា នេះយើងព្រមកែសម្រួលបញ្ហានេះ ។ ហើយនៅថ្ងៃ១៨ មករា ដែលទូលបង្គំខ្ញុំបាទបានថ្វាយពង្រាងនេះថ្វាយសម្តេចព្រះប្រធានរដ្ឋសភានៅថ្ងៃទី១៨ មករា ឆ្នាំ២០០០ ។ នៅខែកុម្ភៈ ថ្ងៃ៨ កុម្ភៈ ឆ្នាំ២០០០គឺលោកអគ្គលេខាធិការ កូហ្វី អាណាន់ បានផ្ញើលិខិតមួយទៀតលិខិតនោះគឺថានៅតែតានតឹងដដែលគឺលើកឡើងនៅចំណុច៤ៗ ៤ចំណុចដែលជាចំណុចតានតឹង ទី១ គឺថាសូមឲ្យយើងធានារ៉ាប់រងថា ចាប់អ្នកដែលត្រូវចាប់ខ្លួននោះឲ្យ ។ បាទទី២ គេថាសុំមិនឲ្យមានការលើកលែងអនុគ្រោះទោស ទី៣ សុំឲ្យមានព្រះរាជអាជ្ញាបរទេសឯករាជ្យ បើតាមរបៀប Prosecutor នោះឯករាជ្យបានន័យថាសហព្រះរាអាជ្ញាមាន២ អ៊ីចឹងទៅប៉ុន្តែម្នាក់ៗធ្វើការដាច់ដោយឡែកពីគ្នាទៅ ឯករាជ្យពីគ្នា ចំណុចនេះគឺយើងមិនបានព្រមព្រៀងតាមនេះទេ ប៉ុន្តែទូលបង្គំខ្ញុំបាទសូមរំឭកថា នៅថ្ងៃ៨ ខែកុម្ភៈ នេះគឺមានសំណើ៤ចំណុចហ្នឹង ហើយទី៤ គឺទាមទារឲ្យមានចៅក្រមបរទេសភាគច្រើន ភាគច្រើន ។ អ៊ីចឹង គឺថាចំណុច៤នេះគឺនៅតែតានតឹងណាស់រហូតដល់ខែកុម្ភៈ ឆ្នាំ២០០០នេះហើយ ចំណុចទាំង៤ ដែលលោកអគ្គលេខាធិការទាមទារនោះគឺតានតឹងណាស់ ។ នៅថ្ងៃ១២ ខែកុម្ភៈនេះ គឺមានការជួបប្រជុំឡើងវិញជួបរវាងឯកឧត្តមអគ្គលេខាធិការជាមួយនឹងសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅបាងកកក្នុងឱកាសប្រជុំ UNTAG ប្រជុំអង្គការដែលគេហៅថាពាណិជ្ជកម្មនិងអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិនោះ អ៊ីចឹងនៅជួបគ្នានៅបាងកកនេះគឺធ្វើឲ្យដំណើរការនឹងឈានឡើងវិញ បានន័យថាឯកឧត្តមអគ្គលេខាធិការ ប្រកាសថាមានសុទិដ្ឋិនិយមហើយនិងបញ្ជូនលោកឯកឧត្តម ហេន កូរែល នោះមកភ្នំពេញម្តងទៀត អ៊ីចឹងនៅខែមីនា ឆ្នាំ២០០០ គឺមានការមានគណៈប្រតិភូទី២របស់អគ្គលេខាធិការអង្គការសហប្រជាជាតិដែលដឹកនាំដោយឯកឧត្តម ហេន កូរែល មកភ្នំពេញនៅខែមីនា ឆ្នាំ២០០០ ។ អ៊ីចឹងនៅពេលនោះគឺក៏បានក្រុម Task Force ក៏បានធ្វើការឲ្យរយៈប្រហែលជិតមួយអាទិត្យអ៊ីចឹងដែរ ដើម្បីសម្រួលលើចំណុចទាំងប៉ុន្មានដែលយើងមិនទាន់ឯកភាពគ្នាជាពិសេសចំណុចទាំង៤ ដែលទូលបង្គំខ្ញុំបាទបានលើកឡើងថា ជាសំណើរបស់ឯកឧត្តមអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ខែមេសា ឆ្នាំ២០០០ គឺមានការជួបគ្នាម្តងទៀតនៅទីក្រុងឡាហាវ៉ាន គុយបា ប្រទេសគុយបា រវាងសម្តេច នាយករដ្ឋមន្ត្រី ហ៊ុន សែន ជាមួយនឹងលោកអគ្គលេខាធិការ ហេន កូរែល ហើយក៏បានមានការជួបគ្នារវាងសម្តេចជាមួយនឹងលោកព្រឹទ្ធសមាជិក ចន ឃែរី ដែរ ។ ការជួបនោះគឺបាននាំមកនៅ ឡាហាវ៉ាន មិនទាន់មានការឯកភាពគ្នាទេ ប៉ុន្តែមោដល់ភ្នំពេញគឺលោក ចន ឃែរី បានមោភ្នំពេញម្តងទៀតនៅខែមេសា ឆ្នាំ២០០០ ហើយក៏បានឈានទៅដល់ការឯកភាពសម្របសម្រួលគ្នាម្តងទៀតស្តីអំពីករណីដែលមានការខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា ។ អ៊ីចឹងគឺដំណោះស្រាយមួយទៀតបានត្រូវរកឃើញ បានត្រូវឯកភាពគ្នានៅក្នុងអំឡុងខែមេសា ឆ្នាំ២០០០នេះ ។ នៅខែឧសភា ឆ្នាំ២០០០ នេះគឺមានការផ្ញើលិខិតមួយទៀតជាសារលិខិតមួយទៀតរបស់សម្តេចនាយករដ្ឋមន្ត្រីជូនឯកឧត្តម កូហ្វី អាណាន់ និងជូនលោក ចន ឃែរី បញ្ជាក់អំពីការដែលមានការសម្របសម្រួលលើគោលការណ៍ថ្មីដូចដែលទូលបង្គំខ្ញុំបាទបានលើកឡើងអម្បាញ់មិញ ។ នៅខែកក្កដា គឺលោក ហេន កូរែល បានដឹកនាំគណៈប្រតិភូមកម្តងទៀត មោភ្នំពេញម្តងទៀត ដើម្បីបន្តធ្វើការចរចានៅលើដំណើរការរៀបចំយន្តការនេះ ។ នៅក្នុងការរៀបចំនៅក្នុង

ការដែលចរចាលើកក្រោយនេះឃើញថាយើងបានដោះស្រាយនូវចំណុចផ្សេងៗ ហើយបានឈានមកដល់ការព្រមព្រៀងគ្នាលើគោលការណ៍ធំៗ អញ្ចឹងមិនមែនព្រមព្រៀងគ្នាល្អិតទាំងអស់មួយរយភាគរយទេ ប៉ុន្តែព្រមព្រៀងគ្នាលើគោលការណ៍ធំៗ បានន័យថាការសម្រុះសម្រួលនោះគឺបានឈានមកដល់មួយចំណុចដែលយើងមានសព្វថ្ងៃនេះ ។ នៅខែកញ្ញា ឆ្នាំ២០០០ ក្រុម Task Force ក្រុមការងាររបស់រាជរដ្ឋាភិបាលបានចាប់ផ្តើមធ្វើការឡើងវិញជាមួយនឹងគណៈកម្មការនីតិកម្មរបស់រដ្ឋសភា ។ ហើយនៅថ្ងៃ២០ ខែវិច្ឆិកា ថ្មីៗនេះ២០វិច្ឆិកា ឆ្នាំ២០០០ នេះគឺលោកព្រឹទ្ធសមាជិក ចន ឃែរី អញ្ជើញមកម្តងទៀត ដើម្បីធ្វើការងារចុងក្រោយបញ្ជាក់ដូចថាលោកចង់បានដំណើរការនេះចង់ឲ្យច្បាស់លាស់ថាតើដំណើរការនេះទៅមុខទេ រដ្ឋសភាយើងនឹងប្រជុំពិភាក្សាលើច្បាប់នេះទេ គ្រាន់តែជាការបញ្ជាក់ឡើងវិញអំពីការប្រកាន់ជំហររបស់ព្រះរាជាណាចក្រកម្ពុជា ។ ហើយនៅថ្ងៃទី២៨ វិច្ឆិកា គឺក្រុមការងារជាមួយនឹងគណៈកម្មការនីតិកម្មបានបញ្ចប់ការងាររបស់ខ្លួនក៏ជាស្ថាពរ ហើយក៏ឈានមកដល់ការងារដែលមាននៅថ្ងៃនេះ ។ ទូលបង្គំខ្ញុំបាទមុននឹងឈានមកចូលសេចក្តីសន្និដ្ឋាននេះ គឺក៏សូមបញ្ជាក់ឡើងវិញអំពីចំណុចដែលលើកឡើងថាជាចំណុចសំខាន់នៃការសម្រុះសម្រួលដែលយើងហៅថាកំប្រូមីនេះនៅក្នុងការសម្រុះសម្រួលនេះ ទូលបង្គំខ្ញុំបាទមើលឃើញថាបើយើងគិតពីដំណាក់កាលៗ យើងឃើញថាមានការសម្របសម្រួល៤ជំហានយ៉ាងធំ ដែលបញ្ជាក់ពីការខិតខំរបស់ភាគីទាំងពីរសម្រុះសម្រួល៤ជំហានយ៉ាងធំ ហើយជំហានទី១គឺនៅពេលដែលយើងមានការឃ្លាតគ្នាទាំងស្រុង ម្ខាងទាមទារតុលាការអន្តរជាតិ យើងទាមទារតុលាការជាតិ ដូច្នេះជំហានទាំង៤នៃការសម្រុះសម្រួលនេះ នេះជាជំហានទី១គឺថាគេឈប់និយាយអំពីតុលាការអន្តរជាតិនេះគេនិយាយអំពីតុលាការដែលមានលក្ខណៈអន្តរជាតិ ដូច្នេះយើងបានឈានមកដល់ការសម្រុះសម្រួលលើកទី១ គឺថាតុលាការជាតុលាការជាតិៗ ប៉ុន្តែមានអង្គជំនុំជម្រះវិសាមញ្ញដែលមានចៅក្រមបរទេសចូលរួម ។ នេះជាការសម្រុះសម្រួលលើកទី១ជាគោលការណ៍ថ្មីនៅក្នុងច្បាប់តុលាការនៅក្នុងច្បាប់ខាងប្រព័ន្ធយុត្តិធម៌ ព្រោះថាមិនដែលមានដូចថា ទូលបង្គំខ្ញុំបាទបានលើកឡើងអ៊ីចឹង គឺថាវាអត់ដែលមានទេអាហ្នឹងអ្នកច្បាប់អន្តរជាតិ អ្នកច្បាប់ធំៗខាងតុលាការអន្តរជាតិហ្នឹង គាត់ត្រូវមករៀនសូត្រពីយើងវិញដកពិសោធន៍ពីយើងវិញ ព្រោះថាជាលើកទី១ដែលមាន ដែលមានគោលការណ៍របៀបនេះ ។ អ៊ីចឹងគឺថាអាច និងឯកឧត្តមអស់លោកច្បាប់អាចអ្នកឆ្ងល់ថាអ៊ីចឹងយើងធ្វើច្បាប់ម៉េចក៏អត់ត្រូវនិងច្បាប់ដែលយើងធ្លាប់មាន អ៊ីចឹង ពីព្រោះថាអានេះជាការករណីវិវត្តន៍ថ្មីជាករណីដែលមានលើកដំបូងនៅលើសកលលោក បើអ៊ីចឹងវាមិនអាចយកតែគោលការណ៍យកច្បាប់ដែលមានស្រាប់មកអនុវត្តទេអ៊ីចឹងគោលការណ៍ក៏ត្រូវថ្មីដែរ បើវាត្រូវបញ្ចេញជាលើកដំបូងអ៊ីចឹងដែរ ។ អ៊ីចឹងហើយការសម្របសម្រួលទី១នោះ គឺគោលការណ៍ថ្មីទី១ គឺតុលាការជាតិដោយមានអង្គជំនុំជម្រះវិសាមញ្ញ ហើយមានការចូលរួមពីចៅក្រមបរទេស ។ គោលការណ៍ទី២ ការសម្រុះសម្រួលទី២ ដល់បានអ៊ីចឹងហើយបានថា ឥឡូវយើងទទួលឲ្យចៅក្រមបរទេសចូលរួមហើយជំហានទី២នៅតែទាល់ច្រកទៀតនៅតែទើសគ្នាទៀត គឺគេលើកឡើងថាសូមឲ្យចៅក្រមបរទេសភាគច្រើនយើងថាចៅក្រមខ្មែរភាគច្រើន ។ អ៊ីចឹងវាគាំងមួយគន្លាក់ទៀតដោះស្រាយការគាំងនេះគឺថាយើងឈានមកដល់គោលការណ៍ថ្មីមួយទៀតគឺ ថាគេសុខចិត្តឲ្យយើងមានភាគច្រើន គេភាគតិច ប៉ុន្តែគេជា Minority bloquante នឹងជាភាគតិចដែលអាចរាំងស្ទះបាន អ៊ីចឹងគេចេញតាមរូបមន្តថ្មីមួយទៀតដែលមិនដែលមាននៅលើសកលលោកដែរ គឺការសម្រេចតាមរូបមន្តអ្វីដែលហៅថា Super Majorité អ្នកដែលសម្រេចបានកម្រិតទី៣មាន៩នាក់ ទាល់តែ៦នាក់បានសម្រេចបាន បានន័យថាទាល់តែមានចៅក្រមបរទេសម្នាក់ចូលរួមសម្រេចដែរ នឹងទើបយកការសម្រេចបាន ។ នេះជាគោលការណ៍ថ្មីទី២ដូចដែលទូលបង្គំខ្ញុំបានលើកឡើងថាវាអត់ដែលមាននៅតុលាការណាគេធ្វើអ៊ីចឹងទេ នេះជាលើកទី១ដែលយើងធ្វើអ៊ីចឹង ។ ជំហានទី៣នៃការសម្រុះសម្រួលគឺសហចៅក្រមស៊ើបអង្កេតដូចដែលទូលបង្គំខ្ញុំបានលើកឡើងគឺថាយើងបានប្រាប់គេថា បើអស់លោកមិនដែលស្គាល់អាចៅក្រមស៊ើបអង្កេតហ្នឹងផង មិនបាច់ធ្វើៗអី ទុកឲ្យកម្ពុជាធ្វើតែឯង លោកមានតែសហព្រះរាជអាជ្ញាបានហើយ ដល់អ៊ីចឹងអាហ្នឹងគេអត់ព្រមដែរៗ អ៊ីចឹងតាមការសម្រុះសម្រួលមួយរយៈទៅយើងឈានមោះដល់រូបមន្តសម្រុះសម្រួលទី៣ គឺឲ្យមានសហចៅក្រមស៊ើបអង្កេត ។ ចំណុចទី៤ ជំហានទី៤ដែលជាជំហានធំ ហើយមានសារៈសំខាន់ដែរមានសារៈសំខាន់ខ្លាំងមិនដែរទេ គឺនៅពេលដែលសហព្រះរាជអាជ្ញាគាត់មិនឯកភាពគ្នា បានន័យថាការងាររបស់សហព្រះរាជអាជ្ញាគឺគាត់ចោទប្រកាន់ អ៊ីចឹងម្នាក់ថាត្រូវចោទម្នាក់ថាទេអត់ចោទទេ អ៊ីចឹងត្រូវសម្រេចយ៉ាងម៉េច ។ ត្រូវសម្រេចយ៉ាងម៉េច ព្រោះធម្មតាតែសហៗ អ៊ីចឹងទាល់តែ២នាក់ព្រមជាមួយគ្នា ជាគោលការណ៍គឺថាយើងនិយាយពីសហប្រតិបត្តិការ ដូច្នេះគោលការណ៍ទី១ថាត្រូវធ្វើយ៉ាងម៉េច២នាក់នឹងឲ្យគាត់មាន កុងសង់សុស (Consensus) ជាមួយគ្នាបាទ ឲ្យគាត់មានភាពឯកច្ឆ័នជាមួយគ្នាដើម្បីធ្វើការជាមួយគ្នា ឲ្យរត់លួនជាមួយគ្នា ប៉ុន្តែយើងក៏បានត្រៀមថាចុះបើគាត់មិនរត់លួនបាន គាត់រលូនៗទៅមួយកម្រិតទៅ ទៅថ្ងៃកន្លែងមួយគាត់ទាស់គ្នាទៅធ្វើម៉េចអ៊ីចឹងបានឯកភាពគ្នាយកដំណោះស្រាយមួយគឺបង្កើតឯកសារច្បាប់ថ្មីទៀត អានឹងក៏ថ្មីមិនដែលមានទេមិនដែលមាននៅក្នុងប្រវត្តិច្បាប់

តុលាការទេ គឺអ្វីដែលគេហៅថាគេប្រើពាក្យអង់គ្លេសថា Pre-trial chamber ។ Pre-trial chamber បានន័យថាហ្នឹងមុនជំនុំជម្រះគេមិនទាន់ជំនុំជម្រះទេ គេជម្រះមួយគន្លាក់សិន ក្បាលម៉ាស៊ីនហ្នឹងគាត់ជម្រះមួយគន្លាក់សិន ក្បាលម៉ាស៊ីនហ្នឹង យើងបកជាខ្មែរថា អង្គបុរេជំនុំជម្រះ បើអ៊ីចឹងអាចឯកឧត្តមអស់លោកហ្នឹង សួរទូលបង្គំខ្ញុំបាទថាអ្ហេ ម៉េចក៏ប្រើពាក្យអីថ្មីមកពីណាទៀត ហើយពាក្យហ្នឹងវាមិនដែលមានក្បាលម៉ាស៊ីនហ្នឹងវាមិនដែលមានផង អ៊ីចឹងទាល់តែរកពាក្យថ្មីដាក់ អ៊ីចឹងពាក្យថ្មីហ្នឹងគឺយើងដាក់ថាអង្គបុរេជំនុំជម្រះ សួរថាអ្ហេនៅក្នុងតុលាការមិនដែលឮអាហ្នឹងមិនដែលឮមានអង្គបុរេជំនុំជម្រះ ហ្នឹងថាព្រោះវាថ្មីមែន មិនដែលមានមែនដល់វាថ្មីអត់ដែលមានអានេះវាទើបតែកើតលើកទី១ ដើម្បីផ្តល់ដំណោះស្រាយក្នុងករណីដែលសហព្រះរាជអាជ្ញាឬសហចៅក្រមស៊ើបអង្កេតគាត់ទាស់គ្នាៗ ។ អ៊ីចឹងឲ្យគេកាត់លើគាត់មួយគន្លាក់សិន បាទអ៊ីចឹងនេះជាដំណោះស្រាយដែលជាជំហានទាំង៤នៃការសម្រុះសម្រួលរវាងយើងនិងអង្គការសហប្រជាជាតិ ។ នៅក្នុងការសន្និដ្ឋាន ទូលបង្គំខ្ញុំបាទយល់ឃើញថាបើយើងពិនិត្យច្បាប់នេះគឺទាល់តែយើងគិតអំពីទិដ្ឋភាពទាំងអស់ឲ្យគ្រប់ជ្រុងជ្រោយបានន័យថា ទាំងទិដ្ឋភាពច្បាប់ ទាំងទិដ្ឋភាពនយោបាយ ទាំងទិដ្ឋភាពប្រវត្តិសាស្ត្រ វាពាក់ព័ន្ធគ្នា វាប្រទាក់ប្រទិនគ្នាទាំងអស់បើយើងគិតតែអំពីច្បាប់យើងផ្អែកទៅលើច្បាប់អ្វីដែលយើងមានស្អីដែលយើងអត់យើងថាខុសច្បាប់ អាហ្នឹងគឺអត់ទៅរួចទេ ច្បាប់នេះអ៊ីចឹងបានទូលបង្គំខ្ញុំបាទសូមលើកចំណុចនេះជាមុនសិន បើយើងគិតថាអ្ហេ យើងយកតែច្បាប់ដែលមានយើងយកច្បាប់ដែលមាន យកមកមើលតម្រូវកន្លែងណាដែលច្បាប់នេះអត់មានយើងគិតថាអាហ្នឹងខុសច្បាប់គឺច្បាប់នេះទៅមិនរួចទេ ហើយច្បាប់នេះលើកឡើងនូវរូបមន្តថ្មីនៃទស្សនាទានថ្មី ហើយក៏គោលការណ៍ថ្មីធំៗដូចដែលទូលបង្គំខ្ញុំបាទបានទូលថ្វាយនិងជម្រាបជូនអង្គសភាជាទីគោរពដែរ ហើយដែលឆ្លុះបញ្ចាំងនូវជំហានសម្រុះសម្រួលទាំង៤ដ៏ធំៗដែលជាការជាលទ្ធផលនៃការចរចាយ៉ាងយូរអង្វែងនៃដំណើរការមួយយ៉ាងយូរអង្វែងតាំងពី៩៧,៩៨,៩៩ ដល់ចុង២០០០យើងនេះ ទូលបង្គំខ្ញុំបាទសូមធ្វើសេចក្តីផ្តើមតែប៉ុណ្ណេះ ។

**សម្តេចក្រុមព្រះ:** សូមអរគុណឯកឧត្តម ឥឡូវឈានទៅដល់ការពិនិត្យពិភាក្សាលើជំពូកទី១ សូមស្នើអញ្ជើញសម្រាក ។

សូម ម៉ៅញ សាផាន អានជំពូកទី១ជូនអង្គសភា ។

**ឯកឧត្តម ម៉ៅញ សាផាន:** ទូលបង្គំខ្ញុំបាទសូមព្រះរាជានុញ្ញាតនិងអនុញ្ញាតពីអង្គសភាទាំងមូលដើម្បីអាននូវជំពូកទី១ ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ជំពូកទី១ បទបញ្ញត្តិទូទៅ មាត្រា១ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជាការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ហើយ ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩ ។ ទូលព្រះបង្គំខ្ញុំបាទ សូមព្រះរាជានុញ្ញាតនិងអនុញ្ញាតដាក់ជូននូវខ្លឹមសារនៃជំពូកទី១នេះថ្វាយនិងជូនអង្គសភាដើម្បីពិភាក្សានិងអនុម័តតាមការគួរសូម អរព្រះគុណនិងអរគុណ ។

**សម្តេចក្រុមព្រះ:** សូមអញ្ជើញឯកឧត្តម ជាម យៀប

**ឯកឧត្តម ជាម យៀប:** សូមថ្វាយបង្គំសម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភា សូមគោរពសម្តេចអនុប្រធានទី១ ឯកឧត្តមអនុ ប្រធានទី២និងសូមធ្វើការវេកិច្ចចំពោះអង្គសភាទាំងមូលជាទីស្នេហា ចំពោះសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនៅក្នុងជំពូកទី១ ស្តីពីបទបញ្ញត្តិនិងមាត្រា១មានតែមួយមាត្រានេះទូលបង្គំសូមមកចូលរួមចំណែកដើម្បីពិភាក្សាដែលមានខ្លឹមសារដូចតទៅ ។ ជាបឋម ជំនួសមុខក្នុងនាមតំណាងរាស្ត្រមណ្ឌលព្រៃវែង ទូលបង្គំខ្ញុំសូមសម្តែងនូវការដឹងគុណនិងអរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះរាជរដ្ឋាភិបាល សហគមអន្តរជាតិទាំងឡាយពិសេសអង្គការសហប្រជាជាតិដែលបានយកចិត្តទុកដាក់បង្កើននូវវណ្ណកម្មថ្មីជាប្រវត្តិសាស្ត្រដល់កម្ពុជាអីដែលមានសេចក្តីព្រាងច្បាប់នេះជាអាទិ៍ ។ ទូលបង្គំសូមក្រោយពីបានទទួលនូវរបាយការណ៍ក៏ដូចជានូវសេចក្តីរាយការណ៍ ជាក់ស្តែងរបស់ឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីនៃក្រុមប្រឹក្សារដ្ឋមន្ត្រី ទូលបង្គំសូមឯកភាពទាំងស្រុងលើខ្លឹមសារនៃសេចក្តីព្រាងមាត្រា១នេះ ប៉ុន្តែទន្ទឹមនឹងការឯកភាពនេះក៏សូមជម្រាបជូនអំពីមូលហេតុនៃការឯកភាពមានដូចតទៅៈ ទី១) ទូលបង្គំ ខ្ញុំយល់ឃើញថាក្រោយពីបានទទួលនូវសេចក្តីព្រាងច្បាប់នេះគឺរាជរដ្ឋាភិបាលក៏ដូចជាសហគមអន្តរជាតិ ពិសេសអង្គការសហប្រជាជាតិបានឯកភាពគ្នាដើម្បីធ្វើយ៉ាងណាជំរុញឲ្យសេចក្តីព្រាងច្បាប់នេះឡើងដោយឈរលើគោលការណ៍៣ដែលប្រជាជាតិ ក៏ដូចជាប្រជាជនកម្ពុជាទាំងមូលកំពុងតែរង់ចាំ ទីមួយ នៅលើយុត្តិធម៌ លើយុត្តិធម៌នេះ ឯកឧត្តម សុខ អាន លោកបានជម្រាបជូនអង្គសភារួចហើយ គឺថាធំបំផុត

ក្នុងប្រវត្តិសាស្ត្រនៃមនុស្សជាតិក៏ដូចជាកម្ពុជាគឺក្នុងរយៈពេលពី១៧ មេសា ៧៥ ដល់៦ មករា ៧៩ គឺជារយៈពេលស្ថិតនៅក្នុងរបត់អន្ធកាលមួយរបស់ប្រជាជាតិកម្ពុជា ។ អន្ធកាលនេះគឺមានការកាប់សម្លាប់ដ៏អយុត្តិធម៌អ៊ីចឹងទេ ដើម្បីបន្ថយការប្រទេចផ្តាសានៃប្រជាជនដែលត្រូវរងគ្រោះព្រមទាំងត្រូវកាប់សម្លាប់ដោយអំពើអយុត្តិធម៌នៃរបបចន្លោះឆ្នាំ៧៥ ដល់៧៩នេះគឺច្បាប់នេះបានលើកឡើងជាអាទិ៍ដូចឯកឧត្តម សុខ អាន បានជម្រាបជូន ។ ទី២ទៀតយើងពិនិត្យឃើញថា ដើម្បីកុំឲ្យមានអវិភាពរវាងអ្នកដែលធ្លាប់រស់នៅហើយធ្លាប់ជួបប្រទះនៅក្នុងរបបនេះដែលមានគ្រួសារគេដែលបានបាត់បង់ជីវិត ដោយសារតែរបបនេះបានសម្លាប់ដោយអយុត្តិធម៌និងធ្វើទុក្ខបុកម្នេញដោយអយុត្តិធម៌ យើងឃើញថាច្បាប់នេះបានលើកឡើងអំពីការកាត់ទោសនៃមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ ។ ទី៣ទៀត ទូលបង្គំឯកភាពទៅលើច្បាប់នេះដែលបានចែងនូវគោលការណ៍ទី៣ដែលស្តីអំពីអធិបតេយ្យភាព ។ អធិបតេយ្យភាពទោះបីយ៉ាងណាក៏ដោយ យើងឃើញថាទី១គឺយើងបានការពារនូវអធិបតេយ្យរបស់រាជាណាចក្រកម្ពុជាដោយរៀបចំនូវស្ថាប័នក៏ដូចជារចនាសម្ព័ន្ធ ឬក៏យន្តការមួយនៃតុលាការវិសាមញ្ញនេះឡើងដើម្បីធ្វើយ៉ាងណាឲ្យគឺថាអង្គចៅក្រម ឬក៏ចៅក្រមនៃកម្ពុជាមានចំនួនច្រើនជាងបរទេសដែលមានការចូលរួមពីបរទេសមួយចំនួនតែប៉ុណ្ណោះ ។ ទូលបង្គំខ្ញុំសុំជម្រាបជូនដល់អង្គសភាផងដែរថា ទូលបង្គំសូមអំពាវនាវដល់ទៅបងប្អូនដែលធ្លាប់បានស្ថិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សុំកុំឲ្យយល់ច្រឡំយើងមើល ខ្លឹមសារនៃច្បាប់នេះគឺមានគោលបំណងច្បាស់ណាស់គឺច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាធិបតេយ្យ អ៊ីចឹងទេគឺថាស្នើក៏ដូចជាអំពាវនាវចំពោះមន្ត្រីស៊ីវិលឬក៏មន្ត្រីយោធានិងយុទ្ធជនដែលធ្លាប់បានរស់នៅក្នុងរបបខ្មែរក្រហមនិងចូលរួមក្នុងរបបខ្មែរក្រហម ក្រោយពីធ្វើសមាហរន្តកម្ម ឬចុះចូលរាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន រួចហើយនោះគឺថាសូមមេត្តាកុំមានការព្រួយបារម្ភអ្វី ពីព្រោះថាកន្លងទៅក្នុងនាមខ្ញុំបាទជាទូលបង្គំខ្ញុំបាទជាអ្នកតំណាងរាស្ត្របានស្តាប់ទៅ គឺថាបងប្អូនដែលធ្លាប់នៃចូលរួមក្នុងសកម្មភាពនៃកម្ពុជាធិបតេយ្យគឺថាមានអានៃមានការរំដើបរំជួលខ្លះ ប៉ុន្តែទូលបង្គំខ្ញុំសុំអំពាវនាវថាកុំឲ្យមានការរំដើបរំជួលអីពីព្រោះអ្វីមាត្រាមួយនេះបានចែងច្បាស់ណាស់អំពីបំណងគោលបំណងទិសដៅនៃច្បាប់នេះគឺវិនិច្ឆ័យទោស ចំពោះតែមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះទេ ។ ប៉ុន្តែមេដឹកនាំនេះក៏ចែកចេញជាពីរទៀតតាមការអំពាវនាវរបស់រាជរដ្ឋាភិបាលកម្ពុជាក៏ដូចជាការអនុគ្រោះទោសរបស់អ្វីព្រះមហាក្សត្រឬក៏របស់សភាជាតិកន្លងមកហើយយើងឃើញថានេះគឺជាអ្វីគោលការណ៍របស់អង្គជម្រះក្តីនៃអ្វីក្រុមប្រឹក្សាក្រុមជំនុំជម្រះវិសាមញ្ញនៃតុលាការវិសាមញ្ញនេះទេ អ៊ីចឹងទេបានជាយើងចែកចេញជាពីរគឺថាមិនមែនតែមេដឹកនាំទាំងស្រុងដែលគ្មានការអ្វីមួយគឺថាមានអាដែងនៃការសណ្តោះត្រាប្រណីដែលមានព្រះមហាក្សត្រ ឬក៏មានអ្វីតំណាងរាស្ត្រដែលបានធ្វើកន្លងមក ហើយមួយទៀតគឺថាបានចូលមកសុំអ្វីជ្រកកោន ឬក៏មកសុំចុះចូលជាមួយរាជរដ្ឋាភិបាលអ៊ីចឹងទេបានជាទូលបង្គំមានការបារម្ភថាខ្លាចក្រែងបងប្អូនដែលបានចូលមករួមរស់នៅក្នុងមហាសង្គមខ្មែរវិញហើយនោះគឺថាលោកមានអ្វីបានទទួលនូវពីពេលនេះទៅហ៊ើនូវសភាកំពុងតែធ្វើការអ្វីពិភាក្សាអនុម័តច្បាប់ទៅលោកមានការព្រួយបារម្ភអ៊ីចឹងទេគឺថាសុំមេត្តាកុំមានការព្រួយបារម្ភអីទាំងអស់គឺថាក្នុងច្បាប់នេះគឺថាបានចែងអំពីគោលបំណងនៃការវិនិច្ឆ័យទោសនេះចំពោះតែមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាធិបតេយ្យទូលបង្គំខ្ញុំអស់យោបល់សូមអរគុណ! អរគុណ! ។

**សម្តេចក្រុមព្រះ :** ស្នើសុំឯកឧត្តម ប៉ែន បញ្ញា

**ឯកឧត្តម ប៉ែន បញ្ញា:** សូមថ្វាយបង្គំសម្តេចព្រះប្រធាន សូមគោរពអង្គសភា ជារួមទូលបង្គំខ្លួន ខ្ញុំបាទសុំឯកភាពទៅលើបទបញ្ញត្តិជាទូទៅនេះ ជំពូកទីមួយនេះដែលមានតែមួយមាត្រា ប៉ុន្តែបានកំណត់ច្បាស់លាស់អំពីគោលបំណងអំពីមុខសញ្ញាដែលត្រូវវិនិច្ឆ័យទោសនិងអំពីកាលបរិច្ឆេទច្បាស់លាស់នេះជាបទបញ្ញត្តិទូទៅដែលគ្របដណ្តប់ទៅលើខ្លឹមសារទាំងឡាយនៃច្បាប់ដែលសភាយើងពុំភ្លេចយក ខ្ញុំបាទរីករាយដោយយើងកំពុងតែខិតខំបិទនូវទំព័រប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតមួយរបស់ប្រជាជាតិកម្ពុជាយើង ។ ការបិទទំព័រនេះវាមិនងាយស្រួលដូចយើងបិទទំព័រសៀវភៅដែលយើងចេញពីប្រជុំបន្តិចទេ ពីព្រោះប្រវត្តិសាស្ត្រវាជក់ទៅដោយញើសឈាមជីវិត ទារុណកម្មរបស់មនុស្សរាប់លាននាក់ ដូច្នេះចាំបាច់យើងត្រូវតែបិទទំព័រប្រវត្តិសាស្ត្រនេះប្រកបដោយយុត្តិធម៌ ប្រកបដោយមនសិកាប្រកបដោយកិត្តិយសនិងដោយការទទួលខុសត្រូវ យើងបិទទំព័រនេះដោយយើងគោរពដល់វិញ្ញាណក្ខ័ន្ធដល់អ្នកដែលបានបាត់បង់ជីវិតទៅគោរពទៅដល់អចិភាពប្រជាជនខ្មែរដែលកំពុងតែរស់រាន្តមានជីវិតសព្វថ្ងៃនេះនិងគោរពទៅដល់អនាគតកូនចៅដែលជាអ្នកបន្តវេន ។ ការបិទទំព័រប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតនេះចាត់ទុកដូចជាស្នូរជួងអមតៈមួយដែលរន្ទឺឡើងដើម្បីដាស់នូវអារម្មណ៍របស់ជនខ្មែរគ្រប់រូបដាស់នូវអារម្មណ៍របស់បណ្តាលប្រជាជាតិដទៃទៀតដែលកំពុងតែរងគ្រោះរងលំបាកវេទនាដោយសារអំពើប្រល័យពូជសាសន៍ឬក៏អំពើរើសអើងផ្សេងៗដាស់នូវអារម្មណ៍របស់មនុស្សជាតិទាំងមូល ធ្វើយ៉ាងណាឲ្យយើងទាំងអស់គ្នាឲ្យគ្រួសារនៃមនុស្សជាតិទាំងអស់បានទទួលនូវសុខសន្តិភាពមានសិទ្ធិសេរីភាពរស់នៅបានសុខសាន្តនៅក្នុងពិភពលោកយើងនេះសូមអរព្រះគុណ! សូមអរគុណ! ។ (**នៅមានត**)

# សៀវភៅកំណត់ហេតុជីវិត

**(តពីលេខមុន) ម័រហ្គាត ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៧៥**

ថ្ងៃនេះធាតុអាកាសត្រជាក់ មានខ្យល់បក់បោកយ៉ាងច្រើន ទឹកសមុទ្ររលកបែកផ្កាគ្រែងសស្កុស ថ្វីត្បិតតែត្រជាក់តែមាន ថ្ងៃរះយ៉ាងត្រចះ ខ្ញុំអង្គុយនៅក្នុងបន្ទប់តែម្នាក់ឯងគន់មើល ទៅទឹករលក ។ សមុទ្រមានពណ៌ប្លែកៗទៅតាមពន្លឺដែលថ្ងៃចាំង ។ ទេសភាពដ៏ត្រជាក់នៃខែកញ្ញាធ្វើឲ្យខ្ញុំនឹកដល់ស្រុកកំណើតណាស់ ។ ខ្ញុំមិនដឹងថាតើមានមន្តស្នេហ៍អ្វីបានជានឹកជានិច្ចដល់ស្រុកខ្មែរ ទោះបីគេនិយាយបន្តុះបង្អាប់របបថ្មីនេះយ៉ាងណា ចំពោះខ្ញុំ ខ្ញុំនៅតែមានជំនឿថារបបនេះមិនមែនអាក្រក់ទេ ខ្ញុំទៅស្រុក ខ្មែរវិញមិនមែនទៅដោយសារនយោបាយបង្ខំឲ្យខ្ញុំទៅនោះទេ ។ ការវិលត្រឡប់របស់ខ្ញុំពិតជាផុសពីដួងចិត្តខ្ញុំដោយគ្មានល្អក់ គឺខ្ញុំត្រូវតែបម្រើប្រយោជន៍ខ្មែរ ទោះជាខ្មែរជាប្រទេសក្រខ្ញុំត្រូវ ធ្វើការពិបាកយ៉ាងណាក៏ដោយ ឲ្យតែកម្លាំងដែលខ្ញុំធ្វើនោះចូល ក្នុងចំណែកនៃការជួយដល់ការកសាងជាតិខ្មែរ ។ ការពិតការរស់ នៅក្នុងប្រទេសសម្ភារនិយមពិតជាសប្បាយហើយជាក់ស្តែង តាមការពិតគឺយើងជាទាសករនៃវត្ថុទាំងនោះ ។ ខ្ញុំស្រឡាញ់ ធម្មជាតិ ចូលចិត្តធម្មជាតិ ត្រូវតែត្រឡប់ទៅរស់នៅក្នុងសង្គម ជាតិមួយដែលខ្ញុំស្រឡាញ់ ដែលបានកសាងខ្ញុំ ។ ការរស់បានត្រឹម តែមួយរស់ដូចគ្នាតើមានអ្វីប្លែកទៅ បើដូច្នេះដដែលរស់នៅក្នុង ស្រុកយើងវិញប្រសើរជាងនៅធ្វើការដូចខ្ញុំគេនៅទីនេះ ។ ហើយ មួយចំណែកទៀតខ្ញុំត្រូវតែត្រឡប់ទៅវិញ ព្រោះខ្ញុំចង់ជួបមុខ គ្រួសារដែលព្រាត់ប្រាសអស់កាលជាយូរមកហើយ ។ តើ សប្បាយអ្វីតែម្នាក់ឯង បើម្តាយជាទីស្រឡាញ់មានទុក្ខព្រួយរាល់ ពេលវេលាព្រោះគិតមកដល់រូបខ្ញុំ ។ តើសប្បាយអ្វីនឹងរស់នៅ ទីនេះបើខាងផ្លូវចិត្តគ្មានស្ងប់ស្ងៀមសោះស្គាល់តែភាពកង្វល់ ព្រួយគ្មានល្ហែ ។ សូវលំបាកកាយប្រសើរជាងលំបាកចិត្ត ។ ហេតុនេះហើយបានជាខ្ញុំហាក់សម្រេចចិត្តថាត្រឡប់ៗ ត្រឡប់ ទៅវិញៗ ។ ទោះជាលំបាកម្តេចម្តាក៏ខ្ញុំអាចទ្រាំបានទាំងអស់ ឲ្យតែខាងផ្លូវចិត្តបានស្រួលស្ងប់ស្ងៀម ។

**ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៧៥**

ថ្ងៃនេះមេឃមិនសូវមានពន្លឺថ្ងៃទេ ធាតុអាកាសត្រជាក់ ខ្ញុំមិនសូវស្រួលខ្លួនសោះដោយសារអាកាសត្រជាក់ពេក ។ ទឹកសមុទ្រនឹងថ្កល់ មេឃចុះអ័ព្ទមើលអ្វីមិនបានឆ្ងាយទេ ខ្ញុំនៅក្នុង បន្ទប់តែឯងរៀបចំឥវ៉ាន់ដើម្បីត្រឡប់ទៅប៉ារីសវិញ ខ្ញុំតែងនឹកថា តើខ្ញុំបានមកទីនេះម្តងទៀតទេ ។ នៅទីនេះទេសភាពល្អណាស់ គួរឲ្យទាក់ភ្នែកជាប់ចិត្តជាប់គំនិត តែមនុស្សដែលនៅជុំវិញខ្ញុំ មានប្លែកៗគ្នា ខ្លះល្អ ខ្លះអាក្រក់ តែនៅទីនេះអាចឲ្យខ្ញុំដឹងចិត្ត អ្នកដែលខ្ញុំធ្វើការជាមួយយ៉ាងច្បាស់ណាស់ ។ ឱចិត្តមនុស្ស! គ្មានអ្នកណាម្នាក់សប្បាយនឹងការបម្រើនៃមនុស្សម្នាក់ទៀតទេ ។ ឱ! ជីវិតខ្ញុំមានតែឧបសគ្គជានិច្ច មិនដែលបានស្រួលចិត្ត ស្រួល កាយរហូតទេ ។ ឱទឹកសមុទ្រ! ថ្ងៃនេះអ្នកមិនបោកបក់ដូចរាល់ថ្ងៃ ទេ សោតឯសម្រស់អ្នកក៏ស្រពាប់ស្រពោនជាងរាល់ថ្ងៃដែរ តើ មានមានទុក្ខព្រួយដែរឬទេ? តើហេតុក៏អ្នកចេះប្រែប្រួលសម្រស់ ដូច្នេះដែរ ។ អ្នកហាក់ដូចជាដឹងថាខ្ញុំមានកង្វល់ ។ ឱ! មានតែ ធម្មជាតិទេដែលចេះកំដរអារម្មណ៍ខ្ញុំកុំឲ្យអផ្សុកឲ្យប្រាសចាកទុក្ខ កង្វល់បានមួយគ្រាៗ បើគ្មានអ្នកទេប្រហែលជាខ្ញុំតឹងទ្រូងជាងនេះ ឆ្ងាយណាស់ ។ ម៉ោង៩យប់ទៅហើយ ថ្ងៃនេះខែរះភ្លឺត្រចះតែ មិនទាន់ពេញវង់នៅឡើយទេ ចាំងរស្មីផ្ទេកលើទឹកសមុទ្រនឹងថ្កល់ គេអាចមើលឃើញច្បាស់នូវកប៉ាល់ចម្បាំងមួយដែលបំភ្លឺដោយ ពន្លឺព្រោងព្រាត ធាតុអាកាសត្រជាក់ណាស់ ខុសពីស្រុកខ្ញុំ កាលណាមានព្រះចន្ទភ្លឺថ្លាដូច្នេះគេអាចអង្គុយយកខ្យល់អាកាស គយគន់សម្រស់ ទេសភាពរាត្រីបានយ៉ាងសប្បាយ តែនៅទីនេះ ត្រជាក់ណាស់គេមិនអាចធ្វើដូច្នេះកើតទេ ។ ឱ! ខ្ញុំស្រណោះ ណាស់ រាត្រីចន្ទថ្លានៃផ្ទះកំណើតខ្ញុំ សម្រស់ទន្លេមេគង្គក្រោមពន្លឺ ចន្ទថ្លាក៏មិនចាញ់សម្រស់ទេសភាពនៅទីនេះដែរ តើថ្ងៃណាទើ៍ខ្ញុំ បានយល់ភូមិកំណើតខ្ញុំ ។ ៦ឆ្នាំហើយដែលខ្ញុំចាកចេញពីភូមិ កំណើត ។ ហើយ២ឆ្នាំគត់ហើយដែលខ្ញុំបែកពីគ្រួសារជាទី ស្រឡាញ់និងជាទីគោរព គំនិតដក់ជាប់ជានិច្ចនិងចងចាំជានិច្ចនូវ

ព្រឹត្តិការណ៍ទាំងឡាយ ។ កូនបែកពីលោកឪពុកអ្នកម្តាយទាំងខ្លោចផ្សាបំផុត ។ ពេលខ្ញុំនឹកដល់ម្តាយខ្ញុំ ខ្ញុំនឹករឮកឃើញនូវពាក្យដំបូន្មានគាត់ នឹកឃើញនូវគុណសម្បត្តិរបស់ម៉ែដែលគ្មានពីរ ។ ម៉ែពុកជាអ្នកក្រ តែលោកប្រឹងខំតស៊ូគ្រប់ឧបសគ្គទាំងអស់ដើម្បីកូន ៗ ខាងជាតិ ខាងនយោបាយ ក៏ឆាប់ចេះយល់ច្បាស់ ។ ឱ! បើសិនជាស្ត្រីខ្មែរទាំងអស់មានចិត្តគំនិតដូចម៉ែ ម៉្លេះសមស្រុកខ្មែរមានការជឿនលឿនល្អណាស់ ។ កូនឃើញគ្រួសារគេជុំគ្នា កូនរឮកម៉ែណាស់ ។ ម៉ែប្រហែលមិនដឹងថាកូនមកដល់ទីទេ ។ ម៉ែមិនដឹងថាជីវិតកូនស្រីម៉ែរសាត់មកដល់ទីនេះសោះ ។ កូនរឮកម៉ែពុកណាស់រកពាក្យណាមកថ្លែងឲ្យស្មើពុំបានឡើយ ។ កូនតែងចងចាំជានិច្ចដំបូន្មានម៉ែ អ្វីដែលម៉ែផ្តែផ្តាំ រូបម៉ែឃ្លាតឆ្ងាយពីកូនមែន តែគំនិតម៉ែ ឧត្តមគតិម៉ែ នៅជាប់ជាមួយកូនជានិច្ច ។ ហើយទោះជាយ៉ាងណា ទោះជាមានឧបសគ្គយ៉ាងណាក៏កូនតស៊ូយកជ័យជំនះលើជីវិតឲ្យបាន ហើយសង្ឃឹមថានឹងត្រឡប់ទៅជួបម៉ែក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ ដើម្បីរួមចំណែកក្នុងការកសាងប្រទេសខ្មែរឲ្យរុងរឿង ។

**ម៉័រហ្គាត ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៥**

ថ្ងៃនេះធាតុអាកាសត្រជាក់ដែរតែមានថ្ងៃរះហើយមិនសូវមានអ័ព្ទ ។ កុំអីថ្ងៃនេះខ្ញុំត្រូវទៅដល់ប៉ារីស តែឥឡូវត្រូវលើកទៅវិញ ។ ឱម៉័រហ្គាត! ធាតុអាកាសត្រជាក់ណាស់ពេលធ្លាក់ខ្យល់ម្តងៗ តើឆ្នាំក្រោយខ្ញុំបានមកទៀតឬទេ? ឬមួយខ្ញុំត្រូវត្រឡប់ទៅស្រុកវិញ? ឱ! នឹកឃើញរឿងទៅស្រុកវិញខ្ញុំសែនសប្បាយលាយការព្រួយបារម្ភ ។ សប្បាយព្រោះសង្ឃឹមថាបានជួបគ្រួសារ បានជួបមិត្តភក្តិ បារម្ភព្រោះខ្លាចប្រទេសខ្ញុំមិនមែនឯករាជ្យម្ចាស់ការដោយខ្លួនឯង ។ ចិត្តគំនិតគិតវិលវល់ស្ទើររាល់ថ្ងៃនៅលើតែបញ្ហាជាតិ គិតហើយគិតទៀត តែទោះយ៉ាងណាក៏ខ្ញុំសម្រេចចិត្តថាត្រូវតែទៅដើម្បីឲ្យឃើញព្រឹត្តិការណ៍ដែលកើតឡើងនៅស្រុកខ្ញុំឲ្យច្បាស់ជាក់នឹងភ្នែក ទោះលំបាកម្តេចម្តាក៏ខ្ញុំត្រូវតែទៅ ក្នុងជីវិតនេះខ្ញុំស្គាល់អស់ហើយការពិបាកកាយពិបាកចិត្ត ការស្រួល ស្រណុក ការដែលគេបម្រើការដើរលេងទស្សនាស្រុកគេ ខ្ញុំធ្លាប់បានឃើញវប្បធម៌ស្រុកជឿនលឿន បានឃើញប្រទេសដែលគេថាបានអភិវឌ្ឍ ប្រទេសដែលកំពុងអភិវឌ្ឍ តែប្រទេសទាំងអស់ដែលខ្ញុំស្គាល់អាចធ្វើឲ្យខ្ញុំចេះវិនិច្ឆ័យដល់ប្រទេសខ្ញុំ អាចឲ្យខ្ញុំស្គាល់តម្លៃនៃប្រទេសខ្ញុំច្បាស់ ហេតុនេះហើយបានជាចិត្តខ្ញុំនៅតែដក់ជាប់ជានិច្ចចាំជានិច្ចនូវទំនៀមទម្លាប់ សម្រស់ និងធនធាននៃប្រទេសខ្ញុំដែលគេចាត់ទុកថាជាប្រទេសមិនទាន់អភិវឌ្ឍ ខ្ញុំយល់ថាខ្ញុំបានឃើញប្រទេសគេដូច្នេះខ្ញុំនឹងយកគំនិតខ្លះដែលអាចអនុវត្តនៅស្រុកខ្ញុំបានទៅអនុវត្តដើម្បីច្នៃប្រឌិតនូវភាពក្រខ្សត់នៃប្រជាជនឲ្យមានភាពភ្លឺថ្លាស្រណុកសុខសប្បាយឡើង ។ បើសិនជាការវិលត្រឡប់របស់ខ្ញុំមានជួបឧបសគ្គយ៉ាងណាក៏ខ្ញុំពេញចិត្តទាំងអស់ ព្រោះជាការសម្រេចចិត្តរបស់ខ្ញុំដែលធ្វើឡើងដោយការគិតពិចារណាដ៏ហ្មត់ចត់ ។ រូបខ្ញុំមិនអាចសូមជាអ្នកជ្រកកោនផ្នែកនយោបាយបានទេ ។ ខ្ញុំធ្លាប់រស់នៅក្នុងត្រកូលអ្នកក្រខ្សត់ រូបខ្ញុំមិនឈ្លក់នឹងទ្រព្យសម្បត្តិ មិនឈ្លក់នឹងភាពសង្ហានៅស្រុកគេទេ ថ្វីត្បិតតែនៅទីនេះខ្ញុំអាចដើរលេងសប្បាយតាមចិត្តក្តី ក៏ខ្ញុំមិនពេញចិត្តមិនសប្បាយនឹងរស់នៅទីនេះដែរ ។ ពីព្រោះរូបរាងខ្ញុំជាកូនខ្មែរខ្ញុំត្រូវខំជួយប្រទេសខ្មែរដែលបានខំចិញ្ចឹមខ្ញុំតាំងពីតូចរហូតដល់ធំ ។ ចំពោះខ្ញុំការជម្លៀសនៃទីក្រុងភ្នំពេញនេះពិតជាត្រូវណាស់ គឺឲ្យមនុស្សទាំងអស់គ្នាមានឋានៈស្មើគ្នាទាំងអស់ នេះមិនមែនជាការសងសឹកទេគឺជាការបោសសម្អាតសង្គមចាស់ដែលពោរពេញដោយការពុករលួយឲ្យស្អាតស្អំតាំងពីឫសគល់ឡើងទៅ ឲ្យអស់មនុស្សដែលធ្លាប់ជិះជាន់គេ ។ ដែលធ្លាប់តែគេបម្រើឆ្អែតស្កប់មិនស្គាល់ច្បាស់ការលំបាកវេទនារបស់អ្នកឯទៀតដែលខំធ្វើដើម្បីបម្រើខ្លួន ។ ហេតុនេះហើយបានជាខ្ញុំយល់ថាត្រូវ ។ តែចំពោះអ្នកដែលមិនធ្លាប់ស្គាល់ការពិបាកសោះនោះគេពិតជាយល់ច្រាកដថាឋាននរកពិតៗ ព្រោះខ្លួនមិនដែលបានស្គាល់សោះដូចម្តេចដែលហៅថាការនឿយលំបាក ។ មិនដែលស្គាល់ដូចម្តេចដែលហៅថាដើមស្រូវ ។ ហេតុដូចនេះហើយបានជាខ្ញុំសម្រេចចិត្តត្រឡប់ទៅវិញដើម្បីឲ្យបានឃើញឲ្យច្បាស់នឹងភ្នែកនូវហេតុការណ៍ទាំងនេះ ។

**ម៉័រហ្គាត ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៧៥**

យប់នេះជាយប់ចុងក្រោយបង្អស់ដែលខ្ញុំត្រូវនៅម៉័រហ្គាត ។ យប់នេះភ្លៀងរលឹមស្រិចៗមើលទៅគ្មានឃើញអ្វីទាំងអស់ ចុះអ័ព្ទមើលអ្វីមិនឃើញសោះឡើយ ឃើញតែសស្កុស ។ ខ្ញុំនឹងចាកចេញពីម៉័រហ្គាតនៅព្រឹកស្អែក ។ ខ្ញុំមិនដឹងថាតើឆ្នាំ

ក្រោយខ្ញុំបានមកទៀតឬទេ? ឱធម្មជាតិ! អ្នកហាក់ដូចជាជួយព្រួយខ្ញុំ ដូចមានកន្សល់ដោយបាត់រូបខ្ញុំពីទីនេះឬ? យប់នេះអារម្មណ៍ខ្ញុំហាក់ហោះហើរទៅឆ្ងាយ ឆ្ងាយ ៗ រកទិសដៅគ្មាន ។ ខ្ញុំគិតថាដល់ខ្ញុំត្រឡប់ទៅប៉ារីសវិញតើខ្ញុំត្រូវធ្វើអ្វីខ្លះ ។ ជួបអ្នកណាៗខ្លះ? ខ្ញុំនឹកមិត្តភក្តិដែលនៅស្រុកខ្មែរមិនដឹងជាមានសុខទុក្ខយ៉ាងណា? គ្មានដំណឹងសោះ តើពេលណាទើបមានទំនាក់ទំនងមកវិញ ។ ខ្ញុំមានសេចក្តីនឹករឭកគេណាស់ មិនដឹងជាកម្មអ្វីបានជាឲ្យខ្ញុំជាប់ជំពាក់ចិត្តដូច្នេះ ។ តើក្នុងជាតិនេះយើងបានជួបមុខគ្នាជាថ្មីទៀតឬទេ? តើសព្វថ្ងៃបងនៅឯណាមាននឹកមកខ្ញុំឬទេ? ខ្ញុំសម្រេចចិត្តថានឹងត្រឡប់ទៅវិញដើម្បីជួបជុំគ្រួសារនិងបានជួបគ្នាជាថ្មី តែខ្ញុំមិនដឹងថាចិត្តបងប្រែប្រួលដូចម្តេចទៅហើយ ថ្វីត្បិតតែចិត្តខ្ញុំគិតទៅដល់បងរាល់ពេលវេលា តែខ្ញុំមិនមែនខូចចិត្តគំនិតដោយសេចក្តីស្នេហាទេ ។ ពេលនឹកឃើញអត្តចរិតរបស់បងខ្លះធ្វើឲ្យខ្ញុំអាណិតបងណាស់ តែដល់នឹកភាពអំណួតខ្លះរបស់បងធ្វើឲ្យខ្ញុំសែនស្អប់ ហើយហាក់ដូចជាសប្បាយចិត្តនឹងបដិវត្តន៍នៃស្រុកយើងដែលកែប្រែដូច្នេះ គឺអាចឲ្យបងស្គាល់ការពិបាក ប្រាសចាកគុណវិបត្តិដែលបងមានទាំងប៉ុន្មាន ។ គ្រួសារបងដែលល្បីល្បាញខាងមាននិងមើលងាយគេនោះត្រូវបាក់ធ្លុងដូចគេដូចឯងស្មើគ្នាទាំងអស់ គឺគ្មានវណ្ណៈដូចមុនទៀតទេ ។ ភាពសុខស្រណុកស្រួលរបស់បងទាំងប៉ុន្មានក៏ត្រូវរលាយ ភាពសង្ហានិងឡាននិងទ្រព្យសម្បត្តិរបស់គ្រួសារបងក៏ត្រូវចប់ ។ តើបងយល់យ៉ាងណាចំពោះបដិវត្តន៍នេះ ។ មនុស្សដូចបងដែលស្គាល់តែការសប្បាយរហូតតាំងពីតូចរហូតដល់ធំប៉ុណ្ណេះទើបមកប្រទះការលំបាកដូច្នេះតើបងមានអារម្មណ៍ដូចម្តេចដែរ ។ គឺនេះហើយជីវិតកាលពីដើមមានគេទាំងឡាយខំធ្វើការដើម្បីផ្តល់ការសប្បាយឲ្យបងនិងគ្រួសារ ឥឡូវគ្មានអ្នកណាបម្រើអ្នកណាទេ ។ បងប្រាកដជាបានយល់ច្បាស់នូវការលំបាកវេទនាក្នុងការខំរកទ្រព្យសម្បត្តិដើម្បីចិញ្ចឹមជីវិតរូបបងកាលពីដើមមិនត្រឹមតែអ្នកមិនរកទេ តែជាអ្នកបំផ្លាញទៅទៀត ។ ឥឡូវតើបងយល់ហើយឬនៅ? បើសិនជាបងយល់ច្បាស់នូវគំនិតទាំងនេះហើយ ហើយបងមានចិត្តជំពាក់លើខ្ញុំដូចខ្ញុំមានលើបងដែរនោះ យើងនឹងចាប់ដៃគ្នាយ៉ាងណែនដើម្បីសាងជីវភាពមួយថ្មីក្នុងរបបថ្មីនៃស្រុកយើងឆ្ពោះទៅរកសេចក្តីរុងរឿងនិងសុភមង្គលនៃយើងទៅថ្ងៃមុខ តើបងយល់ព្រមឬទេ? ខ្ញុំសរសេរនេះដើម្បីជាចំណងដៃដល់ការនឹករឭកដល់បងដែលជាទីស្រឡាញ់និងជាទីរឭកអស់ពីដួងចិត្ត ។

## រូអឺ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៧៥

ពេលវេលាកន្លងផុតទៅដូចជារហ័សណាស់ ជិតមួយឆ្នាំទៀតទៅហើយដែលខ្ញុំមកប៉ារីសជាលើកទី២នេះ ។ រដូវផ្ការីក រដូវស្លឹកឈើលាស់បានកន្លងផុតទៅអស់ហើយ រដូវស្លឹកឈើជ្រុះក៏មកដល់ រដូវរងាក៏ជិតមកដល់ដែរ ឱធម្មជាតិ! អ្នកបេះក្រៀមស្រពោនហើយរីកស្រស់វិញបានខុសផ្ទុយស្រឡះពីមនុស្សគ្រប់រូបគ្មានអ្នកណាម្នាក់អាចបត់ថយក្រោយវិញបានទេ ។ ឱ! ស្លឹកឈើពណ៌លឿងដែលជ្រុះចាកទងមកលើប្រថពី បង្កើតបានជាកម្រាលធម្មជាតិមួយដ៏មានពណ៌យ៉ាងស្រស់គួរឲ្យគយគន់ ឱ! រដូវស្លឹកឈើជ្រុះ ថ្វីត្បិតតែអ្នកហាក់មានសភាពក្រៀមក្រំតែអ្នកក៏មានសម្រស់ល្អណាស់ដែរ ។ យប់ស្ងាត់សូន្យទៅហើយខ្ញុំគ្មានឮសូរសំឡេងអ្វីទេ ។ នៅក្នុងបន្ទប់តែឯងបិទជិតឈឹងសូន្យធ្វើឲ្យអារម្មណ៍ខ្ញុំនឹកដល់អនុស្សាវរីយ៍ផ្សេងៗដែលខ្ញុំបានសាងកាលពីមុន លាយឡំនឹងការសប្បាយនិងទុក្ខព្រួយ ការភ័យបារម្ភអរព្រឺព្រួច ស្លុតស្មារតី ខឹង យំ ប្របូកប្រចបល់ឲ្យវិលវល់ចូលគ្នាទាំងអស់នេះហើយដែលគេហៅថាជីវិតកាលនៅពីតូចមិនទាន់ដឹងក្តីមិនដែលស្គាល់ដូចម្តេចហៅថាទុក្ខនោះទេ គឺមានម៉ែបីបមថ្នាក់ថ្នមគ្រប់ពេលវេលា ។ តាំងពីពេលដែលដឹងក្តីពេលណាខ្ញុំមិនដែលបានស្គាល់ដូចម្តេចដែលហៅថាការសប្បាយឲ្យដូចចិត្តដែលប្រាថ្នាទេ ។ តើមកពីហេតុអ្វីទ៍ តើកាលពីជាតិមុនខ្ញុំបានសាងអំពើអ្វីបានជាជាតិនេះយ៉ាងដូច្នេះ ។ តែទោះជាលំបាកកាយឬចិត្តបន្តិចបន្តួចយ៉ាងណាក៏ដោយ ឲ្យតែខ្ញុំបានរស់នៅជិតគ្រួសារខ្ញុំអស់ចិត្តហើយតែមិនដូច្នេះខ្ញុំបែកពីគ្រួសារទៅទៀត ។ ឱជីវិត! តើជីវិតគេឯទៀតមានឧបសគ្គគ្មានចប់ដូចខ្ញុំដែរឬទេ?

## រូអឺ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៥

ថ្ងៃនេះខ្ញុំបានទៅមើលកុនរឿង *West Side Story* ជារឿងមួយល្អមើលគួរឲ្យចាប់ចិត្ត មានគំនិតទូទៅដែលឈរលើមូលដ្ឋានឫសគល់ច្បាស់លាស់ស្នេហាក្នុងរឿងនេះជាស្នេហាប្តូរផ្តាច់ស្លាប់រស់ តែទីបំផុតឥតបានជួបគ្នាទេ ។ **(នៅមានត)**

# ចង់ដឹងការពិត

លោក វ៉ាន់ សរ បានសរសេរនៅក្នុងលិខិតចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០០ ផ្ញើមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានសេចក្តីថា «សំណើសុំឯកសារទាក់ទងឈ្មោះ យុគ ចាន់ថា ភេទប្រុស ដែលមានចុះផ្សាយក្នុងទស្សនាវដ្តីស្វែងរកការពិត លេខ៦ ខែមិថុនា ឆ្នាំ២០០០ ទំព័រ១៧» ។ រូបថតជនរងគ្រោះ យុគ ចាន់ថា ដែលត្រូវបានរៀបចំថតដោយក្រុមអ្នកថតរូបនៅទួលស្លែងមុនពេលត្រូវបានយកទៅសម្លាប់ដោយគ្មានការជម្រះទោស បានចុះផ្សាយក្នុងទស្សនាវដ្តីស្វែងរកការពិតលេខ៦ ប៉ុន្តែមិនទាន់មានពត៌មានអ្វីដែលទាក់ទិននឹងជនរងគ្រោះនេះច្រើននៅឡើយ ។

យោងឯកសារលេខ Y ១៨៣ យុគ ចាន់ថា ជាអតីតលេខាទី២ប្រចាំស្ថានទូតខ្មែរនៅប្រទេសតង់ហ្សានីចាប់ពីឆ្នាំ១៩៧២ដល់ឆ្នាំ១៩៧៦ ទើបអង្គការបញ្ជូនត្រឡប់មកស្រុកខ្មែរវិញ ។ មុនពេលត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៨ យុគ ចាន់ថា បានមករស់នៅក្នុងជំរំកែប្រែមួយនៅអតីតវិទ្យាល័យបឹងត្របែក ក្នុងមន្ទីរ ក-១៧ ។ ប្រពន្ធរបស់គាត់មានឈ្មោះថា ឆាយ សាមិត្ត ហៅ មុំ ត្រូវបានចាប់ខ្លួនព្រមគ្នា រួចហើយបញ្ជូនទៅដាក់នៅក្នុងមន្ទីរ(គុកទួលស្លែង) ។ ឆាយ សាមិត្ត ហៅ មុំ ជាប់ក្នុងមន្ទីរឃុំឃាំងមន្ទីរស-២១ នៅផ្ទះលេខ៣៣ បន្ទប់ធំលេខ៤ ។ ប្តីប្រពន្ធទាំងពីរនាក់នេះមានកូនចំនួន៣នាក់ ។ ពុំមានពត៌មានទាល់តែសោះថាអាចនៅរស់ឬយ៉ាងណានោះទេ ។ ជាមួយនឹងឯកសារ Y ១៨៣ ដដែលនេះបានបង្ហាញទៀតថា បន្ទាប់ពីសួរចម្លើយលើរូប យុគ ចាន់ថា នៅថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៨ រួចមក អ្នកសួរចម្លើយឈ្មោះ ឈុន ជាមួយនឹងហត្ថលេខារបស់ខ្លួនផង បានរាយការណ៍ទៅអង្គការថា «អាចប្រហែលក្បត់តាំងពីវារស់នៅជាមួយឪពុកវា យុគ ឃុន ធ្វើការខាងតុលាការសឹក ។ នេះដោយឡែកតែសំខាន់ពេលវាទៅរស់នៅសូវៀតអស់រយៈ១០ឆ្នាំ ដូច្នេះការទាក់ទងបម្រើអង្គការសំងាត់ឲ្យសូវៀតគឺមាន» ។ ចម្ងល់ដ៏ធំមួយបានចោទសួរ ថាតើដោយការសំអាងទៅលើរបាយការណ៍នេះឬដែល យុគ ចាន់ថា ត្រូវបានសម្លាប់នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៨?

លោក វ៉ាន់ សរ ត្រូវជាបងជីដូនមួយរបស់ជនរងគ្រោះ លោកមានប្រសាសន៍ថា «ចង់រកយុត្តិធម៌ឲ្យបានត្រឹមត្រូវ» ។ លោកក៏ចង់ដឹងទៀតថាតើគេ (ខ្មែរក្រហម) ចោទប្រកាន់ យុគ ចាន់ថា ថាយ៉ាងម៉េច ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើកិច្ចការរបស់ខ្លួនក៏ដើម្បីស្វែងរកការពិត ចង់បានយុត្តិធម៌ជូនជនរងគ្រោះក្នុងរបបខ្មែរក្រហម ។ តាមរយៈកិច្ចការនេះ





ហើយដែលនាំឲ្យកើតមានឡើងនូវវេទិកាស្វែងរកគ្រួសារនៅក្នុងទស្សនាវដ្តីស្វែងរកការពិត ដើម្បីជួយព្យាបាលរបួសផ្លូវចិត្តរបស់ក្រុមគ្រួសារសាច់ញាតិជនរងគ្រោះដែលយ៉ាងហោចណាស់ក្រុមគ្រួសារសាច់ញាតិបានដឹងច្បាស់ថាសាច់ញាតិរបស់គាត់ស្លាប់ពិតប្រាកដនៅឯណា ក្នុងឆ្នាំណា មូលហេតុអ្វី ។ លោក វ៉ាន់ សរ ចង់ដឹងច្បាស់និងឲ្យអស់ចិត្តចំពោះការស្លាប់របស់ប្អូនជីដូនមួយរបស់លោក ។ **វ៉ាន់ថាន់ ពៅដារ៉ា**

**សេចក្តីកែតម្រូវ**

អត្ថបទដែលមានចំណងជើងថា «សារជាតិនៃសេចក្តីព្រាងច្បាប់ខ្មែរក្រហម» នៅក្នុងទស្សនាវដ្តីលេខ១៣ ទំព័រទី៤៩ កូឡោនទី២ បន្ទាត់ទី១៣ ត្រង់ឃ្លា «មាត្រាទី១០២» សូមកែតម្រូវមក «មាត្រាទី១០» វិញ និងអត្ថបទជាស្នាដៃរបស់លោក **ធូច បូរ៉ា** ។





ហួត សំបាត់
អតីតទូតប្រចាំប្រទេសយូហ្គោស្លាវី



ទូតប្រចាំប្រទេសសូវៀត



ហូ ស៊ុមេង
លេខាទី២ទូតនៅបារាំង

ចម្រៀងខ្មែរក្រហម

# សូមកូនកុំភ្លេចឈាមស្រស់យុទ្ធមិត្តយើងឱ្យសោះ

ឱកូនមាសម្ដាយកូនរង់ចាំស្ដាប់
ពុកក៏ផ្ដែផ្ដាំកូនចាំរាល់ថ្ងៃ
កូនរស់នៅបានក្ដីសុខា
ហើយគ្មានមានគ្មានក្រជិះជាន់ឡើយ
កម្មករកសិករបានឡើងជាម្ចាស់
មានសិទ្ធិអំណាចជីវភាពធូរធារ
កូនចាំឲ្យច្បាស់សង្គមថ្មីហ្នឹង
យុទ្ធមិត្តរាប់សែនបានត្រូវបូជា
បងប្អូនលះបង់គ្មានស្ដាយស្រណោះ
ដណ្ដើមរដ្ឋអំណាចពិសេសពេកក្រៃ
ហេតុនេះកូនត្រូវការពារដាច់ខាត
សម្អិតសម្អាងឲ្យកាន់តែថ្ងៃថ្លា
បងប្អូនត្រូវដុតភ្លើងតស៊ូបដិវត្តន៍
ពិនិត្យរូបកូនគ្រប់វិនាទី
សូមកូនគោរពអង្គការវិន័យ
សមតាមគន្លងសីលធម៌បដិវត្តន៍
សូមកូនកុំភ្លេចឈាមស្រស់ក្ដៅៗ
ដែលហូរជាស្ទឹងក្លីផ្ដេកពណ្ណរាយ
សូមកូនរស់នៅធ្វើការរៀនសូត្រ
ឲ្យសមជាអ្នកបន្តវេនថ្ងៃថ្លា

ម្ដាយនឹងរ៉ាយរាប់ប្រាប់ដល់អ្នកថ្ងៃ
ចាំមួយជីវិតកុំបីភ្លេចឡើយ ។
ក្នុងសង្គមកម្ពុជាថ្មីស្រឡាង
បងប្អូនប្រុសស្រីរស់ស្មើមុខគ្នា ។
វាសនាខ្លួនច្បាស់ឯករាជ្យម្ចាស់ការ
អគ្គភាពកម្ពុជាល្បីពេញលោកា ។
មិនមែនកើតឡើងឯងៗទេណា
ជីវិតថ្ងៃថ្លាក្រហមប្រថពី ។
លះបង់ឈាមស្រល់លះបង់ជីវី
មកដាក់ក្នុងដៃនៃយើងរាល់គ្នា ។
ក្នុងសង្គមល្អស្អាតយុត្តិធម៌នេះណា
ទុកកេរយូរយារជិនាន់ក្រោយៗ ។
ឲ្យក្ដៅជាប់មោះមុតកុំភ្លេចខ្លួនឡើយ
តាមមាគ៌ាថ្ងៃថ្លានៃអង្គការយើង ។
រស់នៅរាល់ថ្ងៃតាមរបបអង្គការកំណត់
កុំបីភ្លាំងភ្លាត់ភ្លើតភ្លើនណាមាសម្ដាយ ។
ក្រហមឆ្អិនឆ្អៅយុទ្ធមិត្តទាំងឡាយ
នាំសុខសព្វថ្ងៃឲ្យយើងរាល់គ្នា ។
ឲ្យសមយុទ្ធមិត្តដែលបានបូជា
កុំភ្លេចឡើយណាឱកូនមាសស្ងួន ។

**កត់ត្រាចងក្រងជាឯកសារ**

**កញ្ញា សើ សាយព្រាណា**

ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្ដីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្ដីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្ដីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: Searching for the Truth! Number 14, February 2001.
Funded by the Royal Ministry of Foreign Affairs,Oslo, Norway, Section for the Human Rights and Humanitarian Assistance; the Canada Funds, Canadian Embassy,Phnom Penh, Cambodia; the Swedish International Development Cooperation Agency (Sida), Embassy of Sweden, Phnom Penh; The Royal Danish Government and the Royal Netherlands Government, *The Hague*.